សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ ធ្នូ ឆ្នាំ 2013

# លីអាហូណា

## ប្រសូតមកដើម្បីឲ្យ យើងមានសេរីភាព ទំព័រ 16, 44

ពរជ័យនៃការបម្រើនៃអន្តរនិកាយ ទំព័រ 26

ដំណើររបស់យុវនារីម្នាក់យកឈ្នះលើការញៀន ទំព័រ 56

សកម្មភាពរបស់កុមារ ៖ បង្កើតសៀវភៅ អំពីព្រះយេស៊ូវរបស់អ្នកផ្ទាល់ ទំព័រ 68





*« នៅពេលខ្ញុំបានឃើញ យ៉ូសែប ស៊្មីធ លោកបាន លើកឡើងពីរឿងនៅ ស្ថានសួគ៌ហើយទាញចុះមក ផែនដី ហើយលោកបានលើក ឡើងពីរឿងលើផែនដីរហូតដល់ ស្ថានសួគ៌ ក្នុងភាពច្បាស់លាស់ ហើយសាមញ្ញ ជារឿងនៃព្រះ ហើយថានោះគឺជា ភាពស្រស់ស្អាតនៃបេសកកម្ម របស់លោក »* ។

ប្រធាន ព្រិកហាំ យ៉ង់ (1801–77)
Discourses of Brigham Young
រៀបរៀងដោយ ចន អេ វីឌសូ
( ឆ្នាំ 1954 ) ទំព័រ 458–59 ។

# លីអាហូណា ខែ ធ្នូ ឆ្នាំ 2013




4

## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ ៖ គ្រួសារ និង មិត្តជានិរន្តរ**
ដោយ ប្រធាន ហិនរី ប៊ី អាវរិង

7 **សារលិខិតបង្រៀនសួរសុខទុក្ខ ៖ បេសកកម្មដ៏ទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទ ៖ បុត្រាបង្កើតតែមួយគត់**


## អត្ថបទពិសេស។


16 **ចូរយើងនាំគ្នាចូលមកថ្វាយបង្គំទ្រង់**
ដោយអែលឌើរ ប្រ៊ូស ឌី ភទើរ
*ការបំពេញនូវការព្យាករណ៍មួយពីបុរាណបាននាំមកនូវឥស្សរភាពដល់ជនដែលជាប់ទោស និងសេចក្ដីសង្ឃឹមដល់គ្រួសារមនុស្សលោក ។*

22 **សារៈសំខាន់នៃការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់**
ដោយ ចិននីហ្វឺរ ហ្រ្គេស យ៉ូនស៍
*តើរឿងដ៏សាមញ្ញមួយពិតជាអាចធ្វើឲ្យមានការផ្លាស់ប្ដូរ សម្រាប់ក្រុមគ្រួសារនៅជុំវិញពិភពលោកដែរឬទេ ?*

26 **ការក្លាយខ្លួនជាពួកបរិសុទ្ធដ៏ប្រពៃតាមរយៈកម្មវិធីប្រឡងគ្នាខាងសាសនា**
ដោយ បេិតស៊ី វ៉ាន់ឌេនប៊ឺហ្គហេ
*របៀបបម្រើបុគ្គលដែលមានជំនឿផ្សេងអាចអភិវឌ្ឍភាពជាសិស្សរបស់យើង ។*

32 **ពី*អ្នកដទៃ*ក្លាយទៅជាមិត្ត**
ដោយ ដេវីឌ ឌីកសុន
*ហ្គត់ហ្វ្រីមិនចង់ពាក់ព័ន្ធនឹងសាសនាចក្ររហូតដល់មានគំនរមែកឈើដែលបានកាត់ចោល មួយពំនូកបានជួយផ្លាស់ប្ដូរគំនិតរបស់គាត់ ។*

34 **អាហ្វ្រិក—ទ្វីបនៃសេចក្ដីសង្ឃឹមដ៏ភ្លឺត្រចះត្រចង់**
ដោយ រ៉ឆាត អិម រ៉មនី
*អាហ្វ្រិកជាទីកន្លែងមួយដែលយើងអាចមើលឃើញពីអព្ភូតហេតុនៃការស្ដារឡើងវិញបានបើកសម្ដែង ។*


## ផ្នែកទាំងឡាយ


8 **អ្វីដែលយើងជឿ: ព្រះអម្ចាស់នឹងយាងត្រឡប់មកផែនដីវិញក្នុងសិរីល្អ**

10 **គេហដ្ឋាន និង ក្រុមគ្រួសាររបស់យើង: ការជួយកុមារឲ្យស្គាល់ព្រះវិញ្ញាណបរិសុទ្ធ**
ដោយមេរីលី ប្រោន បូយ៉ាក

13 **ការបង្រៀន*ដើម្បីកម្លាំងនៃយុវជន:* ការប្រែចិត្ត**

14 **ព័ត៌មានសាសនាចក្រ**

40 **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

80 **លុះត្រាជួបទៀត: ដំណើរត្រឡប់ទៅផ្ទះវិញ**
ដោយ ហ៊ុតធើរ វិតធល ហ្វ្រីចលី


នៅលើគម្រប
ខាងមុខ ៖ *ពន្លឺនៃលោកិយ* ដោយ ជេ ប្រាយអិន វូដ ។ ខាងក្រោយ ៖ *ពួកអ្នកគង្វាលចៀមប្រាប់ពីការប្រសូតរបស់ព្រះយេស៊ូវ* ដោយ អរធើរ អេ. ឌីកសិន ។ ខាងក្នុងគម្របខាងមុខ ៖ រូបថតនៃព្រះវិហារបរិសុទ្ធ ណៅវូ អិលលីណោយ ដោយ ក្រុមហ៊ុនថតរូប ស្កត ចារី ។

## មជ្ឈិមវ័យវ័យក្មេង





44 **សេចក្ដីសន្យានៃបុណ្យគ្រីស្ទម៉ាស**
ដោយ អែលឌើរ រ៉ូប៊ើត ឌី ហែល
*តើការសន្យាអ្វីខ្លះដែលអ្នកនឹងធ្វើចំពោះព្រះអង្គសង្គ្រោះរបស់អ្នក នៅរដូវបុណ្យគ្រីស្ទម៉ាសនេះ ?*




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណា ដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ ជាងកាត់សក់នឹងជួយអ្នក ។***

## យុវវ័យ


48 **ការរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ**
ដោយ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន
*ដោយសារគ្រាកាន់កាប់ត្រួតត្រារបស់យើងគឺជាជំនាន់ចុងក្រោយ ហើយអស្ចារ្យជាងគេបំផុត នោះយើងមានទំនួសខុសត្រូវដើម្បីរៀបចំសាសនាចក្រនេះ ដើម្បីទទួលកូនចៀមនៃព្រះ ។*

52 **សំណួរ និងចម្លើយ**
*តើខ្ញុំទប់ទល់នឹងការល្បួងដោយរបៀបណា ?*

54 **ដើម្បីកម្លាំងនៃយុវជន: ទិដ្ឋភាពពីចុងផ្លូវ**
ដោយ អែលឌើរ ប្រេដលី ឌី ហ្វស្ទ័រ
*អ្នកអាចប្រែចិត្តបាន ។ ហើយនៅពេលអ្នកប្រែចិត្ត នោះអ្វីៗគ្រប់យ៉ាងនឹងបានប្រសើរឡើង ។*

56 **ឈប់ញៀនទៀតហើយ ៖ ដំណើររបស់ខ្ញុំដើម្បីយកឈ្នះលើរូបអាសគ្រាម**
ឈ្មោះត្រូវបានដកចេញ
*កាលពីក្មេង ខ្ញុំពុំធ្លាប់គិតថា ខ្ញុំនឹងជួបប្រទះបញ្ហារូបអាសគ្រាមឡើយ ។*

58 **លើសពីដៃគូ**
*តើអ្នកគិតថានៅពេលអ្នកទៅបង្រៀនតាមផ្ទះគឺអ្នកគ្រាន់តែរួមដំណើរនឹងមនុស្សម្នាក់ដើម្បីទៅសួរសុខទុក្ខមែនទេ ? សូមគិតម្ដងទៀត ។*

60 **ការឈរនៅទីដ៏បរិសុទ្ធ**
*រូបថតពីជុំវិញពិភពលោកបង្ហាញពីរបៀបដែលយុវវ័យកំពុងឈរនៅទីដ៏បរិសុទ្ធ ។*

64 **ចម្រៀងបុណ្យគ្រីស្ទម៉ាសដ៏ពេញចិត្ត**
ដោយ ស៊ី ជី លីនស្ត្រូម
*នៅពេលបងស្រីម្នាក់បានដើរឡើងមកច្រៀង ខ្ញុំបានគិតអវិជ្ជមានថា តើចម្រៀងនោះនឹងពិរោះដែរ ឬអត់ ។*


## កុមារ





66 **បងប្រុសខ្ញុំជាអ្នកផ្សព្វផ្សាយសាសនា**
ដោយ ខេវីន រី
*ឥឡូវខ្ញុំមានបន្ទប់ដេកផ្ទាល់ខ្លួនហើយ ។ ខ្ញុំមិនបាននឹកដល់បងប្រុសខ្ញុំទេ— ឬតើខ្ញុំគួរនឹកគាត់ទេ ?*

67 **សាក្សីពិសេស: ហេតុអ្វីការចំណាយពេលជាមួយក្រុមគ្រួសាររបស់យើងសំខាន់ ?**
ដោយ ប្រធាន ប៊ិយដ៏ ឃេ ផាកកឺ

68 **ការនាំមេរៀនថ្នាក់កុមារមកក្នុងលំនៅដ្ឋាន: ខ្ញុំដឹងថាព្រះយេស៊ូវគ្រីស្ទនឹងយាងមកម្ដងទៀត**

71 **ទំព័ររបស់យើង**

72 **ការរង់ចាំព្រះយេស៊ូវ**
ដោយ ម៉ាថាយ ឌី ហ្វិតតុន
*តើព្រះឱរសយេស៊ូវនៅឯណា ? យើងមិនអាចអបអរបុណ្យគ្រីស្ទម៉ាសដោយគ្មានទ្រង់បានឡើយ ។*

74 **នៅតាមផ្លូវ: កន្លែងនេះហើយ !**
ដោយ អាន់នី បៀរ

76 **សម្រាប់កុមារតូចៗ**

81 **រូបគំនូរព្យាការី: យ៉ូសែប ហ្វិលឌីង ស្មីធ**




**វ៉ុល ខែ ធ្នូ ឆ្នាំ 2013 ច្បាប់ 13 លេខ. 6**
**លីអាហូណា 10792 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** បយដ៍ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូប៊ើត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា,ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល ៖** ក្រេក អេ. ខារដុន
**អ្នកប្រឹក្សា ៖** សមើរវីន ប៊ី អាណុល, រូនេ អិម. បូរិន, ប្រ៊ែដលី ឌី. ហ្វូស្ទើរ, គ្រីស្តូហ្វែល ហ្គូលឌិន ជុញ្ញ័រ

**នាយកគ្រប់គ្រង ៖** ដេវីឌ ធី. វ៉ នើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយបិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** ប៉អិន ខារ, ឡារិននេ ផតធើរ ហ្គុន
**និពន្ធ និងកែសម្រួល ៖** ស៊ូសាន បាប៉េត, ប្រ៊ឺតថានី ប៊ីតធី, ដេវីដ ឌិកសុន, ដេវីដ អេ. អេដវឺដ, ម៉ាថាយ ឌី. ហ្វលិតតុន, មិនឌី ប៉ ហ្វ្រីដមែន, ហ្គែរី អេច. ហ្គាហ្វ, ជេនីហ្វើរ ហ្រ្គេស ជូនស៍, ម៉ៃឃើល អ័រ. ម៉ូរីស, សាលី ចនសុន អូឌេឃឺក, យ៉ូស្វេ ជេ ភឺគី, ជេន ភីនប៊ូរ៉ាហ្វ, រីឆាដ អិម. រ៉មនី, ប៉ុល វ៉ែនដិនប៊ើជ, ម៉ារីស្សា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ចាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជេនែត អែនឌ្រូ, ហ្វៃ ភី អែនឌ្រើស, ស៊ី. ឃិមបល ប៊ុត, ថូម៉ាស ឆាលដ៍, ខូលីន ហ៊ីងគ្លី, អ៊ីរីក ភី. ចនសិន, ស៊ូហ្សិន ឡហ្វ័ហ្រ្គេន, ស្កត អិម. មួយ, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រេដ ធាប៉

**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នែបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខេវិន ស៊ី បេងស៍, ខននី ប៊ូស្រូប ប្រ៊ីជ, ជូលី បឺរដេត, ប្រាយអែន ដបុលយូ. ជីគី, ដេនីស តើបេ, ហ្គីននី ជេ. នីលសុន, ហ្គេលី ថេត វ៉ាហ្វើធី, ឃេ នីកូល វ៉កខេនហោស្ត
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ. សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្ដេហ្វិន អ័រ គ្រីស្ទិនសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona,* Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2013 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
December 2013 Vol. 13 No. 6. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# យោបល់ទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពទាំងឡាយដែលអាចប្រើប្រាស់ សម្រាប់ធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ចំនួនពីរ ។*



« **ការជួយកុមារឲ្យស្គាល់ព្រះវិញ្ញាណបរិសុទ្ធ** » ទំព័រ 10 ៖ បន្ទាប់ពីអានអត្ថបទនេះឡើងវិញ សូមពិចារណានូវការរៀបចំផែនការសកម្មភាពជាសំឡេង ជារូបភាព និង ខាងបញ្ចេញសកម្មភាពដែលនឹងជួយដល់កូនចៅរបស់អ្នកឲ្យរៀនសូត្រពី របៀបដែលព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកកាន់ពួកគេ ។ អ្នកអាចអាន ហើយសម្ដែងពីដំណើររឿងបុណ្យគ្រីស្ទម៉ាស ។ អ្នកអាចរៀនពីទំនុកតម្កើងព្រះ និង ចម្រៀងកុមារពីការប្រសូតរបស់ព្រះអង្គសង្គ្រោះ ហើយច្រៀងបទនោះដល់មិត្ត និង អ្នកជិតខាង ។ អ្នកអាចមើលរូបភាពនៃព្រះអង្គសង្គ្រោះរួមគ្នា ឬ ដាក់ព្រះប្រសូតិកម្មមួយនៅក្នុងផ្ទះរបស់អ្នកត្រង់កន្លែងមួយដែលងាយមើលឃើញ ។ អ្នកអាចរៀបចំសកម្មភាពបម្រើមួយជាគ្រួសារ ។ មិនថាអ្នកជ្រើសរើសធ្វើអ្វីនោះទេ សូមជួយកូនចៅរបស់អ្នកឲ្យស្គាល់ពី ពេលដែលពួកគេនឹងទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។

« **ការក្លាយខ្លួនជាពួកបរិសុទ្ធដ៏ប្រពៃតាមរយៈកម្មវិធីរួបរួមគ្នាខាងសាសនា** »ទំព័រ 26 ៖ សូមពិចារណាពីការស្វែងរកពីរបៀបមួយដើម្បីទាក់ទង នឹងសាសនាមួយទៀតនៅអំឡុងពេលរដូវបុណ្យគ្រីស្ទម៉ាសនេះ ។ អ្នកអាចចូលរួមនឹងគ្រួសារគ្រីស្ទានផ្សេងទៀតដើម្បីអានពីដំណើររឿងបុណ្យគ្រីស្ទម៉ាស ឬ ធ្វើការបម្រើ ។ អ្នកអញ្ជើញគ្រួសារមួយដែលពុំមែនជាគ្រីស្ទានឲ្យចូលរួមនឹងអ្នកក្នុងរាត្រីជួបជុំក្រុមគ្រួសារ ហើយប្ដូរវេនរៀនសូត្រពីជំនឿ និងទំនៀមទម្លាប់ពីគ្នាទៅវិញទៅមក ។ ក្រោយមក សូមពិចារណាដោយពិភាក្សានឹងកូនចៅរបស់អ្នកពីសេចក្ដីពិតដែលពួកគេបានរៀនពីមិត្តរបស់អ្នក ។

## ជាភាសារបស់អ្នក

*លីអាហូណា* និង ឯកសារផ្សេងទៀតរបស់សាសនាចក្រមានជាច្រើនភាសា សូមចូលទៅកាន់ languages.lds.org ។

ប្រធានបទទាំងឡាយក្នុងច្បាប់នេះ
*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

***ការបង្រៀន,*** *10*
***ការបង្រៀនតាមផ្ទះ,*** *58*
***ការបម្រើ,*** *26, 32, 58*
***ការប្រែចិត្ត,*** *13, 16, 54, 56*
***ការព្យាករណ៍,*** *44*
***ការយាងមកជាលើកទីពីរ,*** *8, 48, 68, 72*
***ការរិះគន់,*** *80*
***ការល្បួង,*** *52, 56*
***ការសារភាព,*** *54*
***ការអភ័យទោស,*** *54*
***កិច្ចការផ្សព្វផ្សាយសាសនា,*** *4, 32, 34*
***កិច្ចការព្រះវិហារបរិសុទ្ធ,*** *22*
***កុមារ,*** *10*
***ក្រុមគ្រួសារ,*** *10, 66, 67*
***គ្រាកាន់កាប់ត្រួតត្រា,*** *48*
***ថ្នាក់អង្គការបឋមសិក្សា,*** *71*
***បុណ្យគ្រីស្ទម៉ាស,*** *4, 16, 40, 41, 43, 44, 64, 72, 76*
***ប៊ីស្សព,*** *54*
***ប្រព័ន្ធផ្សព្វផ្សាយ,*** *56*
***ពង្សប្រវត្តិ,*** *22*
***ព្យាការីទាំងឡាយ,*** *34, 48*
***ព្រះយេស៊ូវគ្រីស្ទ,*** *7, 8, 16, 48, 68*
***ព្រះវិញ្ញាណបរិសុទ្ធ,*** *10*
***ភាពពិការ,*** *64*
***រូបអាសគ្រាម,*** *56*
***សិទ្ធិជ្រើសរើស,*** *52*
***សីលធម៌,*** *56*
***សេចក្ដីមេត្តាករុណា,*** *80*
***សេចក្ដីសញ្ញាទាំងឡាយ,*** *44*
***សេរីភាព,*** *16*
***ស្មីធ យ៉ូសែប ហ្វិលឌីង,*** *1*
***អាហ្វ្រិក,*** *32, 34*
***អ្នកត្រួសត្រាយផ្លូវ,*** *34, 74*



ដោយ ប្រធាន
ហិនរី ប៊ី អាវរិង
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ



# គ្រួសារ និង មិត្ត ជានិរន្តរ

មិនថាអ្នករស់នៅទីណានោះទេ អ្នកមានមិត្តដែលកំពុងតែស្វែងរកសុភមង្គលដ៏កាន់តែប្រសើរ ដែលអ្នកបានរកឃើញនៅក្នុងការរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ។ ពួកគេប្រហែលជាមិនអាចថ្លែងពីសុភមង្គលនោះឡើយ ប៉ុន្តែពួកគេបានស្គាល់វានៅពេលពួកគេមើលឃើញវានៅក្នុងជីវិតរស់នៅរបស់អ្នក ។ ពួកគេនឹងមានចិត្តចង់រៀនពីប្រភពនៃសុភមង្គលនោះ ជាពិសេសនៅពេលពួកគេមើលឃើញវា នៅពេលអ្នកប្រឈមមុខនឹងការសាកល្បងដូចជាពួកគេផងដែរ ។

អ្នកបានទទួលសុភមង្គល នៅពេលអ្នកបានគោរពព្រះបញ្ញត្តិរបស់ព្រះ ។ នោះជាផលផ្លែដែលបានសន្យានៃការរស់នៅតាមដំណឹងល្អ ( សូមមើល ម៉ូសាយ 2:41 ) ។ អ្នកពុំមែនគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដោយស្មោះត្រង់ ដើម្បីធ្វើឲ្យមនុស្សដទៃទៀតមើលឃើញនោះទេ ប៉ុន្តែជនដែលសង្កេតឃើញសុភមង្គលរបស់អ្នក គឺកំពុងតែរៀបចំខ្លួនដោយព្រះអម្ចាស់ដើម្បីស្ដាប់ឮនូវសេចក្ដីល្អនៃការស្ដារឡើងវិញនៃដំណឹងល្អ ។

ពរជ័យដែលអ្នកទទួលបានបង្កើតនូវកាតព្វកិច្ច និង ឱកាសដ៏អស្ចារ្យសម្រាប់អ្នក ។ ក្នុងនាមជាសិស្សមួយរូបរបស់ព្រះយេស៊ូវគ្រីស្ទដែលបានចុះសេចក្ដីសញ្ញា អ្នកមានទំនួលខុសត្រូវ ដើម្បីផ្ដល់ឱកាសដល់មនុស្សដទៃទៀតនៅក្នុងការស្វែងរកសុភមង្គលដែលប្រសើរជាងមុន ជាពិសេសចំពោះមិត្ត និង សមាជិកគ្រួសាររបស់អ្នក ។

ព្រះអម្ចាស់បានឃើញពីឱកាសរបស់អ្នក ហើយបានរៀបរាប់ពីកាតព្វកិច្ចរបស់អ្នកនឹងព្រះបញ្ញត្តិនេះថា ៖ « តម្រូវឲ្យមនុស្សម្នាក់ៗណាដែលបានព្រមាននោះត្រូវព្រមានអ្នកជិតខាងរបស់ខ្លួន » (គ. និង ស. 88:81 ) ។

ព្រះអម្ចាស់បានធ្វើឲ្យព្រះបញ្ញត្តិកាន់តែងាយស្រួលក្នុងការគោរព តាមរយៈការផ្លាស់ប្ដូរ ដែលកើតឡើងនៅក្នុងដួងចិត្តរបស់អ្នក នៅពេលអ្នកទទួលយក ហើយរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ ជាលទ្ធផលសេចក្ដីស្រឡាញ់របស់អ្នកចំពោះមនុស្សដទៃទៀត មានភាពចម្រើនឡើង រួមទាំងក្ដីប្រាថ្នារបស់អ្នក ដើម្បីឲ្យពួកគេមាននូវសុមភមង្គលដូចជាអ្នកផងដែរ ។

គំរូមួយនៃការផ្លាស់ប្ដូរនោះ គឺរបៀបដែលអ្នកស្វាគមន៍ដល់ការផ្លាស់ប្ដូរ ដើម្បីជួយក្នុងកិច្ចការផ្សព្វផ្សាយសាសនារបស់ព្រះអម្ចាស់ ។ ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងបានដឹងភ្លាមថា ពួកគេអាចរំពឹងទុកពីអ្នកផ្លាស់ប្រែចិត្តជឿដ៏ពិតម្នាក់នូវចម្លើយដ៏កក់ក្ដៅមួយចំពោះការស្នើរសុំនូវឈ្មោះមនុស្សម្នាក់ ដែលចង់រៀនពីដំណឹងល្អ ។ អ្នកប្រែចិត្តជឿរូបនោះចង់ចែកចាយសុភមង្គលឲ្យមិត្តភក្តិ និង សមាជិកគ្រួសាររបស់ពួកគេ ។

នៅពេលអ្នកដឹកនាំបេសកកម្មវួដរបស់អ្នក ឬ ពួកអ្នកផ្សព្វផ្សាយសាសនាសុំឈ្មោះរបស់មនុស្សណាម្នាក់ដើម្បីបង្រៀន វាគឺជាពាក្យសរសើរដ៏ធំមួយចំពោះអ្នក ។ ដូច្នេះហើយ ពួកគេដឹងថា មិត្តដែលធ្លាប់ឃើញសុភមង្គលរបស់អ្នក ជាមិត្តដែលបានរៀបចំខ្លួន ដើម្បីស្ដាប់ ហើយបានជ្រើសរើសដើម្បីទទួលយកដំណឹងល្អ ។ ហើយពួកគេមានទំនុកចិត្តថា អ្នកនឹងធ្វើជាមិត្តដែលពួកគេត្រូវការនៅពេលពួកគេចូលមកក្នុងនគរនេះ ។

អ្នកមិនត្រូវខ្លាចថា អ្នកនឹងបាត់បង់មិត្តដោយការអញ្ជើញពួកអ្នកផ្សព្វផ្សាយសាសនាឲ្យជួបពួកគេនោះទេ ។ ខ្ញុំមានមិត្តដែលបានបដិសេធពួកអ្នកផ្សព្វផ្សាយសាសនា ប៉ុន្តែពួកគេបានអរគុណខ្ញុំអស់រយៈពេលជាច្រើនឆ្នាំ ចំពោះការផ្ដល់ឲ្យពួកគេនូវអ្វីមួយ ដែលពួកគេបានដឹងថា វាមានតម្លៃបំផុតសម្រាប់ខ្ញុំ ។ អ្នក




អាចបង្កើតមិត្តភាពជានិរន្តរបានដោយការផ្ដល់នូវដំណឹងល្អ ដែលពួកគេបានឃើញថាវាបាននាំមកនូវសុភមង្គលដល់អ្នក ។ សូមកុំខកខាននូវឱកាសដើម្បីអញ្ជើញមិត្តម្នាក់ ហើយជាពិសេសគឺសមាជិកគ្រួសារម្នាក់ ដើម្បីជ្រើសរើសធ្វើតាមផែនការនៃសុភមង្គល ។

គ្មានឱកាសណាមួយធំជាងឱកាសសម្រាប់អញ្ជើញនោះ នៅក្នុងព្រះវិហារបរិសុទ្ធនៃសាសនាចក្រឡើយ ។ នៅទីនោះ ព្រះអម្ចាស់អាចផ្ដល់នូវពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះដល់ដូនតារបស់យើងដែលមិនអាចទទួលពិធីបរិសុទ្ធកាលនៅរស់ ។ ពួកគាត់បានសម្លឹងមកអ្នកដោយសេចក្ដីស្រឡាញ់ និង សេចក្ដីសង្ឃឹម ។ ព្រះអម្ចាស់បានសន្យាថា ពួកគាត់នឹងមានឱកាសដើម្បីចូលមកក្នុងនគររបស់ទ្រង់ ( សូមមើល គ. និង ស. 137:7–8 ) ហើយទ្រង់បានបណ្ដុះសេចក្ដីស្រឡាញ់មួយចំពោះពួកគាត់នៅក្នុងចិត្តរបស់អ្នក ។

អ្នករាល់គ្នាភាគច្រើនធ្លាប់មានសេចក្ដីអំណរនៅក្នុងការធ្វើពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធដល់មនុស្សដទៃ អ្នកនឹងមានអារម្មណ៍ដូចគ្នាដែរ ពេលអ្នកឲ្យឈ្មោះមនុស្សឲ្យពួកអ្នកផ្សព្វផ្សាយសាសនាជួប ។ អ្នកកាន់តែមានសេចក្ដីអំណរលើពីនេះទៀតដោយបានធ្វើពិធិបរិសុទ្ធសម្រាប់ដូនតារបស់អ្នក ។ រឿងនេះបានបើកសម្ដែងដល់ព្យាការី យ៉ូសែប ស្ម៊ីធ ថា សុភមង្គលដ៏នៅអស់កល្បជានិច្ចរបស់យើង គឺអាចកើតមានលុះត្រាតែយើងបានផ្ដល់នូវផ្លូវមួយដើម្បីឲ្យពរជ័យនោះកើតមានចំពោះដូនតារបស់យើងតាមរយៈពិធីបរិសុទ្ធជំនួស នៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ( សូមមើល គ. និង ស. 128:18 ) ។

ពេលបុណ្យគ្រីស្ទម៉ាស់បានបង្វែរចិត្តយើងទៅកាន់ព្រះអង្គសង្គ្រោះ និង ទៅរកសេចក្ដីអំណរដែលដំណឹងល្អរបស់ទ្រង់បាននាំមកឲ្យយើង ។ យើងបង្ហាញការដឹងគុណរបស់យើងចំពោះទ្រង់បានយ៉ាងល្អបំផុត នៅពេលយើងផ្ដល់សុភមង្គលដូចគ្នានេះដល់មនុស្សដទៃទៀត ។ ការដឹងគុណបានប្រែទៅរកសេចក្ដីអំណរ នៅពេលយើងផ្ដល់ឈ្មោះដល់ពួកអ្នកផ្សព្វផ្សាយសាសនា និង នៅពេលយើងយកឈ្មោះដូនតារបស់យើងទៅព្រះវិហារបរិសុទ្ធ ។ ភស្ដុតាងនៃការដឹងគុណរបស់យើងនោះអាចបង្កើតជាមិត្ត និង ក្រុមគ្រួសារដែលមានជានិរន្តរ ។ ■

**ការបង្រៀនចេញពីសារលិខិតនេះ**

ប្រធាន អាវរិង បានពន្យល់ថា យើងអាចបង្ហាញការដឹងគុណរបស់យើងចំពោះព្រះអង្គសង្គ្រោះដោយការចែកចាយដំណឹងល្អដល់មនុស្សដទៃទៀត ។ អ្នកអាចពិភាក្សាជាមួយនឹងសមាជិកដែលអ្នកបង្រៀនពីរបៀបដែលអំណោយទាននៃដំណឹងល្អបានប្រទានពរដល់ជីវិតរបស់ពួកគាត់ ។ សូមពិចារណាពីការអញ្ជើញពួកគេឲ្យគិតប្រកបដោយការអធិស្ឋានអំពីមនុស្ស ដែលពួកគេចង់ចែកចាយអំណោយទាននៃដំណឹងល្អ និង ពីរបៀប ដែលពួកគេអាចធ្វើកិច្ចការនោះ

រូបថតដោយ ប្រ៊ីក កាប៊ី




## ចែកចាយទីបន្ទាល់របស់អ្នក

អ្នកអាចចែកចាយអំណោយទាននៃដំណឹងល្អ នៅបុណ្យគ្រីស្ទម៉ាសនេះ ដោយការឲ្យព្រះគម្ពីរមរមនមួយក្បាល ដោយមានសរសេរនូវទីបន្ទាល់របស់អ្នកទៅដល់មិត្ត ឬ អ្នកជិតខាងម្នាក់ ។ សូមធ្វើតាមដំណាក់ការទាំងនេះ ដើម្បីរៀបចំវាឲ្យរួចរាល់ ៖

1. សូមគូសចតុកោណកែងមួយដែលមានទំហំប្រមាណជា (11½ x 16½ ស.ម.) នៅលើក្រដាសមួយសន្លឹក ហើយឲ្យមនុស្សពេញវ័យម្នាក់ជួយអ្នកដើម្បីកាត់វាចេញ ។
2. ដាក់រូបភាពរបស់អ្នក—អាចជារូបគំនូរ ឬ រូបថត—នៅផ្នែកខាងលើទំព័រនោះ ។
3. សូមសរសេរទីបន្ទាល់របស់អ្នកនៅខាងក្រោមរូបភាពរបស់អ្នក ។
4. សុំឲ្យមនុស្សពេញវ័យម្នាក់ជួយអ្នកបិទក្រដាសនោះ នៅក្នុងគម្រប ព្រះគម្ពីរមរមន ។



## តើខ្ញុំអាចចែកចាយព្រះគម្ពីរមរមនបានដែរឬទេ ?

ដោយ ចស្ស អាណេត

នាឆ្នាំដំបូងរបស់ខ្ញុំនៅវិទ្យាល័យ គ្រូបង្រៀនថ្នាក់សិក្ខាសាលារបស់ខ្ញុំបានអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ដល់ព្រះគម្ពីរមរមនទៅមិត្តដែលពុំមែនជាសមាជិក ។ ទោះបីជាខ្ញុំមានការខ្មាស់អៀនខ្លាំងក្ដី ក៏ខ្ញុំបានទទួលយកការអញ្ជើញនោះផងដែរ ។

ខ្ញុំបានចំណាយពេលពីរបីថ្ងៃ ដើម្បីបង្កើននូវសេចក្ដីក្លាហាន ប៉ុន្តែនៅទៅបំផុតខ្ញុំបានឲ្យព្រះគម្ពីរនោះទៅមិត្តរបស់ខ្ញុំឈ្មោះ ប្រ៊ីតនី អំឡុងពេលអាហារថ្ងៃត្រង់ ហើយបានថ្លែងទីបន្ទាល់មួយយ៉ាងខ្លី ។ ប្រ៊ីតនី បានអរគុណខ្ញុំសម្រាប់ព្រះគម្ពីរនោះ ។

នៅពេលវិស្សមកាលឆ្នាំនោះ ប្រ៊ីតនី បានផ្លាស់ទីលំនៅ ប៉ុន្តែយើងនៅតែទាក់ទងគ្នា ។ នាងបានប្រាប់ខ្ញុំពីសាលាថ្មីរបស់នាង ហើយថាមិត្តរបស់នាងស្ទើរតែទាំងអស់ជាសមាជិកសាសនាចក្រ ប៉ុន្តែនាងពុំដែលនិយាយពីរឿងខាងវិញ្ញាណជាមួយខ្ញុំនោះទេ ។

រឿងនោះបានផ្លាស់ប្ដូរពីមុនខ្ញុំបានចេញទៅបេសកកម្មរបស់ខ្ញុំ ។ ខ្ញុំបានទទួលសារមួយពីប្រ៊ីតនី ដោយប្រាប់ថានាងមានដំណឹងដ៏រីករាយមួយសម្រាប់ខ្ញុំ ៖ នាងនឹងទទួលបុណ្យជ្រមុជទឹក ហើយនាងចង់អរគុណខ្ញុំសម្រាប់ការធ្វើជាមិត្តរបស់នាង ហើយធ្វើជាគំរូមួយដ៏ល្អ ។

ព្រះបានដកយកការខ្មាស់អៀនរបស់ក្មេងប្រុសម្នាក់អាយុ 15 ឆ្នាំ ដែលគ្មានបទពិសោធន៍ផ្សព្វផ្សាយសាសនា ហើយបានដឹកនាំគាត់ឲ្យចែកចាយដំណឹងល្អជាមួយនឹងមនុស្សម្នាក់ដែលទ្រង់បានដឹងថា នឹងទទួលយកដំណឹងល្អនោះ ។ ខ្ញុំដឹងថា តាមរយៈការស្ដាប់តាមព្រះវិញ្ញាណ នោះយើងទាំងអស់គ្នាអាចរកឃើញមនុស្សនៅជុំវិញយើងដែលកំពុងតែរង់ចាំ ដើម្បីរៀនពីដំណឹងល្អដែលបានស្ដារឡើងវិញ ។ ខ្ញុំដឹងថា ប្រសិនបើយើងជួយនាំសូម្បីតែម្នាក់មករកព្រះអម្ចាស់ « នោះ [ យើង ] នឹងមានសេចក្ដីអំណរដ៏មហិមាជាមួយអ្នកនោះនៅក្នុងនគរនៃព្រះវរបិតា [ របស់យើង ]! » ។ (គ. និង ស. 18:15) ។

*អ្នកនិពន្ធម្នាក់ដែលរស់នៅក្នុងរដ្ឋវ៉ាស៊ីងតោន ស.រ.អា. ។*



*សូមសិក្សាឯកសារនេះ ហើយស្វែងរកដើម្បីបានដឹងនូវអ្វីដែលត្រូវចែកចាយប្រកបដោយការអធិស្ឋាន ។ តើការយល់ដឹងពីឆាកជីវិត និង បេសកកម្មរបស់ព្រះអង្គសង្គ្រោះ នឹងពង្រឹងដល់សេចក្ដីជំនឿរបស់អ្នកលើទ្រង់ ហើយប្រទានពរដល់ជន ដែលមើលថែតាមរយៈការបង្រៀនតាមផ្ទះដោយរបៀបណា ? ចំពោះព័ត៌មានបន្ថែម សូមចូលទៅ reliefsociety.lds.org ។*

# បេសកកម្មដ៏ទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទ ៖ បុត្រាបង្កើតតែមួយគត់

*នេះជាផ្នែកជាគំរូមួយអំពីសារលិខិតបង្រៀនតាមផ្ទះ ឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ។*

ព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ត្រូវបានហៅថាជាបុត្រាបង្កើតតែមួយគត់ ដោយសារទ្រង់គឺជាអង្គតែម្នាក់គត់នៅលើផែនដី ដែលប្រសូតពីម្ដាយដែលមានជីវិតរមែងស្លាប់ និង ព្រះវរបិតាដែលមានជីវិតអមតៈ ។ ទ្រង់បានគ្រងអំណាចដ៏ទេវភាពពីព្រះ ជាព្រះវរបិតាទ្រង់ ។ ពីមាតាទ្រង់ ម៉ារា ទ្រង់បានទទួលមរតកជាជីវិតរមែងស្លាប់ ហើយទទួលរងនូវការស្រេកឃ្លាន ការនឿយហត់ ការឈឺចាប់ និង សេចក្ដីស្លាប់ ។[1]

ដោយសារព្រះយេស៊ូវគ្រីស្ទជាបុត្រតែមួយគត់របស់ព្រះវរបិតា ទ្រង់អាចដាក់ជីវិតរបស់ទ្រង់ចុះ ហើយអាចយកវាត្រឡប់មកវិញម្ដងទៀត ។ ព្រះគម្ពីរបង្រៀនថា « តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ » យើង « ទទួលដំណើររស់ឡើងវិញ » ( យ៉ាកុប 4:11 ) ។ យើងក៏រៀនផងដែរថា មនុស្សទាំងអស់ « អាចបានប្រោសពីអមតភាពទៅរកជីវិតដ៏នៅអស់កល្បជានិច្ច » ប្រសិនបើយើង « នឹងជឿ » ( គ. និង ស. 29:43 ) ។

នៅពេលយើងបានយល់ទាំងស្រុងពីហេតុផលដែលព្រះយេស៊ូវបានក្លាយជាបុត្រាបង្កើតតែមួយគត់ នៃព្រះវរបិតា នោះសេចក្ដីជំនឿរបស់យើងលើព្រះគ្រីស្ទនឹងកើនឡើង ។ អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ គឺជាការជឿស៊ប់ និង ការបញ្ជាក់ពី (1) ឋានៈរបស់ទ្រង់ក្នុងនាមជាបុត្រាបង្កើតតែមួយគត់របស់ព្រះ (2) ដង្វាយធួនដ៏គ្មានទីបញ្ចប់របស់ទ្រង់ និង (3) ការរស់ឡើងវិញដ៏ពិតប្រាកដរបស់ទ្រង់ » ។[2] ពួកព្យាការីសម័យទំនើបបានថ្លែងទីបន្ទាល់ថា « [ ព្រះយេស៊ូវគ្រីស្ទ ] គឺជា . . . បុត្រាបង្កើតតែមួយគត់ខាងសាច់ឈាម ជាព្រះអង្គប្រោសលោះនៃពិភពលោក » ។[3]





### *ដកស្រង់ចេញពីព្រះគម្ពីរ*

យ៉ូហាន 3:16, គោលលទ្ធិ និង សេចក្ដីសញ្ញា 20:21–24, ម៉ូសេ 5:6–9

**កំណត់ចំណាំ**

1. សូមមើល *គោលការណ៍ទាំងឡាយនៃដំណឹងល្អ* ( ឆ្នាំ 2009 ) ទំព័រ 52–53 ។
2. D. Todd Christofferson « Building Faith in Christ » *Liahona* ខែ កញ្ញា ឆ្នាំ 2012 ទំព័រ 13 ។
3. « The Living Christ: The Testimony of the Apostles » *Liahona* ខែ មេសា ឆ្នាំ 2000 ទំព័រ 2–3 ។

## *តើខ្ញុំអាចធ្វើអ្វីខ្លះ ?*

1. ហេតុអ្វីបានជាការយល់ដឹងពីតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទ មានសារៈសំខាន់ចំពោះខ្ញុំ ?

2. តើសេចក្ដីជំនឿរបស់យើងអាចកើនឡើងដោយរបៀបណា នៅពេលយើងរក្សាសេចក្ដីសញ្ញារបស់យើងនោះ ?

**សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ**

### *ដកស្រង់ចេញពីប្រវត្តិសាស្ត្ររបស់យើង*

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងបានអានពីដំណើររឿងរបស់ស្ត្រី ទាំងមានឈ្មោះ និង ពុំស្គាល់ឈ្មោះ ដែលបានអនុវត្តសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ បានរៀន ហើយបានរស់នៅតាមការបង្រៀនរបស់ទ្រង់ ហើយបានថ្លែងទីបន្ទាល់ពីការបម្រើ អព្ភូតហេតុ និង ភាពអស្ចារ្យរបស់ទ្រង់ ។ ស្ត្រីទាំងនេះបានក្លាយជាពួកសិស្សដ៏ល្អ និង ជាសាក្សីដ៏ពិសេសនៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ ។

ឧទាហរណ៍ ម៉ាថា បានថ្លែងទីបន្ទាល់ដ៏រឹងមាំពីទេវភាពរបស់ព្រះអង្គសង្គ្រោះ នៅពេលគាត់បាននិយាយទៅកាន់ទ្រង់ថា « ខ្ញុំម្ចាស់ជឿហើយថា ទ្រង់ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ដែលត្រូវយាងមកក្នុងលោកិយមែន » ( យ៉ូហាន 11:27 ) ។

ពួកអ្នកសាក្សីនៃទេវភាពរបស់ព្រះអង្គសង្គ្រោះមុនគេបង្អស់មួយចំនួនមានមាតារបស់ទ្រង់ ម៉ារា និង បងប្អូនជីដូនមួយរបស់គាត់ អេលីសាបិត ។ មិនយូរប៉ុន្មានបន្ទាប់ពីទេវតា កាព្រីយ៉ែល បានទៅជួបនឹងម៉ារា នាងបានទៅជួបនឹង អេលីសាបិត ។ រំពេចដែលអេលីសាបិតបានឮពាក្យជំរាបសួររបស់ ម៉ារា ភ្លាម គាត់ « បានពេញជាព្រះវិញ្ញាណបរិសុទ្ធ » ( លូកា 1:41 ) ហើយបានថ្លែងទីបន្ទាល់ថា ម៉ារា នឹងក្លាយទៅជាមាតានៃព្រះរាជបុត្រានៃព្រះ ។

# ព្រះអម្ចាស់នឹងយាងត្រឡប់មកផែនដីវិញក្នុងសិរីល្អ

គ្រប់កិច្ចការដែលយើងធ្វើនៅក្នុងសាសនាចក្រ—ដូចជា កិច្ចការផ្សព្វផ្សាយសាសនា កិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ការបង្រៀនដំណឹងល្អ ការរស់នៅក្នុងជីវិតដូចជាព្រះគ្រីស្ទ—រៀបចំយើង និង មនុស្សដទៃទៀតសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច និង សម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។[1]

ការយាងមកលើកដំបូងរបស់ទ្រង់—ជីវិតរមែងស្លាប់របស់ទ្រង់—មានមនុស្សតិចតួចណាស់ដែលបានឃើញ ។ នៅពេលទ្រង់ត្រលប់មកវិញ « ដោយព្រះចេស្ដា និង សិរីល្អដ៏ធំ » នោះមនុស្សលោកទាំងអស់នឹងបានឃើញហេតុការណ៍នោះ ( គ. និង ស. 29:11 ) ។ ការយាងមកជាលើកទីពីរនឹងគូសចំណាំនូវការចាប់ផ្ដើមនៃសហស្សវត្ស ជាពេលដែលព្រះអង្គសង្គ្រោះនឹង « ស្ថិតនៅក្នុងសេចក្ដីសុចរិតជាមួយមនុស្សលោកនៅលើផែនដីអស់មួយពាន់ឆ្នាំ » ( គ. និង ស. 29:11 ) ។

ព្រះគម្ពីរបានរៀបរាប់ពីហេតុការណ៍ជាច្រើនដែលនឹងកើតមានឡើងពីមុនការយាងមកជាលើកទីពីរ ។ ហេតុការណ៍មួយចំនួនក្នុងចំណោមហេតុការណ៍ទាំងនោះរួមមាន ៖

- ការក្បត់សាសនាដ៏ធំ ជាការដកយកនូវសេចក្ដីពិត ( សូមមើល ថែស្សាឡូនីចទី 2 2:1–3, ធីម៉ូថេទី 2 4:3–4 ) ។
- ការស្ដារឡើងវិញនៃដំណឹងល្អ និង បព្វជិតភាព រួមទាំងការមកដល់នៃព្រះគម្ពីរមរមនផងដែរ ( សូមមើល អេសាយ 29:4–18, កិច្ចការ 3:19–21 ) ។
- ដំណឹងល្អនឹងត្រូវបានប្រកាសនៅជុំវិញពិភពលោក ( សូមមើល ម៉ាថាយ 24:14 ) ។
- គ្រានៃសង្គ្រាម អំពើទុច្ចរិត និង គ្រោះធម្មជាតិ ( សូមមើល ម៉ាថាយ 24:6–7, ធីម៉ូថេទី 2 3:1–7 ) ។
- « ការអស្ចារ្យនៅលើមេឃ ហើយនៅលើផែនដី » ( យ៉ូអែល 2:30, សូមមើលផងដែរ ម៉ាថាយ 24:29–30, គ. និង ស. 29:14–16, 49:23 ) ។

ទោះបីជាយើងអាចមើលឃើញពីសញ្ញាទាំងឡាយ ថាការយាងមកជាលើកទីពីររបស់ទ្រង់ជិតចូលមកដល់ក្ដី ក៏គ្មាននរណាដឹងពីពេលវេលាពិតប្រាកដដែល ព្រះអម្ចាស់នឹងយាងត្រលប់មកវិញដែរ ៖ « ម៉ោង និង ថ្ងៃនោះ នោះគ្មាននរណាដឹងឡើយ សូម្បីតែពួកទេវតានៅលើស្ថានសួគ៌ផងដែរ ហើយពួកគេនឹងពុំដឹងឡើយ រហូតដល់ទ្រង់យាងមក » ( គ. និង ស. 49:7 ) ។

មនុស្សមួយចំនួននឹងពុំបានរៀបចំខ្លួន សម្រាប់ការយាងត្រលប់មកវិញរបស់ព្រះអង្គសង្គ្រោះឡើយ ។ វានឹងក្លាយជាគ្រាមួយគួរឲ្យភ័យខ្លាចសម្រាប់ពួកទុច្ចរិត ប៉ុន្តែវាជាគ្រាមួយនៃសេចក្ដីសុខសាន្ត និង ជ័យជំនះសម្រាប់ពួកសុចរិត ។ ដូច្នេះ ព្រះគម្ពីរ និង ពួកព្យាការីនៅសម័យចុងក្រោយ បានបង្រៀនយើងពីរបៀបរស់នៅ ដើម្បីយើងអាចរៀបចំខ្លួនទៅជួបនឹងព្រះអង្គសង្គ្រោះរបស់យើង នៅពេលដែលទ្រង់នឹងយាងមកម្ដងទៀត ។ ព្រះអម្ចាស់បានបង្រៀនថា ៖

« ហើយនៅថ្ងៃនោះ ក្នុងកាលដែលយើងនឹងយាងមក ដោយនូវសិរីល្អរបស់យើង នោះពាក្យប្រៀបប្រដូចនឹងត្រូវបានសម្រេច ដែលយើងបានមានបន្ទូលពីស្រីព្រហ្មចារីដប់នាក់ ។

« ត្បិតពួកអ្នកណាដែលមានប្រាជ្ញា ហើយបានទទួលសេចក្ដីពិត ហើយបានទទួលយកព្រះវិញ្ញាណបរិសុទ្ធទុកជាអ្នកណែនាំរបស់ខ្លួន ហើយដែលពុំត្រូវបានគេបញ្ឆោត យើងប្រាប់អ្នកជាប្រាកដថា ពួកគេនឹងពុំត្រូវកាប់បោះចោលទៅក្នុងភ្លើងឡើយ ប៉ុន្តែនឹងធន់នៅថ្ងៃនោះ » ( គ. និង ស. 45:56–57, សូមមើលផងដែរ ម៉ាថាយ 25:1–13 ) ។ ■



« យើងសូមថ្លែងទីបន្ទាល់ថា [ ព្រះយេស៊ូវគ្រីស្ទ ] នឹងយាងត្រលប់មកផែនដីនៅថ្ងៃណាមួយ ។ ‹ នោះសិរីល្អនៃព្រះយេហូវ៉ានឹងសម្ដែងមក គ្រប់មនុស្សទាំងឡាយនឹងបានឃើញព្រមគ្នា › ( អេសាយ 40:5 ) ។ ទ្រង់នឹងធ្វើជាស្ដេចលើអស់ទាំងស្ដេច ហើយគ្រងជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ហើយគ្រប់ក្បាលជង្គង់នឹងឱនចុះ ហើយគ្រប់អណ្ដាតនឹងថ្លែងពាក្យថ្វាយបង្គំនៅចំពោះទ្រង់ ។ យើងម្នាក់ៗនឹងឈរទទួលការកាត់សេចក្ដីពីទ្រង់ស្របតាមកិច្ចការរបស់យើង និង បំណងប្រាថ្នាក្នុងដួងចិត្តរបស់យើង » ។

**« The Living Christ: The Testimony of the Apostles »** ***Liahona*** **ខែ មេសា ឆ្នាំ 2000 ទំព័រ 3 ។**

សម្រាប់ព័ត៌មានបន្ថែម សូមមើល លូកា 21, ពេត្រុស 2 3, គោលលទ្ធិនិងសេចក្ដីសញ្ញា 45:16–52, 88:87–107, 133:17–56 ។

**កំណត់ចំណាំ**

1. ឧទាហរណ៍ សូមមើល ដេវីឌ អេ បែដណា « The Hearts of the Children Shall Turn » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 24 និង នែល អិល អាន់ឌើរសិន « Preparing the World for the Second Coming » *Liahona* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 49 ។

ពីឆ្វេងទៅស្ដាំ ៖ រូបភាពពី *ព្រះគ្រីស្ទនៅឯភូមិ អេម៉ាអូស* ដោយ ខាល ហ្សិច ប្លុក ។ រូបភាពពី *ការយាងមកជាលើកទីពីរ* ដោយ ហារី អែនឌើរសិន © IRI ។ រូបថតពីផ្កាយ © GETTY IMAGES ។ រូបថតព្រះអាទិត្យ © CORBIS ។ រូបភាពពី *ដើម្បីព្រះរាជាមាំង* ដោយ ញូអ៊ិល ខាយ



*ពីមុនការយាងមកជាលើកទីពីរ នឹងកើតមានការរញ្ជួយដី ខ្យល់ព្យុះ និង ព្យុះភ្លៀងផ្គរ និង រន្ទះ ហើយរលកសមុទ្រនឹងមានកម្ពស់ខ្ពស់ « ហួសណាហួសណី » ( សូមមើល គ. និង ស. 88:89–90 ) ។*



*« ព្រះអាទិត្យនឹងប្រែទៅជាងងឹត ហើយព្រះច័ន្ទនឹងទៅជាឈាម មុនដែលថ្ងៃធំគួរស្ញែងខ្លាចរបស់ព្រះយេហូវ៉ាបានមកដល់ » ( យ៉ូអែល 2:31 ) ។*



*ព្រះអង្គសង្គ្រោះនឹងយាងត្រលប់មកវិញក្នុងសិរីល្អ ៖ « សិរីល្អនៃវត្តមានរបស់ទ្រង់នឹងទៅជាធំអស្ចារ្យដែលព្រះអាទិត្យនឹងលាក់ភ័ក្ត្រាដោយក្ដីខ្មាស » ( គ. និង ស. 133:49 ) ។*

*ព្រះអង្គសង្គ្រោះនឹងឈរនៅលើភ្នំអូលីវ ហើយពួក យូដា នឹងសួរថា « តើរបួសអ្វីហ្នឹងនៅដៃអ្នក និង នៅជើងអ្នក ? » ទ្រង់នឹងឆ្លើយថា « របួសទាំងនេះគឺជារបួសដែលយើងត្រូវរបួសនៅក្នុងផ្ទះរបស់មិត្តសំឡាញ់យើង ។ . . . យើងជាព្រះយេស៊ូវដែលត្រូវគេឆ្កាង » ។ ( សូមមើល គ. និង ស. 45:48–52 ) ។*



*ពួកសុចរិតនឹងបានរស់ឡើងវិញ ហើយនាំទៅជួបនឹងព្រះអង្គសង្គ្រោះនៅលើពពក (សូមមើល គ. និង ស. 88:95–97) ។*

# ការជួយកុមារឲ្យស្គាល់ព្រះវិញ្ញាណបរិសុទ្ធ

ដោយមេរីលី ប្រោន ប៊ូយ៉ាក

*យើងអាចប្រើរបៀបខុសៗគ្នាដែលព្រះវិញ្ញាណបរិសុទ្ធទំនាក់ទំនងដើម្បីជួយកូនចៅរបស់យើងឲ្យអភិវឌ្ឍទីបន្ទាល់ ។*

ក្នុងនាមជាឪពុកម្ដាយដែលមានកូនប្រុសបួននាក់ ស្វាមីខ្ញុំ និងខ្ញុំតែងស្វែងរកនូវវិធីដើម្បីជួយកូនរបស់យើង ឲ្យទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ហើយទទួលបានទីបន្ទាល់មួយ ។ យើងមានបទពិសោធន៍ដ៏សំខាន់មួយ នៅក្នុងការយល់ដឹងតាមរបៀបចម្លែកមួយ ។ ខ្ញុំបានឈរនៅក្នុងហាងមួយ ពេលការបំផុសគំនិតនោះបានកើតមានឡើង ។

ចំណាត់ថ្នាក់របស់កូនប្រុសច្បងរបស់យើង ក្នុងមុខវិជ្ជាសង្គមវិទ្យានៅឯសាលាមានការធ្លាក់ចុះយ៉ាងខ្លាំង ។ យើងបាននិយាយជាមួយនឹងគាត់ពីបញ្ហានេះ ដោយលើកទឹកចិត្តគាត់ឲ្យខិតខំសិក្សាបន្ថែមទៀត ប៉ុន្តែនៅតែគ្មានភាពប្រសើរឡើង ។ យើងបានអធិស្ឋានដើម្បីមានគំនិតជួយដល់គាត់ ។ មានថ្ងៃមួយនៅក្នុងបណ្ណាគារ ខ្ញុំមាននូវអារម្មណ៍ជំរុញមួយដ៏ខ្លាំងឲ្យទិញសៀវភៅមួយក្បាលក្នុងចំណោមសៀវភៅមួយពំនូកដែលបានដាក់លក់ ។

សៀវភៅនិយាយពីរបៀបដែលយើងម្នាក់ៗមានរបៀបរៀនសូត្រខុសៗគ្នា ។ មានមនុស្សជាច្រើនជាអ្នករៀនតាមរយៈចក្ខុវិញ្ញាណ គឺមានន័យថាពួកគេរៀនបានល្អបំផុតតាមរយៈអ្វីដែលបានពួកគេឃើញ ។ ជារឿយៗ ពួកអ្នករៀនទាំងនេះស្រឡាញ់គំនូរ និងការអាន ។ មានមនុស្សខ្លះទៀតរៀនបានល្អបំផុតតាមរយៈអ្វីដែលពួកគេស្ដាប់ឮ ។ ពួកគេយល់ព័ត៌មានយ៉ាងមានប្រសិទ្ធភាពបំផុតនៅពេលពួកគេបានស្ដាប់ឮវា ។ ជារឿយៗ មនុស្សទាំងនេះស្រឡាញ់តន្ត្រី ។ ប្រភេទចុងក្រោយនោះគឺអ្នករៀនមួយចំនួនរៀនបានល្អបំផុតតាមរយៈការធ្វើចលនា ។ ពួកគេរៀនបានល្អបំផុតពេលមានចលនា



ឬសកម្មភាព ។ ពេលខ្លះ ពួកអ្នករៀនទាំងនេះមានការលំបាកនៅឯសាលា ពេលគ្រូបង្រៀនប្រាប់ឲ្យពួកគេអង្គុយស្ងៀមនោះ ។ ពួកគេរៀនបានល្អបំផុតពេលពួកគេធ្វើចលនា ។

នោះជាចម្លើយ ! ប្រាកដណាស់ កូនប្រុសរបស់យើងពិតជាអ្នករៀនដោយការស្ដាប់—គាត់ចូលចិត្តតន្ត្រី និងការនិយាយគ្នា ! យើងបានរកឃើញថា ជារឿយៗ គាត់ត្រូវបានដកចេញពីសកម្មភាពផ្សេងទៀតនៅក្នុងថ្នាក់សង្គមវិទ្យា ហើយបន្ទាប់មកត្រូវគ្រូបង្រៀនប្រាប់ទៅអានឯកសារនៅផ្ទះ ។ គាត់មានការលំបាក ដោយសារគាត់បានឮពីការពិភាក្សាក្នុងថ្នាក់ ។ នៅពេលនៅយើងយល់ពីបញ្ហា

នេះ យើងបានលើកទឹកចិត្តគាត់ឲ្យអានឯកសាររបស់គាត់ឮៗ រួចហើយពិភាក្សាវាជាមួយនឹងយើង ។ ពិន្ទុរបស់គាត់បានមានភាពប្រសើរឡើងវិញ ។

### ការចាត់ចែងបទពិសោធន៍ខាងវិញ្ញាណ

ប៉ុន្តែការយល់ដឹងរបស់យើងពីរបៀប នៃការរៀនសូត្រមិនបញ្ចប់ត្រឹមនេះឡើយ ។ យើងបានដឹងថា នៅពេលយើងសិក្សាបញ្ហានេះកាន់តែច្រើន ហើយសង្កេតមើលកូនចៅរបស់យើងឃើញថា ជារឿយៗ ព្រះវិញ្ញាណបរិសុទ្ធបង្រៀនកូនចៅរបស់យើងតាមរបៀបដែលពួកគេរៀនបានល្អបំផុត ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា ព្រះវិញ្ញាណមានបន្ទូលមកកាន់យើងតាមភាសារបស់យើង និងតាមរបៀបដែលយើងអាចយល់ ។ ព្រះវិញ្ញាណបរិសុទ្ធសម្របសម្រួលភាសារបស់ទ្រង់ ដើម្បីឲ្យមនុស្សទាំងអស់អាចយល់ សូម្បីតែកុមារតូច ។ « ព្រះវរបិតាសួគ៌របស់យើងតែងមានពេលវេលាសម្រាប់យើងជានិច្ច ។ ទ្រង់សម្របសម្រួលទៅនឹងកម្រិតនៃការយល់ដឹងរបស់យើង ។ ‹ ប្រសិនបើទ្រង់យាងមកជួបនឹងកុមារតូចម្នាក់ នោះទ្រង់នឹងសម្របសម្រួលខ្លួនទៅនឹងភាសា និងសមត្ថភាពនៃកុមារតូច › ( យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church,* 3:392 ) » ។[1]

ការដឹងថាព្រះវិញ្ញាណសម្របសម្រួលទំនាក់ទំនងរបស់ទ្រង់ នឹងការយល់ដឹងរបស់យើងអាចលើកទឹកចិត្តដល់ឪពុកម្ដាយ ឲ្យបង្កើតនូវឱកាសនានាសម្រាប់កូនចៅរបស់ពួកគេ ដើម្បីស្ដាប់ការបង្រៀនពីព្រះវិញ្ញាណបរិសុទ្ធតាមរបៀប ដែលពួកគេនឹងយល់បានល្អបំផុត ។ « ឯកូនចៅទាំងប៉ុន្មានរបស់ឯងនឹងធ្វើជាសិស្សរបស់ព្រះយេហូវ៉ា ហើយវារាល់គ្នានឹងមានសន្តិសុខជា បរិបូរណ៍ » ( អេសាយ 54:13 ) ។

ដូចខ្ញុំបានលើកឡើងហើយថា វិធីសាស្ត្រនៃការរៀនសូត្រដ៏ចម្បងរបស់កូនប្រុសច្បងបង្អស់របស់យើងគឺតាមរយៈការស្ដាប់ឮ ។ គាត់ និងកូនប្រុសទីបីរបស់យើងចូលចិត្តតន្ត្រីដូចគ្នា ដូច្នេះជារឿយៗ យើងបានចាក់ចម្រៀងដ៏ពីរោះនៃក្រុមចម្រៀងរោងឧបោសថមរមន និងតន្ត្រីបុរាណនៅក្នុងផ្ទះរបស់យើងផងដែរ ។ ពួកគេបានទទួលអារម្មណ៍ពីព្រះវិញ្ញាណ នៅក្នុងបរិយាកាសបែបនេះ ។ យើងក៏មានការពិភាក្សាដ៏សកម្មជាច្រើនផងដែរស្ដីពីដំណឹងល្អ ហើយកិច្ចការនេះបានជួយពួកគេឲ្យរៀនពីសេចក្ដីពិតដែលត្រូវបានពង្រឹងដោយព្រះវិញ្ញាណនៅពេលពួកគេស្ដាប់នូវរឿងទាំងនោះ ។

កូនប្រុសម្នាក់ទៀតគឺជាអ្នករៀនដោយចក្ខុវិញ្ញាណ ។ គាត់ចូលចិត្តអាន ហើយនឹងទទួលអារម្មណ៍ពីព្រះវិញ្ញាណបានល្អបំផុត នៅពេលអានព្រះគម្ពីរ ឬសៀវភៅដែលទាក់ទងនឹងដំណឹងល្អ ។ យើងបានផ្ដល់សៀវភៅជាច្រើនឲ្យគាត់អានដើម្បីជួយគាត់ឲ្យទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយទទួលបានទីបន្ទាល់ ។ យើងក៏បានដាក់រូបភាពនៃដំណឹងល្អ និងពាក្យស្លោកនៅតាមជញ្ជាំងផ្ទះរបស់យើង ដើម្បីផ្ទះរបស់យើងផ្ដល់ការរៀនសូត្រតាមរយៈចក្ខុវិញ្ញាណឲ្យបានច្រើន ។

កូនប្រុសទីពីររបស់យើងគឺជាអ្នករៀនតាមរយៈចក្ខុវិញ្ញាណ និងការធ្វើចលនា ។ គាត់ជាក្មេងប្រុសដែលសកម្ម ហើយសប្បាយបំផុតក្នុងការជិះកង់ឡើងភ្នំ ឬការ ឡើងភ្នំជាមួយនឹងឪពុករបស់គាត់ ។ យើងបានរកឃើញថា គាត់ទទួលបានអារម្មណ៍ពីព្រះវិញ្ញាណបានល្អបំផុត នៅពេលគាត់នៅខាងក្រៅផ្ទះ ហើយធ្វើចលនា ។ យើងមានការបោះជំរំជាគ្រួសារជាច្រើន ជាទីកន្លែងដែលយើងបាននិយាយពីព្រះយេស៊ូវគ្រីស្ទ ការបង្កបង្កើត និងផែនការនៃសេចក្ដីសង្គ្រោះ ។ កូនប្រុសទីពីររបស់យើងបានទទួលសារលិខិតទាំងនេះតាមរបៀបមួយដ៏អស្ចារ្យ នៅពេលគាត់ចូលរួមចំណែកក្នុងសកម្មភាពទាំងនេះ ។

ស្វាមីខ្ញុំ និងខ្ញុំ ក៏បានរកឃើញផងដែរថា ការរៀនតាមរយៈការធ្វើចលនាអាចកើតឡើងពេលធ្វើការបម្រើ ។ ដូច្នេះយើងបានធ្វើសកម្មភាពបម្រើជាច្រើនជាមួយនឹងកូនចៅរបស់យើង ដើម្បីពួកគេអាចមើលឃើញ ស្ដាប់ ហើយចូលរួម ។ កិច្ចការនេះបានបង្កើតបរិយាកាសដ៏ល្អមួយដែលកូនប្រុសទាំងអស់របស់យើងអាចរៀនមេរៀនពីសេចក្ដីសប្បុរស និងការបម្រើដូចជាព្រះគ្រីស្ទ ហើយជាពិសេស គម្រោងទាំងនេះបានដក់ជាប់នឹងកូនប្រុសទីពីររបស់យើង ។



### ការស្ដាប់ និងការយល់ដឹង

យើងក៏បានរៀនផងដែរថា មនុស្សទូទៅ « ស្ដាប់ » ព្រះវិញ្ញាណបរិសុទ្ធតាមរបៀបផ្សេងៗពីគ្នា ។ ខ្ញុំកំពុងបង្រៀនមេរៀនថ្នាក់សាលាថ្ងៃអាទិត្យមួយទៅពួកអ្នកផ្លាស់ប្រែចិត្តជឿថ្មីៗ ហើយខ្ញុំបានសួរសំណួរថា « តើអ្នករាល់គ្នាទទួលអារម្មណ៍ពីព្រះវិញ្ញាណដោយរបៀបណា ? » ចម្លើយរបស់ពួកគេគឺមានសារៈសំខាន់ណាស់ ។ មានម្នាក់បាននិយាយថា « ខ្ញុំទទួលអារម្មណ៍នូវភាពច្បាស់លាស់ក្នុងគំនិតរបស់ខ្ញុំ » ។ មានម្នាក់ទៀតនិយាយថា « ខ្ញុំមានអារម្មណ៍កក់ក្ដៅនៅក្នុងចិត្ត » ខណៈដែលម្នាក់ផ្សេងទៀតបានចែកចាយថា « ខ្ញុំមានអារម្មណ៍នូវសេចក្ដីសុខសាន្តយ៉ាងជ្រាលជ្រៅ » ។ មានស្ត្រីម្នាក់ដែលបានក្លាយជាសមាជិកពីរបីខែបាននិយាយថា « ខ្ញុំមានអារម្មណ៍ព្រឺពេញទាំងខ្លួន ! » ហើយមានអ្នកផ្សេងពីរបីនាក់ទៀតបានលើកឡើងថា ម្ដងម្កាលពួកគេបាន « ឮ » សំឡេងមួយនិយាយមកកាន់ពួកគេ ឬថាមានគំនិតថ្មីៗបានកើតមានចំពោះពួកគេ ។

អែលឌើល ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « ក្នុងទម្រង់ស្រដៀងគ្នា វិវរណៈ ឬការបំផុសគំនិតកើតឡើងតាមរយៈពាក្យសម្ដី ឬគំនិតដែលបានទាក់ទងទៅចិត្ត ( សូមមើល អេណុស 1:10, គ. និង ស. 8:2–3 ) ដោយការបំភ្លឺភ្លាមៗ

© 2007



( សូមមើល គ. និង ស. 6:14–15 ) ដោយអារម្មណ៍វិជ្ជមាន ឬអវិជ្ជមានចំពោះទង្វើ ឬសូម្បីតែដោយការសម្ដែងដ៏បំផុសគំនិត ដូចជាក្នុងការសម្ដែងសិល្បៈក្ដី ។ . . . ‹ ការបំផុសគំនិតកើតឡើងជាអារម្មណ៍ច្រើនជាងជាសំឡេង › » ។[2]

វាច្បាស់ណាស់ថា យើងម្នាក់ៗអាចស្ដាប់ឮ ហើយទទួលអារម្មណ៍ពីទំនាក់ទំនងនៃព្រះវិញ្ញាណបរិសុទ្ធតាមរបៀបផ្សេងៗគ្នា ។ យើងគួរតែធ្វើឲ្យច្រើនលើសពីការដែលគ្រាន់តែបង្រៀនកូនចៅថា ពួកគេនឹងមានអារម្មណ៍កក់ក្ដៅមួយដោយសារពួកគេពុំធ្លាប់មានបទពិសោធន៍ពីអារម្មណ៍នោះ ពួកគេអាចទទួលការបំផុសគំនិតតាមរបៀបផ្សេងៗគ្នា ។

អែលឌើរ ជេ អ៊ី ជែនសិន ជាអតីតគណៈប្រធានពួកចិតសិបនាក់ បានរៀបរាប់ដំណើររឿងនេះពីសមាជិកម្នាក់ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលកំពុងធ្វើទស្សនកិច្ចនៅបេសកកម្មមួយ ។ នៅចន្លោះសន្និសីទហ្សូន សាវក រូបនេះបានងាកទៅសមាជិកនៃពួកចិតសិបនាក់ម្នាក់ ដែលបាននិយាយនៅសន្និសីទពីមុន ហើយបាននិយាយថា « ខ្ញុំគិតថាអ្នកបានផ្ដល់នូវគំនិតមួយដល់ពួកអ្នកផ្សព្វផ្សាយសាសនា ដែលបង្កើតបញ្ហាកាន់តែច្រើនលើសពីអ្វីដែលលោកអាចដោះស្រាយបានទៅទៀត ។ នៅពេលខ្ញុំបានធ្វើដំណើរទូទាំងសាសនាចក្រនេះ ខ្ញុំបានរកឃើញមនុស្សមួយចំនួនដែលមានបទពិសោធន៍នៃភាពខ្វល់ខ្វាញ់ក្នុងដើមទ្រូង ។ ជាការពិតណាស់ ខ្ញុំធ្លាប់មានមនុស្សជាច្រើនបានប្រាប់ខ្ញុំថា ពួកគេមានអារម្មណ៍ខកចិត្តដោយសារពួកគេពុំធ្លាប់មានបទពិសោធន៍ពីអារម្មណ៍នោះ ទោះជាពួកគេបានអធិស្ឋាន ឬបានតមអាហាររយៈពេលវែងយ៉ាងណាក្ដី » ។ អែលឌើរ ជែនសិន បានបន្តទៀតថា ៖ « អស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំបានព្យាយាមរៀនពីរបៀបផ្សេងគ្នាដែលព្រះវិញ្ញាណនៃព្រះអម្ចាស់ធ្វើការ ។ ប្រាកដណាស់ ព្រះមានបន្ទូលពីស្ថានសួគ៌ពិតមែន ប៉ុន្តែទ្រង់សម្ដែង បញ្ជាក់ ឬផ្ដល់ការណែនាំតាមរបៀបផ្សេងៗគ្នា » ។[3] វាជាការសំខាន់ណាស់ដើម្បីបង្រៀនដល់កូនចៅយើងថា ពួកគេត្រូវរៀនស្ដាប់ព្រះវិញ្ញាណតាមរបៀបដែលទ្រង់មានបន្ទូលទៅកាន់ពួកគេ ។

នៅពេលយើងបង្រៀនកូនចៅរបស់យើង យើងចែកចាយពីគោលការណ៍នៃសេចក្ដីជំនឿ ការប្រែចិត្ត បុណ្យជ្រមុជទឹក និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ ការបង្រៀនពួកគេឲ្យស្ដាប់ ហើយយល់ពីការបំផុសគំនិតដែលកើតមានចំពោះពួកគេ គឺជារឿងសំខាន់ចំពោះការអភិវឌ្ឍខាងវិញ្ញាណរបស់ពួកគេ ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( 1910–2008 ) បានប្រឹក្សាយើងថា « [ កូនចៅរបស់អ្នក ] នឹងត្រូវការកម្លាំង និងសេចក្ដីជំនឿទាំងអស់ ដែលអាចផ្ដល់ឲ្យពួកគេ ខណៈពួកគេនៅក្បែរអ្នកនៅឡើយ ។ ហើយពួកគេក៏នឹងត្រូវការនូវកម្លាំងដ៏ធំមួយ ដែលកើតចេញពីអំណាចដ៏ខ្ពស់ផងដែរ » ។[4]

ការទទួលការណែនាំ និងការដឹកនាំពីព្រះវរបិតាសួគ៌របស់យើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធគឺជាពរជ័យមួយដ៏អស្ចារ្យ នៅក្នុងជីវិតរបស់យើង ។ នៅពេលយើងបង្រៀនកូនចៅរបស់យើងពីរបៀបទទួល ហើយផ្ដោតអារម្មណ៍ទៅនឹងការបំផុសគំនិត និងការណែនាំទាំងនេះ នោះពួកគេនឹងមានលទ្ធភាពទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនដែលនឹងផ្ដល់កម្លាំងដល់ពួកគេនាពេលអនាគត ។ ព្រះវិញ្ញាណបរិសុទ្ធអាចជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់ពួកគេ ហើយពួកគេនឹងមានលទ្ធភាពស្ដាប់តាមទ្រង់កាន់តែច្រើនឡើង ។ ក្នុងនាមជាឪពុកម្ដាយយើងអាចជួយក្នុងដំណើរការនេះ ហើយជួយផ្ដល់ពរដល់កូនចៅរបស់យើង ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ កាលីហ្វ័រញ៉ា ស.រ.អា. ។*

**កំណត់ចំណាំ**

1. ហេរ៉ាល់ ខូស្បេ « Even a Child Can Understand » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 32 ។
2. ដាល្លិន អេក អូក « Eight Reasons for Revelation » *Liahona* ខែ កញ្ញា ឆ្នាំ 2004 ទំព័រ 8 ។
3. ជេ អ៊ី ជែនសិន « Have I Received an Answer from the Spirit? » *Ensign* ខែ មេសា ឆ្នាំ 1989 ទំព័រ 21–22 ។
4. ហ្គរដុន ប៊ី ហ៊ិងគ្លី « These, Our Little Ones » *Liahona* ខែ ធ្នូ ឆ្នាំ 2007 ទំព័រ 7 ។

# ការប្រែចិត្ត



## បទគម្ពីរអំពីការប្រែចិត្ត

សុភាសិត 28:13
អេសាយ 1:16–18
អេណុស 1:2–8
ម៉ូសាយ 4:1–3, 26:30–31
អាលម៉ា 34:32–33
ហេលេមិន 12:23
នីហ្វៃទី 3 9:20–22
គោលលទ្ធិ និង សេចក្ដីសញ្ញា 18:10–13, 58:42–43

ដង្វាយធួននៃព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទធ្វើឲ្យការប្រែចិត្តអាចកើតឡើងបាន ហើយយើងគ្រប់គ្នាត្រូវតែប្រែចិត្ត ។

អែលឌើរ ប្រេដលី ឌី ហ្វស្ដឺរ នៃពួកចិតសិបនាក់បានពន្យល់នៅក្នុងអត្ថបទមួយនៅទំព័រ 54–55 ក្នុងការចេញផ្សាយខែនេះថា ពេលខ្លះ យើងមានការភ័យខ្លាចនៅពេលអំពើបាបមួយដ៏ធំតម្រូវឲ្យមានការសារភាពទៅប៊ីស្សព ឬប្រធានសាខា ។ ប៉ុន្តែ « ជនទាំងឡាយណាដែលបានធ្វើដំណើរលើផ្លូវនៃការប្រែចិត្តនឹងប្រាប់អ្នកថា ពុំមែនតែការធ្វើដំណើរនោះអាចកើតឡើងតែម្យ៉ាងនោះទេ ប៉ុន្តែថានៅពេលអ្នកបានទៅដល់ទីនោះ ហើយក្រឡេកមើលមកខាងក្រោយវិញ នេះគឺជាអ្វីដែលអ្នកនឹងបានឃើញ ៖

« *អ្នកអាចធ្វើកិច្ចការនេះបាន ។ ហើយនៅពេលអ្នកធ្វើកិច្ចការនេះ អ្វីៗគ្រប់យ៉ាងនឹងបានប្រសើរឡើង ។ . . .*

« *កាលណាអ្នកចាប់ផ្ដើមកាន់តែលឿន នោះអ្នកនឹងមានអារម្មណ៍ធូរស្រាល ។ . . .*

« *ប៊ីស្សពរបស់អ្នកនឹងជួយអ្នកនៅក្នុងដំណើរការនេះ ។ អ្នកនឹងស្រឡាញ់គាត់ ហើយនឹងពុំភ្លេចគាត់ឡើយ* » ។

### យោបល់ទាំងឡាយសម្រាប់បង្រៀនយុវវ័យ

សូមអានជាមួយនឹងកូនជំទង់របស់អ្នក នូវផ្នែកពីការប្រែចិត្តក្នុងសៀវភៅ*ដើម្បីកម្លាំងនៃយុវជន* ។ សូមពិភាក្សាពីពរជ័យដែលយើងអាចទទួលបានតាមរយៈដង្វាយធួន និងពីរបៀបដែលការប្រែចិត្តធ្វើឲ្យពរជ័យទាំងនេះអាចកើតមានឡើង ។

អ្នកក៏អាចចែកចាយទីបន្ទាល់របស់អ្នកពីការប្រែចិត្ត និងពីដង្វាយធួន និងពីសារៈសំខាន់របស់វានៅក្នុងជីវិតរបស់អ្នក ។ អ្នកក៏គួរសុំឲ្យកូនជំទង់របស់អ្នកចែកចាយពីទីបន្ទាល់ខ្លួនពួកគេ ពីការប្រែចិត្តជាមួយនឹងអ្នកផងដែរ ។ ហើយប្រសិនបើសមរម្យ អ្នកអាចអញ្ជើញកូនជំទង់របស់អ្នក ឲ្យជួយដល់ប្អូនប្រុសស្រីជាមួយនឹងសកម្មភាពដែលបានរៀបរាប់ខាងក្រោម ។

### យោបល់ទាំងឡាយដើម្បីបង្រៀនកូនចៅ

ដើម្បីបង្ហាញពីអត្ថន័យនៃការដើរលើផ្លូវដែលព្រះអម្ចាស់បានបញ្ជាដល់យើងឲ្យដើរតាមនោះ សូមពិចារណាពីការប្រើឡានសម្រាប់ក្មេងលេង ( ឬយន្តហោះ កប៉ាល់ ឬរទេះ ) ជាឧបករណ៍សម្រាប់មេរៀន ។ សូមប្រើផែនទីមួយ ហើយសុំឲ្យកូនរុញឡានពីចំណុចមួយទៅកាន់ចំណុចមួយទៀត នៅលើផែនទី ។ សូមសួរថា « ប្រសិនបើឡាននោះចាប់ផ្ដើមបើកចេញពីផ្លូវ តើចាំបាច់ត្រូវធ្វើអ្វី ? »

ប្រាកដណាស់ថា ឡានមួយបើកចេញពីផ្លូវនោះវាត្រូវយកមកដាក់នៅលើផ្លូវត្រូវវិញ សូមសួរថាតើដំណើរការនេះដូចគ្នានឹងការប្រែចិត្តយ៉ាងដូចម្ដេចទៅ ។ សូមពន្យល់ថា ពេលខ្លះនៅពេលធ្វើដំណើរនៅក្នុងជីវិត យើងត្រូវផ្លាស់ប្ដូរទិសដៅរបស់យើង ដើម្បីធ្វើឲ្យប្រាកដថា យើងបានដើរនៅលើផ្លូវត្រូវ ។ ពេលខ្លះ យើងអាចធ្វើកិច្ចការនេះដោយខ្លួនឯង ។ ប៉ុន្តែពេលខ្លះយើងត្រូវការជំនួយ ។ ចូរសុំឲ្យកូនចៅ ប្រាប់ពីពេល ដែលពួកគេបានជួយដល់ខ្លួនឯង ពេលដែលអ្នកដទៃបានជួយដល់ពួកគេ និងពីរបៀបដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទអាចជួយពួកគេ ។ នៅពេលអ្នកបង្រៀនពីប្រធានបទនេះ សូមចងចាំថា កុមារដែលមានអាយុក្រោមប្រាំបីឆ្នាំពុំមានទំនួលខុសត្រូវ និងពុំត្រូវការការប្រែចិត្តឡើយ ប៉ុន្តែវារឿងដ៏មានតម្លៃសម្រាប់ពួកគេដើម្បីរៀនសូត្រពីគោលការណ៍នៃការប្រែចិត្ត ។

សូមពិភាក្សាចម្លើយពួកគេជាមួយនឹងពួកគេ ហើយពិភាក្សាពីរបៀបដែលការប្រែចិត្តគឺជាអំណោយទានមួយពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ដែលវាអាចធ្វើឲ្យយើងត្រលប់ទៅរក ទ្រង់ម្ដងទៀតបាន ។ ■

# ព័ត៌មានសាសនាចក្រ

*សូមមើលគេហទំព័រ news.lds.org សម្រាប់ព័ត៌មាន និង ព្រឹត្តិការណ៍បន្ថែមទៀត ។*

## អែលឌើល អិម រ័សុល បាឡឺដ ថ្លែងសុន្ទរកថាទៅកាន់ពួកបរិសុទ្ធនៅទ្វីបអឺរ៉ុប

អែលឌើល អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ នៅអំឡុងពេលធ្វើការចាក់ផ្សាយទៅកាន់សមាជិកសាសនាចក្រនៅក្នុងប្រទេស ស៊ុយអែត ដាណាម៉ាក ហ្វាំងឡង់ និង ន័រវេ ថា ក្នុងយុគសម័យនេះ សេចក្ដីជំនឿដែលបានបង្ហាញដោយពួកអ្នកត្រួសត្រាយនៅទ្វីបអឺរ៉ុបពីដើម គឺតម្រូវឲ្យមាន បើសិនពួកបរិសុទ្ធថ្ងៃចុងក្រោយចង់ឲ្យសាសនាចក្រ និង នគរនៃព្រះរីកលូតលាស់ ។

« តើសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយនឹងក្លាយទៅជាយ៉ាងណា ក្នុងរយៈពេល 20 ឆ្នាំទៅមុខទៀត ដោយគិតចាប់ពីពេលឥឡូវនេះទៅ នៅទីនេះ នៅក្នុងប្រទេសរបស់អ្នក ? » ។ អែលឌើរ បាឡឺដ បានមានប្រសាសន៍យ៉ាងនេះ ។ « តើយើងនឹងនិយាយបែបណាចំពោះពួកសមាជិក ស្កាឌីណាវៀន ពីដើមៗនៃសាសនាចក្រ បើសិនយើងមិនអាចប្រកាសថា សេចក្ដីជំនឿ ភាពក្លាហាន សកម្មភាពរបស់យើងគឺដូចពួកគេនោះ ថាយើងបានប្រឹងប្រែងអស់ពីសមត្ថភាពរបស់យើង ដើម្បីពង្រឹងសាសនានៅគ្រប់វួដ សាខា ស្តេក និង មណ្ឌលនិមួយៗនោះ ? »

ការចាក់ផ្សាយនេះ គឺជាវគ្គមួយនៃទស្សនកិច្ចថ្មីៗនេះរបស់ អែលឌើរ បាឡឺដ ទៅកាន់ទីក្រុង ស្តុកខូម ប្រទេស ស៊ុយអែត ទីក្រុង ឡុងដ៍ ប្រទេស អង់គ្លេស និង ទីក្រុង ប៉ារីស ប្រទេស បារាំង ។

អែលឌើរ បាឡឺដ បានជួបពួកអ្នកផ្សព្វផ្សាយសាសនាដែលកំពុងបម្រើនៅក្នុងប្រទេស ស៊ុយអែត និង បានមានប្រសាសន៍ទៅកាន់ពួកមជ្ឈិមវ័យវ័យក្មេងនៅលីវនៅក្នុងទីក្រុង ស្តុកខូម ។ ការប្រជុំនោះត្រូវបានចាក់ផ្សាយទៅកាន់សាលាប្រជុំចំនួន 402 នៅក្នុងតំបន់អឺរ៉ុប ។ លោកបានមានប្រសាសន៍ពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ ហើយគូសបញ្ជាក់ថាជម្រើសទាំងឡាយដែលមជ្ឈិមវ័យនៅក្មេងបានធ្វើដើម្បីរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អនោះ នឹងសម្រេចពីជោគវាសនារបស់សាសនាចក្រនាពេលអនាគត ។ លោកបានអញ្ជើញពួកគេគ្រប់គ្នាឲ្យនាំមនុស្សម្នាក់មកព្រះវិហារ ឬ នាំមនុស្សណាម្នាក់ឲ្យត្រឡប់មកសកម្មក្នុងព្រះវិហារវិញនៅដំណាច់ឆ្នាំនេះ ។

*អែលឌើល អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឈរជាមួយសមាជិកសាសនាចក្រ បន្ទាប់ពីការប្រជុំមួយនៅក្នុងប្រទេស ស៊ុយអែត ក្នុងខែ មិថុនា ។*



អែលឌើរ បាឡឺដ ក៏បានថ្លែងទៅកាន់ សមាជិកសាសនាចក្រនៅក្នុង សន្និសីទ ន័រឌីក ដែលត្រូវបានចាក់ផ្សាយទៅកាន់សាលាប្រជុំទាំងអស់នៅក្នុងប្រទេស ស៊ុយអែត ដាណាម៉ាក ហ្វាំងឡង់ និង ន័រវេ ។ សមាជិកភាពនៃសាសនាចក្រនៅក្នុងប្រទេស ន័រឌីក មានចំនួនជាង 23,000 នាក់ នៅក្នុងក្រុមជំនុំចំនួន 123 ។

នៅទីក្រុង ឡុងដ៍ ប្រទេស អង់គ្លេស អែលឌើរ បាឡឺដ និង អែលឌើរ ហូសេ ធាស៊ីរ៉ា ប្រធានតំបន់អឺរ៉ុប បានជួបពួកអ្នកផ្សព្វផ្សាយសាសនាកំពុងបម្រើនៅក្នុងបេសកកម្ម ទីក្រុង ឡុងដ៍ និង បេសកកម្មទីក្រុង ឡុងដ៍ ភាគខាងត្បូង ។ ពួកអ្នកផ្សព្វផ្សាយសាសនារាប់រយនាក់បានស្តាប់ទីបន្ទាល់របស់ អែលឌើរ បាឡឺដ ហើយទទួលអារម្មណ៍នៃភាពសោមនស្សរីករាយចំពោះកិច្ចការផ្សព្វផ្សាយសាសនា ។

នៅប្រទេស បារាំង អែលឌើរ បាឡឺដ បានជួបពួកអ្នកផ្សព្វផ្សាយសាសនានៅ វ៉ីសែលេស ។ លោកក៏បានឆ្លៀតចូលទស្សនាទីធ្លានៃព្រះវិហារបរិសុទ្ធ ប៉ារីស ប្រទេស បារាំង ដែលនឹងសង់នៅពេលខាងមុខ ដែលត្រូវបានប្រកាសនៅក្នុងសន្និសីទទូទៅខែ តុលា ឆ្នាំ 2011 ។ ■

*ដំណើររឿងមកពី សារ៉ា ជេន វីវ៉ឺ ព័ត៌មានសាសនាចក្រ ។*

## ព្រះគម្ពីរមរមនបានបោះពុម្ពជាភាសា ម៉ាឡេ

សាសនាចក្របានប្រកាសពីការបោះពុម្ពនៃព្រះគម្ពីរមរមនជាភាសា ម៉ាឡេ ដែលជាភាសាទី 109 នៃព្រះគម្ពីរនេះ ។ ព្រះគម្ពីរមរមនជាភាសាស្លូវ៉ាគី បានបោះពុម្ពហើយដាក់ឲ្យប្រើប្រាស់នៅក្នុងខែ មិនា ឆ្នាំនេះ ។ ភាសា ម៉ាឡេ ត្រូវបានគេនិយាយនៅក្នុងប្រទេស អាស៊ី ភាគអាគ្នេយ៍ ដូចជាប្រទេស ម៉ាឡេស៊ី សង្ហ៊ឹបុរី ឥណ្ឌូនេស៊ី និង ឥណ្ឌា ។

ឥឡូវនេះ ព្រះគម្ពីរមរមនជាភាសា ម៉ាឡេ មានលក់នៅតាមមជ្ឈមណ្ឌលចែកចាយសាសនាចក្រក្នុងមូលដ្ឋាន និង តាមស្តុកអ៊ីនធើរណែតនៅគេហទំព័រ store.lds.org ( លេខ 35607 348 ) នឹងនៅគេហទំព័រ scriptures.lds.org ។

## ធនធានសម្រាប់បង្រៀនកុមារនៅគេហទំព័រ LDS.org

អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ គ្រូបង្រៀន អ្នកដឹកនាំ និង ឪពុកម្តាយទាំងឡាយបានពង្រីកការបង្រៀនដំណឹងល្អរបស់ខ្លួនដោយមានជំនួយមកពីទស្សនាវដ្តី *Friend* និង *លីអាហូណា* ។ ឥឡូវនេះ ធនធានដូចគ្នាមួយចំនួននេះ មាននៅតាមអ៊ីនធើរណែនៅគេហទំព័រLDS.org ហើយត្រូវបានរៀបចំ ដូច្នេះអ្នកអាចងាយស្វែងរកមេរៀនដ៏មានប្រយោជន៍ដែលអ្នកកំពុងស្វែងរក ។

អ្នកអាចស្រាវជ្រាវរកធនធានទាំងនោះតាមប្រធានបទ ប្រភេទ និង តាមលេខរៀងមេរៀនថ្នាក់អង្គការបឋមសិក្សាជាភាសាអង់គ្លេសបានផងដែរដោយវាយបញ្ចូល « Resources for Teaching Children » នៅក្នុងរបាស្វែងរកនៅគេហទំព័រ LDS.org ។ អ្នកអាចរាវរកទំព័រនេះបានផងដែរពីទំព័រនៃសៀវភៅសិក្សាថ្នាក់អង្គការបឋមសិក្សា ។

ផ្នែកប្រធានបទនៃធនធាននានាសម្រាប់បង្រៀនកុមារមានជាភាសា អេស្ប៉ាញ និង ព័រទុយហ្គាល់ ហើយអាចរកបានទាំងមកពី LDS.org ឬមកពីគេហទំព័រដើមនៃ*លីអាហូណា*ជាភាសាទាំងនេះ ។

ធនធាននានារួមមាន រឿង សកម្មភាព អត្ថបទ*លីអាហូណា*និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតដែលសាសនាចក្របានអនុមតិ សម្រាប់បង្រៀនកុមារនៅគេហដ្ឋាន ឬ នៅព្រះវិហារ ។ ប្រធានបទបន្ថែម នឹងដាក់បន្ថែមជារៀងរាល់ខែ ។

*ដំណើររឿងមកពី ខាមីល វ៉េស LDS.org ព័ត៌មាន និង ព្រឹត្តិការណ៍នានា*

## ការប្រារព្ធខួបលើកទី 135 ឆ្នាំនៃថ្នាក់អង្គការបឋមសិក្សា

កាលពី 135 ឆ្នាំកន្លងទៅ នៅក្នុងទីក្រុង ហ្វាមមីងតុន រដ្ឋ យូថាហ៍ ស.រ.អា. ប៊ីស្សព ចន ដបុលយូ ហេស បានព្រួយបារម្ភពីអាកប្បកិរិយារបស់កុមារនៅក្នុងវួដរបស់គាត់ ។គាត់បានសុំជួបម្តាយគ្រប់រូបនៅក្នុងវួដ ហើយពិភាក្សាពីសារៈសំខាន់នៃការណែនាំដល់កូនចៅតូចៗរបស់ពួកគាត់ ។

អូរេលីយ៉ា ស្ពែនស័រ រ៉ូជើរ បានស្តាប់ ហើយបន្ទាប់មកពិភាក្សាពីបញ្ហានេះជាមួយ លីស្សា អ៊័រស្ទ ដែលបានធ្វើទស្សនកិច្ចទៅ ហ្វាមមីងតុង នៅក្នុងរដូវផ្ការីកឆ្នាំ 1878 ។ បន្ទាប់មក ស៊ីស្ទើរ ស្ន បានជួបប្រធានសាសនាចក្រ គឺប្រធាន យ៉ូហាន ថេល័រ ដែលបានផ្តល់សិទ្ធិដល់ប៊ីស្សព ហេស ឲ្យបង្កើតអង្គការសម្រាប់កុមារនៅក្នុងវួដរបស់គាត់ ។ សមាគមន៍ថ្នាក់អង្គការបឋមសិក្សាវួដ ហ្វាមមីងតុន ត្រូវបានបង្កើតឡើងដោយស្របច្បាប់នៅថ្ងៃទី 11 ខែ សីហា ឆ្នាំ 1878 ដែលមានស៊ីស្ទើរ រ៉ូជើរ ជាប្រធាន ។

សព្វថ្ងៃនេះ កុមារប្រមាណជាមួយលាន់នាក់នៅលើពិភពលោក ទទួលបានផលប្រយោជន៍ពីថ្នាក់អង្គការបឋមសិក្សារៀងរាល់សប្តាហ៍ ។ ពួកអ្នកដឹកនាំ និង គ្រូបង្រៀនថ្នាក់អង្គការបឋមសិក្សាព្យាយាមគាំទ្រឪពុកម្តាយនៅក្នុងតួនាទីរបស់ពួកគាត់ដើម្បីជួយកុមារឲ្យទទួលបានទីបន្ទាល់ពីព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អដែលបានស្តារឡើងវិញ ។ ■

*ដំណើររឿងមកពី រ៉ូសេម៉ារី អិម វ៉ាកស៊ុម, ជេន អេ ស្ទេវិន និង ឈើរីល អេ អ៊ីស្តីន គណៈប្រធានអង្គការបឋមសិក្សាទូទៅ*


© IRI

សារលិខិតគណៈប្រធានទីមួយស្តីពីសមាគមន៍ថ្នាក់អង្គការបឋមសិក្សា*ដោយ លីន ហ្វូសស្បែត និង ហ្គរដុន ខុប ។*


ថតរូបដោយ គ្រីស្ទីណា ស្មីធ © IRI

*អ្នកដឹកនាំ និង គ្រូបង្រៀនថ្នាក់អង្គការបឋមសិក្សា ព្យាយាម ជួយកុមារទទួលបានទីបន្ទាល់ពីព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អដែលបានស្តារឡើងវិញ ។*





ISTOCKPHOTO/THINKSTOCK

ដោយ អែលឌើរ
ប្រ៊ូស ឌី ភទើរ៍
នៃពួកចិតសិបនាក់



# ចូរយើងនាំគ្នាចូល មក ថ្វាយបង្គំទ្រង់

*ទោះជាមានអ្វីមកចងយើងក្ដី—អំពើបាប កាលៈទេសៈ ឬព្រឹត្តិការណ៍ពីអតីតកាល—ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ជាអេម៉ាញូអែលដ៏អស្ចារ្យ បានយាងមកដើម្បីរំដោះយើងឲ្យមានសេរីភាព ។*

ច្រើនជាង 700 ឆ្នាំ មុនការប្រសូតមករបស់ព្រះយេស៊ូវគ្រីស្ទ អេសាយ បានព្យាករពីទ្រង់ជាពាក្យសម្ដីដែលបានប្រើដោយអ្នកនិពន្ធ ជួច ហ្វ្រិឌើរិក ហានឌេល នៅក្នុងការងារតន្ត្រី *The Messiah* ( *ព្រះមែស៊ី* ) ថា ៖ « ត្បិតមានបុត្រមួយកើតដល់យើង ព្រះទ្រង់ប្រទានបុត្រាមួយមកយើងហើយ ឯការគ្រប់គ្រងនឹងនៅលើស្មារបស់បុត្រនោះ ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ និងជាម្ចាស់នៃមេត្រីភាព » ( អេសាយ 9:6 ) ។

*Messiah* ( *ព្រះម៉ែស៊ី* ) របស់ហានឌេល ក៏បានបង្ហាញតាមរយៈការសម្ដែងតន្ត្រីដ៏អស្ចារ្យនូវការណែនាំដូចតទៅនេះ ដោយផ្អែកលើ អេសាយ 40:9 ថា ៖ « ឱអ្នកដែលនាំដំណឹងល្អមកដល់ក្រុងស៊ីយ៉ូនអើយ . . . ឱអ្នកដែលនាំដំណឹងល្អមកដល់ក្រុង យេរូសាឡិម អើយ ចូរបន្លឺសំឡេងឡើងជាខ្លាំង ចូរបន្លឺឡើងកុំខ្លាចឡើយ ចូរប្រាប់ដល់ទីក្រុងនៃស្រុក យូដា ទាំងប៉ុន្មានថា មើលន៍ ព្រះនៃអ្នករាល់គ្នា ! »[1]

មើលន៍ ព្រះនៃអ្នករាល់គ្នា ប្រសូតមកជាព្រះឱរសក្នុងភូមិ បេថ្លេហិម ហើយបានរុំនឹងសំពត់ ។ មើលន៍ ព្រះនៃអ្នករាល់គ្នា បានប្រសូតមកក្នុងភាពក្រខ្សត់ ហើយសាមញ្ញ ដែលទ្រង់ត្រូវយាងនៅក្នុងចំណោមមនុស្សទូទៅ ក្នុងនាមជាមនុស្សសាមញ្ញម្នាក់ ។ មើលន៍ ព្រះនៃអ្នករាល់គ្នា ជាព្រះប្រោសលោះដ៏គ្មានព្រំដែន និងនៅអស់កល្បជានិច្ច បានទទួលរូបកាយជាសាច់ឈាម ហើយបានយាងមករស់លើផែនដីដែលទ្រង់បានបង្កើត ។

សូមទៅជាមួយខ្ញុំទៅកាន់បុណ្យគ្រីស្ទម៉ាសដំបូងដ៏ពិសិដ្ឋនោះនៅក្នុងភូមិ បេថ្លេហិម ដើម្បីសញ្ជឹងគិតពីការប្រសូតរបស់ព្រះអម្ចាស់ ។ ទ្រង់បានយាងមកនៅ





វេលាយប់ដ៏ស្ងប់ស្ងាត់ ក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត ដែលទ្រង់ជាអេម៉ាញូអែល ( សូមមើល អេសាយ 7:14 ) ជាលំពង់របស់អ៊ីសាយ ( សូមមើល អេសាយ 11:1 ) ជាថ្ងៃជិតរះ ( សូមមើល លូកា 1:78 ) ព្រះអម្ចាស់ដ៏មានមហិទ្ធិឫទ្ធិ ( សូមមើល កូរិនថូសទី 2 6:18 ) ។ ការប្រសូតរបស់ទ្រង់បានកត់ចំណាំពីការយាងមកកាន់ផែនដីនៃព្រះបង្កបង្កើត ជាការយាងចុះមកនៃព្រះធ្វើជាមនុស្ស ( សូមមើល នីហ្វៃទី 1 11:16–27 ) ។ ដូចដែល អេសាយ បានសរសេរពីព្រឹត្តិការណ៍នោះថា « ឯបណ្ដាជនដែលដើរក្នុងសេចក្ដីងងឹត គេបានឃើញពន្លឺយ៉ាងធំ ពួកអ្នកដែលអាស្រ័យនៅក្នុងស្រុកនៃម្លប់សេចក្ដីស្លាប់ គេមានពន្លឺភ្លឺមកលើគេហើយ » ( អេសាយ 9:2 ) ។

យើងដឹងពីវិវរណៈសម័យទំនើបថា ស្ដេចនៃអ៊ីស្រាអែល ដែលបានតែងតាំងទុកជាមុនបានយាងមកកាន់ផែនដីក្នុងនិទាឃៈរដូវ ( សូមមើល គ. និង ស. 20:1 ) ។ មីកា បានព្យាករណ៍ថា ទ្រង់នឹងប្រសូតមកក្នុងភូមិ បេថ្លេហិម— « តូចនៅក្នុងពួកយូដាទាំងពាន់ » ( មីកា 5:2 ) ។ ភូមិដែលទ្រង់ប្រសូតគឺនៅក្បែរនឹងទីក្រុង យេរូសាឡិម គឺមានចម្ងាយ 8 គ.ម. ទៅភាគខាងជើង ។ យេរូសាឡិម ជារាជធានីនៃយូដា ជាទីក្រុងដែលមានព្រះវិហារបរិសុទ្ធ ហើយការគ្រប់គ្រងដោយពួករ៉ូម ។ ផ្ទុយទៅវិញ ភូមិ បេថ្លេហិម គឺជាទីជនបទដាច់ស្រយាល ដែលប្រជាជនប្រកបរបរធ្វើស្រែចម្ការ និងការចិញ្ចឹមសត្វ ។ ហេតុផលមួយដែលត្រូវបានគេស្គាល់ គឺដោយសារវាជាទីកន្លែងកំណើតរបស់ដាវីឌ ជាស្ដេចអ៊ីស្រាអែល បុរាណ ដែលព្រះគ្រីស្ទបានប្រសូតមកតាមរយៈពូជពង្សរបស់លោក ដូច្នេះហើយ ភូមិតូចនេះត្រូវបានគេស្គាល់ជាទូទៅថាជាទីក្រុងដាវីឌ ។ ឈ្មោះរបស់វាជាភាសា ហេព្រើរ គឺ*បេ ថ្លេហិម* មានន័យថា « ដំណាក់នៃនំប៉័ង »[2] ជាឈ្មោះមួយដែលពុំមានសារៈសំខាន់ រហូតដល់ទ្រង់ជាអង្គដែលត្រូវបានគេស្គាល់ថាជានំប៉័ងនៃជីវិតបានប្រសូតមក ។

*ព្រះអង្គសង្គ្រោះបានស្គាល់ពីជីវិតនៅគ្រប់ជ្រុងជ្រោយ ទាំងខាងស្មុគ៌ា និងផែនដីផងដែរ។ ទ្រង់ដែលជាអង្គដ៏អស្ចារ្យ បំផុត បានធ្វើឲ្យអង្គទ្រង់តូចបំផុត—ជាអ្នកគង្វាលចៀមស្មុគ៌ា បានក្លាយជាកូនចៀម ។*

ទីវាលនៅជុំវិញភូមិ បេថ្លេហិម គឺជាក្រោលហ្វូងចៀមជាច្រើនក្បាល ហើយនៅដើមនិទាឃៈរដូវគឺជារដូវកាលដែលសត្វចៀមកើត ។ ពួកអ្នកគង្វាលត្រូវនៅចាំយាមសត្វចៀមរបស់ពួកគេស្ទើរតែរាល់យប់ នៅក្រោមផ្ទៃមេឃស្រឡះនាពេលរាត្រី ពេលនោះ ពួកទេវតាដែលបានមកប្រកាស ពីការប្រសូតរបស់ព្រះអង្គសង្គ្រោះពុំចាំបាច់ត្រូវដាស់ពួកគេឲ្យភ្ញាក់ពីដំណេកនោះឡើយ ។

## កូនចៀមនៃព្រះ

ព្រះឱរសតូចដែលបានប្រសូតមកនារដូវកាលនោះត្រូវបានគេស្គាល់ថាជា « កូនចៀមនៃព្រះ » ( យ៉ូហាន 1:29, នីហ្វៃទី 1 11:31, គ. និង ស. 88:106 ) ។ វាគឺជានាមមួយដ៏សំខាន់ ពីព្រោះទ្រង់បានប្រសូតមកក្បែរហ្វូងសត្វចៀម ហើយថ្ងៃណាមួយនឹងត្រូវនាំយកទៅ « ដូចជាកូនចៀមដែលគេដឹកទៅសម្លាប់ » ( អេសាយ 53:7 ) ។ ប៉ុន្តែចម្លែកណាស់ ទ្រង់ក៏ជាអ្នកគង្វាលចៀមដ៏ល្អផងដែរ ( សូមមើល យ៉ូហាន 10:11 ) ជាអ្នកដែលមើលថែកូនចៀម ។ ដូច្នេះ សញ្ញាទាំងពីរនេះនៃជីវិតរបស់ទ្រង់តំណាងឲ្យទាំងអ្នកដែលបម្រើ និងអ្នកដែលត្រូវបានគេប្រើ ។ ដោយសារតែតាមរយៈសិទ្ធិរបស់ទ្រង់ប៉ុណ្ណោះ ទើបព្រះគ្រីស្ទត្រូវដើរតួនៅក្នុងតួនាទីទាំងពីរនេះ ពីព្រោះនៅក្នុងជីវិត ទ្រង់ « បានយាងចុះក្រោមគ្រប់ទាំងអស់ » ( គ. និង ស. 88:6 ) ហើយនៅក្នុងភាពអស់កល្បជានិច្ច ទ្រង់ « បានយាងឡើងទៅស្ថានខ្ពស់ » ហើយនៅក្នុង និងតាមរយៈ និង « នៅព័ទ្ធជុំវិញគ្រប់ទាំងអស់ » ( គ. និង ស. 88:6, 41) ។ ទ្រង់បានស្គាល់ពីជីវិតនៅគ្រប់ជ្រុងជ្រោយ ។ ទ្រង់

*THE LIGHT OF THE WORLD* ដោយ ហ្គ្រេក ខេ អុលសិន ចាប់អនុញ្ញាត, *THE CRUCIFIXION* ដោយ ហារី អែនឌើសិន, *THE PASSOVER* ដោយ វិល្លៀម ហេនរី ម៉ាហ្គេតសិន

ដែលជាអង្គដ៏អស្ចារ្យបំផុតបានធ្វើឲ្យអង្គទ្រង់តូចបំផុត—ជាអ្នកគង្វាលចៀមសួគ៌ាបានក្លាយជាកូនចៀម ។

ការយាងមករបស់ទ្រង់គឺលើសពីការប្រសូតជាព្យាការីដ៏អស្ចារ្យមួយអង្គទៅទៀត ការយាងមកនៃពូជហ្លួងមួយអង្គដែលបានសន្យានឹងមកគ្រងបល្ល័ង្ក ឬថែមទាំងជាការយាងមកដល់នៃអង្គដ៏ល្អបំផុតតែមួយគត់ដែលនឹងដើរនៅលើផែនដីនេះ ។ វាគឺជាការយាងមកនៃព្រះនៃស្ថានសួគ៌ « ដើម្បីដើរលើកល់បាទទ្រង់ដូចជាមនុស្សធម្មតា » ។[3]

ព្រះយេស៊ូវគ្រីស្ទគឺជាព្រះបង្កបង្កើតនៃលោកិយ និងជាព្រះយេហូវ៉ាដ៏អស្ចារ្យនៃព្រះគម្ពីរសញ្ញាចាស់ ។ វាគឺជាព្រះបន្ទូលរបស់ទ្រង់ដែលបន្លឺឡើងនៅលើភ្នំ ស៊ីណៃ វាជាព្រះចេស្ដាទ្រង់ដែលបានជួយដល់រាស្ត្រ អ៊ីស្រាអែល ដែលបានជ្រើសរើសនៅពេលវង្វេងនៅក្នុងទីរហោស្ថាន ហើយវាជាវត្តមានរបស់ទ្រង់ដែលបានបង្ហាញដល់អេណុស អេសាយ និងពួកព្យាការីគ្រប់រូបនូវសិរីល្អនៃរឿងដែលនឹងកើតមាន ។ ហើយនៅក្នុងនោះគឺមាននូវអព្ភូតហេតុដ៏អស្ចារ្យនៃព្រះប្រសូតិកម្ម ៖ ជាពេលដែលព្រះ និងព្រះបង្កបង្កើតស្ថានសួគ៌ និងផែនដីបានបង្ហាញអង្គទ្រង់ជាលើកដំបូង ដោយអង្គ ទ្រង់ផ្ទាល់ចំពោះពិភពលោក ទ្រង់បានជ្រើសរើសធ្វើដូច្នេះក្នុងនាមជាព្រះឱរសមួយអង្គ ដែលគ្មានទីពំនឹង ហើយត្រូវការពឹងអាស្រ័យ ។

មានប្រពៃណី ហេព្រើរ ពីបុរាណមួយបានប្រាប់ថា ព្រះមែស៊ីនឹងប្រសូតនៅបុណ្យរំលង ។ យើងដឹងថា ខែ មេសា ក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត ពិតជាស្ថិតនៅក្នុងសប្តាហ៍នៃបុណ្យរំលងមែន—ជាបុណ្យរំឭកខួបដ៏ពិសិដ្ឋ សម្រាប់ពួក យូដា នៃការសង្គ្រោះរាស្ត្រ អ៊ីស្រាអែល ពីទេវតាបំផ្លិចបំផ្លាញដែលបាននាំមកនូវសេចក្ដីស្លាប់ដល់ពួកកូនប្រុសច្បងនៃ អេស៊ីព្ទ ។ គ្រួសារ អ៊ីស្រាអែល និមួយៗដែលបានបូជាកូនចៀម ហើយបានយកឈាមវាមកលាបនៅលើមាត់ទ្វារផ្ទះរបស់ពួកគេនឹងបានរួចផុតជីវិត ( សូមមើល និក្ខមនំ 12:3–30 ) ។ សាមសិបបីឆ្នាំក្រោយពីបុណ្យរំលងនៃការប្រសូតរបស់ព្រះគ្រីស្ទមក ព្រះលោហិតរបស់ទ្រង់ត្រូវបានប្រឡាក់នៅលើឈើឆ្កាង ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់ពីពួកទេវតានៃសេចក្ដីស្លាប់ និងអំពើដែលបំផ្លិចបំផ្លាញ ។

បុណ្យរំលងនោះប្រហែលជាមូលហេតុដែលធ្វើឲ្យគ្មានបន្ទប់ក្នុងផ្ទះសំណាក់សម្រាប់ ម៉ារា និងយ៉ូសែប ។ ចំនួនប្រជាជននៃទីក្រុង យេរូសាឡិម បានកើនដល់ទៅរាប់ម៉ឺននាក់នៅអំឡុងបុណ្យរំលង ដោយធ្វើឲ្យអ្នកធ្វើដំណើរត្រូវស្វែងរកកន្លែងសម្រាកនៅខាងក្រៅទីក្រុង ។ ម៉ារា និង យ៉ូសែប បានធ្វើដំណើរទៅ បេថ្លេហិម ជាផ្ទះដូនតារបស់ យ៉ូសែប ដើម្បីបំពេញតម្រូវការនៃបញ្ជាធ្វើជំរឿនរបស់ស្ដេចដោយ សេសា អូគូស ។ តម្រូវការនៃការធ្វើជំរឿននោះបានអនុញ្ញាតឲ្យពួកគេបង្ហាញខ្លួនពួកគេ នៅភូមិ បេថ្លេហិម នៅពេលណាមួយក៏បាននៅអំឡុងឆ្នាំនោះ ប៉ុន្តែពួកគេប្រហែលជាជ្រើសយករដូវបុណ្យរំលង ដោយសារក្រឹត្យវិន័យរបស់ ម៉ូសេ តម្រូវឲ្យបុរសទាំងអស់បង្ហាញខ្លួន នៅទីក្រុង យេរូសាឡិម នៅបុណ្យរំលង ។[4] ដោយសារភូមិ បេថ្លេហិម នៅក្បែរនឹងទីក្រុង បរិសុទ្ធ ស្វាមីភរិយាមួយគូមកពី ណាសារ៉ែតនេះ អាចធ្វើកាតព្វកិច្ចពីរក្នុងពេលតែមួយ ។

ម្ចាស់ផ្ទះសំណាក់ត្រូវបានគេពិចារណាថា ជាបុគ្គលម្នាក់ដ៏មានប្រជាប្រិយភាពក្នុងប្រវត្តិសាស្ត្រសង្គមវិទ្យា ។ ប៉ុន្តែដោយសារតែមានមនុស្សច្រើនពេក នៅក្នុងតំបន់នោះអំឡុងពេលបុណ្យរំលង យើងពិបាកនឹងបន្ទោសគាត់ណាស់ ចំពោះការគ្មានបន្ទប់ឲ្យស្វាមីភរិយានេះមកពី ណាសារ៉ែត ។ ខណៈដែលមានមនុស្សជាច្រើនបានធ្វើដំណើរមកសម្រាប់បុណ្យរំលងបានបោះជំរំរាប់ពាន់ត្រសាលនៅលើវាលស្មៅនៅជុំវិញ យេរូសាឡិម នោះមានមនុស្សរាប់ពាន់នាក់ផ្សេងទៀតបានស្វែងរកទីជម្រក នៅក្នុងផ្ទះសំណាក់ក្នុងមូលដ្ឋាន ។ ពិតណាស់ ផ្ទះសំណាក់នៅភូមិ បេថ្លេហិម គឺប្រាកដជាពេញអស់ហើយ ហើយការផ្ដល់នូវក្រោលសត្វរបស់ម្ចាស់ផ្ទះសំណាក់នោះពិតជាទង្វើមួយ នៃសេចក្ដីមេត្តាករុណាដ៏លើសលុប ។

ទោះជាស្វាមីភរិយាមួយគូនេះអាចរកបន្ទប់នៅក្នុងផ្ទះសំណាក់បានក្ដីក៏វាអាចផ្ដល់ឲ្យត្រឹមតែបន្ទប់សាមញ្ញមួយប៉ុណ្ណោះ ។ នៅសម័យនោះ ជាធម្មតាផ្ទះសំណាក់គឺធ្វើឡើងពីថ្មដែលមានបន្ទប់តូចៗ ហើយបន្ទប់និមួយៗ

*មានប្រពៃណី ហេព្រើរ ពីបុរាណមួយបានប្រាប់ថា ព្រះមែស៊ីនឹងប្រសូតនៅបុណ្យរំលង ។ យើងដឹងថា ខែ មេសា ក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត ពិតជាស្ថិតនៅក្នុងសប្តាហ៍នៃបុណ្យរំលងមែន ។*



មានជញ្ជាំងតែបីខណ្ឌ ហើយបើកឲ្យមនុស្សដទៃអាចមើលឃើញតាមរយៈខណ្ឌមួយទៀត ។ ប៉ុន្តែ ក្រោលសត្វនោះ គឺមានជញ្ជាំងព័ទ្ធជុំវិញ ឬជារូងថ្មមួយដែលធ្វើពីថ្មកំបោ ជាកន្លែងសម្រាប់ទុកសត្វពាហនៈរបស់ភ្ញៀវ ។[5] មិនថានៅតាមទីធ្លាផ្ទះ ក្នុងរូងថ្ម ឬជម្រកផ្សេងទៀតនោះទេ ការប្រសូតរបស់ព្រះគ្រីស្ទនៅក្នុងចំណោមសត្វពាហនៈបានមានភាពវិសេសវិសាលយ៉ាងពិតប្រាកដមួយ ជាងពួកអ្នកដែលស្នាក់នៅក្នុងផ្ទះសំណាក់គឺ ៖ យ៉ាងហោចណាស់នៅទីនេះមាននូវភាពស្ងប់ស្ងាត់ និង ផ្ទាល់ខ្លួន ។នៅក្នុងទិដ្ឋភាពនេះ ការផ្ដល់ឲ្យនូវក្រោលសត្វនោះគឺជាពរជ័យមួយ ដែលអនុញ្ញាតឲ្យការប្រសូតដ៏ពិសិដ្ឋបំផុតនៅក្នុងប្រវត្តិសាស្ត្រសង្គមវិទ្យាមនុស្សបានកើតមានឡើងក្នុងទីកន្លែងដ៏ស្ងប់ស្ងាត់បំផុត ។

**ឥស្សរភាពដល់ពួកអ្នកជាប់ឃុំឃាំង**

ប្រាំពីររយឆ្នាំមុនបុណ្យគ្រីស្ទម៉ាសដំបូងនោះ ព្យាការី អេសាយ បានសរសេរការព្យាករណ៍មួយពីព្រះមែស៊ី ដែលក្រោយមកព្រះអង្គបានអានទៅកាន់ពួកអ្នកភូមិណាសារ៉ែត ថា ៖ « ព្រះវិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ា ទ្រង់សណ្ឋិតលើខ្ញុំ ពីព្រោះព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំឲ្យមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង នឹងប្រកាសប្រាប់ពីសេចក្ដីប្រោសលោះដល់ពួកអ្នកឈ្លើយ ហើយពីការដោះលែងដល់ពួកអ្នកជាប់ចំណង » ( អេសាយ 61:1, សូមមើលផងដែរ លូកា 4:18–19 ) ។

នៅពេលយើងអានពីបេសកកម្មរបស់ព្រះគ្រីស្ទ ដើម្បីប្រកាសឥស្សរភាពដល់ពួកអ្នកជាប់ឃុំឃាំង ហើយបានដោះលែងដល់អ្នកដែលជាប់ចំណងដំបូងយើងប្រហែលជាគិតពីការបម្រើរបស់ទ្រង់ក្នុងពិភពវិញ្ញាណក្នុងចំណោមពួកអ្នកស្លាប់ ។ *ប៉ុន្តែយើងទាំងអស់គ្នាគឺជាប់ឃុំឃាំង*—ជាប់ឃុំដោយសារភាពពុករលួយ និងភាពទន់ខ្សោយនៃរូបកាយរមែងស្លាប់ ហើយទទួលរងនូវការល្បួងខាងសាច់ឈាម ទទួលរងនូវពិការភាព ហើយសំខាន់បំផុតគឺសេចក្ដីស្លាប់—*ហើយយើងទាំងអស់គ្នាត្រូវការការ មានសេរីភាព* ។

ទោះជាមានអ្វីមកចងយើងក្ដី—អំពើបាប កាលៈទេសៈ ឬព្រឹត្តិការណ៍ពីអតីតកាល—ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ជាអេម៉ាញូអែលដ៏អស្ចារ្យ បានយាងមកដើម្បីរំដោះយើងឲ្យមានសេរីភាព ។ ទ្រង់បានប្រកាសពីឥស្សរភាពដល់ពួកអ្នកជាប់ឃុំឃាំង និងពីសេរីភាពពីចំណងនៃសេចក្ដីស្លាប់ និងគុកនៃអំពើបាបភាពល្ងង់ខ្លៅ អំនួត និងកំហុស ។ វាត្រូវបានព្យាករណ៍ថា ទ្រង់នឹងមានបន្ទូលទៅកាន់ពួកអ្នកជាប់ឃុំឃាំងថា « ចូរចេញទៅ » ( អេសាយ 49:9 ) ។ លក្ខខណ្ឌតែមួយគត់ចំពោះសេរីភាពរបស់យើងគឺថា យើងមករកទ្រង់ដោយដួងចិត្តសង្រេង និងវិញ្ញាណទន់ទាប ប្រែចិត្ត ហើយខិតខំធ្វើតាមព្រះទ័យរបស់ទ្រង់ ។

ប្រហែលជា 30 ឆ្នាំមុន ខ្ញុំបានជួបនឹងបុរសម្នាក់ដែលខ្ញុំនឹងហៅគាត់ថា ថូម៉ាស ។ គាត់មានអាយុ 45 ឆ្នាំ នៅពេលខ្ញុំបានជួបនឹងគាត់ ។ កាលពីម្ភៃឆ្នាំមុន ឪពុកម្ដាយរបស់គាត់បានចូលរួមក្នុងសាសនាចក្រ ។ ថូម៉ាស ពុំមានចំណាប់អារម្មណ៍នឹងសាសនាថ្មីរបស់ឪពុកម្ដាយគាត់ឡើយ ។ ប៉ុន្តែឪពុកម្ដាយគាត់ស្រឡាញ់គាត់ ហើយពួកគេបានសង្ឃឹមទុកថា ថ្ងៃណាមួយកូនប្រុសរបស់ខ្លួនអាចត្រូវបាននាំឲ្យស្គាល់សេចក្ដីពិតនៃដំណឹងល្អដែលបានស្ដារឡើងវិញ ។ លុះជាច្រើនឆ្នាំបានកន្លងផុតទៅ ពួកគេបានព្យាយាមជាច្រើនដង ដើម្បីណែនាំគាត់ យ៉ាងហោចណាស់បានឲ្យគាត់ជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនា ហើយស្ដាប់ សារលិខិតរបស់ពួកគេ ។ គាត់បានបដិសេធម្ដងហើយម្ដងទៀត ហើយគាត់បានចំអកដាក់ឪពុកម្ដាយគាត់ ចំពោះសេចក្ដីជំនឿលើសាសនារបស់ពួកគេ ។

មានថ្ងៃមួយម្ដាយរបស់គាត់និយាយទាំងអស់សង្ឃឹមថា « ថូម៉ាស ប្រសិនបើកូននឹងជួបជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាតែម្ដងទៀត នោះម៉ាក់នឹងឈប់និយាយជាមួយកូនពីរឿងសាសនាចក្រទៀតហើយ » ។ ថូម៉ាស បានគិតថានេះជាការព្រមព្រៀងមួយដ៏ល្អ ហើយក៏សម្រេចចិត្តព្រមជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនា ។ នៅក្នុងការពិភាក្សាបីដំបូង គាត់គ្រាន់តែអង្គុយនៅទីនោះពោរពេញដោយអំនួត ហើយម្ដងម្កាលបាននិយាយចំអកពីអ្វីដែលពួកអែលឌើរកំពុងបង្រៀន ។

នៅក្នុងការពិភាក្សាលើកទីបួន អំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងគោលការណ៍ទីមួយនៃដំណឹងល្អ ថូម៉ាស ពុំបាននិយាយអ្វីទាំងអស់ ប៉ុន្តែបាននៅស្ងៀម ហើយស្ដាប់យ៉ាងយកចិត្តទុកដាក់ ។ នៅចុងបញ្ចប់មេរៀននោះ ពួកអែលឌើរបានថ្លែងទីបន្ទាល់របស់ពួកគេពីព្រះអង្គសង្គ្រោះ ។ បន្ទាប់មក អ្នកផ្សព្វផ្សាយសាសនាម្នាក់បានទទួលអារម្មណ៍បំផុសគំនិត ឲ្យបើកព្រះគម្ពីរប៊ីបរបស់ខ្លួន ហើយអាននូវពាក្យទាំងនេះថា ៖

« អស់អ្នកដែលនឿយព្រួយ និងមានបន្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាបានកន្លែងសម្រាក ។

« ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ត្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្ដីសម្រាកដល់ព្រលឹង » ( ម៉ាថាយ 11:28–29 ) ។

ដោយពុំបានប្រាប់ជាមុន ថូម៉ាស បាន សម្រក់ទឹកភ្នែក ។ តើអ្នកកំពុងព្យាយាមប្រាប់ថា ព្រះគ្រីស្ទអាចអភ័យទោសដល់ខ្ញុំពីអំពើបាប*របស់ខ្ញុំ*បានឬ ? » គាត់បានសួរ ។ « ខ្ញុំបានរស់នៅក្នុងជីវិតមួយដ៏អាក្រក់ ។ ខ្ញុំបានរងទុក្ខដោយការចងចាំពីអំពើបាបរបស់ខ្ញុំ ។ ខ្ញុំនឹងធ្វើអ្វីគ្រប់យ៉ាងដើម្បីបានរួចផុតពីកំហុសដែលខ្ញុំមាន » ។

អំនួតរបស់គាត់បានក្លាយជាអាការៈខាងក្រៅមួយ ដែលបិទបាំងនូវព្រលឹងដែលជាប់ឃុំឃាំងដោយអំពើបាប និងកំហុស ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានអះអាងដល់ ថូម៉ាស ថា ព្រះគ្រីស្ទនឹងអភ័យទោសឲ្យគាត់ ហើយរំដោះគាត់ចេញពីបន្ទុកនៃកំហុស ប្រសិនបើគាត់ប្រែចិត្ត ហើយធ្វើបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ។ បន្ទាប់មកពួកគេបានថ្លែងទីបន្ទាល់ពីអំណាចនៃដង្វាយធួន ។ ចាប់ពីពេលនោះមក អ្វីៗគ្រប់យ៉ាងបានផ្លាស់ប្ដូរនៅក្នុងជីវិតរបស់ ថូម៉ាស ។ គាត់មានរឿងជាច្រើនដែលត្រូវប្រែចិត្ត ហើយយកឈ្នះ ប៉ុន្តែតាមរយៈពរជ័យរបស់ព្រះអម្ចាស់ គាត់បានមានភាពសក្ដិសមសម្រាប់បុណ្យជ្រមុជទឹក ។

ច្រើនជាង 20 ឆ្នាំក្រោយមក នៅពេលខ្ញុំអង្គុយនៅក្នុងរោងថ្វាយបង្គំនៃព្រះវិហារបរិសុទ្ធ ហ្វ្រេងហ្វឺតអាល្លឺម៉ង់ មានបុរសសក់សម្នាក់ដែលនៅពីមុខខ្ញុំបានងាកមករកខ្ញុំ ហើយនិយាយថា « តើលោកជាអែលឌើរ ប្រ៊ូស ឌី ភទើរមែនទេ ? » ដោយមានចិត្តអំណរយ៉ាងខ្លាំង ខ្ញុំបានស្គាល់ថាជា ថូម៉ាស—ជាបុរសម្នាក់បានរួចខ្លួនពីសេវកភាពដោយព្រះចេស្ដានៃព្រះយេស៊ូវគ្រីស្ទហើយនៅតែស្មោះត្រង់នៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ ។





ប្រហែលជានៅរដូវបុណ្យគ្រីស្ទម៉ាសនេះ យើងម្នាក់ៗអាចសម្រេចចិត្តដើម្បីងាកទៅរកព្រះវរបិតា ដែលគង់នៅស្ថានសួគ៌របស់យើង ដោយចិត្តរាបសានៅក្នុងការអធិស្ឋាន និងការទូលសុំព្រះចេស្ដានៃព្រះរាជបុត្រាសំណព្វរបស់ទ្រង់ឲ្យគង់នៅជាមួយនឹងពួកគេក្នុងជីវិតប្រចាំថ្ងៃរបស់យើង ហើយរំដោះយើងចេញពីការជាប់ឃុំឃាំងផ្ទាល់ខ្លួនរបស់យើងគ្រប់ប្រភេទ ទោះតូច ឬធំក្ដី ។

*ប្រហែលជានៅរដូវបុណ្យគ្រីស្ទម៉ាសនេះ យើងម្នាក់ៗអាចសម្រេចចិត្តដើម្បីងាកទៅរកព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ដោយចិត្តរាបសានៅក្នុងការអធិស្ឋាន និងការទូលសុំព្រះចេស្ដានៃព្រះរាជបុត្រាសំណព្វរបស់ទ្រង់ឲ្យគង់នៅជាមួយនឹងពួកគេក្នុងជីវិតប្រចាំថ្ងៃរបស់យើង ហើយរំដោះយើងចេញពីការជាប់ឃុំឃាំងផ្ទាល់ខ្លួនរបស់យើងគ្រប់ប្រភេទ ទោះតូច ឬធំក្ដី ។*

**ឱ យប់ដ៏បរិសុទ្ធ**

នៅខែ ធ្នូ ឆ្នាំ 1987 ប្រហែលជាពីរសប្ដាហ៍ពីមុនបុណ្យគ្រីស្ទម៉ាស ខ្ញុំត្រូវធ្វើដំណើរទៅអ៊ីស្រាអែលសម្រាប់មុខជំនួញរបស់ខ្ញុំ ។ ជាអកុសល វាជាគ្រាមួយដ៏ច្របូកច្របល់នៅក្នុងដែនដីបរិសុទ្ធនោះ ។ មានការធ្វើមួយជាច្រើននៅក្រុងវេសប៊ែង ផ្លូវនៃទីក្រុង យេរូសាឡិម បុរាណទាំងអស់គឺមានភាពទទេស្អាត ហើយហាងទាំងឡាយត្រូវបានបិទទ្វារ ។ ភាពតានតឹងខាងនយោបាយបានលាន់ខ្ទរពេញផ្ទៃអាកាស ហើយការធ្វើឲ្យបញ្ហាទាំងឡាយកាន់តែដុនដាបទៅទៀត គឺមានភ្លៀងធ្លាក់ស្ទើរតែពេញមួយសប្ដាហ៍នោះ ។ ដោយភ័យខ្លាចនូវអំពើហិង្សា ពួកទេសចរណ៍បានដកខ្លួនឆ្ងាយពីតំបន់នោះ ។ ប៉ុន្តែនៅពេលខ្ញុំបានដើរកាត់ទីក្រុង យេរូសាឡិម សេចក្ដីសុខសាន្តបានមានពេញដួងចិត្តរបស់ខ្ញុំ ដោយដឹងថា នេះជាទីក្រុងដែលព្រះប្រោសលោះបានស្រឡាញ់ខ្លាំងបំផុត ។

ខ្ញុំបានត្រលប់មក សហរដ្ឋ វិញនៅយប់ថ្ងៃសុក្រពីមុនបុណ្យគ្រីស្ទម៉ាស ។ ពីរថ្ងៃក្រោយមកនៅថ្ងៃឈប់សម្រាកនាទ្បិការបស់ខ្ញុំបានពោទ៍ឡើងដាស់ខ្ញុំជាមួយនឹងបទ « ឱ យប់ដ៏បរិសុទ្ធ » ៖

*ស្ដេចនៃអស់ទាំងស្ដេចបានផ្ទំនៅក្នុងស្នូក*
*នៅរាល់ការសាកល្បងរបស់យើង ទ្រង់ប្រសូតមកធ្វើជាមិត្តរបស់*
*យើង ។*[6]

តន្ត្រី និងសារលិខិត បានចាក់ទម្លុះយ៉ាងជ្រៅទៅក្នុងដួងចិត្តខ្ញុំ ហើយទឹកភ្នែកបានហូរចុះមក នៅពេលខ្ញុំបានសញ្ជឹងគិតពី ពលិកម្មដ៏រុងរឿង និងជីវិតដ៏ល្អឥតខ្ចោះនៃព្រះប្រោសលោះនៃអ៊ីស្រាអែល—ទ្រង់បានប្រសូតមកដើម្បីធ្វើជាមិត្តនៃជនទន់ទាប និងមនុស្សទន់ខ្សោយ ។ ខ្ញុំបានគិតពីបទពិសោធន៍របស់ខ្ញុំនៅក្នុង យេរូសាឡិម និងសេចក្ដីស្រឡាញ់ជ្រៀតចូលពេញក្នុងចិត្តរបស់ខ្ញុំចំពោះទ្រង់ដែលបានយាងមកកាន់ផែនដី ហើយបានលើកដាក់មកលើខ្លួនទ្រង់នូវបន្ទុករបស់យើងទាំងអស់គ្នា ។ ខ្ញុំបានរំភើបចិត្តយ៉ាងខ្លាំងដែល ទ្រង់អាចចាត់ទុកខ្ញុំជាមិត្តម្នាក់ ។ ខ្ញុំពុំដែលភ្លេចនូវអារម្មណ៍ដ៏ទន់ភ្លន់នៃព្រឹកព្រលឹមនាថ្ងៃអាទិត្យនោះឡើយ ដែលវាជាសាក្សីមួយយ៉ាងច្បាស់ដែលខ្ញុំធ្លាប់បានទទួលពីមុនមក ។

ខ្ញុំសូមថ្លែងជាសាក្សីពីព្រះអង្គសង្គ្រោះនៃពិភពលោក ។ ខ្ញុំដឹងថា ទ្រង់មានព្រះជន្មរស់ ។ ខ្ញុំដឹងថា ទ្រង់ត្រូវបានតែងតាំងទុកពីមុនការបង្កបង្កើតផែនដីមកម្ល៉េះ ដើម្បីប្រកាសពីឥស្សរភាពដល់ពួកអ្នកជាប់ឃុំឃាំង ។ ខ្ញុំសូមថ្លែងពីការប្រសូត និងឆាកជីវិតរបស់ទ្រង់ថា « ចូរយើងនាំគ្នាចូលមកថ្វាយបង្គំទ្រង់ » ។[7] ■

*ដកស្រង់ចេញពីសុន្ទរកថាក្នុងការប្រជុំពិសេសមួយ « A Child Is Born » ដែលបានធ្វើឡើងនៅថ្ងៃទី 9 ខែ ធ្នូ ឆ្នាំ 2008 នៅសកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ។ សម្រាប់អត្ថបទទាំងស្រុងជាភាសាអង់គ្លេស សូមចូលទៅកាន់ speeches.byu.edu ។*

**កំណត់ចំណាំ**

1. *The Messiah* និពន្ធដោយ ជី ធីធ័ស ណូប៊ល ( ឆ្នាំ 1912 ) ទំព័រ ។
2. សូមមើល សេចក្ដីណែនាំដល់បទគម្ពីរ « បេថ្លេហិម » scriptures.lds.org ។
3. « ឱព្រះ ជាព្រះវរបិតា » *ទំនុកតម្កើងព្រះ* ទំព័រ 18 ។
4. សូមមើល Bible Dictionary « Feasts » ។
5. សូមមើល រ័សុល អិម ណិលសុន « សេចក្ដីសុខសាន្ត និងសេចក្ដីអំណរពីការដឹងថា ព្រះអង្គសង្គ្រោះមានព្រះជន្មរស់ » *លីអាហូណា* ខែ ធ្នូ ឆ្នាំ 2011 ទំព័រ 19 ។
6. « Cantique de Noël » ( « ឱយប់ដ៏បរិសុទ្ធ » ) *Recreational Songs* ( ឆ្នាំ 1949 ) ទំព័រ 143 ។
7. « Oh, Come, All Ye Faithful » *Hymns* លរ. 202 ។

*LIGHT AND TRUTH* ដោយ ស៊ីម៉ុន ឌូវី, *THE HEALING BALM,* ដោយ ជេហ្វ វ៉ាដ

# សារៈសំខាន់នៃ ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់

*ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់បានធ្វើឲ្យកំណត់ត្រាជាច្រើន ត្រូវបានដាក់ឲ្យប្រើនៅលើអ៊ីនធឺណិត ដើម្បីឲ្យសមាជិកអាចស្វែងរក ហើយយកឈ្មោះគ្រួសារទៅកាន់ព្រះវិហារបរិសុទ្ធ ។*

**ដោយ ចិននីហ្វឺរ គ្រែស យ៉ូនស៍**
ទស្សនាវដ្ដីសាសនាចក្រ

ក្រដាសកំណត់ចំណាំខ្លីមួយនៅលើក្ដារចុចបានសរសេរថា « កុំព្យូទ័រនេះត្រូវបានរក្សាទុកសម្រាប់សាំយ៉ូអែល នៅម៉ោង 5:00 ព្រឹក » ។ ជាការឆ្លើយតបទៅនឹងសំណូមពររបស់ប្រធានស្តេកគាត់ សុំឲ្យស្តេកធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ឲ្យបានឈ្មោះមួយលាន នោះ សាំយ៉ូអែល ប៊ី អាយុ 14 ឆ្នាំ នៅរដ្ឋ យូថាហ៍ បានចាប់ផ្ដើមក្រោកពីដំណេកនៅម៉ោង 5:00 ព្រឹក ដើម្បីគាត់អាចធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ពីមុនគាត់ទៅសាលារៀន ។ ដោយមានកុំព្យូទ័រតែមួយនៅក្នុងផ្ទះ ហើយមានបងប្អូនដល់ទៅប្រាំមួយនាក់ត្រូវការធ្វើកិច្ចការសាលា នោះ សាំយ៉ូអែល ត្រូវលះបង់ពេលដេកមួយចំនួនដើម្បីមានពេលប្រើកុំព្យូទ័រនោះ ។

ប៉ុន្ដែភាពរីករាយរបស់ សាំយ៉ូអែល បានរាលដាលទៅដល់គ្រួសារទាំងមូល ។ មិនយូរប៉ុន្មាន បងប្រុសរបស់គាត់ ណាថាន់ បានលះបង់ពេលវេលាលេងបាល់បោះ ហើយប្អូនស្រីរបស់គាត់ អ៊ីវឡីន បានលះបង់ពេលអានសៀវភៅដើម្បីមកធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ ។ ឪពុករបស់ សាំយ៉ូអែល បាននិយាយថា « កូនៗរបស់ខ្ញុំពុំធ្លាប់ដែលលើកទឹកចិត្តយ៉ាងខ្លាំងចំពោះខ្ញុំ បែបនេះ ពីមុន ឡើយ » ។ « ខ្ញុំបានគិតថាការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ជារឿងដ៏លំបាក រហូតដល់ពួកគេបានធ្វើកិច្ចការនេះ ។ ពួកគេបានបង្រៀនខ្ញុំថា វាជារឿងងាយស្រួល ហើយសប្បាយ » ។ លុះដល់យប់ឆ្នាំថ្មីចូលមកដល់ ក្មេងទាំងនោះបានរួសរាន់បញ្ចប់គោលដៅ ធ្វើលិបិក្រមអ្នកស្លាប់ប្រចាំឆ្នាំរបស់ខ្លួនឲ្យបានពីមុនពាក់កណ្ដាលអាធ្រាត្រ ។

នៅចម្ងាយរាប់ពាន់គីឡូម៉ែត្រ គ្រួសារ ឡានូហ្សា នៅប្រទេស ហ្គាតេម៉ាឡា បានមានភាពរីករាយដូចគ្នានេះផងដែរ ។ គ្រួសារដែលមានគ្នាប្រាំបួននាក់នេះ—កូនប្រាំនាក់ ម្ដាយ ឪពុក ជីដូន និងជីតា—បានប្រើកុំព្យូទ័រមួយរួមគ្នា ។ ដោយកូនៗប្រើកុំព្យូទ័រធ្វើកិច្ចការសាលា ម្ដាយបញ្ចប់ថ្នាក់របស់ខ្លួននៅឯសកលវិទ្យាល័យ ហើយឪពុកទៅធ្វើការ នោះកុំព្យូទ័រតែងតែជាតម្រូវការដ៏ខ្ពស់បំផុត ហើយសមាជិកគ្រួសារម្នាក់ៗបានប្ដូរវេនគ្នាធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ ។ គ្រួសារនេះបានធ្វើលិបិក្រមឈ្មោះអ្នកស្លាប់រួមគ្នា ដែលមានចំនួនលើសពី 37,000 កំណត់ត្រា ក្នុងឆ្នាំ 2011 ។

ក្មេងទាំងនេះ និងក្រុមគ្រួសាររបស់ពួកគេបានទទួលយកសំណូមពរដែល អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានស្នើសុំដល់យុវវ័យ ក្នុងសាសនាចក្រកាលពីខែ តុលា ឆ្នាំ 2011 ៖

« មានអ្នករាល់គ្នាជាច្រើនប្រហែលជាគិតថា កិច្ចការពង្សប្រវត្តិគឺត្រូវតែធ្វើឡើងដោយពួកមនុស្សវ័យចំណាស់ ។ ប៉ុន្ដែ ខ្ញុំដឹងថាគ្មានការកំណត់អាយុណាមួយបានរៀបរាប់នៅក្នុងព្រះគម្ពីរ ឬសេចក្ដីណែនាំណាមួយដែលបានប្រកាសដោយពួកអ្នកដឹកនាំសាសនាចក្របានដាក់កំហិតនូវការបម្រើដល់សំខាន់នេះទៅលើមនុស្សវ័យចំណាស់ឡើយ ។ . . .

« ខ្ញុំសូមអញ្ជើញយុវវ័យនៃសាសនាចក្រ ដើម្បីរៀន ហើយទទួលបទពិសោធន៍នៃវិញ្ញាណរបស់អេលីយ៉ា » ។[1]

## ពង្សប្រវត្តិដែលស្រួល ហើយរហ័ស

ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់គឺជាវិធីងាយមួយសម្រាប់មនុស្សគ្រប់គ្នាដើម្បីចាប់ផ្ដើមជាមួយនឹងពង្សប្រវត្តិ ហើយទទួលបទពិសោធន៍ពីវិញ្ញាណនៃអេលីយ៉ា ។ រដ្ឋាភិបាល និងព្រះវិហារបានរក្សាទុកកំណត់ត្រារបស់ប្រជាជន និងក្រុមគ្រួសារជាច្រើនទសវត្សរ៍ ប៉ុន្ដែកំណត់ត្រាទាំងនេះមានការលំបាកដើម្បីយកមកប្រើប្រាស់ ហើយចំណាយពេលវេលាដើម្បីស្វែងរក ។ កាលពីមុន មនុស្សដែលបានបែកចេញពីដែនដីដូនតារបស់ខ្លួន ត្រូវធ្វើដំណើរទៅកាន់ទីកន្លែងទាំងនោះ ហើយស្វែងរកកំណត់ត្រា ដោយគ្មានការធានាអះអាងថាពួកគេនឹងរកឃើញឈ្មោះគ្រួសារឡើយ ។

ការណែនាំឲ្យស្គាល់ពីការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ក្នុង FamilySearch នៅឆ្នាំ 2006 បានពន្លឿនដល់ការស្រាវជ្រាវពង្សប្រវត្តិ ។ នៅពេល ឈ្មោះជាច្រើនត្រូវបានលាក់ទុក នៅក្នុងក្រដាសកំណត់ត្រាដែលសរសេរដោយដៃ ហើយបានទុកនៅក្នុងឃ្លាំងដ៏ត្រជាក់បានកត់ត្រា ( ធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ ) ហើយឥឡូវនេះអាចស្វែងរកបានដោយផ្ទាល់នៅលើកុំព្យូទ័រ ។ ការសម្រេចកិច្ចការនេះបាន ពួកអ្នកធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ស្ម័គ្រចិត្តទាញយក « បាច់ » នៃ

កំណត់ត្រាដែលមានប្រមាណជា 10 ទៅ 50 ឈ្មោះពីកុំព្យូទ័រនៅផ្ទះរបស់ពួកគេ ។ ពួកគេបានវាយឈ្មោះ កាលបរិច្ឆេទ និងព័ត៌មានផ្សេងទៀតចូលទៅក្នុងមូលដ្ឋានទិន្នន័យរបស់ FamilySearch ការធ្វើដូច្នេះ អាចផ្ដល់លទ្ធភាពនៃការបង្កើតលិបិក្រមឈ្មោះអ្នកស្លាប់ជាអេឡិចត្រូនិកដែលអាចស្វែងរកបាន ។

ពីមុនដាក់ឲ្យប្រើកម្មវិធីលិបិក្រមឈ្មោះអ្នកស្លាប់ក្នុង FamilySearch វាអាចចំណាយពេលរាប់ឆ្នាំដើម្បីបង្កើតលិបិក្រមឈ្មោះអ្នកស្លាប់មួយដែលអាចស្វែងរកបាន សូម្បីតែសំណុំកំណត់ត្រាមួយ ដោយប្រើបច្ចេកទេសពីមុននៃការដកស្រង់ឈ្មោះ ។ ម៉ែខល ជូដសិន ជានាយកផ្នែកលិបិក្រមឈ្មោះអ្នកស្លាប់សម្រាប់កម្មវិធី FamilySearch បានមានប្រសាសន៍ថា វាត្រូវចំណាយពេលអស់ 11 ឆ្នាំ ដើម្បីធ្វើលិបិក្រមឈ្មោះអ្នកស្លាប់សម្រាប់ Freedman Bank Records ( កំណត់ត្រារបស់ សហរដ្ឋ ពីទាសករដែលមានសេរីភាព ដែលបានបង្កើតគណនីធនាគារ ) ។ ឥឡូវនេះ គាត់ប៉ាន់ប្រមាណ វាត្រូវចំណាយពេលតែមួយខែប៉ុណ្ណោះ ។

ពួកអ្នកស្ម័គ្រចិត្តទូទាំងពិភពលោកបានធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ច្រើនជាងមួយពាន់លានកំណត់ត្រាចាប់តាំងពីឆ្នាំ 2006 ប៉ុន្តែមានការងារជាច្រើនទៀតដែលត្រូវធ្វើ ។ មានកំណត់ត្រារាប់ពាន់លានបន្ថែមទៀត ដែលកំពុងរង់ចាំនៅក្នុងទូរដែករក្សាកំណត់ត្រា ក្នុងទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ។ ហើយលើសពីនោះទៀត គឺមានកំណត់ត្រាដែលបានរកឃើញ នៅក្នុងបណ្ណាសារផ្សេងទៀតទូទាំងសកលលោក ដែលនាយកដ្ឋានពង្សប្រវត្តិកំពុងធ្វើការថតរូបភាពប្រមាណជា 35 លាន រូបភាពក្នុងមួយខែ ។

## ស្ថានភាពជាក់លាក់ ពរជ័យជាក់លាក់

គណៈប្រធានទីមួយបានថ្លែងថា « សមាជិកទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យចូលរួម នៅក្នុងការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ក្នុង FamilySearch ដែលវាមានសារៈសំខាន់ចំពោះកិច្ចការពង្សប្រវត្តិ និងព្រះវិហារបរិសុទ្ធ » ។[2] សមាជិក



រូបថតដោយ ឡេស្លី នីលសិន © IRI

មកពីជុំវិញពិភពលោកកំពុងឆ្លើយតបចំពោះការទូន្មាននេះ ហើយកំពុងទទួលបានពរជ័យយ៉ាងអស្ចារ្យ ។

ពួកបរិសុទ្ធនៅក្នុងប្រទេស អ៊ុយក្រែន កំពុងខិតខំ ដើម្បីបង្កើតលិបិក្រមឈ្មោះអ្នកស្លាប់ជាអេឡិចត្រូនិក ដែលនឹងជួយជម្រុញដល់ការស្រាវជ្រាវពង្សប្រវត្តិនៅក្នុងទ្វីបអឺរ៉ុបភាគខាងកើត ។ គ្រួសារ រូដិនកូ នៅ ខីអីវ កំពុងធ្វើជាគំរូមួយយ៉ាងអស្ចារ្យ ។ ពួកគេបានចំណាយលើថ្លៃអ៊ីនធឺណិត ដើម្បីពួកគេ និងកូនរបស់ពួកគេអាចធ្វើលិបិក្រមសម្រាប់ឈ្មោះអ្នកស្លាប់ ទាំងឡាយ ។ បងស្រី រូដិនកូ បានទុកកុំព្យូទ័រយួរដៃរបស់គ្រួសារនៅលើតុផ្ទះបាយ ដើម្បីគាត់អាចធ្វើ លិបិក្រមឈ្មោះអ្នកស្លាប់ នៅពេលគាត់មានពេលអំឡុងថ្ងៃនោះ ។ គាត់បានប្រើដៃម្ខាងវាយឈ្មោះ ខណៈដែលប្រើដៃម្ខាងទៀតបីកូន ។ កូនប្រុសអាយុ 16 ឆ្នាំ និងកូនស្រីអាយុ 12 ឆ្នាំរបស់ពួកគេក៏បានក្លាយជាអ្នកធ្វើលិបិក្រមសម្រាប់អ្នកស្លាប់ផងដែរ ហើយពេលខ្លះគ្រួសារនេះបានចូលទៅបណ្ណាសាររបស់រដ្ឋាភិបាលដើម្បីស្រាវជ្រាវឈ្មោះគ្រួសារទៀតផង ។ ជាធម្មតា គ្រួសារ រូដិនកូ បានផ្ញើឈ្មោះទៅកាន់ព្រះវិហារបរិសុទ្ធ ហើយធ្វើពិធីបរិសុទ្ធឲ្យឈ្មោះទាំងនោះ ពេលខ្លះបានទៅព្រះវិហារបរិសុទ្ធជាច្រើនដងក្នុងមួយសប្ដាហ៍ ។

បងស្រី រូដិនកូ បាននិយាយពីពរជ័យដែលគាត់បានទទួលតាមរយៈកិច្ចការពង្សប្រវត្តិថា ៖ « ខ្ញុំជឿថា ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ និងកិច្ចការពង្សប្រវត្តិការពារដល់យើង ។ ខ្ញុំត្រូវបានសន្យានៅក្នុងពរជ័យអយ្យកោរបស់ខ្ញុំថា ការធ្វើនូវកិច្ចការនេះនឹងការពារដល់ខ្ញុំ និងកូនចៅខ្ញុំ ។ គំនិតរបស់ពួកគេនឹងបានស្អាតស្អំ ហើយពួកគេនឹងមានលទ្ធភាពដើម្បីទប់ទល់នឹងឥទ្ធិពលអាក្រក់នៃពិភពលោកនេះ ។ . . . [ កូនរបស់ខ្ញុំ ] បានទទួលនូវព្រះចេស្ដានៃព្រះតាមរយៈកិច្ចការនេះ » ។

មានសមាជិកជាច្រើនកំពុងរកឃើញថា ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់បានផ្ដល់ឱកាសបម្រើមួយដ៏មានន័យ ដោយមិនគិតពីជំនាញ ឬស្ថានភាពនោះឡើយ ។ ម៉ាលីនដា កែរី មកពីរដ្ឋ យូថាហ៍ ស.រ.អា. បានជួបនឹងគ្រោះថ្នាក់រថយន្តនៅពេលគាត់មានអាយុ 24 ឆ្នាំ ដែលធ្វើឲ្យកំរើកខ្លួនមិនរួចចាប់ពី-កចុះក្រោម ។ នៅពេលគាត់បានសម្របសម្រួលទៅនឹងជីវិតថ្មីនេះ បងស្រី កែរី បានអធិស្ឋានស្វែងរកវិធីដែលគាត់អាចបម្រើ ។ គាត់បានទទួលចម្លើយរបស់គាត់នៅពេល រលីន អែនឌឺសិន មកពីគណៈប្រធានសមាគមសង្គ្រោះស្ដេកបានមកសួរសុខទុក្ខគាត់ ហើយបានបង្រៀនគាត់ពីរបៀបធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ ។ ឥឡូវនេះ បងស្រី កែរ បានចំណាយពេលនៅមុខកុំព្យូទ័ររាល់ថ្ងៃដោយមានឈើមួយបិទជាប់នឹងដៃរបស់គាត់ ហើយរំកិលវាល្មមនឹងអាចវាយអក្សរបាន ។ គាត់បានធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ឈ្មោះអ្នកស្លាប់មួយចំនួនរៀងរាល់ថ្ងៃ ។

បងស្រី កែរី និយាយថា « ជាជាងផ្ដោតអារម្មណ៍ពីខ្លួនខ្ញុំ ដូចដែលខ្ញុំធ្លាប់បានធ្វើ នោះការផ្ដោតអារម្មណ៍របស់ខ្ញុំបានផ្លាស់ប្ដូរទៅរកការបម្រើអ្នកដទៃ » ។ « ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ហើយខ្ញុំចូលចិត្តនឹងផ្ដល់ពរជ័យរបស់ទ្រង់ទៅដល់អ្នកដទៃទៀតតាមរយៈការធ្វើ លិបិក្រមឈ្មោះអ្នកស្លាប់ » ។

ខណៈដែលកំពុងស្ដាប់បទបង្ហាញមួយពីពង្សប្រវត្តិ ប្រធានស្ដេក ដេវីឌ ភីកាប់ នៅ ឆ័រលី ប្រទេសអង់គ្លេស បានទទួលអារម្មណ៍បំផុសគំនិតមួយថា ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ អាចជួយសមាជិកនៅក្នុងស្ដេករបស់លោក ឲ្យបង្កើតបំណងប្រាថ្នារបស់ពួកគេ ដើម្បីថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ ។ ប៉ុន្តែលោកបានឆ្ងល់ថា តើអ្វីមួយដែលមើលទៅដូចជាការវាយបញ្ចូលទិន្នន័យទូទៅនឹងអាចដឹកនាំមនុស្សទៅរកព្រះវិហារបរិសុទ្ធបានដោយរបៀបណា ?

លោកបានសម្រេចចិត្តសាកល្បងធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ ហើយបានរកឃើញថា វាបាននាំនូវវិញ្ញាណរបស់ អេលីយ៉ា បន្ថែមទៀតមកក្នុងជីវិតរបស់



លោក ។ចំពោះលោក ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ បានក្លាយទៅជាកិច្ចការ « បន្ទុទ្ធ » មួយ ។ លោកបានមានប្រសាសន៍ថា « អ្នកមិនអាចធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ ដោយគ្មានការគិតពីឈ្មោះដែលអ្នកធ្វើលិបិក្រមឈ្មោះអ្នកស្លាប់តែម្យ៉ាងនោះទេ ប៉ុន្តែអ្នកក៏គិតពីឈ្មោះរបស់គ្រួសារអ្នកផងដែរ » ។

ប្រធាន ភីកាប់ បានសំណូមពរដល់សមាជិកនៅក្នុងស្តេករបស់លោកឲ្យប្រើការធ្វើលិបិក្រមអ្នកស្លាប់ ជាវិធីមួយដើម្បីចូលរួមចំណែកនៅក្នុងកិច្ចការពង្សប្រវត្តិ ។ ក្នុងរយៈពេលមួយដ៏ខ្លីប៉ុណ្ណោះ លោក និងពួកអ្នកដឹកនាំស្តេកផ្សេងទៀតបានសង្កេតឃើញការកើនឡើងមួយ យ៉ាងធំនៅក្នុងភាពសក្តិសមសម្រាប់ប័ណ្ណចូលព្រះវិហារបរិសុទ្ធ និងការចូលរួមសាក្រាម៉ង់ ។ ពួកគេបានសង្កេតឃើញថា សមាជិកដែលបានចូលរួមនៅក្នុងការធ្វើលិបិក្រមសម្រាប់អ្នកស្លាប់ កំពុងអភិវឌ្ឍនូវបំណងប្រាថ្នាមួយ ដើម្បីនាំយកឈ្មោះរបស់ក្រុមគ្រួសាររបស់ពួកគេទៅព្រះវិហារបរិសុទ្ធ ។

ម៉ាខិនស៊្សី អេជ អាយុដប់ប្រាំពីរឆ្នាំ បានធ្វើតាមសំណូមពររបស់ប្រធាន ភីកាប់ ដោយអស់ពីចិត្ត ហើយបានចាប់ផ្តើមធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ ហើយនាងបានជួយដល់បងប្អូន ឪពុកម្តាយ និងលោកតាលោកយាយរបស់នាងចូលរួមចំណែកផងដែរ ។ តិចជាងពីរឆ្នាំ ម៉ាខិនស៊្សី ធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ បានលើសពី 44,000 ឈ្មោះ ។ សំខាន់ជាងនេះទៀត ម៉ាខិនស៊្សី និងគ្រួសារនាងបានទទួលអារម្មណ៍បំផុសគំនិតឲ្យស្វែងរកឈ្មោះរបស់គ្រួសារពួកគេ យកឈ្មោះទាំងនោះទៅព្រះវិហារបរិសុទ្ធ ហើយចូលរួមនៅក្នុងពិធីបរិសុទ្ធនៃការសង្គ្រោះ ។

ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ បានជួយសមាជិកក្នុងស្តេក ឆ័រលីដោយបាននូវព្រះវិញ្ញាណចូលមកក្នុងជីវិតរបស់ពួកគេ និងដោយការផ្តល់ដល់ពួកគេនូវឧបករណ៍ដែលពួកគេត្រូវការ ដើម្បីយកឈ្មោះគ្រួសាររបស់ពួកគេទៅព្រះវិហារបរិសុទ្ធ ។ ប្រធាន ភីកាប់ បានមានប្រសាសន៍ថា « អ្នកពុំចាំបាច់ត្រូវមានភាពសក្តិសមចូលព្រះវិហារបរិសុទ្ធទើបធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ បាននោះទេ ប៉ុន្តែនៅពេលអ្នកធ្វើលិបិក្រមសម្រាប់អ្នកស្លាប់ វានឹងបន្ទុទ្ធអ្នក ហើយអ្នកនឹងចង់មានភាពសក្តិសមដើម្បីទៅព្រះវិហារបរិសុទ្ធ ហើយអ្នកនឹងចង់ទៅព្រះវិហារបរិសុទ្ធ ហើយអ្នកនឹងចង់ធ្វើកិច្ចការសម្រាប់បុព្វការីជនរបស់អ្នក ។ . . . ខ្ញុំដឹងពីកិច្ចការនេះ ដោយសារវាបានកើតឡើងចំពោះខ្ញុំ » ។

## ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ បានជួយដល់មនុស្សគ្រប់គ្នា

ព្រះអម្ចាស់បានសន្យាថា « មើលចុះ យើងនឹងពន្លឿនកិច្ចការរបស់យើងឲ្យឆាប់កើតនៅពេលកំណត់ » ( គ. និង ស. 88:73 ) ។ ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់គឺជារបៀបមួយដែលព្រះអម្ចាស់កំពុងបំពេញការសន្យានោះ ។ មនុស្សទាំងអស់អាចស្វែងរកបុព្វការីជនរបស់ពួកគេ ហើយទុកឲ្យអ្នកដទៃអាចស្វែងរកបុព្វការីជនរបស់ពួកគេ ប៉ុន្តែធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ជួយសម្រួល ហើយជួយដល់ការស្រាវជ្រាវរកពង្សប្រវត្តិរបស់មនុស្សគ្រប់រូប ។ បងប្រុស ជូដសិន បាននិយាយថា « ព្រះអម្ចាស់បានប្រទានបច្ចេកវិទ្យាដល់យើងសម្រាប់ធ្វើឲ្យមានភាពប្រសើរឡើងដ៏ធំនៅក្នុងការស្វែងរកឈ្មោះ » ។ « ឥឡូវនេះ អ្នកពុំមែនគ្រាន់តែអាចធ្វើពង្សប្រវត្តិសម្រាប់គ្រួសារប៉ុណ្ណោះទេ ការធ្វើលិបិក្រមអ្នកស្លាប់គឺការប្រមូលនូវកិច្ចខិតខំមួយដើម្បីជួយរាល់កូនចៅទាំងអស់របស់ព្រះវរបិតាសួគ៌ » ។ ■

### លើសពីការវាយបញ្ចូលទិន្នន័យ

ដំបូង ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ប្រហែលជាស្រដៀងនឹងការវាយបញ្ចូលទិន្នន័យធម្មតាប៉ុន្តែជាច្រើន។ពួកអ្នកធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ ដែលធ្លាប់បានទទួលបទពិសោធន៍បានថ្លែងទីបន្ទាល់ថា ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់គឺជាការស្វែងរកខាងវិញ្ញាណមួយ ដែលប្រទានពរដល់ជីវិតទាំងផ្នែកសង្ខាងនៃវាំងនន ។

ខាងក្រោមនេះជាយោបល់មួយចំនួនដែលនឹងជួយដល់ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ឲ្យក្លាយទៅជាបទពិសោធន៍ខាងវិញ្ញាណមួយ ៖

1. ចាប់ផ្តើមដោយការអធិស្ឋាន ។ អ្នកអាចអធិស្ឋានដ៏ជាក់លាក់ដើម្បីទទួលបទពិសោធន៍នូវវិញ្ញាណនៃ អេលីយ៉ា ដើម្បីឲ្យដួងចិត្តរបស់អ្នកនឹងបង្វែរទៅរកបុព្វការីជនរបស់អ្នក ។
2. លុបបំបាត់ការរំខាន រួមទាំងទូរទស្សន៍ ឬតន្ត្រីដែលនាំឲ្យឃ្លាតឆ្ងាយពីព្រះវិញ្ញាណ ។
3. ធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ជាមួយនឹងគ្រួសារ ឬមិត្តភក្តិ ។ ការធ្វើបែបនេះពុំមែនគ្រាន់តែផ្តល់ជំនួយដល់អ្នកឲ្យអាននូវអក្សរដៃដ៏ពិបាកមើលប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប្រហែលជានឹងបើកទ្វារសម្រាប់អ្នកដើម្បីពិភាក្សាពីពង្សប្រវត្តិរបស់គ្រួសារអ្នក ។
4. សូមចងចាំថា គ្រប់ឈ្មោះដែលអ្នកធ្វើលិបិក្រមឈ្មោះអ្នកស្លាប់តំណាងឲ្យបុគ្គលម្នាក់ទៀត ដែលអាចរកឃើញដោយសាច់ញាតិដែលនៅរស់ ហើយទទួលពិធីបរិសុទ្ធដោយការធ្វើជំនួសនៅក្នុងព្រះវិហារបរិសុទ្ធ ។
5. សូមចងចាំថា ព្រះអម្ចាស់នឹងជួយដល់អ្នក ។ តាមរយៈព្រះអង្គសង្គ្រោះអ្នកអាចយកឈ្នះលើឧបសគ្គទាំងឡាយដែលអ្នកអាចជួបនៅក្នុងការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់ ( សូមមើល កូរិនថូសទី 2 12:9–10 ) ។

ការធ្វើលិបិក្រមឈ្មោះអ្នកស្លាប់មានជាភាសា ហូឡង់ អង់គ្លេស បារាំង អាល្លឺម៉ង់ អ៊ីតាលី ជប៉ុន ប៉ូឡូញ ព័រទុយហ្គាល់ រុស្ស៊ី អេស្ប៉ាញ និង ស៊ុយអែត ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់**familysearch.org/indexing** ។

**កំណត់ចំណាំ**

1. ដេវីឌ អេ បែដណា « The Hearts of the Children Shall Turn » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 26 ។
2. សារលិខិតគណៈប្រធានទីមួយចុះថ្ងៃទី 29 ខែ កុម្ភៈ ឆ្នាំ 2012 ។



នៅឯរោងឧបោសថនៃវិសាលដ្ឋានព្រះវិហារបរិសុទ្ធក្នុងទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ លោកបណ្ឌិត ដេវីឌ អ័រ ផាកកឺ ជានាយករងនៃមជ្ឈមណ្ឌលជាតិ យូនីស ខេនណេឌ ស្រីវើរ សម្រាប់សមាគមន៍នៃការថែទាំ បានធ្វើសញ្ញាណជាភាសា-គ ថា « ចូរឲ្យមានសេចក្ដីសុខសាន្តលើផែនដី » ខណៈដែលអ្នកចូលរួមកំពុងច្រៀង ។ ដោយបានប្រារព្ធឡើងនៅខែ កុម្ភៈ ឆ្នាំ 2012 ព្រឹត្តិការណ៍នេះស្ថិតនៅក្រោមគណៈកម្មាធិការនៃការប្រជុំអន្តរនិកាយនៅទីក្រុង សលត៍ លេក ។

## ការក្លាយខ្លួនជាពួកបរិសុទ្ធដ៏ប្រពៃតាមរយៈ

# កម្មវិធីរួបរួមគ្នាខាងសាសនា

*នៅពេលយើងបម្រើជាមួយនឹងអ្នកដែលមានជំនឿផ្សេងៗ យើងមិនគ្រាន់តែស្ថាបនាដល់សហគមន៍របស់យើង ហើយធ្វើឲ្យទំនាក់ទំនាក់របស់យើងបានប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ក្លាយជាសិស្សដ៏ប្រពៃផងដែរ ។*

**ដោយ ឈើតសី វ៉ាន់ឌេនប៊ឺហ្គហេ**

ជាញឹកញាប់ ពួកអ្នកដឹកនាំសាសនាចក្របានអំពាវនាវឲ្យសមាជិកទាំងឡាយ ចូលរួមចំណែកដោយស្មោះអស់ពីដួងចិត្ត—ដោយមិនគិតពីសាសនា—នៅក្នុងការបម្រើ និងនៅក្នុងបុព្វហេតុនៃបញ្ហាសីលធម៌ ។ ហើយជារឿយៗ ពួកអ្នកដឹកនាំសាសនាចក្របានធ្វើជាគំរូ ។ ថ្មីៗនេះ ប្រធានឌៀថើរ អេហ្វ អុជដូហ្វ អមដំណើរដោយភរិយារបស់លោកគឺ ហារីត បានទទួលរង្វាន់ប្រចាំឆ្នាំផ្នែកមនុស្សធម៌ពីសមាគម កាតូលីក លោកបានមានប្រសាសន៍ថា វាគឺជាស្ថានភាពដែលគួរឲ្យហួសចិត្តមួយដែល « ជនជាតិអាល្លឺម៉ង់ ពីរនាក់ ជាអតីតសាសនា លូធើររិន ឥឡូវជាពួក មរមន ដ៏ស្មោះត្រង់ ត្រូវបានផ្ដល់កិត្តិយសដោយពួកកាតូលិក នៅក្នុងសហរដ្ឋអាមេរិក » ។[1]

សមាជិកនៅជុំវិញពិភពលោកបានឆ្លើយតប ដោយការលើកតម្កើងចំពោះការអំពាវនាវ ដើម្បីបម្រើប្រកៀកស្មាគ្នាជាមួយនឹងសមាជិកនៃអង្គការផ្សេងទៀត ។ ខ្ញុំបានរំជួលចិត្តពីដំណើររឿងនៃសមាគមដែលរីកចម្រើនរបស់ អិល.ឌី.អែស. ដោយធ្វើសន្និសីទអន្តរនិកាយស្ដីពីតម្លៃសីលធម៌ និងការសម្អាតក្នុងសហគមន៍ជាមួយនឹងសាសនាផ្សេងៗ ទៀត ។

នៅក្នុងការបម្រើជាមួយអ្នកដែលមានជំនឿសាសនាផ្សេងៗនោះខ្ញុំបានរកឃើញថាការលើកទឹកចិត្តពីអែលឌើរឃ្វីនថិន អិល ឃុក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់គឺជាការពិត ៖ ការបម្រើនៃអន្តរនិកាយដោយការគោរព និងស្មោះត្រង់ មិនគ្រាន់តែស្ថាបនាសហគមន៍របស់យើងប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចឲ្យរីកចម្រើនរួមគ្នា និងផ្ទាល់ខ្លួននៅក្នុងសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះ និងកូនចៅរបស់ទ្រង់ ។[2]

### ការធ្វើឲ្យពិភពលោកនេះបានប្រសើរឡើង

ប៉ុន្មានឆ្នាំមុន មានគ្រូគង្វាលខាងជំនឿ ប្រែសប៊ីធារាន បានផ្លាស់ចូលមកក្នុងសហគមន៍របស់យើងដោយចង់បម្រើដល់ពួកអ្នកជិតខាងរបស់គាត់ទាំងអស់ ពុំមែនគ្រាន់តែក្រុមជំនុំក្នុងព្រះវិហាររបស់គាត់ប៉ុណ្ណោះទេ ។ នៅពេលគាត់បានផ្ដើមទំនាក់ទំនងទៅក្នុងសហគមន៍របស់យើងដែលភាគច្រើនជាគ្រួសារ អិល.ឌី.អែស. ដើម្បីជួយ និងការ

©2012 IRI 1



*កម្មវិធី Holladay Matters ( នៅទីក្រុង ហូឡាដេ រដ្ឋ យូថាហ៍ ស.រ.អា. ) ត្រូវបានរៀបចំឡើងដើម្បីស្វាគមន៍មនុស្សមកពីគ្រប់សាសនា ឬគ្មានការចូលរួមខាងសាសនា ចូលមកក្នុងគម្រោង និងសកម្មភាពអ្នកជិតខាង ។ ស្ត្រីមកពីនិកាយផ្សេងៗគ្នានៅក្នុងរូបថតនេះគឺជាសមាជិកស្ថាបនិក ។*



*នៅខែ ធ្នូ ឆ្នាំ 2011 កុមារមកពីព្រះវិហារទស្សនៈបរិសុទ្ធ កាតូលិក នៅរដ្ឋ ញូវ ជើស៊ី ស.រ.អា. បានសម្ដែងកម្មវិធីគ្រីស្ទម៉ាសមួយជាមួយនឹងកុមារមកពី ក្រុមជំនុំនៃសាសនាចក្រនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ការប្រគុំតន្ត្រីភោគទាននេះបានជួយប្រមូល យកអាហារសម្រាប់ឃ្លាំងស្តុកអាហារក្នុងមូលដ្ឋាន ។*

អញ្ជើញសម្រាប់ពិធីជប់លៀងក្នុងសហគមន៍ នោះសមាជិកវួដបានចាប់ផ្ដើមចូលរួមនៅក្នុងគម្រោងនៃការបម្រើរបស់ក្រុមជំនុំគាត់ ដោយធ្វើការរួមគ្នា នោះគាត់ និងអ្នកជិតខាងដែលមានជំនឿផ្សេងៗគ្នាបានធ្វើការរៃអង្គាសមូលនិធិដើម្បីជួយដល់គ្រួសារអិល.ឌី.អែស មួយជាមួយនឹងការចំណាយថ្លៃពេទ្យបន្ទាន់ ។

សាវក អ្លុសុន អែហ្វ វិតនី (1855–1931) បានថ្លែងថា « ព្រះកំពុងប្រើមនុស្សជាច្រើនដើម្បីសម្រេចនូវកិច្ចការដ៏ធំ ហើយអស្ចារ្យរបស់ទ្រង់ ។ . . . វាមានភាពធំ ហើយអស្ចារ្យពន់ពេកសម្រាប់មនុស្សមួយក្រុម » ។[3] រឿងដ៏អស្ចារ្យទាំងឡាយអាចសម្រេចឡើងបាន នៅពេលក្រុមនៃមនុស្សល្អធ្វើការរួមគ្នា ។ ការខំប្រឹងប្រែងរបស់គ្រូគង្វាលដែលជាអ្នកជិតខាងរបស់យើង បានដឹកនាំទៅការបង្កើតជាគណៈកម្មការសហគមន៍អន្តរនិកាយ ដោយរួមជាមួយនឹងសមាគមសង្គ្រោះស្ដេករបស់យើងផងដែរ បានបង្កើតសន្និសីទស្ត្រីមួយដោយផ្ដត់ផ្គង់កញ្ចប់សម្ភារអនាម័យ និងសៀវភៅដល់ទីភ្នាក់ងារជនភៀសខ្លួន ។ បន្ទាប់មក ទំនាក់ទំនងខាងអន្តរនិកាយទាំងនេះបានផ្ដល់លទ្ធភាពដល់សមាជិកស្តេក ឲ្យជួយដល់ក្រុមជំនុំមួយផ្ដល់ម្ហូបអាហារដល់ជនភៀសខ្លួនមួយក្រុមធំ ហើយបានចូលជួយនៅពេលព្រះវិហារផ្សេងត្រូវការពួកអ្នកស្ម័គ្រចិត្តបន្ថែមទៀតនៅទីជម្រកជនដែលគ្មានផ្ទះសម្បែង ។

ប្រធាន ថូម៉ាស អេស ម៉នសុន បានប្រាប់ដល់សមាជិកថា « យើងមានទំនួលខុសត្រូវមួយ . . . ដើម្បី សហការជាមួយនឹងព្រះវិហារ និងអង្គការផ្សេងៗទៀត »[4] ហើយការឈោងទៅជួយនេះបានប្រទានពរដល់ពិភពលោកនេះលើសពីការបម្រើខាងផ្នែកមនុស្សធម៌ទៅទៀត ។ នៅក្នុងសុន្ទរកថាមួយទៅកាន់ពួកអ្នកដឹកនាំគ្រីស្ទានក្នុងសហរដ្ឋ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងក្ញុំមនៃពួកសាវកដប់ពីរនាក់បានរៀបរាប់ ពីការពិភាក្សាជាផ្លូវការមួយជាបន្តបន្ទាប់រវាងសមាជិក អិល.ឌី.អែស. និងពួកគ្រីស្ទានផ្សេងទៀតដែលបានធ្វើឡើងនៅសកលវិទ្យាល័យ ព្រិកហាំយ៉ង់ ។[5] លទ្ធផលមួយនៃសន្និសីទទាំងនេះបានកើតឡើងនៅពេលមានអ្នកដឹកនាំសាសនាដ៏ល្បីឈ្មោះម្នាក់បានធ្វើការសុំទោសចំពោះ កាយវិការមិនសមរម្យដោយពួកមនុស្សមួយចំនួនទៅលើជំនឿរបស់ពួកមរមននៅក្នុងសហគមន៍របស់គាត់ ។[6] អែលឌើរ ហូឡិន បានមានប្រសាសន៍ពីការចងភ្ជាប់មិត្តភាពនោះថា « ខ្ញុំជឿថាកិច្ចការនេះជាផ្នែកមួយនៃការរៀបចំព្រឹត្តិការណ៍មួយមកពីព្រះនៅក្នុងគ្រាដ៏មានបញ្ហាទាំងនេះ » ។[7]

## ការធ្វើឲ្យទំនាក់ទំនងរបស់យើងបានប្រសើរឡើង

នៅពេលយើងបម្រើជាមួយអ្នកដទៃ សេចក្ដីណែនាំដ៏ជាក់លាក់នានាអាចជួយយើងឲ្យបង្កើតទំនាក់ទំនងរបស់យើងកាន់តែមានអត្ថន័យ ហើយជៀសវាងការធ្វើឲ្យអាក់អន់ចិត្ត ។ មានពេលមួយខ្ញុំបានរស់នៅក្នុងទីក្រុងធំមួយ ហើយបានធ្វើជាអ្នកស្ម័គ្រចិត្តសម្រាប់កម្មវិធីបង្រៀនរបស់ព្រះវិហារមួយ ក្នុងមូលដ្ឋានដែលបើកសម្រាប់មនុស្សទូទៅ—ប៉ុន្តែបានរកឃើញថា អ្នកដែលដឹងពីសមាជិកភាពរបស់ខ្ញុំនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទថ្ងៃចុងក្រោយមិនអាចទទួលយកបាន ។ បទពិសោធន៍នោះបានជំរុញខ្ញុំឲ្យផ្ដល់តម្លៃដល់ការបរិច្ចាគរបស់មនុស្សគ្រប់គ្នាដោយមិនគិតពីទំនាក់ ទំនង ( ឬការខ្វះខាត ) ខាងសាសនារបស់ពួកគេនោះទេ ។ ខ្ញុំបានតាមដានដោយអំណរគុណពីចំណាប់អារម្មណ៍របស់មនុស្សគ្រប់គ្នាពីសាសនាចក្រ ប៉ុន្តែខ្ញុំបានដឹងផងដែរថា យើងជាពួកបរិសុទ្ធថ្ងៃចុងក្រោយ បានធ្វើតាមការបង្រៀនរបស់ព្រះយេស៊ូវទាំងស្រុង នៅក្នុងការស្រឡាញ់អ្នកជិតខាងយើង ស្លៀកពាក់ដល់ជនអាក្រាត ផ្ដល់អាហារដល់ជនអត់ឃ្លាន ហើយសួរសុខទុក្ខដល់ជនជាប់ឃុំ ( សូមមើល ម៉ាថាយ 25:34–36 ) ។ ការតាំងចិត្តខាងអន្តរនិកាយដ៏ស្មោះត្រង់ ហើយមានការគោរពពុំតម្រូវឲ្យក្រុមណាមួយ បដិសេធនូវជំនឿរបស់ខ្លួនឡើយ រួមទាំងក្រុមរបស់យើងផងដែរ ។ តែផ្ទុយទៅវិញ វាបានលើកទឹកចិត្តដល់ពួកអ្នកចូលរួមមិនឲ្យ « ប្រឆាំង



នឹងសាសនាណាឡើយ » ( គ. និង ស. 18:20 ) ហើយ « បំពាក់[ ខ្លួនពួកគេ ] ដោយចំណងនៃសេចក្តីសប្បុរស » ( គ. និង ស. 88:125 ) ។

សេចក្តីណែនាំដ៏មានអត្ថប្រយោជន៍មួយទៀតបានមកពីអ្នកដឹកនាំស្តេកដ៏ឈ្លាសវៃមួយរូប នៅក្នុងសហគមន៍អ្នកជិតខាងរបស់យើងដែលជា អិល.ឌី.អែស. ភាគច្រើន ។ គាត់បានណែនាំសមាជិកឲ្យបម្រើជាមួយនឹងសាសនាដទៃផ្សេងទៀត ពុំមែនដើម្បី « គ្រប់គ្រង » ដោយការដឹកនាំលើការសម្រេចចិត្ត ឬភាពជាអ្នកដឹកនាំនោះទេ ប៉ុន្តែដើម្បីធ្វើការជាក្រុម ហើយអនុញ្ញាតឲ្យមនុស្សគ្រប់គ្នា « បានសិទ្ធិស្មើគ្នា » ( គ. និង ស. 88:122 ) ។ អ្នកដឹកនាំរូបនេះ ដែលមានបទពិសោធន៍យ៉ាងច្រើនក្នុងការចូលរួមនឹងសាសនាដទៃ ក៏បានលើកទឹកចិត្តសមាជិកឲ្យអភិវឌ្ឍទំនាក់ទំនងល្អ ។ គាត់បានរកឃើញថា សាសនាមួយចំនួនដែលបានធ្វើជាដៃគូនឹងពួកបរិសុទ្ធថ្ងៃចុងក្រោយបានរកឃើញថាពួកគេខិតខំធ្វើការ ហើយរីករាយ ប៉ុន្តែមានចំណាប់អារម្មណ៍ច្រើននៅក្នុងការបញ្ចប់ការងារជាជាងការអភិវឌ្ឍន៍មិត្តភាព ។

បទពិសោធន៍របស់ខ្ញុំនៅក្នុងសហគមន៍ និងខាងវិស័យអប់រំបានធ្វើឲ្យខ្ញុំជឿថា ព្រះវិញ្ញាណមានឥទ្ធិពលខ្លាំងនៅពេលមនុស្សផ្សេងគ្នាបានរួបរួមគ្នានៅក្នុងបេសកកម្មមួយដ៏មានតម្លៃ ។សេចក្តីស្រឡាញ់ និងភាពបរិសុទ្ធជាបងប្អូនបានជំរុញឲ្យការបម្រើធ្វើដំណើរឆ្ពោះទៅមុខលើសពីការខិតខំធ្វើការទៅទៀត ។[8]

អ្នកទ្បើងនិយាយម្នាក់ជា អិល.ឌី.អែស ដែលបានចូលរួមនៅក្នុងសន្និសីទអន្តរនិកាយមួយបានសង្កេតឃើញថា ការមានទំនាក់ទំនងនឹងមនុស្សដទៃជួយដល់ជន ដែលមានជំនឿខុសពីយើងយល់ពីយើងកាន់តែប្រសើរជាងមុន ។[9] មានសាស្ត្រាចារ្យម្នាក់ទៀត នៅសាសនាផ្សេង បានបង្រៀនសន្និបាតពីសាសនាមរមននៅសកលវិទ្យាល័យអាមេរិកដោយបើកចំហ ។ គាត់បានរកឃើញថា និស្សិតរបស់គាត់ចង់រៀនពីសាសនាចក្ររបស់យើង « ជាខ្លាំង . . . ដោយសារពួកគេត្រូវបានចិញ្ចឹមបីបាច់មកឲ្យជឿថា សាសនានេះជាលទ្ធិសាសនាមួយ ប៉ុន្តែបទពិសោធន៍របស់ពួកគេជាមួយនឹងមិត្ត និងមិត្តរួមការងារជា មរមន គឺមិនដូចជាអ្វីដែលបានលើកឡើងឡើយ » ។[10]

## ការធ្វើឲ្យខ្លួនយើងបានប្រសើរឡើង

ការបម្រើជាមួយនឹងអ្នកដទៃមិនគ្រាន់តែជួយពួកគេឲ្យយល់ពីយើងប៉ុណ្ណោះទេ ប៉ុន្តែវាក៏លើកទឹកចិត្តយើងឲ្យរៀនពីពួកគេ ហើយដឹងកាន់តែច្រើនថា ព្រះ « មិនរើសមុខជនណាទេ » ( គ. និង ស. 1:35 ) ។ ទ្រង់បានជួយមនុស្សល្អគ្រប់សាសនា និងវប្បធម៌ទាំងអស់នៅក្នុងកិច្ចខិតខំរបស់ពួកគេដើម្បីធ្វើឲ្យជីវិតកូនចៅរបស់ទ្រង់បានប្រសើរឡើង ។

ការទទួលស្គាល់អំពើល្អរបស់អ្នកដទៃនេះជួយយើងឲ្យនៅតែមានចិត្តរាបទាប មិនដូចជាពួកផារ៉ាស៊ី ដែលព្រះយេស៊ូវបានស្តីបន្ទោស ដោយសារតែសេចក្តីអំនួត

### ចំណុចគោលលទ្ធិ

- ព្រះប្រើអ្នកដែលមានចិត្តស្មោះត្រង់នៅគ្រប់និកាយ និងវប្បធម៌ដើម្បីពន្លឿនដល់កិច្ចការរបស់ទ្រង់លើផែនដី ។
- ការធ្វើការជាមួយនឹងមនុស្សដទៃទៀតដែលពុំជឿដូចយើង ដើម្បីធ្វើបុព្វហេតុនៃសេចក្តីល្អឲ្យបានប្រសើរឡើង ធ្វើឲ្យយើងធ្វើការល្អបានច្រើនជាងយើងធ្វើតែម្នាក់ឯងទៅទៀត ។
- ការចូលរួមនៃអន្តរនិកាយដោយការគោរព និងមិត្តភាពកាត់បន្ថយការយល់ខុសនានា ហើយបង្កើតអារម្មណ៍នៃភាពជាបងប្អូនប្រុសស្រី ព្រមទាំងនាំយើងខិតទៅជិតព្រះវរបិតានៃយើងទាំងអស់គ្នាផងដែរ ។

*ពួកអ្នកចូលរួមបានពិភាក្សាពីការការពារដល់សិទ្ធិសេរីភាពខាងសាសនានៅក្នុងសន្និសីទអន្តរនិកាយមួយដែលធ្វើឡើងនៅទីក្រុង សៅ ប៉ាឡូ ប្រទេសប្រេស៊ីល នៅខែ មិនា ឆ្នាំ 2013 ។*



ពីខាងឆ្វេង ៖ រូបថតដោយ ឡេស្លី និលសិន© 2011 IRI, © 2013 IRI

*ខាងក្រោម ពីខាងឆ្វេង ៖ ពួកអ្នករបាំបារ៉ាតាណាទីយ៉ាំ បានសម្ដែង នៅក្នុងរោងឧបោសថ សលត៍ លេក អំឡុងការប្រគំតន្ត្រីអន្តរនិកាយនៅខែ កុម្ភៈ ឆ្នាំ 2010 ។ សមាជិកអ្នកទស្សនាម្នាក់បានរីករាយនឹងការប្រគំតន្ត្រីនោះ ។ នៅក្នុងវីដេអូមួយរបស់សាសនាចក្រ មរមន មានពួកយុវវ័យក្មេងមកពីសាសនាផ្សេងគ្នាពិភាក្សាពីសារៈសំខាន់នៃភាពបរិសុទ្ធផ្លូវភេទ ។ ពួកអ្នកចូលរួមនៅក្នុងព្រឹត្តិការណ៍ធ្វើភួយ សម្រាប់សប្បុរសធម៌ជាអន្តរនិកាយប្រចាំឆ្នាំ ដែលធ្វើឡើងនៅទីក្រុង ហ៊ូស្តុន រដ្ឋ តិចសាស ស.រ.អា. បានធ្វើភួយសម្រាប់ក្រុមគ្រួសារដែលខ្វះខាត ។*

ខាងវិញ្ញាណរបស់ពួកគេ ( សូមមើល ម៉ាថាយ 23 ) ឬពួកសាសន៍ សូរាំ ដែលព្រះគម្ពីរមរមនបានពិពណ៌នាថា ជាមនុស្សមិនចុះសម្រុង ហើយអួតអាង ( សូមមើល អាលម៉ា 31 ) ។ ការបើកទូលាយចំពោះសេចក្ដីល្អរបស់អ្នកដទៃអាចជួយយើងឲ្យក្លាយជាមនុស្សដ៏ប្រសើរ ។

សេចក្ដីស្រឡាញ់របស់យើងមិនគ្រាន់តែអាចពង្រីកពីក្រុមតូច ដែលជាគ្រួសាររបស់យើងផ្ទាល់ ទៅដល់មិត្តភក្តិរបស់យើងតែប៉ុណ្ណោះទេ គឺអាចថែមទាំងដល់អ្នកជិតខាងយើង—និងសត្រូវរបស់យើងទៀតផង ។ មានសមាជិកសាសនាចក្រម្នាក់ដែលបម្រើក្នុងទ័ពអាមេរិកនា–សង្គ្រាមលោកលើកទី II នៅប្រទេសជប៉ុនបានប្រាប់ពីអារម្មណ៍ដ៏ ជូរចត់របស់គាត់ចំពោះប្រជាជន ជប៉ុន ។ បន្ទាប់ពីគាត់ត្រូវបានស្វាគមន៍ឲ្យទៅក្នុងអគារពិសិដ្ឋសម្រាប់ថ្វាយបង្គំដោយប្រជាជន ជប៉ុន ប៉ុន្តែគាត់បានរកឃើញថា « វិញ្ញាណរបស់ពួកគេបានរំជួលដល់វិញ្ញាណរបស់ខ្ញុំ ហើយខ្ញុំបានទទួលអារម្មណ៍នៃការផ្លាស់ប្ដូរដួងចិត្តដ៏អស្ចារ្យមួយចំពោះពួកគេ ។ អារម្មណ៍ដ៏ ជូរចត់របស់ខ្ញុំបានរសាយបាត់ ។ . . . ខ្ញុំបានគិតពីអ្វីដែលបានកើតឡើងនៅក្នុងអគារពិសិដ្ឋនោះ និង ការផ្លាស់ប្ដូរដ៏អស្ចារ្យនោះ ដែលខ្ញុំមានចំពោះប្រជាជននៅទីនោះ » ។[11]

ដូចគ្នានេះដែរ នៅពេលយើងស្វាគមន៍ដោយចិត្តស្មោះដល់មនុស្សដទៃទៀត នោះពួកគេអាចទទួលអារម្មណ៍នូវការផ្លាស់ប្ដូរផងដែរ ។ មានអ្នកគ្រីស្ទានម្នាក់ដែលបញ្ចប់ការសិក្សាពីសកលវិទ្យាល័យ ព្រិកហាំយ៉ង់ បានសរសេរអត្ថបទមួយពីបទពិសោធន៍របស់នាង ហើយបានរៀបរាប់ពីការការពារដំបូងរបស់នាងចំពោះនិស្សិតអិល.ឌី.អែស. ។ ប៉ុន្តែនៅទីបំផុតបន្ទាប់ការចងមិត្តភាពដ៏ល្អមក នាងមានអំណរគុណ « សារៈសំខាន់ដែលខ្ញុំបានទទួលអារម្មណ៍ថាពួកបរិសុទ្ធថ្ងៃចុងក្រោយបានផ្ដោតលើភាពជិតស្និទ្ធរបស់ព្រះចំពោះមនុស្សលោក ។ ខ្ញុំបានចាប់ផ្ដើមស្គាល់ថា នៅក្នុងកិច្ចខិតខំមួយដើម្បីរក្សានូវភាពដ៏អស្ចារ្យរបស់ព្រះ ខ្ញុំបានលះបង់នូវភាពនៅជិត ព្រះ—ហើយការយល់ដឹងនេះបានឥទ្ធិពលមកលើខ្ញុំយ៉ាងខ្លាំង » ។[12]

នៅក្នុងសុន្ទរកថារបស់លោកទៅកាន់ពួកអ្នកដឹកនាំគ្រីស្ទាន អែលឌើរ ហូឡិន បានទទួលស្គាល់ « ហានិភ័យដែលទាក់ទងនឹងការរៀននូវអ្វីមួយថ្មីពីមនុស្សម្នាក់ផ្សេងទៀត ។ គំនិតសឹជម្រៅថ្មីតែងតែជះឥទ្ធិពលទៅលើទស្សនៈចាស់ ហេតុដូច្នេះហើយ ការគិតឡើងវិញ ការរៀបចំឡើងវិញ និងការបង្កើតឡើងវិញមួយចំនួន នៃការយល់ដឹងរបស់យើងពីពិភពលោកនេះគឺមិនជៀសវាងបានឡើយ » ។[13] នៅក្នុងការជួយដល់មនុស្សនៃជំនឿផ្សេង ជារឿយៗ ខ្ញុំបានរកឃើញខ្លួនឯងវិភាគពីភាពខុសគ្នារបស់យើង ដោយព្យាយាមញែកភាពខុសគ្នាខាងវប្បធម៌ចេញពីភាពខុសគ្នាខាងគោលលទ្ធិ ខណៈ ដែលនៅពេលដូចគ្នានោះបានព្យាយាមដឹងគុណដល់អ្វីៗគ្រប់យ៉ាងដ៏មានគុណធម៌ និងគួរ











*អាឡិន បាច់មិន ប្រធាននៃការប្រជុំអន្តរនិកាយនៅទីក្រុង សលត៍ លេក បាននិយាយនៅក្នុងរោងឧបោសថ សលត៍ លេក នៅខែ កុម្ភៈ ឆ្នាំ 2012 ។*



*ស្ត្រីពួកបរិសុទ្ធថ្ងៃចុងក្រោយបីនាក់បានចូលរួមពិធីជប់លៀងខាងសាសនា ជាអាហារពេលល្ងាចមួយដែលរៀបចំឡើង ដោយក្រុមមួយមកពីវប្បធម៌ផ្សេងគ្នានៅទីក្រុង ស្ប៉ូកេន រដ្ឋ វ៉ាស៊ីងតោន ស.រ.អា. ។ ពួកគាត់ និងអ្នកចូលរួមផ្សេងទៀតបានដើរទស្សនាវិហារ អ៊ីស្លាម ក្នុងមូលដ្ឋានមួយ ជាកន្លែងថ្វាយបង្គំមួយសម្រាប់សមាជិកសាសនា ស៊ីខ និងព្រះវិហារ ប្រែសប៊ីធារាន ។*

ឲ្យស្រឡាញ់ដែលពួកគេបានផ្តល់ឲ្យ ។ ពិតណាស់ ពេលខ្លះការព្យាយាមនោះមានអារម្មណ៍ថាជារឿងប្រថុយប្រថាន ប៉ុន្តែវាតែងមានតម្លៃជានិច្ច ។ នៅក្នុងដំណើរការនៃការកែសម្រួលបទដ្ឋានរបស់ខ្ញុំ ខ្ញុំរកឃើញថាខ្លួនឯងបានលះបង់យ៉ាងច្រើននូវទំនៀមទម្លាប់របស់ខ្ញុំ ចំពោះការមើលតែអាការៈខាង ក្រៅ ហើយខិតទៅជិតនឹងសារៈសំខាន់នៃដំណឹងល្អ ។

មានក្រុម អិល.ឌី.អែស មួយចំនួនបានអញ្ជើញគ្រូគង្វាលដែលជាមិត្តរបស់ខ្ញុំឲ្យនិយាយពីប្រធានបទនៃ « ការស្រឡាញ់អ្នកជិតខាងរបស់យើងដោយមិនគិតពីភាពខុសគ្នាខាងសាសនា » ហើយគាត់បានទទួលការគាំទ្រយ៉ាងខ្លាំងពីអ្នកដែលបានចូលរួម ។ ដូចគ្នានេះដែរ គាត់បានអញ្ជើញពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួន រួមទាំងរូបខ្ញុំផងដែរ ដើម្បីនិយាយទៅកាន់ក្រុមជំនុំផ្សេងៗគ្នាពីប្រធានបទដដែល ។ បន្ទាប់ពីការប្រជុំទាំងនោះ ខ្ញុំបានរកឃើញថាខ្លួនឯងហ៊ុមព័ទ្ធទៅដោយពួកក្រុមជំនុំដែលចង់មកនិយាយនឹងខ្ញុំ ឱបខ្ញុំ ហើយថែមទាំងសម្រក់ទឹកភ្នែកដោយសារសេចក្តីស្រឡាញ់ និងការយល់ដឹងពីគ្នាទៅវិញទៅមក ។ នៅក្នុងបទពិសោធន៍បែបនេះ ខ្ញុំបានរកឃើញថាការសន្និដ្ឋានរបស់អែលឌើរ ហូឡិន គឺជាការពិត ៖

« នៅពេលយើងសម្លឹងមើលមនុស្សលើសពីពណ៌សម្បុរ ជាតិសាសន៍ ក្រុមសង្គម ព្រះវិហារ សាលាប្រជុំ វិហារ សាសនា ជំនឿ ហើយនៅពេលយើងព្យាយាមឲ្យអស់ពីលទ្ធភាពដើម្បីមើលឃើញពីអត្តសញ្ញាណពិតរបស់ពួកគេជាកូនចៅនៃព្រះតែមួយ នោះនឹងមានអ្វីមួយដែលល្អប្រសើរកើតឡើងនៅក្នុងខ្លួនយើង ដោយហេតុនេះហើយនឹងបានខិតទៅជិតព្រះ ដែលជាព្រះវរបិតានៃយើងទាំងអស់គ្នា » ។[14] ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**

1. Dieter F. Uchtdorf, in Marjorie Cortez « Catholic Community Services honors Uchtdorfs, Eccles as humanitarians of the year » ថ្ងៃទី 7 ខែ វិច្ឆិកា ឆ្នាំ 2012, deseretnews.com ។
2. សូមមើល ឃ្វីនថិន អិល យុក « “Partnering with Our Friends from Other Faiths » ថ្ងៃទី 9 ខែ សីហា ឆ្នាំ 2010, patheos.com ។.
3. អ្ហ្វសុន អែហ្វ វិតនី នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1928 ទំព័រ 59 ។
4. ថូម៉ាស អេស ម៉នសុន នៅក្នុង « The Mormon Ethic of Civility » ថ្ងៃទី 16 ខែ តុលា ឆ្នាំ 2009 mormonnewsroom.org
5. សូមមើល ជែហ្វ្រី អ័រ ហូឡិន « Standing Together for the Cause of Christ » *Liahona* ខែ សីហា ឆ្នាំ 2012 ទំព័រ 24–26 ។
6. យ៉ូសែប វ៉រឃើរ « Evangelical leader says LDS Church is not a cult » ថ្ងៃទី 10 ខែ តុលា ឆ្នាំ 2011, deseretnews.com ។
7. ជែហ្វ្រី អ័រ ហូឡិន « Standing Together » *Liahona* ទំព័រ 24 ។
8. សូមមើល ម៉ៃខល អេ ណែលឌើរ « The Voice of the People » *Ensign* ខែ តុលា ឆ្នាំ 2012 ទំព័រ 38–40 ។
9. សូមមើល ប៊្លែរ ឌី ហាចស៍ « Mormons, Methodists meet to consider similarities, compare cultures, theology, music » ថ្ងៃទី 25 ខែ កុម្ភៈ ឆ្នាំ 2012, deseretnews.com ។
10. យ៉ូសែប វ៉រឃើរ « University of Virginia Chair in Mormon studies named for Richard L. Bushman » ថ្ងៃទី 12 ខែ តុលា ឆ្នាំ 2012, deseretnews.com ។
11. ហ្សើរ៉ុន អេ អុលសុន « Forgiveness at Wakayama » *Ensign* ខែ ធ្នូ ឆ្នាំ 2011 ទំព័រ 57 ។
12. សារ៉ា ថៃឡើរ នៅក្នុង « An Evangelical Student’s Experience at BYU » *Meridian Magazine* ldsmag.com ។
13. ជែហ្វ្រី អ័រ ហូឡិន « Standing Together » *Liahona* ទំព័រ 29 ។
14. ជែហ្វ្រី អ័រ ហូឡិន « Standing Together »*Liahona* ទំព័រ 29 ។

ពីឆ្វេង ៖ © 2010 IRI, © 2012 IRI, © 2011 IRI, © 2007 IRI, © 2012 IRI, [illegible]



# ពី អ្នកដទៃ ក្លាយទៅជាមិត្ត

*ទង្វើនៃការបម្រើដ៏សាមញ្ញមួយមកពីអ្នកផ្សព្វផ្សាយសាសនាវ័យចំណាស់ម្នាក់បានផ្ដុកនូវចំណាប់អារម្មណ៍មួយជារៀងរហូត ។*

**ដោយ ដេវីឌ ឌីកសុន**
ទស្សនាវដ្ដីសាសនាចក្រ



មាន *ជនចំឡែក*ម្នាក់នៅលើដើមឈើ ? តើ*ជនចំឡែក*កំពុងធ្វើអ្វីនៅលើដើមឈើ ? ចុះតើឧបករណ៍អ្វីដែលគាត់ប្រើដើម្បីកាត់មែកឈើបានយ៉ាងរហ័សនោះ?

សំណួរទាំងនេះបានកើតឡើងនៅក្នុងគំនិតនៃប្រជាជន យូហ្គាដា មួយក្រុមដែលឈរមើល ( *ជនចំឡែក* ) ម្នាក់ ប្រើរណាអារតម្រឹមឈើប្រើថ្មពិលកាត់តម្រឹមមែកឈើងាប់ពីដើមឈើមួយដែលមានម្លប់ដ៏ត្រឈឹងត្រឈៃធំ ។ ឧបករណ៍នោះ គឺមានភាពអស្ចារ្យណាស់សម្រាប់ប្រជាជននៅទីនោះ ។ ភាគច្រើនពួកគេពុំធ្លាប់ឃើញអ្វីបែបនេះពីមុនមកឡើយ ។

ប៉ុន្តែ *ជនចំឡែក* ម្នាក់នោះរឹតតែធ្វើឲ្យពួកគេភាពភ្ញាក់ផ្អើលថែមទៀត ។ អែលឌើរ រ៉ូឡិន ហ៊ែរីស ជាអ្នកផ្សព្វផ្សាយវ័យចំណាស់ម្នាក់មកពីរដ្ឋ យូថាហ៍ ស.រ.អា. បានកាត់តម្រឹមមែកឈើមួយហើយមួយទៀត ដោយកាត់មែកងាប់ចេញពីដើមឈើមួយដ៏ខ្ពស់ ។ មនុស្សដែលនៅខាងក្រោមបានភ្ញាក់ផ្អើលដែលជនបរទេសម្នាក់បានធ្វើកិច្ចការបែបនេះ ដែលជាកិច្ចការមួយរបស់ពួកគេផ្ទាល់នោះ ។

នៅទីបំផុត ទង្វើនៃការបម្រើដ៏សាមញ្ញរបស់អែលឌើរហារីស បានគូសចំណាំនូវការចាប់ផ្ដើមនៃមិត្តភាពមួយជាមួយនឹងមនុស្សម្នាក់ដែលមិនចាប់អារម្មណ៍នឹងសាសនាចក្រ ឬ សមាជិកនៃសាសនាចក្រនោះឡើយ ។

**ការចាប់ផ្ដើមស្គាល់ ហ្គត់ហ្វ្រី**

អែលឌើរ រ៉ូឡិន ហារីស និង ស៊ិស្ទើរ ចានេត ហារីស កំពុងបម្រើបេសកកម្មរយៈពេល 23 ខែ នៅក្នុងបេសកកម្ម កំប៉ាឡាអ៊ូហ្គង់ដា ។ ស៊ិស្ទើរ ហារីស ជាគិលានុបដ្ឋាយិកាចុះឈ្មោះម្នាក់ ត្រូវបានហៅជាអ្នកប្រឹក្សាផ្នែកវេជ្ជសាស្ត្រដល់ពួកអ្នកផ្សព្វផ្សាយសាសនា ។ អែលឌើរ ហារីស ជាអ្នកគ្រប់គ្រងផ្នែកសំណង់ចូលនិវត្តន៍ម្នាក់ដែលអាចជួសជុលស្ទើរតែអ្វីៗទាំងអស់នៅក្នុងចក្រវាល បានថែទាំអគារសាសនាចក្រ និងរថយន្តរបស់បេសកកម្ម ។

មិនយូរប៉ុន្មានបន្ទាប់ពីមកដល់ប្រទេសអ៊ូហ្គង់ដា អែលឌើរ និង ស៊ិស្ទើរ ហារីស បានជួយសមាជិកសាសនាចក្រនៅទីនោះម្នាក់ឈ្មោះ ម៉ារី ដើម្បីជួយបោសសម្អាតផ្ទះពួកគាត់ ។

ម៉ារី បានជ្រមុជទឹកកាលពីបីឆ្នាំមុន ។ ស៊ិស្ទើរហារីស បាននិយាយថា « យើងកាន់តែស្រឡាញ់នាងខ្លាំងឡើងៗ » ។ « នាងបានជួយបង្រៀនយើងពីរបៀបរបបនៃប្រទេស អ៊ូហ្គង់ដា » ។

កាលពួកគាត់ស្គាល់ ម៉ារី កាន់តែច្រើន នោះមិត្តភាពរបស់ពួកគេកាន់តែមានភាពជ្រាលជ្រៅ ។ មួយរំពេចនោះ ពួកគាត់បានរៀនពីស្វាមីរបស់នាង ឈ្មោះ ហ្គត់ហ្វ្រី ជាបុរសល្អម្នាក់តែមិនចង់ពាក់ព័ន្ធនឹងសមាជិកសាសនាចក្រ ជាពិសេសពួកអ្នកផ្សព្វផ្សាយសាសនា ។ ស៊ិស្ទើរ ហ៊ែរីស បានពន្យល់ថា « គាត់មិនអនុញ្ញាតឲ្យពួកអ្នកផ្សព្វផ្សាយសាសនាចូលផ្ទះរបស់គាត់ឡើយ » ។ ប៉ុន្តែម៉ារី នៅតែចង់ឲ្យ ហ្គត់ហ្វ្រី ជួបនឹងពួកគេ ។

នាងបានអញ្ជើញគ្រួសារហារីស មកលេងផ្ទះនាងក្នុងរយៈពេលខ្លីមួយ ។ ស៊ិស្ទើរ ហារីបានពន្យល់ថា « យើងគ្មានការរំពឹងទុកណាមួយនោះឡើយ » ។ « យើងបានប្រាប់ ហ្គត់ហ្វ្រី ថា ឥឡូវនេះ ម៉ារី ជាមិត្តសម្លាញ់របស់យើង ហើយយើងចង់ស្គាល់ពីគ្រួសាររបស់នាង » ។ ហ្គត់ហ្វ្រី បាននិយាយនឹងពួកគាត់ ប៉ុន្តែគ្មានគំនិតចង់រាប់អានពួកគាត់ជាមិត្តនោះឡើយ ។

ការណ៍នោះបានផ្លាស់ប្ដូរទាំងស្រុងនៅថ្ងៃដែលអែលឌើរ ហារីស បានបង្ហាញខ្លួនជាមួយនឹងឧបករណ៍ដ៏អស្ចារ្យ ជណ្ដើរ ហើយសុំធ្វើការបម្រើមួយ ។

**ពេលដែលមានការផ្លាស់ប្ដូរ**

ផ្ទះរបស់ ហ្គត់ហ្វ្រី និង ម៉ារី គឺហ៊ុមព័ទ្ធទៅដោយដើមឈើខ្ពស់ៗមានសុទ្ធតែមែកងាប់ និងមែកចាស់យ៉ាងច្រើនបានគ្របលើដំបូលផ្ទះរបស់ពួកគេ ។

អែលឌើរ ហារីស បានចាប់ផ្ដើមធ្វើការភ្លាម ។ គាត់បានចំណាយពេលបួនម៉ោងនៅចុងដើមឈើនោះ ដើម្បីកាត់មែកឈើដែលមានអង្កត់ផ្ចិតរហូតដល់ទៅ 25 ស.ម. ។ ការងារនេះគួរតែមានគេធ្វើជាយូរមកហើយ ។ អែលឌើរ ហារីស បាននិយាយថា « យ៉ាងហោចណាស់ ខ្ញុំឡើងដល់កម្ពស់ 6 ម. ពីដី » ។ នៅពេលមានមនុស្សដើរក្បែរ ពួកគេមិនចង់ជឿនឹងភ្នែករបស់ពួកគេឡើយ ។

រីឯ ហ្គត់ហ្វ្រី វិញបាននៅឈរស្រឡាំងកាំង ។ ស៊ិស្ទើរ ហារីស និយាយថា « គាត់បានអរគុណយើងយ៉ាងខ្លាំង » ។ សូម្បីតែសកម្មភាពដ៏សាមញ្ញដូចជា



ការកាត់តម្រឹមដើមឈើអាចនាំមកនូវគ្រោះថ្នាក់ដ៏ធំ ។ ស៊ិស្ទើរ ហារីស បានពន្យល់ថា « ពួកគេគ្មានប្រាក់សម្រាប់ថ្លៃពេទ្យនោះទេ » ។ ឧទាហរណ៍ ប្រសិនបើនរណាម្នាក់ធ្លាក់ពីលើដើមឈើមក ហើយបាក់ដៃ ឬជើង ពួកគេប្រហែលជាត្រូវព្យាបាលដោយខ្លួនឯង ។

កំណាត់ឈើមួយពំនូកធំនៅលើដី បានស្ថាបនាជាគ្រឹះសម្រាប់មិត្តភាពដ៏រីករាយមួយ ។ អែលឌើរ ហារីស បាននិយាយថា « ចាប់ពីពេលនោះមក ហ្គត់ហ្វ្រី បានចេញមករាក់ទាក់នឹងយើង » ។ ហ្គត់ហ្វ្រី និង ម៉ារី ក៏បានចាប់ផ្ដើមស្វាគមន៍សមាជិកសាសនាចក្រដទៃទៀតចូលមកក្នុងផ្ទះរបស់ពួកគេផងដែរ ។

**ការឆ្លងកាត់ទន្លេ នីល**

អែលឌើរ និង ស៊ិស្ទើរ ហារីស បានមានភាពជិតស្និទ្ធនឹង ហ្គត់ហ្វ្រី និង ម៉ារី កាលពេលវេលាចេះតែកន្លងទៅ ។ នៅទីបំផុត មិត្តភាពនេះបានប្រែក្លាយជាកម្លាំង និងការគាំទ្រមួយសម្រាប់គ្រួសារហារីស នៅពេលគ្រោះថ្នាក់មួយដែលមិនបានរំពឹងទុកបានកើតឡើង ចំពោះពួកគាត់ នៅពាក់កណ្ដាលនៃបេសកកម្មរបស់ពួកគាត់ ។ ពួកគាត់បានទទួលដំណឹងថា កូនប្រុសពួកគាត់ឈ្មោះ ប្រាដ បានស្លាប់ដោយសារគ្រោះថ្នាក់រថយន្ត ។

នៅពេល ហ្គត់ហ្វ្រី និង ម៉ារី បានដឹងពីរឿងនេះភ្លាម ពួកគេបានស្លៀកសំលៀកបំពាក់ល្អបំផុតរបស់ពួកគេ ហើយធ្វើដំណើរមួយប្រកបដោយគ្រោះថ្នាក់ ដើម្បីបាននៅក្បែរមិត្តជាទីស្រឡាញ់របស់ពួកគេ ។

នៅប្រទេសអ៊ូហ្គង់ដា មានមនុស្សពីរបីនាក់ប៉ុណ្ណោះដែលមានរថយន្ត ។ ពួកគេត្រូវដើរ ឬក៏ជិះរថយន្តតាក់ស៊ី ។ តាក់ស៊ីជាទូទៅគឺ *បូដា បូដា* ជាម៉ូតូមួយដែលជារឿយៗមានគេឃើញដឹកមនុស្សដល់ទៅប្រាំមួយនាក់ក្នុងពេលតែមួយ ។



ស៊ិស្ទើរ ហ៊ែរីស ពន្យល់ថា « ការជិះ*បូដា បូដា* នៅពេលយប់គឺគ្រោះថ្នាក់ណាស់ » ។ « ពួកគេឆ្លងទន្លេ នីល ដោយ *បូដា បូដា* នៅពេលយប់ » ។

បន្ទាប់ពីធ្វើដំណើរលើផ្លូវដ៏គ្រោះថ្នាក់នៅពេលយប់ដោយចំណាយប្រាក់ផ្ទាល់ខ្លួនមក ហ្គត់ហ្វ្រី និងម៉ារីបានទៅដល់ ដើម្បី « ទួញយំជាមួយនឹងអ្នកណាដែលទួញយំ » ហើយ « កម្សាន្តទុក្ខដល់អស់អ្នកណាដែលកំពុងត្រូវការកម្សាន្តទុក្ខ » ( ម៉ូសាយ 18:9 ) ។ នៅយប់នោះ សេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដបានទទួលត្រលប់មកវិញ ។ ម៉ារី និង ហ្គត់ហ្វ្រី គឺជាអ្នកដែលផ្ដល់ការបម្រើ ។ ស៊ិស្ទើរ ហារីស និយាយថា « វាជារឿងដ៏អស្ចារ្យណាស់ » ។ ម៉ារី បានណែនាំថា ពួកគេទាំងអស់គួរលុតជង្គង់ចុះអធិស្ឋានទាំងអស់គ្នា ។ ហ្គត់ហ្វ្រី បានចូលរួមដោយគ្មានភាពស្ទាក់ស្ទើរ ។

អែលឌើរ និង ស៊ីស្ទើរ ហារីស បានត្រឡប់ទៅរដ្ឋកាលីហ្វ័រញ៉ា ស.រ.អា. វិញដើម្បីចូលបុណ្យសព្វរបស់ប្រាដ ។ ក្រោយមក ពួកគាត់បានត្រឡប់មកប្រទេសអ៊ូហ្គង់ដាវិញដើម្បីបញ្ចប់បេសកកម្មរបស់ពួកគាត់ ។ ឥឡូវនេះ នៅពេលពួកគាត់រស់នៅរដ្ឋ យូថាហ៍ ក្ដី ក៏ រ៉ូឡិន និង ដៃនេត នៅតែទាក់ទងនឹង ម៉ារី និង ហ្គត់ហ្វ្រី ដែរ ។

ការបម្រើជាកូនសោមួយដែលអាចបើកទ្វារដែលរាំងដល់យើង ។ ដូចជាប្រធាន ថូម៉ាស អេស ម៉នសុន បង្រៀនថា « នៅពេលការបម្រើដោយចិត្តសប្បុរសបំបាត់ចោលនូវភាពកំណាញ់ នោះព្រះចេស្ដានៃព្រះនឹងនាំឲ្យគោលបំណងរបស់ទ្រង់បានកើតឡើង » (« Willing and Worthy to Serve » *Liahona* ខែ ឧសភា ឆ្នាំ 2012 ទំព័រ 68 ) ។ ■



# ទ្វីបនៃសេចក្ដីសង្ឃឹមដ៏ភ្លឺត្រចះត្រចង់ អាហ្វ្រិក






**ដោយ រីឆាត អិម រ៉មនី**
ទស្សនាវដ្ដីសាសនាចក្រ

*សេចក្ដីជំនឿ និងការគោរពប្រតិបត្តិរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅអាហ្វ្រិក និងក្រុងម៉ាដាហ្គាស្កា បានធ្វើជាគំរូមួយសម្រាប់សមាជិកសាសនាចក្រនៅគ្រប់ទិសទី ។*

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍នៅ ក្រុង ហ្វ្រីថោន សៀរ៉ា ឡេអូន អំឡុងពេលបំពេញការងារមួយ ដែលរួមទាំងដំណើរទស្សនកិច្ចទៅកាន់ប្រទេសលីបេរីយ៉ា និងប្រទេស ហ្គាណា ថា « ប្រជាជន អាហ្វ្រិក ងាយនឹងស្រឡាញ់ណាស់ »[1] ។

លោកបានមានប្រសាសន៍ថា សេចក្ដីជំនឿ និងការគោរពប្រតិបត្តិរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយជនជាតិ អាហ្វ្រិក ដែលពួកគេទទួលបានដោយសារសេចក្ដីស្រឡាញ់របស់ពួកគេចំពោះដំណឹងល្អ បានធ្វើជាគំរូមួយដល់សមាជិកសាសនាចក្រទាំងអស់ ។

រូបថតដោយ រីឆាត អិម រ៉មនី



*សេចក្ដីសញ្ញានៃបុណ្យជ្រមុជទឹកបើកទ្វារសម្រាប់ពរជ័យជាច្រើន ហើយការសិក្សាដំណឹងល្អដោយស្មោះត្រង់ក៏ដូចគ្នាដែរ ។*



អែលឌើរ ហូឡិន បានមានប្រសាសន៍ថា វាគួរឲ្យចាប់អារម្មណ៍ណាស់ « ដើម្បីមើលឃើញថាដំណឹងល្អមានន័យយ៉ាងណាចំពោះពួកគេ ដើម្បីមើលឃើញពីអ្វីដែលពួកគេបានធ្វើជាមួយនឹងដំណឹងល្អ ពីរបៀបដែលពួកគេស្រឡាញ់ដំណឹងល្អ ដើម្បីមើលឃើញពីសេចក្ដីស្មោះត្រង់របស់ពួកគេ នៅក្នុងដង្វាយមួយភាគក្នុងដប់ និងក្នុងការបម្រើ ក្នុងការទៅព្រះវិហារបរិសុទ្ធ—ខ្ញុំគិតពីព្រះវិហារបរិសុទ្ធជាគោលដៅមួយដ៏ខ្ពស់បំផុត—រួចហើយមើលពួកគេចិញ្ចឹមកូនចៅរបស់ពួកគេ នៅក្នុងសាសនាចក្រ ហើយបញ្ជូនកូនប្រុសស្រីរបស់ពួកគេទៅបេសកកម្ម ។ វាគឺជាភស្ដុតាងដ៏អស្ចារ្យពីសេចក្ដីស្មោះត្រង់របស់ពួកគេ » ។[2]

## នៅចំពោះភ្នែករបស់អ្នក

អែលឌើរ ហូឡិន បានកត់ចំណាំថា ជាមួយនឹងករណីលើកលែងនៃប្រទេស អាហ្វ្រិក ខាងត្បូង ( ដែលមានស្ដេកមួយបានរៀបចំឡើងនៅឆ្នាំ 1970 ) សាសនាចក្របាននៅក្នុងទ្វីប អាហ្វ្រិក តិចជាង 30 ឆ្នាំ ។ ដោយសារតែការណ៍នោះ សាសនាចក្រនៅទីនេះបាន « ស្ថាបនានៅចំពោះភ្នែករបស់អ្នក ហើយបានស្ថាបនាក្នុងរយៈពេលមួយដ៏ខ្លី » ហើយ « ទ្វីប អាហ្វ្រិក គឺជាកន្លែងមួយដ៏ពិសេស ដែលអ្នកអាចមើលឃើញពីសិរីល្អរបស់ព្រះអម្ចាស់ ភាពអស្ចារ្យ និងអព្ភូតហេតុនៃការស្ដារឡើងវិញ បានបើកសម្ដែងនៅចំពោះភ្នែករបស់អ្នក » ។[3]

លោកបានមានប្រសាសន៍ថា លោកតែងតែចងចាំជានិច្ចការបាននៅ អាក្រា ប្រទេស ហ្គាណា ជាមួយនឹងប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( 1910–2008 ) នៅ

ពេលលោកបានប្រកាសថា នឹងមានព្រះវិហារបរិសុទ្ធសាងសង់នៅទៅនោះ ។ » [ ប្រជាជន ] បានឈរស្រែកអបអរ សម្រក់ទឹកភ្នែក ហើយរាំ ឱបគ្នាទៅវិញទៅមក ហើយយំ ។ នៅតាមរបៀបមួយដែលអារម្មណ៍នោះនៅតែបន្ត ។ នោះគឺជាសេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះប្រជាជន អាហ្វ្រិក—វាជាសេចក្ដីអំណរដែលគ្មានកំណត់នៅក្នុងដំណឹងល្អ ។ សម្ភារភាគច្រើនដែលមាននៅក្នុងជីវិតរបស់ពួកគេគឺតិចតួចណាស់ ប៉ុន្តែនៅពេលពួកគេបានដំណឹងល្អ ពួកគេបានទទួល ហើយធ្វើតាម ។ . . . ហើយពួកគេនៅតែធ្វើដូច្នោះ ។ ពួកគេកំពុងធ្វើកិច្ចការនោះរហូតមកដល់សព្វថ្ងៃនេះ » ។[4]

## ការព្យាករណ៍ទាំងឡាយបានបំពេញ

ពួកព្យាការី និងពួកសាវករបស់យើងដែលបានបំពេញកិច្ចការ នៅក្នុងទ្វីប អាហ្វ្រិក បាននិយាយពីទ្វីបនោះថា ជាទីកន្លែងមួយដែលការព្យាករណ៍របស់ព្រះអម្ចាស់កំពុងត្រូវបានបំពេញយ៉ាងពិតប្រាកដ ។

បន្ទាប់ពីដំណើរទស្សនកិច្ចមួយជាមួយនឹងសមាជិកសាសនាចក្រនៅប្រទេស ម៉ូសំប៊ីក និងប្រទេស នីហ្សេរីយ៉ា អែលឌើរ រីឆាដ ជី ស្កុត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « ប្រជាជន អាហ្វ្រិក គឺជាប្រជាជនដែលមានសន្ដានចិត្តល្អ ហើយអត់ធ្មត់ » ។ « ពួកគេគ្មានប្រាក់ចំណូល ឬធនធានច្រើនដែលអនុញ្ញាតឲ្យពួកគេធ្វើនូវរឿងទាំងឡាយនោះទេ ដូច្នេះពួកគេត្រូវធ្វើវាចេញពីការខំប្រឹងប្រែងយ៉ាងខ្លាំង ។ ពួកគេត្រូវដើរនៅលើចម្ងាយផ្លូវដ៏វែងឆ្ងាយ ដើម្បីសម្រេចបាននូវអ្វីមួយដែលពួកគេបានទទួលការបំផុសគំនិតឲ្យធ្វើដោយព្រះវិញ្ញាណបរិសុទ្ធដើម្បីកិច្ចការនោះឲ្យបានចម្រើនឡើង » ។[5]

អែលឌើរ ស្កុត បានកត់ចំណាំថា នៅឆ្នាំ 1999 នៅពេលលោកបានឧទ្ទិសប្រទេស ម៉ូសំប៊ីក សម្រាប់ការផ្សព្វផ្សាយសាសនា នៅទីនោះមានសមាជិកតែ 40 នាក់ប៉ុណ្ណោះ ហើយប្រទេសនេះគឺជាផ្នែកនៃបេសកកម្ម ចូហាន់ណេស្បឺគ អាហ្វ្រិកខាងត្បូង ។ នៅក្នុងដំណើរទស្សនកិច្ចជាលើកទីពីររបស់លោក នាខែ មករា ឆ្នាំ 2011 សាសនាចក្រនៅក្នុងប្រទេស ម៉ូសំប៊ីក បានរីកចម្រើនរហូតដល់មានសមាជិកច្រើនជាង 5,000 នាក់ នៅក្នុងមណ្ឌលចំនួនពីរ និងសាខាចំនួន 19 កន្លែងនៅក្នុងប្រទេសនេះ ។ ប្រទេស ម៉ូសំប៊ីក ក៏ជាទីស្នាក់ការកណ្ដាលនៃបេសកកម្ម ម៉ាពុតូ ម៉ូសំប៊ីក ផងដែរ ដែលរួមបញ្ចូលទាំងប្រទេស អង់ហ្គោឡា ផងដែរ ។[6]

## ក្មេងខ្ចី ប៉ុន្តែកំពុងតែរីកចម្រើន

ខណៈដែលធ្វើទស្សនកិច្ចនៅប្រទេស ម៉ាដាហ្គាស្កា ប្រទេស ម៉ាឡាវី និងប្រទេស កេនយ៉ា អែលឌើរ ស៊ែល អិម ណិលសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ក៏បានមានប្រសាសន៍ផងដែរថា « សាសនាចក្រគឺនៅថ្មីថ្មោងនៅទីនេះ » ។[7] « យើងកំពុងមើលព្រះអម្ចាស់ពន្លឿនកិច្ចការនៅលើទ្វីប អាហ្វ្រិក ដ៏អស្ចារ្យនេះ ដើម្បីប្រទានពរដល់ប្រជាជន ជាមួយនឹងសេចក្ដីពិត ពន្លឺនៃដំណឹងល្អ រួមទាំង ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ និងភាពតម្កើងឡើងផងដែរ » ។[8] លោកបានមានប្រសាសន៍ថា លោកមានចំណាប់អារម្មណ៍ជាពិសេសនឹងភាពរឹងមាំនៃថ្នាក់ដឹកនាំសាសនាចក្រក្នុងមូលដ្ឋាននៅទ្វីប អាហ្វ្រិក ៖ « ខ្ញុំមិនអាចប្រាប់អ្នកថា តើយើងមានអំណរគុណប៉ុណ្ណានោះទេ ចំពោះពួកអ្នកដឹកនាំទាំងនេះនៅក្នុងមូលដ្ឋាន ដែលបានផ្ដល់ពេលវេលា និងទេពកោសល្យ នៅក្នុងការបម្រើព្រះអម្ចាស់ ដើម្បីប្រទានពរដល់ជីវិតនៃប្រជាជនទាំងនេះ » ។[9]

អែលឌើរ ណិលសុន « មានទំនុកចិត្តយ៉ាងខ្លាំង » ចំពោះអនាគតនៃសាសនាចក្រ និងប្រជាជនក្នុងទ្វីប អាហ្វ្រិក និង ម៉ាដាហ្គាស្កា ដោយសារសេចក្ដីជំនឿរបស់ពួកគេគឺខ្លាំងជាងឧបសគ្គរបស់ពួកគេទៅទៀត ។ លោកបានមានប្រសាសន៍ក្នុងការប្រជុំមួយនៅប្រទេស ម៉ាដាហ្គាស្កា ថា « អ្នកពិតជាកូនចៅនៃព្រះ ជាកូនចៅនៃអ៊ីស្រាអែលដែលចុះសេចក្ដីសញ្ញា បានរៀបចំដើម្បីជួបនឹងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងព្រះ ជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ចរបស់យើង ហើយរស់នៅក្នុងវត្តមានរបស់ទ្រង់ជាមួយនឹងក្រុមគ្រួសារ [ របស់អ្នក ] »[10] ។ អែលឌើរ ណិលសុន ក៏បានមានប្រសាសន៍ផងដែរថា « ប្រជាជនទាំងនេះគឺប្រជាជនដែលមានសក្ដានុពលដ៏អស្ចារ្យ ។ ពួកគេមានសេចក្ដីជំនឿ ។ ពួកគេមានសេចក្ដីស្រឡាញ់ចំពោះព្រះអម្ចាស់ ហើយពួកគេមាននូវអ្វីទាំងអស់ដែលចាំបាច់ ដើម្បីធ្វើឲ្យមនុស្សពិតជារឹងមាំយ៉ាងខ្លាំង » ។[11]









អំឡុងបទសម្ភាសន៍មួយនៅ ណៃរ៉ូប៊ី ប្រទេស កេនយ៉ា អែលឌើរ ណែលសុន មានយោបល់ថា « យើងមានសាលាប្រជុំនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ យើងមានស្តេកមួយ [ នៅក្នុង ] ណៃរ៉ូប៊ី នេះ ។ យើងមានសន្និសីទស្តេកមួយនៅថ្ងៃនេះ ។ វាជារឿងដ៏រំភើបមួយដើម្បីជួបនឹងប្រជាជននៅទីនេះ ។ មានមនុស្សលើសពីមួយពាន់នាក់បានប្រមូលផ្ដុំគ្នា [ ហើយពួកគេមាន ] គារវភាព [ ហើយមាន ] ក្រុមចម្រៀងដ៏ពីរោះ មានគណៈប្រធានស្តេកដ៏ប្រពៃ [ និង ] លោកអយ្យកោនៅលើវេទិកា ។ តើខ្ញុំអាចសម្ដែងចេញនូវសេចក្ដីអំណររបស់ខ្ញុំតាមរបៀបណា នៅពេលខ្ញុំមើលឃើញពីការរីកចម្រើនបែបនេះនោះ ? »[12]



*ការខិតខំដើម្បីចងចាំព្រះអង្គសង្គ្រោះជានិច្ច សមាជិកទាំងឡាយត្រូវបានពង្រឹង ហើយរំឭកឡើងវិញដោយការទទួលទានសាក្រាម៉ង់ ។*



**ថ្វីបើមានសេចក្តីលំបាក**

អែលឌើរ ហូឡិន បានមានប្រសាសន៍ថា សាសនាចក្រនៅទ្វីប អាហ្វ្រិក កំពុងរីកចម្រើន ទោះបីប្រឈមមុខនឹងឧបសគ្គក៏ដោយ ។ ជាឧទាហរណ៍មួយ លោកបានមានប្រសាសន៍ថា « ខណៈពេលដែលមានសង្គ្រាមស៊ីវិល នៅក្នុង ខូតេ ឌីវ័រ [ ឆ្នេរអ៊ីវ័រី ] ពួកបរិសុទ្ធថ្ងៃចុងក្រោយ . . . នៅតែបន្តមកកាន់ព្រះវិហារបរិសុទ្ធ ។ ព្រះវិហារបរិសុទ្ធគឺជាកិត្តិយសមួយដ៏អស្ចារ្យចំពោះពួកគេ ។ ខ្ញុំមានការភ្ញាក់ផ្អើល » ។[13]

ដោយលើកឡើងពី ស៊ីរ៉ា ឡេអូន និង លីប៊ើរៀ អែលឌើរ ហូឡិន បានមានប្រសាសន៍ថា « ដោយសារពួកគេមានសង្គ្រាមដ៏ឃោរឃៅកាលពីពេលកន្លងមកថ្មីៗនេះ នោះគឺជាហេតុផលមួយដែលដំណឹងល្អកំពុងតែលូតលាស់យ៉ាងខ្លាំង ។ ពួកគេធ្លាប់ឃើញពីអ្វីដែលជីវិត *មិន* គួរមានហើយឥឡូវនេះ ជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនា និងពួកសមាជិកថ្លែងទីបន្ទាល់ នោះពួកគេបានឃើញពីអ្វីដែលវា *អាច* ប្រែក្លាយ ។ ស្ថានសួគ៌បានបង្វែរ [ ការសាកល្បងរបស់ពួកគេ ] ទៅជាពរជ័យ ហើយពួកគេកំពុងដកខ្លួនចេញ ពីភាពមិនប្រាកដប្រជាខាងនយោបាយ និងវិបត្តិនៃសង្គមស៊ីវិល » ។[14]

អែលឌើរ ហូឡិន បានគូសបញ្ជាក់បន្ថែមទៀតពីការរីកចម្រើននៃសាសនាចក្រនៅ ប្រទេស ស៊ីមបាវ៉េបានបន្ត ថ្វីបើមានគ្រាដ៏លំបាកក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ ៖ « សាសនាចក្របានរីកចម្រើន ។ យើងមានការ

លូតលាស់ យើងមានស្តេក យើងមានបេសកកម្ម ។ នោះជាអ្វីដែលកំពុងកើតឡើងនៅទូទាំងទ្វីប អាហ្វ្រិក » ។[15]

### ការផ្សាយដំណឹងល្អ

អែលឌើរ ហូឡិន បានឲ្យដឹងថា គន្លឹះដ៏សំខាន់មួយចំពោះជោគជ័យរបស់សាសនាចក្រនៅទ្វីប អាហ្វ្រិក គឺថា « យើងមិនពាក់ព័ន្ធនឹងបញ្ហានយោបាយ ឬបញ្ហាសង្គមធំៗនោះទេ ។ យើងផ្សាយដំណឹងល្អ ។ យើងខ្វល់ខ្វាយពីសេចក្តីយុត្តិធម៌ ហើយយើងខ្វល់ខ្វាយពីឱកាស និងភាពស្មើគ្នាក្នុងសង្គម ។ ប៉ុន្តែយើងគិតថា [ ចម្លើយសម្រាប់បញ្ហានោះគឺមាននៅក្នុងព្រះគម្ពីរ ] ដូច្នេះយើងគ្រាន់តែផ្សាយដំណឹងល្អ ។ ហើយវាបានកើតពិតនៅកន្លែងដទៃទៀត ហើយវាមានពិតនៅទ្វីបអាហ្វ្រិក ថានៅពេលមនុស្សដែលបានទទួលការយល់ដឹង ពរជ័យ និងពន្លឺនៅក្នុងជីវិតពួកគេ ហើយរំពេចនោះរឿងទាំងឡាយបានចាប់ផ្តើមផ្លាស់ប្តូរ ហើយជីវិតរបស់ពួកគេបានទទួលពរជ័យ » ។[16]

### សេចក្តីសន្យារបស់ព្រះអម្ចាស់

អែលឌើរ ហូឡិន បានដកស្រង់បន្ទូលព្រះអង្គសង្គ្រោះដែលមានបន្ទូលថា « អ្នកក្រោយនឹងបានទៅជាមុន ហើយពួកអ្នកមុននឹងទៅជាក្រោយវិញ » ( ម៉ាថាយ 20:16 ) ។

លោកបានឲ្យដឹងថា « ដោយសារវិធីមួយចំនួនដំណឹងល្អបានមកដល់ទ្វីបអាហ្វ្រិកដោយយឺតយ៉ាវយ៉ាងហោចណាស់នៅពេលយើងអាចធ្វើវានៅតាមពេលកំណត់របស់ព្រះអម្ចាស់—ហើយវាជាកាលកំណត់របស់ព្រះអម្ចាស់ ខ្ញុំមានការអះអាង ។ ថ្មីៗនេះ វាគ្រាន់តែជាការប្រៀបធៀបមួយថា ប្រជាជនអាហ្វ្រិក បានចាប់ផ្តើមទទួល បេសកកម្ម និង អ្នកផ្សព្វផ្សាយសាសនា ពរជ័យនៃបព្វជិតភាព និងអ្វីៗជាច្រើនទៀត ។ វាជាទ្វីបមួយដ៏ធំ ហើយយើងនៅមានកិច្ចការជាច្រើនទៀតដើម្បីធ្វើ ។ ប៉ុន្តែខ្ញុំជឿថា ការរីកចម្រើនដែលយើងកំពុងមើលឃើញ នៅក្នុងទ្វីប អាហ្វ្រិក សព្វថ្ងៃនេះ គឺជាផ្នែកនៃការបំពេញនូវសេចក្តីសន្យារបស់ព្រះអម្ចាស់ ។ ពួកបរិសុទ្ធថ្ងៃចុងក្រោយ អាហ្វ្រិក កំពុងតែរីកចម្រើនឡើងជាមួយនឹងសេចក្តីជំនឿ ។ ពួកគេកំពុងតែរីកលូតលាស់ ។ ពួកគេកំពុងប្រឈមមុខនឹងបទពិសោធន៍នៃការទទួលយកដំណឹងល្អ ហើយកំពុងធ្វើឲ្យមានភាពច្បាស់លាស់នៅក្នុងជីវិតរបស់ពួកគេ » ។[17] ■

**កំណត់ចំណាំ**

1. ជេហ្វ្រី អ័រ ហូឡិន នៅក្នុង « Emerging with Faith in Africa » www.lds.org/prophets-and-apostles/unto-all-the-world/emerging-with-faith-in-africa ។
2. ជេហ្វ្រី អ័រ ហូឡិន នៅក្នុង « Emerging with Faith in Africa » ។
3. ជេហ្វ្រី អ័រ ហូឡិន នៅក្នុង « Emerging with Faith in Africa » ។
4. ជេហ្វ្រី អ័រ ហូឡិន នៅក្នុង « Emerging with Faith in Africa » ។
5. រីឆាដ ជី ស្កត នៅក្នុង « Mormons in Africa: A Bright Land of Hope »mormonnewsroom.org/article/mormons-africa-bright-land-hope ។
6. សូមមើល « ‹ Jesus Christ Lives › Elder Scott Testifies in Mozambique »lds.org/prophets-and-apostles/unto-all-the-world/jesus-christ-lives-elder-scott-testifies-in-mozambique ។
7. រ័សុល អិម ណិលសុន នៅក្នុងវីដេអូ « Learn of the Savior, Saints in Madagascar and Malawi Are Told, » lds.org/prophets-and-apostles/unto-all-the-world/learn-of-the-savior-saints-in-madagascar-and-malawi-are-told ។
8. រ័សុល អិម ណិលសុន នៅក្នុង « Elder Nelson Completes Trip to Africa in Kenya » lds.org/church/news/elder-nelson-completes-trip-to-africa-in-kenya ។
9. រ័សុល អិម ណិលសុន នៅក្នុងវីដេអូនៃ ហេធើរ វីតថល រីគលី «Elder Nelson Visits Madagascar, Dedicates Malawi » ថ្ងៃទី 28 ខែ តុលា ឆ្នាំ 2011 lds.org/church/news/elder-nelson-visits-madagascar-dedicates-malawi ។
10. រ័សុល អិម ណិលសុន នៅក្នុងវីដេអូ « Learn of the Savior, Saints in Madagascar and Malawi Are Told » ។
11. រ័សុល អិម ណិលសុន នៅក្នុងវីដេអូ «Elder Nelson Visits Madagascar, Dedicates Malawi » ។
12. រ័សុល អិម ណិលសុន នៅក្នុងវីដេអូ « Family Success Comes from Following the Savior »lds.org/prophets-and-apostles/unto-all-the-world/family-success-comes-from-following-the-savior ។
13. ជេហ្វ្រី អ័រ ហូឡិន នៅក្នុង « Emerging with Faith in Africa » ។
14. ជេហ្វ្រី អ័រ ហូឡិន នៅក្នុង « Emerging with Faith in Africa » ។
15. ជេហ្វ្រី អ័រ ហូឡិន នៅក្នុង « Emerging with Faith in Africa » ។
16. ជេហ្វ្រី អ័រ ហូឡិន នៅក្នុង « Emerging with Faith in Africa » ។
17. ជេហ្វ្រី អ័រ ហូឡិន នៅក្នុង « Emerging with Faith in Africa » ។









**តំបន់ អាហ្វ្រិក ភាគអាគ្នេយ៍ និងខាងលិច***
សមាជិក ៖ 381,417
ស្តេក ៖ 70
វួដ ៖ 508
បេសកកម្ម ៖ 22
មណ្ឌល ៖ 60
សាខា ៖ 646
ទីស្នាក់ការកណ្តាល ៖ ចូហាន់ណេស្បឺគ ប្រទេស អាហ្វ្រិកខាងត្បូង និង អាក្រា ប្រទេស ហ្គាណា
**គិតត្រឹមខែ មេសា ឆ្នាំ 2013 ។*

**ព្រះវិហារបរិសុទ្ធ**
*កំពុងដំណើរការ*
អាក្រាហ្គាណា បានឧទ្ទិសនៅថ្ងៃទី 7 ខែ សីហា ឆ្នាំ 2005
អាបានីហ្សេរីយ៉ា បានឧទ្ទិសនៅថ្ងៃទី 11 ខែ មករា ឆ្នាំ 2004
ចូហាន់ណេស្បឺគ អាហ្វ្រិកខាងត្បូង បានឧទ្ទិសនៅថ្ងៃទី 24–25 ខែ សីហា ឆ្នាំ 1985
*បានប្រកាស*
ឌឺបាន អាហ្វ្រិក ខាងត្បូង
គីស្ហា សាសាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ

# អព្ភូតហេតុដ៏អស្ចារ្យបំផុត

នៅថ្ងៃដ៏ភ្លឺស្រឡះមួយនាខែ កញ្ញា កូនស្រីពៅរបស់យើង អេរីកា មានគ្រោះថ្នាក់រថយន្តមួយដ៏ធ្ងន់ធ្ងរ ។ នាងត្រូវបានដឹកតាមយន្តហោះទៅកាន់មន្ទីរពេទ្យ ហើយបន្ទាប់ពីការវះកាត់សង្គ្រោះបន្ទាន់ជាច្រើនម៉ោងមក យើងបានទទួលដំណឹងដ៏រន្ធត់ថា ៖ កូនស្រីរបស់យើងដ៏ស្រស់ស្អាត ហើយរស់រវើកអាយុ 17 ឆ្នាំបានស្លាប់ទៅហើយ ។

ពីរបីខែបន្ទាប់មកទៀតពួកយើងមានការឈឺចាប់ខ្លាំងណាស់ ។ យើងបានស៊ូទ្រាំរហូតដល់ថ្ងៃកំណើតរបស់នាង និងបុណ្យថ្លែងអំណរគុណ ហើយបានរៀបចំខ្លួនយើងសម្រាប់បុណ្យគ្រីស្ទម៉ាស់លើកដំបូងដោយគ្មាននាង ។ មានមនុស្សបានប្រាប់យើងថា ថ្ងៃបុណ្យនោះនឹង ជាពេលមួយដ៏ពិបាក ប៉ុន្តែគ្មានការប្រាប់ណាមួយដែលអាចជួយទប់ចិត្តរបស់យើងបានឡើយ ។

ក្រៅពីអារម្មណ៍ពោរពេញដោយភាពសោកសៅ និងអស់សង្ឃឹម ខ្ញុំបានច្រណែនចំពោះក្រុមគ្រួសារផ្សេងទៀតដែលនៅជុំគ្នា ហើយមានការអបអរដោយរីករាយ ។ ខ្ញុំមានការងឿងឆ្ងល់ទាំងភាពជូរចត់ថា « ហេតុអ្វីជាយើង ? » ហេតុអ្វីបានជាយើងពុំបានទទួលនូវអព្ភូតហេតុមួយដូចដែលមនុស្សដ៏ទៃបានលើកឡើង ? »

នៅក្នុងភាពអស់សង្ឃឹមរបស់ខ្ញុំ ខ្ញុំបានចងចាំពីគ្រាមួយដែលវួដរបស់យើងបានធ្វើសកម្មភាពមួយ ហៅថា « បុណ្យគ្រីស្ទម៉ាស់នៅ បេថ្លេហិម » ។ សមាជិកវួដបានមក ហើយស្លៀកពាក់ដូចជាពួកគេកំពុងរស់នៅក្នុងគ្រាដែលព្រះយេស៊ូវប្រសូត ។ អេរីកា នៅពេលនោះមានអាយុបួនឆ្នាំ នាងបានស្លៀករ៉ូបវែងពណ៌សដែលបានរក្សាទុកតៗគ្នាមក និងកន្សែងបង់-ករុំជុំវិញក្បាលរបស់គាត់ ។ ផ្នែកដ៏សំខាន់នាល្ងាចនោះគឺការរំឭកឡើងវិញមួយពីប្រសូតិកម្មនៅក្នុងក្រោលសិប្បនិមិត្តមួយដែលបានតុបតែងឡើងដោយមានពំនូកចំបើង និងស្នូក ។ មានស្វាមីភរិយាមួយគូ រួមនឹងកូនតូចរបស់ពួកគេបានសម្ដែងផ្នែកម៉ារា យ៉ូសែប និងព្រះឱរស យេស៊ូវ ។

នៅពេលយើងបានផ្ដុំគ្នានៅជុំវិញប្រសូតិកម្មនោះ ខ្ញុំបានសង្កេតឃើញថា អេរីកា បានបាត់ចេញពីខ្ញុំ ។ ខ្ញុំបានភ័យស្លន់ស្លោរហូតដល់ខ្ញុំបានក្រឡេកឃើញរ៉ូប-សរបស់នាងនៅក្បែរប្រសូតិកម្មនោះ ។ បន្ទាប់មក ការស្លន់ស្លោរបស់ខ្ញុំបានប្ដូរពីការភ័យចំពោះសេចក្ដីសុខរបស់នាងទៅជាការភ័យខ្លាចថានាងនឹងរំខានដល់ការសម្ដែង ។ ខ្ញុំរៀបនឹងហៅនាងឲ្យចេញមក ប៉ុន្តែខ្ញុំបានផ្អាក ហើយចាំមើលនៅពេលនាងដើរទៅកាន់ស្នូក ។

អេរីកាបានលុតជង្គង់ភ្លាមនៅក្បែរម៉ារា ហើយសម្លឹងមើលមុខគាត់ ដូចជាចង់សុំការអនុញ្ញាតពីនាង ។ បន្ទាប់មកអេរីកាបានលូកដៃទៅប៉ះទារកដែលកំពុងគេងដោយថ្នមៗ ។ ខ្ញុំពុំមែនជាមនុស្សតែម្នាក់ដែលបានឃើញនោះទេ ។ រំពេចនោះមនុស្សផ្សេងទៀតបាននៅស្ងៀមចាំមើល នៅពេលនាងបានលុតជង្គង់ចុះនៅក្បែរទារកនោះ ។ អារម្មណ៍ដ៏ទន់ភ្លន់មួយបានជ្រៀតចូលមកក្នុងដួងចិត្តនៃបណ្ដាជន នៅពេលពួកគេបានដឹងថា ទារកនេះគឺជាព្រះឱរសព្រះគ្រីស្ទសម្រាប់អេរីកា ។

នៅក្នុងភាពសោកសៅរបស់ខ្ញុំ ការចងចាំពីបុណ្យគ្រីស្ទម៉ាស់នេះបាននាំមកនូវអារម្មណ៍នៃសេចក្ដីសុខសាន្ត និងការលួងលោម នៅពេលខ្ញុំបាននឹងឃើញពីការតាំងចិត្តរបស់កូនស្រីវ័យក្មេងរបស់ខ្ញុំ ។ គំនិតរបស់ខ្ញុំបានពោរពេញដោយសំណួរពីជីវិត និងសេចក្ដីស្លាប់ ជាសំណួរដែលហាក់ដូចជាមិនសូវសំខាន់ពីមុនសេចក្ដីស្លាប់របស់អេរីកា ។ នៅពេលខ្ញុំសញ្ជឹងគិតពីការរស់ឡើងវិញ និងការឆ្កាង ខ្ញុំមានអារម្មណ៍ថា ខ្ញុំយល់ពីអារម្មណ៍របស់ម៉ារា ។ គាត់ស្រឡាញ់ព្រះរាជបុត្រារបស់គាត់ ហើយក្រោយមកគាត់បានស៊ូទ្រាំនឹងការឈឺចាប់ និងការរងទុក្ខដ៏គួរឲ្យភ័យខ្លាច នៅពេលគាត់បានឃើញការរងទុក្ខ និងការសុគតរបស់ទ្រង់ ។ ព្រះគ្រីស្ទពុំអាចរួចផុតពីការរងទុក្ខនៅលើឆ្កាងបាន រីឯម៉ារាពុំអាចរួចផុតពីការរងទុក្ខរបស់គាត់បានឡើយ ។

នៅពេលបុណ្យគ្រីស្ទម៉ាស់យើងមានអំណរគុណនូវការចាប់ផ្ដើមនៃព្រះជន្មនៅលើផែនដីរបស់ព្រះអង្គសង្គ្រោះ ប៉ុន្តែចំពោះខ្ញុំ ការប្រសូតរបស់ទ្រង់ឥឡូវនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងការរងទុក្ខ ការសុគត និងការរស់ឡើងវិញរបស់ទ្រង់—ជាដង្វាយធួន ។ ដោយសារព្រះអង្គសង្គ្រោះបានផ្ដាច់ចំណងនៃសេចក្ដីស្លាប់ ខ្ញុំដឹងថា សេចក្ដីស្លាប់របស់អេរីកានឹងពុំមែនជាទីបញ្ចប់នោះទេ ។ ការណ៍នោះគឺជាអព្ភូតហេតុដើម្បីមានអំណរគុណ—ជាអព្ភូតហេតុដ៏អស្ចារ្យបំផុតនៅគ្រប់ពេលទាំងអស់ ។ ■

អេឡេន ណេល រដ្ឋ យូថាហ៍ ស.រ.អា.

មនុស្សគ្រប់គ្នាបានទទួលអារម្មណ៍ដ៏ទន់ភ្លន់មួយនៅពេលពួកគេបានដឹងថា ទារកនេះគឺជាព្រះឱរសព្រះគ្រីស្ទសម្រាប់អេរីកា ។



# ចម្លើយចំពោះការអធិស្ឋានរបស់គាត់

ខ្ញុំពុំមានអារម្មណ៍ពីវិញ្ញាណនៃបុណ្យគ្រីស្ទម៉ាស់ ។ វាជាខែ ធ្នូ នៃឆ្នាំចុងក្រោយរបស់ខ្ញុំនៅវិទ្យាល័យ ដែលនៅត្រូវបញ្ចប់ និងការដាក់ ពាក្យសុំចូលរៀនរបស់ខ្ញុំនៅមហាវិទ្យាល័យ និងគម្រោងឡូវ៉ែលចុងក្រោយរបស់ខ្ញុំ ។ ខ្ញុំសង្ឃឹមដើម្បីស្វែងរកឱកាសមួយធ្វើការស្ម័គ្រចិត្តដែល ខ្ញុំអាចដាក់នៅក្នុងពាក្យសុំរបស់ខ្ញុំសម្រាប់មហាវិទ្យាល័យ ហើយប្រើវានៅក្នុងគម្រោងឡូវ៉ែលរបស់ខ្ញុំផងដែរ ។ សំណាងល្អអ្នកណែនាំសម្រាប់កុម្រប្រឹក្សាសិស្សរបស់ខ្ញុំបានសុំឲ្យមិត្តរបស់ខ្ញុំជេស៊ីកា និងខ្ញុំរៀបចំកម្មវិធីរៃអង្គាសប្រដាប់ប្រដាក្មេងលេង ឬប្រាក់ដើម្បីឧបត្ថម្ភដល់អង្គការសប្បុរសធម៌មួយក្នុងមូលដ្ឋាន ។

ខ្ញុំបានផ្ដល់ការងារស្ទើរតែទាំងអស់ដល់គណៈកម្មការសម្រាប់គម្រោងនេះ ។ ខ្ញុំបានឲ្យពួកគេបង្កើតក្ដារប្រកាសព័ត៌មានដោយដាក់បង្ហាញពីរូបភាពទែម៉ូម៉ែត្រស្ទង់កំដៅដ៏ធំមួយដែលចង្អុលបង្ហាញពីចំនួនប្រដាប់ប្រដាក្មេងលេងដែលបានបរិច្ចាគ ។ យើងបានគិតថា ការណ៍នោះគឺល្អមគ្រប់គ្រាន់សម្រាប់ការផ្សាយពាណិជ្ជកម្ម ហើយយើងបានចំណាយពេលបាយថ្ងៃត្រង់ដើម្បីប្រមូលការបរិច្ចាគ ។ ប៉ុន្តែ សិស្សទាំងឡាយបានបរិច្ចាគប្រដាប់ប្រដាក្មេងលេងតិចតួច ហើយទែម៉ូម៉ែត្រស្ទង់កំដៅនៅតែមានកម្រិតទាប ។

គួរឲ្យចម្លែក អ្នកណែនាំរបស់យើងបានចាប់ផ្ដើមដាក់ប្រដាប់ប្រដាក្មេងលេងមួយចំនួនទៅម្ខាង ។ នៅពេលជេស៊ីកា និងខ្ញុំបានសួរថាតើគាត់យកប្រដាប់ប្រដាក្មេងលេងទាំងនោះទៅធ្វើអ្វី គាត់បានប្រាប់យើងថា មានគ្រូបង្រៀនម្នាក់នៅឯសាលា ត្រូវបានរកឃើញថ្មីៗនេះថា មានជំងឺមហារីក ។ បន្ទាប់ពីមានការលំបាកនៅក្នុងការបង្រៀន ខណៈពេលដែលទទួលការព្យាបាល នោះគាត់បានសម្រេចចិត្តដាក់ពាក្យសុំច្បាប់សម្រាកពីការងារ ។ នៅពេលថ្ងៃបុណ្យខិតចូលមកដល់ ហើយមានវិក្កយបត្រថ្លៃពេទ្យច្រើន នោះគ្រួសាររបស់គាត់ពុំមានបុណ្យគ្រីស្ទម៉ាស់មួយដ៏រីករាយឡើយ ។ អ្នកណែនាំរបស់យើងបានឲ្យយោបល់ថា យើងខ្ចប់របស់ដែលបានយកចេញនោះជាអំណោយសម្រាប់ពួកគេ ។

ខ្ញុំមានចិត្តរំភើបខ្លាំងណាស់ ។ ខ្ញុំធ្លាប់តែស្វែរកគម្រោងសម្រាប់ការបម្រើរបស់ខ្ញុំសម្រាប់ជាប្រយោជន៍ដល់ខ្លួនឯង តែពុំមែនមនុស្សដទៃនោះទេ ។ ខ្ញុំបានសម្រេចចិត្តដើម្បីបង្កើន គោលដៅរបស់យើងយ៉ាងឆាប់រហ័ស សម្រាប់ការបរិច្ចាគប្រដាប់ប្រដាក្មេងលេង ហើយដើម្បីចាប់ផ្ដើមរៃអង្គាសប្រាក់សម្រាប់គ្រូបង្រៀននោះ និងគ្រួសាររបស់គាត់ ។

ជេស៊ីកា និងខ្ញុំបានទៅតាមថ្នាក់រៀន ហើយផ្សព្វផ្សាយពីគោលបំណងរបស់យើង ។ ការឆ្លើយតបគឺមានទំហំធំធេងណាស់ ។ គ្រូបង្រៀន បុគ្គលិក និងសិស្សទាំងឡាយបានផ្ដល់ជាប្រដាប់ប្រដាក្មេងលេង និងប្រាក់ដើម្បីជួយដល់គ្រួសារនោះ ។ មិនយូរប៉ុន្មានយើងបានសម្រេចគោលដៅរបស់យើងដែលធ្វើឲ្យភ្ញាក់ផ្អើលដល់អង្គការមនុស្សធម៌នោះ ។ យើងក៏បានប្រមូលប្រាក់ច្រើនជាង 1,000 ដុល្លារ សម្រាប់គ្រួសារនោះ ។

នៅពេលយើងខ្ចប់អំណោយដែលយើងបានប្រមូល និងទិញដោយប្រុងប្រយ័ត្ន នោះខ្ញុំបានដឹងថាទីបន្ទាល់នៃការបម្រើដែលខ្ញុំបានទទួលគឺវាមានភាពអស្ចារ្យស្មើនឹងអំណាយដែលយើងបានផ្ដល់ទៅនោះដែរ ។ ខ្ញុំមិនអាចប្រាប់ពីចិត្តរំភើបដែលខ្ញុំមាន នៅពេលយើងលួចមើលគ្រួសារនោះបាន ឃើញអំណោយដែលយើងដាក់នៅរានហាលរបស់ពួកគេដោយមិនបាន ចេញឈ្មោះឡើយ ។

ពីរបីខែក្រោយមក ជេស៊ីកា និងខ្ញុំត្រូវបានសុំឲ្យបង្រៀនថ្នាក់សិក្ខាសាលាមួយពីគម្រោងបម្រើ ។ យើងបានពន្យល់ពីអ្វីដែលយើងបានធ្វើដោយមិនបានប្រាប់ឈ្មោះរបស់គ្រូបង្រៀននោះ ។ មានក្មេងស្រីម្នាក់បានលើកដៃ ហើយក្រោកឈរ ។ នាងបានស្រក់ទឹកភ្នែកនៅពេលនាងនិយាយ ។ គ្រូបង្រៀននោះគឺជាពូរបស់នាង ហើយនាងបានរៀបរាប់ថាការបម្រើរបស់យើងមានន័យខ្លាំងណាស់ចំពោះគាត់ ។ នាងបាននិយាយថា វាគឺជាចម្លើយចំពោះការអធិស្ឋានរបស់គាត់ ។

វាគឺជាសេចក្ដីអំណរខ្លាំងណាស់ដែលរដូវបុណ្យនោះបានធ្វើឲ្យយើងបានជួបជុំគ្នានៅក្នុងការបម្រើ យ៉ាងអស់ពីដួងចិត្ត ហើយដឹងថាយើងបានធ្វើរឿងមួយដែលខុសប្លែកពីមុន ។ ■

លីនស៊ី លីវិត ណេវ៉ាដា ស.រ.អា.



**នៅ**ពេលយើងខ្ចប់អំណោយនោះ ខ្ញុំបានដឹងថាទីបន្ទាល់នៃការបម្រើដែល ខ្ញុំបានទទួលគឺវាមានភាពអស្ចារ្យស្មើនឹងអំណាយដែលយើងបានផ្ដល់ទៅនោះដែរ ។

# ខ្ញុំអាចធ្វើកិច្ចការនេះបាន !

វាជាពេលល្ងាចនារដូវបុណ្យគ្រីស្ទម៉ាស់ ហើយមានព្រិលដ៏ក្រាស់នៅលើដី ។ អស់រយៈពេលជាច្រើនខែដែលដៃគូខ្ញុំ និងខ្ញុំស៊ូទ្រាំនឹងអាកាសធាតុត្រជាក់នៃប្រទេសអាល្លឺម៉ង់ ដើរគោះទ្វារ ហើយចែកព្រះគម្ពីរមរមន ។ នៅពេលនោះ សូម្បីតែសង្គ្រាមលោកលើកទី II បានបញ្ចប់ទៅរយៈពេល 15 ឆ្នាំហើយក្ដី ក៏ប្រជាជនអាល្លឺម៉ង់ជាច្រើននៅតែមានការនឿយណាយចំពោះប្រជាជនអាមេរិកដដែល ។

ប៉ុន្តែនៅយប់នោះ អ៊ីងប៊ិគ ប៊ីនមុលឡឺ ត្រូវទទួលបុណ្យជ្រមុជទឹក ។ ប៉ុន្តែនៅពេលជិះរថយន្តក្រុងទៅមូលដ្ឋានកងអាកាសអាមេរិក គាត់បាននៅស្ងៀម ។ ខ្ញុំបានដឹងពីអារម្មណ៍សោកសៅរបស់គាត់ ។

នៅពេលយើងរៀបនឹងទៅដល់ចំណតរថយន្តក្រុង អ៊ីង្គប៊ិគ បានងាកមករកយើង ហើយនិយាយថា « តើអ្នកដឹងថារឿងនេះលំបាកចំពោះខ្ញុំប៉ុណ្ណាទេ ? ទ័ពវាយប្រឆាំងនឹងប្រទេសអាល្លឺម៉ង់បានសម្លាប់ស្វាមីខ្ញុំនៅក្នុងសង្គ្រាម ហើយការទម្លាក់គ្រាប់បែកតាមយន្តហោះបានសម្លាប់សមាជិកគ្រួសារផ្សេងទៀតជាច្រើន » ។

អ៊ីងប៊ិគ បានមករកយើង ហើយនិយាយថា « តើអ្នកដឹងថារឿងនេះលំបាកចំពោះខ្ញុំប៉ុណ្ណាទេ ? »

គាត់បានប៉ះជើងរបស់គាត់ ។ « គ្រាប់បែកបានផ្ទុះត្រូវជើងរបស់ខ្ញុំ ។ ជើងរបស់ខ្ញុំនឹងពុំជាសះស្បើយឡើយ ។ ខ្ញុំពុំដឹងថាខ្ញុំអាចចូលទៅទីនោះបានឬអត់នោះទេ » ។

យើងបានអង្គុយស្ងៀមស្ងាត់ ខណៈយើងកំពុងសញ្ជឹងគិតពីសម្ដីរបស់គាត់ ហើយរថយន្តក្រុងនោះក៏បានឈប់នៅត្រង់ចំណត ។ អ៊ីង្គប៊ិគ នៅអង្គុយថ្មឹង ។ បេះដូងរបស់ខ្ញុំបានលោតខុសចង្វាក់ ។ ខ្ញុំបានអធិស្ឋាន សូមកុំឲ្យគាត់គេចចេញដោយសេចក្ដីភ័យខ្លាចឡើយ ។

បន្ទាប់មក គាត់បានក្រោកពីកៅអី ហើយបានប្រកាសថា « ព្រះវរបិតាសួគ៌បានផ្ដល់ឲ្យខ្ញុំនូវទីបន្ទាល់មួយពីសេចក្ដីពិតពេញលេញនៃការស្ដារឡើងវិញ ។ ខ្ញុំដឹងថាព្រះគម្ពីរមរមនជាព្រះគម្ពីរពិត ។ ខ្ញុំអាចធ្វើកិច្ចការនេះបាន ! អែលឌើរ អាតគីន សូមជួយខ្ញុំឲ្យដើរផង » ។

យើងបានដើរយ៉ាងឆ្ងាយទៅកាន់របងច្រកចូល ការដកជង្ហើមរបស់អ៊ីងប៊ិគកាន់តែតឹងទៅៗនៅពេលយើងដើរកាត់ពួកសន្តិសុខ ។ យើងបានប្ដូរពាក់សំលៀកបំពាក់ពណ៌-ស ហើយបានរកឃើញអាងទឹកមួយនៅក្នុងមូលដ្ឋាននោះ ។ អាងទឹកនោះបានក្លាយជាទីកន្លែងមួយដ៏ពិសិដ្ឋ ហើយសេចក្ដីសុខសាន្តបានគ្របដណ្ដប់មកលើយើង ។ ភាពសោកសៅនៅលើផ្ទៃមុខរបស់អ៊ីងប៊ិគបានផ្លាស់ប្រែទៅជាសេចក្ដីអំណរ នៅពេលគាត់បានឈានជើងចូលទៅក្នុងទឹក ហើយទទួលបុណ្យជ្រមុជទឹកក្លាយជាសមាជិកនៃសាសនាចក្រ ។

នៅពេលយើងជិះរថយន្តត្រលប់មកផ្ទះវិញ គាត់បានប្រាប់យើងថា « នៅយប់ដែលពួកអែលឌើរបានទុកព្រះគម្ពីរមរមនមួយក្បាលនៅនឹងខ្ញុំ ខ្ញុំមានចិត្តរំភើបណាស់ » ។ « ខ្ញុំបាននៅអានរហូតខ្ញុំអានដល់ម៉ូសាយ 18 នៅត្រង់កន្លែងដែលអាល់ម៉ាបានអញ្ជើញប្រជាជនឲ្យទទួលបុណ្យជ្រមុជទឹកថា ៖ ‹ មើលចុះ នេះជាទឹកមរមន . . . ហើយឥឡូវនេះ ដោយអ្នករាល់គ្នាមានបំណងចង់ចូលរួមក្នុងក្រោលនៃព្រះ ហើយដើម្បីឲ្យបានហៅថាជារាស្ត្ររបស់ទ្រង់ . . . តើមានអ្វីទៅដែលរារាំងអ្នកមិនឲ្យទទួលបុណ្យជ្រមុជទឹក ? ›» ម៉ូសាយ 18:8–10 ។

គាត់បានបន្តដោយសម្ដីទន់ភ្លន់ថា « ខ្ញុំបានដេកលក់ពេលកំពុងអាននូវបន្ទូលទាំងនោះ ហើយខ្ញុំបានមានសុបិនមួយ ។ ខ្ញុំបានឈរនៅក្បែរទន្លេមួយដ៏ស្រស់ស្អាតដូចជាទន្លេមរមនដែរ ។ នៅត្រើយម្ខាងទៀតនៃទន្លេនោះ មានមនុស្សឈរស្លៀកពាក់ពណ៌-ស—ជាគ្រួសាររបស់ខ្ញុំ ! ស្វាមីរបស់ខ្ញុំ ដែលត្រូវបានគេសម្លាប់នៅក្នុងសង្គ្រាម បានញញឹម ហើយបានបក់ដៃហៅខ្ញុំឲ្យទទួលបុណ្យជ្រមុជទឹក » ។

នៅយប់នោះបងស្រីប៊ីនមុលឡឺ បានក្លាយជាសមាជិកនៃសាខាវីស្បប៊ីគ ហើយជាមនុស្សម្នាក់នៅក្នុងចំណោមប្រជាជនអាល្លឺម៉ង់ជាច្រើន ដែលនៅទីបំផុតបានយកឈ្នះលើការភ័យខ្លាចរបស់ខ្លួន ហើយចូលរួមក្នុងសាសនាចក្រ ។ ■

រ៉យ អាតគីន រដ្ឋ កាលីហ្វ័រញ៉ា ស.រ.អា.





# យើងមកយកអំណោយរបស់យើង

នៅពេលខ្ញុំជាសមាជិកនៃគណៈប្រធានមណ្ឌលរបស់យើង ខ្ញុំបានជួយសម្របសម្រួលសកម្មភាព មួយដែលសមាជិកក្នុងមណ្ឌលរបស់យើងបានបរិច្ចាគប្រដាប់ប្រដាក្មេងលេង ដល់កុមារដែលនៅរស់ក្នុងទីក្រុង សៅចា ប្រទេស កូឡុំប៊ី ។ យើងមានការឆ្លើយតបមួយយ៉ាងអស្ចារ្យ ពីសំណាក់សមាជិកគ្រប់រូប ។ រាល់អំណោយទាំងនោះពុំមែនសុទ្ធតែថ្មីនោះទេ ប៉ុន្តែភាគច្រើននៅល្អ ។

នៅពេលបានទុកដាក់អំណោយរួចហើយនៅក្នុងរថយន្តក្រុងដែលនឹងដឹកយើងទៅកាន់ទីក្រុងនោះ នោះមានក្មេងស្រីតូចម្នាក់បានដើរមករកខ្ញុំដោយមានកាន់បាល់ដ៏ដែលមានស្នាមឆូតជាច្រើន ។ ខ្ញុំបានកាន់បាល់នោះក្នុងដៃ ដោយងឿងឆ្ងល់ថាតើនរណាគេទៅដែលបរិច្ចាគបាល់ដែលចាស់បែបនេះ ។ ដោយមាននូវសេចក្ដីមើលងាយ ខ្ញុំបានបោះវាចូលទៅក្រោមកៅអី ។

នៅពេលយើងទៅដល់ យុវវ័យរបស់យើងបានចាប់ផ្ដើមច្រៀងទំនុកតម្កើងសម្រាប់បុណ្យគ្រីស្ទម៉ាស់ ។ តន្ត្រី ជាមួយនឹងម្ហូបគ្រីស្ទម៉ាស់របស់ពួកគេបានទាក់ទាញដល់កុមារមួយក្រុមធំ ។ នៅពេលយើងចាប់ផ្ដើមដាក់ព្យួរអំណោយ កុមារទាំងនោះបានហៅកុមារដទៃទៀតឲ្យមក ។ រំពេចនោះយើងបានចែកអំណោយរបស់យើងទាំងអស់ ។

នៅពេលយើងរៀបនឹងចេញដំណើរ ខ្ញុំបានឃើញក្មេងប្រុសម្នាក់អាយុប្រហែលជាប្រាំបីឆ្នាំបានរត់មករកយើង ដោយកាន់ដៃប្អូនប្រុសរបស់ខ្លួន ។ នៅពេលពួកគេបានមកដល់ ក្មេងប្រុសច្បងបាននិយាយថា « យើងមកយកអំណោយរបស់យើង » ។ ចិត្តបរិសុទ្ធរបស់គាត់បានធ្វើឲ្យខ្ញុំគ្មានពាក្យនឹងនិយាយ ហើយបានដក់ក្នុងដួងចិត្តរបស់ខ្ញុំ ។



ខ្ញុំបានសង្ឃឹមក្នុងចិត្តថា ខ្ញុំនឹងមានបំណងចង់ផ្ដល់ជាពរដល់មនុស្សដទៃទៀតដូចជាក្មេងប្រុសច្បងម្នាក់នោះ មានបំណងចង់ប្រទានពរដល់ប្អូនប្រុសរបស់គាត់ផងដែរ ។

ខ្ញុំបានពន្យល់គាត់ថា អំណោយអស់ហើយ ។ គាត់បានឆ្លើយថា « វាមិនថ្វីទេបើគ្មានអំណោយរបស់ខ្ញុំ ប៉ុន្តែរបស់ប្អូនប្រុសខ្ញុំត្រូវតែមាន » ។

បន្ទាប់មកខ្ញុំបាននឹកឃើញពីបាល់ដែលខ្ញុំបានបោះចូលទៅក្រោមកៅអី ។ ខ្ញុំបានប្រាប់ក្មេងប្រុសនោះថាខ្ញុំនៅសល់អំណោយមួយទៀតប៉ុន្តែវាចាស់បន្តិចហើយ ។

គាត់បាននិយាយថា « មិនថ្វីទេ ទោះជាអ្វីក៏ដោយ » ។ « មួយនោះហើយ » ។

ខ្ញុំបានឡើងទៅលើរថយន្តក្រុងទៅរកឃើញបាល់នោះ ។ នៅពេលខ្ញុំបានឲ្យវាទៅក្មេងប្រុសតូចនោះ គាត់មានសេចក្ដីអំណរយ៉ាងខ្លាំង ។ ដោយលោតទាំងអំណរគុណ គាត់បាននិយាយថា « បាល់ ! នោះជាអំណោយដែលខ្ញុំបានសុំព្រះឱរសព្រះគ្រីស្ទឲ្យមកខ្ញុំ » ។ គាត់បានបន្តរាំដោយរីករាយ នៅពេលគាត់ និងបងប្រុសរបស់គាត់ដើរចេញទៅជាមួយនឹងអំណោយដ៏មានតម្លៃរបស់ពួកគេ ។

ខ្ញុំបានឈរស្ងៀមនៅទីនោះ ហើយសម្រក់ទឹកភ្នែក នៅពេលអារម្មណ៍ដ៏កក់ក្ដៅមួយនៃសេចក្ដីសុខសាន្ត និងការដឹងគុណបានកើតមានចំពោះខ្ញុំ ។ ការខ្វល់ខ្វាយ និងការមើលថែដ៏សប្បុរសដែលក្មេងប្រុសម្នាក់នោះបានផ្ដល់ឲ្យប្អូនប្រុសរបស់គាត់បានដក់ក្នុងចិត្តខ្ញុំ ហើយខ្ញុំបានសង្ឃឹមក្នុងចិត្តថា ខ្ញុំនឹងមានបំណងចង់ប្រទានពរដល់មនុស្សដទៃទៀតដូចជាក្មេងប្រុសច្បងម្នាក់នោះមានបំណងចង់ផ្ដល់ជាពរដល់ប្អូនប្រុសរបស់គាត់ផងដែរ ។

នៅពេលក្មេងប្រុសទាំងពីរនាក់នោះបានដើរចេញទៅទាំងរីករាយ ខ្ញុំបាននឹកឃើញពីសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះចំពោះយើង ។ ទ្រង់មិនភ្លេចសូម្បីតែក្មេងប្រុសតូចម្នាក់រស់នៅតាមជួរភ្នំដែលបានសុំបាល់សាមញ្ញមួយសម្រាប់បុណ្យគ្រីស្ទម៉ាស់នោះឡើយ ។ ■

វ៉លធើរ អេមីលីយ៉ូ ប៉ូសាដា រ៉ូឌ្រីហ្គេស្ស កូឡុំប៊ី



**ដោយ អែលឌើរ រ៉ូប៊ើត ឌី ហែល**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# សេចក្ដីសន្យានៃបុណ្យគ្រីស្ទម៉ាស

*សូមឲ្យយើងយកពេលវេលាក្នុងរដូវបុណ្យគ្រីស្ទម៉ាស ដើម្បីរំឭកឡើងវិញនូវសេចក្ដីសញ្ញារបស់យើងក្នុងការដើរតាមព្រះអង្គសង្គ្រោះ និងដើម្បីធ្វើតាមព្រះហឫទ័យរបស់ទ្រង់ ដូចដែលទ្រង់បានធ្វើតាមព្រះហឫទ័យរបស់ព្រះវរបិតាសួគ៌នៃយើងដែរ ។*

យើងមិនអាចយល់បានទាំងស្រុងនូវអត្ថន័យនៃបុណ្យគ្រីស្ទម៉ាសឡើយ ដរាបណាយើងយល់ពីអត្ថន័យនៃឆាកជីវិតរបស់ព្រះអង្គសង្គ្រោះ ដង្វាយធួន និងការរស់ឡើងវិញសិន ។

ខ្ញុំមិនអាចគិតពីការប្រសូតនៃព្រះអង្គសង្គ្រោះ ដោយពុំគិតពីព្រះបន្ទូលរបស់ទ្រង់ទៅកាន់លោកពីឡាត់ថា ៖ « ខ្ញុំបានកើតមក ហើយក៏ចូលក្នុងលោកិយនេះសម្រាប់តែការណ៍នេះឯង ដើម្បីឲ្យខ្ញុំបានធ្វើបន្ទាល់ពីសេចក្ដីពិត ។ អស់អ្នកណាដែលកើតពីសេចក្ដីពិត នោះក៏ឮសំឡេងខ្ញុំ » ( យ៉ូហាន 18:37 ) ។

នៅពេលយើងចាប់ផ្ដើមរដូវបុណ្យគ្រីស្ទម៉ាស សូមឲ្យយើងពិចារណាសេចក្ដីព្យាករណ៍នៅក្នុងព្រះគម្ពីរពីព្រះអង្គសង្គ្រោះ ។ សេចក្ដីព្យាករណ៍ទាំងនោះពុំមែនគ្រាន់តែជាសេចក្ដីថ្លែងចម្លែកនៃភាពចៃដន្យនោះទេ ប៉ុន្តែវាជាសេចក្ដីថ្លែងដ៏អស្ចារ្យនៃគោលបំណង និងសេចក្ដីសន្យាពីឆាកជីវិត និងបេសកកម្មរបស់ទ្រង់ ហើយនិងអ្វីដែលទ្រង់មានព្រះបំណងប្រទានឲ្យយើងម្នាក់ៗ ។

### សេចក្ដីព្យាករណ៍នៃការយាងមករបស់ទ្រង់

ការយាងមករបស់ព្រះគ្រីស្ទត្រូវបានព្យាកររាប់ពាន់ឆ្នាំមុន ។ ប្រមាណជា 2,000 ឆ្នាំពីមុនការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ អ័ប្រាហាំបានបង្រៀនពីតួនាទីរបស់ទ្រង់នៅក្នុងផែនការនៃសេចក្ដីសង្គ្រោះ ។ ប្រមាណជា 1,400 ឆ្នាំមុនការប្រសូតរបស់ទ្រង់ ម៉ូសេបានបង្រៀនពីសេចក្ដីពិតដ៏អស្ចារ្យដូចគ្នានេះ ។ ប្រមាណជា 700 ឆ្នាំមុនការប្រសូតរបស់ទ្រង់ អេសាយបានបើកសម្ដែងនូវស្ថានភាពនៃការប្រសូត ឆាកជីវិត និងការសុគតរបស់ទ្រង់ថា ៖

« ព្រះអម្ចាស់ទ្រង់នឹងប្រទានទីសម្គាល់មួយមកអ្នករាល់គ្នាដោយព្រះអង្គទ្រង់ មើលនាងព្រហ្មចារីនឹងមានគត៌ប្រសូតបានបុត្រាមួយ ហើយនិងឲ្យព្រះនាមថា អេម៉ាញូអែល » ( អេសាយ 7:14 ) ។



ត្បិតមានបុត្រមួយកើតដល់យើង ព្រះទ្រង់ប្រទានបុត្រាមួយមកយើងហើយ ឯការគ្រប់គ្រងនឹងនៅស្មារបស់បុត្រនោះ ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ប្រសើរអស្ចារ្យ ព្រះដ៏ជួយគំនិត ព្រះដ៏មានព្រះចេស្ដា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព » ( អេសាយ 9:6 ) ។

« ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់ពីសេចក្ដីឈឺចាប់ ។ . . .

« ទ្រង់បានទ្រាំទ្រងអស់ទាំងសេចក្ដីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្ដីទុក្ខព្រួយរបស់យើងជាពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា ។

« តែទ្រង់ត្រូវរបួសដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំដោយព្រោះអំពើទុច្ចរិតរបស់យើង . . . ហើយយើងរាល់គ្នាបានប្រោសឲ្យជាដោយសារស្នាមរំពាត់នៅអង្គទ្រង់ ។ . . .

« ទ្រង់ . . . គឺដូចជាកូនចៀមដែលគេដឹកទៅសម្លាប់ ហើយដូចជាចៀមដែលគេនៅចំពោះពួកអ្នកកាត់រោមយ៉ាងណា ទ្រង់ក៏មិនបានហើបព្រះឱស្ឋសោះយ៉ាងនោះដែរ ។

« ទ្រង់ត្រូវដកចេញពីអំណាចការពារ ហើយពីសេចក្ដីយុត្តិធម៌ ។ . . .

« ហើយក្នុងកាលដែលទ្រង់សុគត នោះគេក៏បញ្ចុះសពទ្រង់នៅជាមួយនឹងពួកអាក្រក់ ហើយនៅក្នុងផ្នូររបស់អ្នកមានម្នាក់ ទោះបើទ្រង់មិនដែលធ្វើអំពើទុច្ចរិតណាមួយក៏ដោយ ក៏មិនដែលមានការបញ្ឆោតនៅក្នុងព្រះឱស្ឋទ្រង់ឡើយផង » ( អេសាយ 53:3–5, 7–9 ) ។

មិនយូរប៉ុន្មានបន្ទាប់ពីសេចក្ដីព្យាករណ៍របស់អេសាយ ព្យាការីលីហៃមានសុបិនមួយដ៏អស្ចារ្យ ហើយបានបង្រៀនដល់គ្រួសាររបស់គាត់ពីអ្វីដែលគាត់បានរៀន ។ នីហ្វៃបានកត់ត្រាថា ៖ « ប្រាំមួយរយឆ្នាំចាប់តាំងពីពេលដែលឪពុកខ្ញុំចាកចេញពីក្រុងយេរូសាឡិមមក នោះនឹងមានព្យាការីម្នាក់ដែលព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងលើកឡើងនៅក្នុងចំណោមពួកសាសន៍យូដា—គឺព្រះមែស៊ីឬពាក្យម្យ៉ាងទៀតថា ព្រះអង្គសង្គ្រោះនៃពិភពលោក » ( នីហ្វៃទី 1 10:4 ) ។

លីហៃក៏បាននិយាយពីពួកព្យាការីដ៏ច្រើន ដែលបានថ្លែងទីបន្ទាល់ស្ដីពីការយាងមកនៃព្រះអង្គប្រោសលោះនៃពិភពលោកផងដែរ ( សូមមើល នីហ្វៃទី 1 10:5 ) ។

**សេចក្ដីសន្យានៃបុណ្យគ្រីស្ទម៉ាស**

ដំណឹងល្អនៃលូកាកត់ត្រាថា ពីមុនការប្រសូតរបស់ព្រះអង្គសង្គ្រោះ មាតារបស់ទ្រង់បានធ្វើដំណើរយ៉ាងប្រញាប់ប្រញាល់ទៅលេងបងប្អូនជីដូនមួយរបស់ខ្លួនឈ្មោះអេលីសាបិត ។

« កាលអេលីសាបិតបានឮពាក្យម៉ារាជម្រាបសួរ នោះកូនក៏បម្រះនៅក្នុងផ្ទៃ រួចគាត់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ ៖

« ក៏បន្លឺសំឡេងយ៉ាងខ្លាំងថា ក្នុងបណ្ដាពួកស្រីៗ គឺនាងហើយ ជាស្ត្រីមានពរពិត ព្រមទាំងនៅក្នុងផ្ទៃនាងផង » ( លូកា 1:41–42 ) ។

នៅពេលព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់ទៅកាន់អេលីសាបិត នោះទ្រង់ថ្លែងទីបន្ទាល់មកកាន់យើងថា ពាក្យសម្ដីរបស់ពួកព្យាការីត្រូវបានបំពេញហើយ ។ ព្រះអង្គសង្គ្រោះបានយាងមក ហើយបានធ្វើកិច្ចការដែលព្រះវរបិតាទ្រង់បានបញ្ជូនទ្រង់ឲ្យមកធ្វើ ។

នីហ្វៃបានកត់ត្រាពីព្រះអង្គសង្គ្រោះថា ៖

« ហើយខ្ញុំក៏មើលហើយបានឃើញនាងព្រហ្មចារីម្ដងទៀតនាងកំពុងតែបីព្រះឱរសក្នុងដៃរបស់នាង ។

« ហើយទេវតាមានបន្ទូល មកខ្ញុំថា ៖ មើលន៍កូនចៀមនៃព្រះ មែនហើយ គឺជាព្រះរាជបុត្រានៃព្រះ វរបិតាដ៏នៅអស់កល្បជានិច្ច ! » ( នីហ្វៃទី 1 11:20–21 ) ។

នៅពេលព្រះអង្គសង្គ្រោះមានព្រះជន្ម 12 ព្រះវស្សា ទ្រង់បានបង្រៀននៅក្នុងព្រះវិហារបរិសុទ្ធ ។ ទ្រង់បានពន្យល់ទៅកាន់ឪពុកម្ដាយរបស់ទ្រង់ដែលកំពុងមានការព្រួយបារម្ភថា ទ្រង់បានទៅធ្វើកិច្ចការរបស់ព្រះវរបិតាទ្រង់ ( សូមមើល លូកា 2:42–49 ) ។

កិច្ចការនោះត្រូវបានសម្រេច នៅពេលទ្រង់ចេញទៅបំពេញបេសកកម្មនៅលើផែនដីរបស់ទ្រង់ ។ ព្រះអង្គសង្គ្រោះបានពិពណ៌នាពីលទ្ធផលនៃ



*ជារៀងរាល់សប្ដាហ៍ នៅពេលយើងចូលរួមនៅក្នុងពិធីបរិសុទ្ធនៃសាក្រាម៉ង់ យើងរំឭកចាំពីសេចក្ដីសន្យានៃការប្រសូតរបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់យើង ។*

បេសកកម្មនោះនៅក្នុងបន្ទូលដ៏ក្អកក្អួលទាំងនេះថា ៖

« យើងបានមកការក្រស្ដ្រយើង តែរាស្ដ្រយើងមិនបានទទួលយើងសោះ ។ ហើយបទគម្ពីរទាំងឡាយដែលស្ដីអំពីការយាងមករបស់យើង នោះត្រូវបានបំពេញហើយ ។

« ហើយអស់អ្នកណាដែលបានទទួលយើង អ្នកនោះហើយដែលយើងបានឲ្យក្លាយទៅជាកូនព្រះ ហើយដូចគ្នានេះ យើងក៏នឹងឲ្យដល់អស់អ្នកណាដែលនឹងជឿដល់នាមរបស់យើង ត្បិតមើលចុះ ដោយសារយើង ទើបមានសេចក្ដីប្រោសលោះកើតឡើង ហើយនៅក្នុងយើង នោះក្រឹត្យវិន័យលោកម៉ូសេត្រូវបានបំពេញ » ( នីហ្វៃទី 3 9:16–17 ) ។

សេចក្ដីសន្យារបស់ទ្រង់ថាយើងអាចក្លាយជាបុត្រាបុត្រីរបស់ទ្រង់នឹងត្រូវបានយល់ដឹង នៅពេលយើងជឿលើទ្រង់ ហើយអនុវត្តសេចក្ដីជំនឿលើទ្រង់ដោយការគោរពប្រតិបត្តិ ។ បន្ទាប់មក យើងនឹងបានរៀបចំខ្លួន ដើម្បីទទួលអំណោយទាននៃជីវិតដ៏នៅអស់កល្បជានិច្ច ។

ទ្រង់បានមានបន្ទូលថា ៖ « មើលចុះ យើងគឺជាតួអង្គដែលត្រូវបានរៀបចំទុកចាប់តាំងពីកំណើតលោកិយមក ដើម្បីប្រោសលោះរាស្ដ្រយើង ។ មើលចុះ យើងជាព្រះយេស៊ូវគ្រីស្ទ ។ . . . ដោយសារខ្ញុំ នោះមនុស្សលោកទាំងអស់នឹងមានជីវិត ឯជីវិតនោះគឺនៅអស់កល្បជានិច្ច គឺពួកអ្នកដែលនឹងជឿដល់នាមយើង ហើយពួកគេនឹងក្លាយទៅជាកូនប្រុស និងកូនស្រីរបស់យើង » ( អេធើរ 3:14 ) ។

### អត្ថន័យនៃបុណ្យគ្រីស្ទម៉ាស

បុណ្យគ្រីស្ទម៉ាស់ គឺជាពេលមួយដើម្បីចែកចាយអំណោយរបស់យើង ពង្រឹងដល់មនុស្សដទៃ ហើយធ្វើផ្នែករបស់យើងនៅក្នុងនគររបស់ព្រះ ។ បុណ្យគ្រីស្ទម៉ាសក៏ជាពេលវេលាមួយដើម្បីសម្ដែងនូវសេចក្ដីស្រឡាញ់របស់យើងដល់មនុស្សដទៃ និងដើម្បីថ្លែងទីបន្ទាល់របស់យើងពីព្រះអង្គសង្គ្រោះ ។

វិធីមួយដែលយើងអាចចែកចាយទីបន្ទាល់របស់យើង គឺត្រូវមានប្រសូតិកម្មនៅក្នុងផ្ទះរបស់យើង ដើម្បីយើងអាចធ្វើឲ្យមានការសន្ទនាពីការប្រសូតរបស់ព្រះអម្ចាស់ ។ វិធីមួយទៀត គឺត្រូវលើកឡើងពីដំណើររឿងរបស់ យ៉ូហាន វ៉េតមែន នៅក្នុង *The Mansion* ( *វិមាន* ) ។

យ៉ូហាន វ៉េតមែន ជាបុរសដ៏ជោគជ័យម្នាក់ដែលបានទទួលការចាប់អារម្មណ៍ និងកេរ្ដិ៍ឈ្មោះដោយសារតែសេចក្ដីសប្បុរសរបស់គាត់ ។ នាយប់មួយ បន្ទាប់ពីមើលអត្ថបទដ៏ច្រើននៅក្នុងសារព័ត៌មានមួយ ដែលបានកោតសរសើរដល់ចំពោះចិត្តសប្បុរសរបស់គាត់មក គាត់ក៏ចាប់យកព្រះគម្ពីរប៊ីបរបស់គាត់ ។ មិនយូរប៉ុន្មានគាត់ក៏បានសម្រាន្ដលក់ទៅ ក្រោយពីអានបន្ទូលរបស់ព្រះអង្គសង្គ្រោះថា ៖ « កុំឲ្យប្រមូលទ្រព្យសម្បត្តិទុកសម្រាប់ខ្លួននៅផែនដីជាកន្លែងដែលមានកន្លាត និងច្រែះស៊ីបំផ្លាញ ហើយចោរទម្លុះប្លន់នោះឡើយ » ( ម៉ាថាយ 6:19 ) ។

នៅពេលគាត់សម្រាន្ដលក់ យ៉ូហាន បានរកឃើញថាខ្លួនគាត់នៅក្នុង « ទីក្រុងសួគ៌ា » ដោយធ្វើដំណើរជាមួយនឹងមនុស្សដទៃទៀត នៅពេលពួកគេបានទទួលវិមានរបស់ខ្លួន ។ នៅពេលអ្នកយាមទ្វារបានឈប់នៅមុខខ្ទមតូចមួយដែលសង់ឡើងពីសម្ភារដែលគេបោះចោល នោះគាត់បាននិយាយទៅកាន់ ចន ថា « នេះជាវិមានរបស់អ្នក » ។

យ៉ូហាន បានតវ៉ា ដោយរៀបរាប់ពីការបរិច្ចាគជាសាធារណៈជាច្រើនដែលគាត់បានធ្វើ ។

« តើរឿងទាំងអស់នេះមិនត្រូវបានកត់ត្រាដោយប្រុងប្រយ័ត្ននៅលើផែនដី ជាទីកន្លែងដែលអ្នកបានទទួលកេរ្ដិ៍របស់អ្នកទេឬអី ? » អ្នកយាមទ្វារបានសួរ ។ « អ្នកបានទទួលរង្វាន់ពីកិច្ចការនោះហើយ ។ តើអ្នកគិតថាអ្នកគួរទទួលបានរង្វាន់ទ្វេរជាពីរឬ ? »[1]

អំឡុងពេលបុណ្យគ្រីស្ទម៉ាស់នេះ ខ្ញុំសង្ឃឹមថាយើងម្នាក់ៗមានឱកាសដើម្បីផ្ដល់ឲ្យដោយមិនចេញមុខ ។

### ការទទួលសេចក្ដីសន្យា

ជារៀងរាល់សប្ដាហ៍ នៅពេលយើងចូលរួមនៅក្នុងពិធីបរិសុទ្ធនៃសាក្រាម៉ង់ យើងរំឭកចាំពីសេចក្ដីសន្យានៃការប្រសូតរបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់យើង ។ យើងលើកដាក់ព្រះនាមរបស់ទ្រង់មកលើខ្លួនយើង ហើយយើងរំឭកចាំ ពីសេចក្ដីសន្យារបស់យើងពីការគោរពប្រតិបត្តិ និងសេចក្ដីសន្យារបស់យើងថា យើងនឹងចងចាំទ្រង់ជានិច្ច ។

ដូចដែលបានកត់ត្រានៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញាណ ដំណឹងល្អគឺដូច្នេះ ៖

« ថាទ្រង់បានយាងមកក្នុងពិភពលោក គឺព្រះយេស៊ូវ ដើម្បីត្រូវគេឆ្កាងជំនួសពិភពលោក ហើយដើម្បីផ្ទុកអំពើបាបទាំងឡាយនៃពិភពលោក ហើយដើម្បីញែកពិភពលោកចេញជាបរិសុទ្ធ ហើយដើម្បីជំរះពិភពលោកឲ្យស្អាតចេញពីអំពើដ៏ឥតសុចរិតទាំងអស់ ។

« ថាតាមរយៈព្រះអង្គ នោះមនុស្សទាំងអស់នឹងអាចបានសង្គ្រោះ » ( គ. និង ស. 76:41–42 ) ។

សូមឲ្យយើងយកពេលវេលាក្នុងរដូវបុណ្យគ្រីស្ទម៉ាស ដើម្បីរំឭកឡើងវិញនូវសេចក្ដីសញ្ញារបស់យើងក្នុងការដើរតាមព្រះអង្គសង្គ្រោះ និងដើម្បីធ្វើតាមព្រះហឫទ័យរបស់ទ្រង់ ដូចដែលទ្រង់បានធ្វើតាមព្រះហឫទ័យរបស់ព្រះវរបិតាសួគ៌នៃយើងដែរ ។ នៅពេលយើងធ្វើដូច្នេះ ពាក្យសម្ដីនៃរាស្ដ្ររបស់ស្ដេចបេនយ៉ាមីន ដែលបានកត់ត្រា 125 ឆ្នាំមុនការប្រសូតរបស់ព្រះអង្គសង្គ្រោះ នឹងត្រូវបានបំពេញចំពោះយើងនៅថ្ងៃនេះថា ៖ « ឱសូមមេត្តាផង ហើយសូមប្រទាននូវព្រះលោហិតដ៏ធួននៃព្រះគ្រីស្ទ ដើម្បីឲ្យយើងអាចបានទទួលនូវការអភ័យទោសចំពោះ អំពើបាបទាំងឡាយរបស់យើង ហើយដើម្បីឲ្យចិត្តយើងអាចបានជ្រះបរិសុទ្ធផងចុះ ព្រោះយើងជឿដល់ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះដែលបានបង្កើតផ្ទៃមេឃ និងផែនដី និងវត្ថុសព្វសារពើ ព្រះអង្គនឹងយាងចុះមកក្នុងចំណោមកូនចៅមនុស្ស » ( ម៉ូសាយ 4:2 ) ។

ខ្ញុំថ្លែងទីបន្ទាល់ថា ព្រះអង្គសង្គ្រោះបានយាងចុះមកក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត ហើយថានឹងយាងមកម្ដងទៀត ។ ខ្ញុំថ្លែងជាសាក្សីថា សាសនាចក្ររបស់ទ្រង់ ដែលបានស្ដារឡើងវិញនៅគ្រាកាន់កាប់ត្រួតត្រាចុង ក្រោយនេះពីមុនការយាងមកជាលើកទីពីររបស់ទ្រង់ គឺជា « ការណ៍មួយយ៉ាងអស្ចារ្យ ហើយចម្លែក » ( នីហ្វៃទី 2 25:17 ) ដែលយើងក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយកំពុងចូលរួមចំណែក ។ ■

**កំណត់ចំណាំ**

1. ហេនរី វ៉ាន់ ដៃក៍ « The Mansion » នៅក្នុង *Inspirational Classics for Latter-day Saints* និពន្ធដោយ ចាក អិម លីអូន ( ឆ្នាំ 2000 ) ទំព័រ 54–57, 62–63 ។



ដោយ អែលឌើរ
ជែហ្វ្រី អ័រ ហូឡិន
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# ការរៀបចំខ្លួនសម្រាប់ ការយាងមកជាលើកទីពីរ

*កាលពីបុរាណ បុរសស្ត្រីដ៏អស្ចារ្យជាច្រើនជំនាន់ បានខិតខំធ្វើតទៅទៀត បានខិតខំថ្លែងទីបន្ទាល់ បានខិតខំធ្វើអស់ពីលទ្ធភាពរបស់ខ្លួន ពុំមែនដោយសារពួកគេបានដឹងថា ពួកគេនឹងទទួលបានជោគជ័យនោះទេ ប៉ុន្តែដោយសារពួកគេបានដឹងថា អ្នកនឹងទទួលបានជោគជ័យ ។*

**យើង** កំពុងបង្ហាញខ្លួនយើងនៅគ្រានៃជីវិតរមែងស្លាប់ ក្នុងគ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អដ៏អស្ចារ្យជាងគេបំផុតនៃដំណឹងល្អដែលបានប្រទានមកដល់មនុស្សលោក ហើយយើងត្រូវឱបក្រសោបវាយ៉ាងជិតស្និទ្ធបំផុត ។

ខ្ញុំស្រឡាញ់នូវឃ្លាមួយដែលព្យាការី យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា ពួកព្យាការី ពួកសង្ឃ និងពួកស្ដេចកាលពីជំនាន់មុន « បានទន្ទឹងរង់ចាំដោយសេចក្ដីសង្ឃឹមដ៏រីករាយចំពោះសម័យដែលយើងរស់នៅ ហើយបានរីករាយដោយសេចក្ដីសង្ឃឹមពីសួគ៌ាដោយអំណររហូតដល់ពួកគេបានច្រៀង ហើយសរសេរ ព្រមទាំងបានព្យាករណ៍ពីជំនាន់របស់យើងនេះ » ។[1] ក៏មានការគូសបញ្ជាក់ស្រដៀងគ្នានេះផងដែរពីប្រធាន វិលហ្វូឌ វូឌរ្រុព្វ ថា ៖ « ព្រះនេត្រនៃព្រះ និងពួកព្យាការីបរិសុទ្ធទាំងអស់កំពុងទតមើលមកយើង ។ នេះជាគ្រាកាន់កាប់ត្រួតត្រាដ៏អស្ចារ្យ ដែលបានពោលឡើងចាប់តាំងពីពិភពលោកបានចាប់ផ្ដើមមកម្ល៉េះ » ។[2]

ខ្ញុំមានទ្រឹស្ដីមួយពីគ្រាកាន់កាប់ត្រួតត្រា និងពួកអ្នកដឹកនាំ ក្រុមគ្រួសារ និងប្រជាជនពីជំនាន់មុន ដែលបានរស់នៅនាពេលនោះ ។ ជារឿយៗ ខ្ញុំបានគិតពីពួកគាត់ និងពីកាលៈទេសៈបំផ្លិចបំផ្លាញដែលពួកគាត់បានជួបប្រទះ ។ ភាគច្រើន ពួកគេបានប្រឈមមុខនឹងគ្រាដ៏លំបាកដែលគួរឲ្យភ័យខ្លាច ពួកគាត់ពុំទទួលបានជោគជ័យនៅក្នុងគ្រាកាន់កាប់ត្រួតត្រារបស់ខ្លួនឡើយ ។ ពិតណាស់ ចំណុចសំខាន់នៃការស្ដារឡើងវិញនៃដំណឹងល្អនៅក្នុងថ្ងៃចុងក្រោយនេះគឺថា ដំណឹងល្អពុំអាចរស់រាននៅក្នុងជំនាន់មុនឡើយ ហេតុដូច្នេះហើយ ដំណឹងល្អត្រូវតែស្ថាបនាឡើងក្នុងជំនាន់ដ៏ជោគជ័យចុងក្រោយមួយ ។

**គ្រាកាន់កាប់ត្រួតត្រាដែលនឹងមិនបរាជ័យ**

និយាយឲ្យខ្លីទៅ ការក្បត់សាសនា និងការបំផ្លិចបំផ្លាញទាំងឡាយគឺជាជោគវាសនានៅចុងបំផុតនៃគ្រាកាន់កាប់ត្រួតត្រាទូទៅ ដែលយើងធ្លាប់ឃើញនៅគ្រប់ជំនាន់ ។ ប៉ុន្តែនេះជាទ្រឹស្ដីរបស់ខ្ញុំ ។ ទ្រឹស្ដីរបស់ខ្ញុំគឺថា បុរសស្ត្រីដ៏អស្ចារ្យទាំងនោះ ជាពួកអ្នកដឹកនាំនៅក្នុងជំនាន់មុន អាចមានលទ្ធភាពដើម្បីខិតខំបន្តទៅទៀត ខិតខំថ្លែងទីបន្ទាល់ ខិតខំព្យាយាមធ្វើអស់ពីលទ្ធភាពរបស់ខ្លួន ពុំមែនដោយសារពួកគាត់ដឹងថា *ពួកគាត់* នឹងទទួលបានជោគជ័យនោះទេ ប៉ុន្តែដោយសារពួកគាត់បានដឹងថា *អ្នក* នឹងទទួលបានជោគជ័យ ។ ខ្ញុំជឿថា ពួកគាត់មានចិត្ត ក្លាហាន និងសេចក្ដីសង្ឃឹម ពុំមែនចេញពីកាលៈទេសៈផ្ទាល់ខ្លួនរបស់ពួកគាត់ ដូចជាការសង្ឃឹមយ៉ាងច្រើនពីកាលៈទេសៈរបស់អ្នកនោះឡើយ—ជាក្រុមជំនុំមួយដ៏អស្ចារ្យនៃយុវវ័យដែលបានប្រមូលផ្ដុំគ្នារាប់ម៉ឺនរាប់សែននាក់ជុំវិញពិភពលោកនៅក្នុងកិច្ចខិតខំដ៏រឹងមាំមួយ ដើម្បីមើលឃើញដំណឹងល្អទទួលបាននូវភាពជោគជ័យ ។

ដោយលើកឡើងពីយើងទាំងអស់គ្នាដែលនឹងបានទទួលកំណត់ត្រារបស់គាត់នៅថ្ងៃចុងក្រោយ មានពេលមួយមរ៉ូណៃបាននិយាយថា ៖

« មើលចុះ ព្រះអម្ចាស់ទ្រង់បានបង្ហាញដល់ខ្ញុំនូវការណ៍ដ៏ធំ ហើយអស្ចារ្យទាំងឡាយអំពីអ្វីដែលត្រូវមកដល់នៅពេលយ៉ាងខ្លី នៅក្នុងថ្ងៃដែលការណ៍ទាំងនេះនឹងកើតឡើងនៅក្នុងចំណោមពួកអ្នក ។

« មើលចុះ ខ្ញុំនិយាយទៅកាន់អ្នករាល់គ្នា ហាក់បីដូចជា អ្នករាល់គ្នានៅទីនេះ ប៉ុន្តែអ្នករាល់គ្នាពុំនៅទីនេះទេ ។ ប៉ុន្តែ មើលចុះ ព្រះយេស៊ូវគ្រីស្ទទ្រង់បង្ហាញអ្នករាល់គ្នាដល់ខ្ញុំ ហើយខ្ញុំដឹងនូវអ្វីៗដែលអ្នករាល់គ្នាធ្វើ » ( មរមន 8:34–35 ) ។

*CHRIST IN A RED ROBE* ដោយ មីនើវ៉ា ធីឆើរ © IRI, ទទួលបានសិទ្ធិអនុញ្ញាតឲ្យប្រើប្រាស់; ផ្ទៃខាងក្រោយដោយ HEMERA/THINKSTOCK, ដោយ/ការរចនាពី ISTOCKPHOTO/THINKSTOCK



មិនថាតាមវិធីណានោះទេ ខ្ញុំគិតថា រាល់ពួកព្យាការីស្ទើរតែ*ទាំងអស់* និងពួកសាវកជំនាន់មុនបានមើលឃើញពីជំនាន់របស់យើង—ជាទិដ្ឋភាពមួយដែលផ្តល់ទៅឲ្យពួកគាត់ដើម្បីលើកទឹកចិត្តពួកគាត់នៅក្នុងជំនាន់ផ្ទាល់របស់ពួកគាត់ដែលមានជោគជ័យតិចតួច ។ បងប្អូនប្រុសទាំងនោះកាលពីជំនាន់មុនបានដឹងជាច្រើនអំពីយើង ។ ពួកព្យាការីដូចជា ម៉ូសេ នីហ្វៃ និងបងប្រុសយ៉ារេឌ បានឃើញពីថ្ងៃចុងក្រោយនៅក្នុងការនិមិត្តជាច្រើនដ៏អស្ចារ្យ ។ អ្វីមួយចំនួនដែលពួកគាត់បានឃើញគឺបានធ្វើឲ្យពួកគាត់មិនសូវពេញចិត្ត ប៉ុន្តែ ពិតណាស់ មនុស្សទាំងអស់ដែលរស់នៅពីជំនាន់មុនបានយល់ដឹងថានៅទីបំផុតនឹងមានគ្រាកាន់កាប់ត្រួតត្រាមួយដែលនឹងមិនបរាជ័យឡើយ ។

វាជាជំនាន់របស់យើងដែលធ្វើឲ្យពួកគាត់មានភាព « រីករាយពីសួគ៌ាដោយសេចក្តីអំណរ » គឺពុំមែនជាជំនាន់របស់ពួកគេនោះទេ ហើយវាបានធ្វើឲ្យពួកគាត់ច្រៀង ហើយព្យាករណ៍ពីជ័យជំនះ ។ និយាយរួមទៅ ជំនាន់របស់យើងគឺជាជំនាន់ឆ្ពោះទៅរកអ្វីដែលពួកព្យាការីបានសម្លឹងមើលតាំងពីដើមដំបូងមកម្ល៉េះ ហើយបងប្អូនប្រុសទាំងនោះពីជំនាន់មុនដែលនៅទីនោះនៅតែអបអរសាទរចំពោះយើង ! តាមរបៀបដ៏ពិតប្រាកដមួយ ឱកាសរបស់ពួកគាត់ដើម្បីគិតថាពួកគាត់ទទួលបានជោគជ័យយ៉ាងពេញលេញគឺអាស្រ័យទៅលើសេចក្តីស្មោះត្រង់ និងជ័យជំនះរបស់យើង ។ ខ្ញុំចូលចិត្តនូវគំនិតនៃការចូលទៅធ្វើចម្បាំងនាថ្ងៃចុងក្រោយដោយតំណាងឲ្យអាលម៉ា និងអ័ប៊ីណាដៃ និងអ្វីដែលពួកគាត់បានទទូចអង្វរ និងតំណាងឲ្យពេត្រុស និងប៉ុល និងការលះបង់ដែលពួកគាត់បានធ្វើ ។ ប្រសិនបើអ្នកគ្មានសេចក្តីត្រេកអរនៅក្នុងកិច្ចការបែបនេះនៅក្នុងដំណើររឿងនៃប្រវត្តិសាស្ត្រនោះទេ នោះអ្នកនឹងគ្មានសេចក្តីត្រេកអរឡើយ !

## ការរៀបចំសាសនាចក្ររបស់ព្រះគ្រីស្ទ សម្រាប់ការយាងមករបស់ទ្រង់

ខ្ញុំសូមបន្ថែមនូវកត្តាមួយទៀតទៅ នឹងទិដ្ឋភាពនៃគ្រាកាន់កាប់ត្រួតត្រានេះដែលខ្ញុំថាវាកើតឡើងដោយស្វ័យប្រវត្តិ ។ ដោយសារជំនាន់យើងគឺជាគ្រាកាន់កាប់ត្រួតត្រាចុងក្រោយ ហើយអស្ចារ្យជាងគេបំផុត ដោយសារគ្រប់កិច្ចការទាំងអស់នៅទីបំផុតនឹងត្រូវបានបញ្ចប់ ហើយបំពេញនៅក្នុងជំនាន់របស់យើង ដូច្នេះហើយ ទំនួលខុសត្រូវដ៏ពិសេស ហើយជាក់លាក់មួយបានធ្លាក់មកលើយើងរាល់គ្នាក្នុងសាសនាចក្រនាពេលឥឡូវនេះ ដែលវាពុំតាមរបៀបដូចគ្នានៅលើស្មានៃសមាជិកសាសនាចក្រកាលពីជំនាន់មុនឡើយ ។ មិនដូចជាសាសនាចក្រនៅជំនាន់អ័ប្រាហាំ ឬម៉ូសេ អេសាយ ឬអេសេគាល ឬសូម្បីតែនៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាថ្មីនៃយ៉ាកុប និងយ៉ូហាននោះទេ *យើងមានទំនួលខុសត្រូវមួយ*

> ***យើងមានទំនួលខុសត្រូវមួយ ដើម្បីរៀបចំសាសនាចក្រនៃកូនចៀមរបស់ព្រះ ដើម្បីទទួលកូនចៀមនៃព្រះ— ដោយផ្ទាល់នៅក្នុងសិរីល្អដ៏រុងរឿង នៅការគ្រងរាជ្យមួយពាន់ឆ្នាំរបស់ទ្រង់ ។***

*ដើម្បីរៀបចំសាសនាចក្រនៃកូនចៀមរបស់ព្រះ ដើម្បីទទួលកូនចៀមនៃព្រះ*—ដោយផ្ទាល់ នៅក្នុងសិរីល្អដ៏រុងរឿង នៅការគ្រងរាជ្យមួយពាន់ឆ្នាំរបស់ទ្រង់ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ និងស្តេចលើអស់ទាំងស្តេច ។ គ្មានគ្រាកាន់កាប់ត្រួតត្រាផ្សេងទៀតណាមួយពីមុនមក ដែលមាននូវកាតព្វកិច្ចនោះឡើយ ។

នៅក្នុងភាសាបទគម្ពីរ យើងជាមនុស្សដែលបានជ្រើសរើសនៅក្នុងអស់ទាំងប្រវត្តិសាស្ត្រ ដែលត្រូវរៀបចំកូនក្រមុំសម្រាប់ការមកដល់របស់កូនកំលោះ ហើយមានភាពសក្តិសមសម្រាប់ការអញ្ជើញមួយឲ្យចូលរួមទទួលទានអាហារក្នុងពិធីមង្គលការនោះ ( សូមមើលម៉ាថាយ 25:1–12, 22:2–14, គ. និង ស. 88:92, 96) ។ និយាយរួមទៅ—វាមិនស្ថិតនៅក្នុងជំនាន់របស់យើង ឬជំនាន់កូនចៅរបស់យើង ឬនៅពេលណានោះទេ—ទោះយ៉ាងណា យើងមានទំនួលខុសត្រូវជាសាសនាចក្រទាំងមូល និងជាសមាជិកសាសនាចក្រម្នាក់ៗ ដើម្បីមានភាពសក្តិសមអញ្ជើញព្រះគ្រីស្ទឲ្យមករកយើង មានភាពសក្តិសមដើម្បីឲ្យទ្រង់បានស្វាគមន៍ដល់យើង ហើយដើម្បីឲ្យទ្រង់បានទទួលយក ហើយឱបក្រសោបយើង ។ ជីវិតដែលយើងបង្ហាញដល់ទ្រង់នៅគ្រាដ៏ពិសិដ្ឋនោះ *ត្រូវតែ* មានភាពសក្តិសមចំពោះទ្រង់ !

## យើងត្រូវតែសក្តិសមចំពោះទ្រង់

ខ្ញុំពោរពេញដោយភាពភ្ញាក់ផ្អើល និងអារម្មណ៍ដ៏លើសលុបនៃកាតព្វកិច្ចដើម្បីរៀបចំជីវិតរបស់ខ្ញុំ ( និងដើម្បីជាវិសាលភាពដែលថាខ្ញុំអាចធ្វើបានដើម្បីជួយរៀបចំជីវិតនៃសមាជិកសាសនាចក្រ ) សម្រាប់ថ្ងៃដែលបានព្យាករណ៍ជាយូរមកហើយនោះ សម្រាប់ការផ្ទេរសិទ្ធិអំណាច សម្រាប់គ្រាដែលយើងនឹងធ្វើបទបង្ហាញមួយពីសាសនាចក្រទៅកាន់ទ្រង់ដែលគ្រប់គ្រងសាសនាចក្រនេះ ។

នៅពេលបុណ្យគ្រីស្ទម៉ាសចូលមកដល់ សមាជិកសាសនាចក្ររបស់ទ្រង់ត្រូវបង្ហាញ ហើយធ្វើឲ្យដូចជាសមាជិកសាសនាចក្ររបស់ទ្រង់ដែលគួរតែបង្ហាញ ហើយធ្វើ ប្រសិនបើយើងត្រូវបានទទួលយកចំពោះទ្រង់ ។ យើងត្រូវតែធ្វើកិច្ចការរបស់ទ្រង់ ហើយត្រូវតែរស់នៅតាមការបង្រៀនរបស់ទ្រង់ ។ ទ្រង់ត្រូវតែស្គាល់យើងយ៉ាងរហ័ស ហើយដោយងាយ ក្នុងនាមជាសិស្សរបស់ទ្រង់ដ៏ពិតប្រាកដនោះ ។ ដូចជា ប្រធាន ជេ រ៉ូប៊ីន ក្លាក ជុញ្ញ័រ ( 1871–1961 ) អតីតទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ មានគ្រាមួយ លោកបានណែនាំថា ៖ សេចក្តីជំនឿរបស់យើង *មិន* ត្រូវឲ្យមានការលំបាកដើម្បីស្គាល់ឡើយ ។[3]

ពិតណាស់ ប្រសិនបើស្ថិតនៅក្នុងគ្រាចុងក្រោយដ៏អស្ចារ្យនោះ យើងនិយាយថា យើងជាពួកអ្នកជឿនោះយើងត្រូវតែបង្ហាញឲ្យឃើញយ៉ាងពិតប្រាកដ ។ អ្នកគង្វាលស្គាល់ចៀមរបស់ទ្រង់ ហើយយើងត្រូវតែបានទទួលស្គាល់នៅក្នុងថ្ងៃដ៏អស្ចារ្យនោះ ក្នុងនាមជាពួកអ្នកដើរតាមរបស់ទ្រង់ទាំងសកម្មភាព និងពាក្យសម្តី ។

មិត្តវ័យក្មេងជាទីស្រឡាញ់របស់ខ្ញុំ នេះជាថ្ងៃ

រចនាដោយ អិមម៉ី ហ៊ែង, រចនាឡើងវិញដោយ ប្រែត្ត ឆាយអ័រ © IRI





***ខ្ញុំចូលចិត្តនូវគំនិតនៃការចូលទៅធ្វើចម្បាំងនាថ្ងៃចុងក្រោយដោយតំណាងឲ្យអាលម៉ា និងអ័មីឡោណៃ និងអ្វីដែលពួកគាត់បានទទួចអង្វរសុំ និងតំណាងឲ្យពេត្រុស និងប៉ុល និងការលះបង់ដែលពួកគាត់បានធ្វើ ។ ប្រសិនបើអ្នកគ្មានសេចក្ដីត្រេកអរនៅក្នុងកិច្ចការបែបនេះនៅក្នុងដំណើររឿងនៃប្រវត្តិសាស្ត្រនោះទេ នោះអ្នកនឹងគ្មានសេចក្ដីត្រេកអរឡើយ !***

ចុងក្រោយ ហើយអ្នករាល់គ្នា និងខ្ញុំត្រូវតែក្លាយខ្លួនជា *ពួកបរិសុទ្ធ* ថ្ងៃចុងក្រោយដ៏ឆ្នើមបំផុតតាមដែលយើងអាចធ្វើបាន ។ សូមផ្ដោតយកចិត្តទុកដាក់បន្ថែមទៀតទៅលើពាក្យថា *ពួកបរិសុទ្ធ* ។

តើរឿងទាំងនេះនឹងបញ្ចប់នៅពេលណា ? តើព្រះគ្រីស្ទនឹងបង្ហាញអង្គទ្រង់ជាសាធារណៈដោយភាពរុងរឿង និងសហស្សវត្សនឹងចាប់ផ្ដើមនៅពេលណា ? ខ្ញុំមិនដឹងនោះទេ ។ អ្វីដែលខ្ញុំដឹងគឺថា គ្រាដំបូងនៃព្រឹត្តិការណ៍នេះបានចាប់ផ្ដើមឡើងកាលពី 193 ឆ្នាំមុន ។ ខ្ញុំពិតជាដឹងថា ដោយសារតែលទ្ធផលនៃការនិមិត្តដំបូង និងអ្វីដែលបានកើតឡើងក្រោយពីនោះ យើងរស់នៅក្នុងគ្រាមួយនៃពរជ័យដែលពុំធ្លាប់មានពីមុនមក—ជាពរជ័យដែលបានប្រទានឲ្យយើងសម្រាប់គោលបំណងនៃការរស់នៅដោយស្មោះត្រង់ និងបរិសុទ្ធ ដើម្បីនៅពេលកូនកំលោះបានមកដល់ដោយភាពរុងរឿងនៅពេលចុងក្រោយ នោះទ្រង់អាចអញ្ជើញយើងឲ្យចូលទទួលទានអាហារក្នុងពិធីមង្គលការនោះដោយផ្ទាល់ ។

បងប្អូនប្រុសស្រីវ័យក្មេងជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំសូម បន្សល់ទុកជាមួយអ្នកនូវសេចក្ដីស្រឡាញ់ និងទីបន្ទាល់របស់ខ្ញុំថា ព្រះមិនគ្រាន់តែមានព្រះជន្មរស់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ស្រឡាញ់យើងផងដែរ ។ ទ្រង់ស្រឡាញ់ *អ្នករាល់គ្នា* ។ អ្វីគ្រប់យ៉ាងដែលទ្រង់ធ្វើគឺសម្រាប់សេចក្ដីល្អរបស់យើង ហើយការពារដល់យើង ។ នៅក្នុងពិភពលោកមាននូវអំពើអាក្រក់ និងសេចក្ដីសោកសៅ ប៉ុន្តែនៅក្នុងទ្រង់គឺគ្មានអំពើអាក្រក់ឬភាពអន្តរាយឡើយ ។ ទ្រង់គឺជាព្រះវរបិតារបស់យើង—ជាព្រះវរបិតាដ៏ល្អឥតខ្ចោះ—ហើយទ្រង់នឹងផ្ដល់ទីជម្រកឲ្យយើងដើម្បីបានរួចផុតពីព្យុះភ្លៀង ។

ពិតណាស់ កង្វល់តែមួយគត់ដែលខ្ញុំនឹងឲ្យយើងគិតគឺជាបញ្ហាផ្ទាល់ខ្លួនមួយ ៖ តើយើងអាចរស់នៅឲ្យបានពេញលេញ ហើយកាន់តែស្មោះត្រង់ដើម្បីឲ្យរាល់ពរជ័យនៃគ្រាកាន់កាប់ត្រួតត្រានេះអាចត្រូវបានបង្ហាញនៅលើយើងម្នាក់ៗ និងនៅលើជីវិតនៃជនទាំងឡាយណាដែលយើងបានជួបដោយរបៀបណា ?

« កុំខ្លាច ហ្វូងតូចអើយ ។ . . . ចូរមើលមកឯ [ ព្រះគ្រីស្ទ ] ដោយនូវគ្រប់ទាំងគំនិត ចូរកុំសង្ស័យ កុំខ្លាចឡើយ » ។ « អ្នករាល់គ្នាពុំទាន់យល់នៅឡើយទេអំពីព្រះពរដ៏ធំណាស់ហ្ន៎ដែលព្រះវរបិតា . . . រៀបចំសម្រាប់អ្នក » ( គ. និង ស. 6:34, 36, 78:17 ) ។

ខ្ញុំសូមបន្សល់ទុកពរជ័យរបស់ខ្ញុំ សេចក្ដីស្រឡាញ់របស់ខ្ញុំ និងសាក្សីជាសាវកពីសេចក្ដីពិតដ៏ពេញលេញនៃរឿងទាំងនេះ ថាគ្រាកាន់កាប់ត្រួតត្រារបស់យើងនឹងមិនបរាជ័យឡើយ ហើយថាអស់អ្នកដែលរស់នៅតាមការបង្រៀនរបស់ព្រះគ្រីស្ទ ហើយធ្វើកិច្ចការរបស់ទ្រង់នឹងមានភាពសក្ដិសមនៃការអញ្ជើញមួយឲ្យចូលទៅទទួលទានអាហារក្នុងពិធីមង្គលការនោះ នៅពេលកូនកំលោះយាងមក ។

*ដកស្រង់ចេញពីការប្រជុំពិសេសមួយនៃប្រព័ន្ធអប់រំសាសនាចក្រសម្រាប់ពួកមជ្ឈិមវ័យវ័យក្មេង « Terror, Triumph, and a Wedding Feast » ដែលធ្វើឡើងនៅថ្ងៃទី 12 ខែ កញ្ញា ឆ្នាំ 2004 ។ សម្រាប់អត្ថបទទាំងស្រុងជាភាសាអង់គ្លេស សូមចូលទៅកាន់ speeches.byu.edu ។*

**កំណត់ចំណាំ**

1. យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* 4:609–10 ។
2. វិលហ្វឹឌ វូឌ្រុព្វ នៅក្នុង *Messages of the First Presidency of The Church of Jesus Christ of Latter-day Saints* វ៉ុល 6 និពន្ធដោយ ជេមស៍ អ័រ ក្លាក ។ ( 1965–75 ), 3:258, សូមមើលផងដែរ ហ្គរដុន ប៊ី ហ៊ិងគ្លី « The Dawning of a Brighter Day » *Ensign* ខែ ឧសភា ឆ្នាំ 2004 ទំព័រ 83 ។
3. សូមមើល ជេ រ៉ូប៊ីន ក្លាក ជុញ្ញរ*The Charted Course of the Church in Education* ក.ស. ។ ក.ណ. ( ឆ្នាំ 1994 ) ទំព័រ 7 ។

# « តើខ្ញុំទប់ទល់នឹងការល្បួង ដោយរបៀបណា ? »

វាចម្លែកណាស់ដែលថាការល្បួងគឺជាការចាំបាច់សម្រាប់ការរីកលូតលាស់ខាងវិញ្ញាណរបស់យើង ។ ប្រសិនបើយើងមិនត្រូវបានល្បួងទេ នោះយើងនឹងមិនអាចជ្រើសរើសរវាងសេចក្ដីល្អ និងសេចក្ដីអាក្រក់បានឡើយ ( សូមមើល គ. និង ស. 29:39 ) ។ ហើយប្រសិនបើយើងមិនអាចជ្រើសរើសសេចក្ដីល្អនៅពេលបានផ្ដល់ឲ្យនូវជម្រើសផ្សេងទេ នោះយើងមិនអាចលូតលាស់ខាងវិញ្ញាណឡើយ ( សូមមើល នីហ្វៃទី 2 2:11–30 ) ។

គន្លឹះមួយដើម្បីទប់ទល់នឹងការល្បួងគឺជាការគោរពប្រតិបត្តិឲ្យបានទៀងទាត់ ។ នៅពេលខ្លះ ប្រសិនបើអ្នកចុះញ៉ម នោះការល្បួងគឺពិបាកនឹងទប់ទល់ជាងនៅពេលអនាគត ។ ប្រសិនបើអ្នកទប់ទល់ជាទៀងទាត់ នោះអ្នកកាន់តែរឹងមាំ ហើយងាយដើម្បីទប់ទល់នាពេលអនាគត ។ កម្លាំងទប់ទល់ដ៏ខ្លាំងកើតចេញពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះធ្វើការនៅក្នុងជីវិតរបស់អ្នក ។ នៅពេលអ្នកធ្វើឲ្យអស់ពីលទ្ធភាពរបស់អ្នកដើម្បីរៀនពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ហើយធ្វើតាមការបង្រៀនទាំងនោះ ព្រះអម្ចាស់ពង្រឹងអ្នកឲ្យទប់ទល់នឹងការល្បួង ។

ព្រះគម្ពីរបង្រៀនពីរបៀបផ្សេងទៀតដើម្បីទប់ទល់នឹងការល្បួង ៖

« ចូរអធិស្ឋានជានិច្ច ប្រយោជន៍ឲ្យអ្នកអាចក្លាយទៅជាអ្នកជំនះបានមែនហើយប្រយោជន៍ អ្នកអាចយកឈ្នះលើអារក្សសាតាំងបាន » ( គ. និង ស. 10:5 ) ។

« អស់អ្នកណាដែលប្រុងស្ដាប់តាមព្រះបន្ទូលនៃព្រះ ហើយតោងជាប់តាមព្រះបន្ទូលនៃព្រះ នោះនឹងមិនត្រូវវិនាសឡើយ សូម្បីតែការល្បួងទាំងឡាយ និងព្រួញភ្លើងទាំងឡាយរបស់មារសត្រូវក៏មិនអាចឈ្នះលើពួកគេដែរ » ( នីហ្វៃទី 1 15:24 ) ។

« តស៊ូនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ ។ ត្រូវចូលទៅជិតព្រះ នោះទ្រង់នឹងចូលមកជិតអ្នករាល់គ្នាដែរ » ( យ៉ាកុប 4:7–8 ) ។

វាក៏ជាការសំខាន់ផងដែរដើម្បីដឹងថា ការដែលត្រូវបានល្បួងពុំមែនជារឿងខុសឆ្គងនោះឡើយ ។ សូម្បីតែព្រះយេស៊ូវក៏ត្រូវបានល្បួងដែរ ។ « ទ្រង់បានរងទុក្ខសេចក្ដីល្បួងទាំងឡាយ ប៉ុន្តែមិនបានរវីរវល់ដល់សេចក្ដីទាំងនោះឡើយ » ( គ. និង ស. 20:22 ) ។ អ្នកអាចមើលពីគំរូរបស់ទ្រង់—និងគំរូនៃមនុស្សជាច្រើននាក់ផ្សេងទៀតនៅក្នុងព្រះគម្ពីរ—ដើម្បីជួយអ្នក ។

### អធិស្ឋានសុំកម្លាំង



ដើម្បីទប់ទល់នឹងសេចក្ដីល្បួង ដំបូងយើងត្រូវការឆន្ទៈ និងបំណងប្រាថ្នាដ៏ស្មោះត្រង់ដើម្បីជ្រើសរើសផ្លូវត្រូវ ។ វាជួយខ្ញុំយ៉ាងច្រើនប្រសិនបើខ្ញុំស្រមៃពីស្ថានភាពមួយទុកជាមុន រួចហើយជ្រើសរើសផ្លូវត្រូវនោះ ។ រឿងមួយទៀតដែលជួយខ្ញុំគឺការអធិស្ឋាន ។ ប្រសិនបើយើងអធិស្ឋានសុំកម្លាំង ស្វែងរកការចិញ្ចឹមបីបាច់ខាងវិញ្ញាណ ហើយជ្រើសរើសដោយប្រុងប្រយ័ត្នពីទីកន្លែងដែលយើងចេញទៅដើរលេងនៅខាងក្រៅ នោះព្រះវិញ្ញាណបរិសុទ្ធអាចក្លាយដៃគូដ៏ខ្ជាប់ខ្ជួនរបស់យើង ដើម្បីគង់នៅជាមួយនឹងយើង និងដើម្បីព្រមានដល់យើង ។

*អេសធើរ ជី អាយុ 18 ឆ្នាំ ឡូវើរ សាហ្សក់នី ប្រទេស អាល្លឺម៉ង់*

### គាំទ្រគ្នាទៅវិញទៅមក



ខ្ញុំគិតថា តាមរយៈការអានព្រះគម្ពីរ ការអធិស្ឋាន ការអនុវត្តការគ្រប់គ្រងលើខ្លួនឯង និងការធ្វើតាមប្រសាសន៍របស់ព្យាការីប្រចាំថ្ងៃ នោះយើងអាចទប់ទល់នឹងការល្បួងបាន ។ ការទប់ទល់នឹងការល្បួងពង្រឹងសេចក្ដីជំនឿរបស់អ្នក ហើយបង្ហាញពីការតាំងចិត្តរបស់អ្នកចំពោះព្រះវរបិតាសួគ៌ ដើម្បីរក្សាសេចក្ដីសញ្ញាទាំងឡាយដែលអ្នកបានធ្វើ ។ ការមានមិត្តនៅក្នុងសាសនាចក្រក៏អាចជួយយើងផងដែរ ពីព្រោះយើងអាចគាំទ្រគ្នាទៅវិញទៅមក ។ វាត្រូវការសេចក្ដីក្លាហានច្រើនដើម្បីនិយាយពាក្យថាទេ ។ សូមចងចាំថា « ត្បិតព្រះទ្រង់មិនបានប្រទានឲ្យយើងមានវិញ្ញាណដែលតែងតែខ្លាចឡើយ គឺឲ្យមានវិញ្ញាណដ៏មានអំណាច សេចក្ដីស្រឡាញ់ និងប្រាជ្ញានឹងធឹងវិញ » ( ធីម៉ូថេទី 2 1:7 ) ។ នៅពេលយើងយកឈ្នះការល្បួង នោះយើងខិតកាន់តែជិតនឹងព្រះយេស៊ូវគ្រីស្ទ ហើយនឹងព្រះវរបិតាសួគ៌របស់យើង ។

*ណាន់ស៊ី អេស អាយុ 19 ឆ្នាំ គុលទីតឡាន់ ប្រទេស ម៉ិចស៊ិក*

### ចែកចាយជំនឿរបស់អ្នក

នៅវិទ្យាល័យ មិត្តរួមថ្នាក់របស់ខ្ញុំភាគច្រើនបានអញ្ជើញខ្ញុំឲ្យផឹកស្រា ហើយមើលរឿងអាសគ្រាម ។ ខ្ញុំតែងតែនិយាយថាទេ ដោយសារខ្ញុំធ្វើអ្វីដែលព្រះអង្គសង្គ្រោះសព្វព្រះឬទ័យចង់ឲ្យខ្ញុំធ្វើ ។ ខ្ញុំចងចាំទ្រង់ ហើយរក្សាសេចក្ដីសញ្ញាទាំងឡាយរបស់ខ្ញុំ ។ ពេលខ្លះមិត្ត និងមិត្តរួមថ្នាក់របស់ខ្ញុំមិនបានល្បួងខ្ញុំឡើយ ដោយសារពួកគេបានដឹងពីសាសនារបស់ខ្ញុំ ។ ការចែកចាយជំនឿ និងទីបន្ទាល់របស់យើងជាមួយនឹងអ្នកដទៃ—ជាពិសេសជាមួយនឹងមិត្ត មិត្តរួមថ្នាក់ អ្នកជិតខាង និងគ្រួសារ—នឹងកាត់បន្ថយនូវការល្បួងនៅក្នុងមជ្ឈដ្ឋានជុំវិញយើង ។ ខ្ញុំដឹងថា តាមរយៈការរស់នៅតាមដំណឹងល្អ យើងអាចយកឈ្នះលើការល្បួងទាំងឡាយនៅក្នុងជីវិតរបស់យើង ។

*រ៉ូមេអូ ប៉េ អាយុ 19 ឆ្នាំ នេហ្គ្រូស ប៉ែកបស្ចិម ប្រទេស ហ្វីលីពីន*



*ចម្លើយទាំងឡាយគឺមានបំណងទុកជាជំនួយ និង ជាទស្សនៈវិស័យមិនមែនជាការប្រកាសតាមផ្លូវការអំពីគោលលទ្ធិសាសនាចក្រនោះទេ ។*



**សម្រេចចិត្តជាមុនដើម្បីអនុវត្តសេចក្តីជំនឿ**

« វានឹងត្រូវការនូវសេចក្តីជំនឿមិនងាករេពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីជ្រើសរើសផ្លូវទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច ។ . . . តាមរយៈការធ្វើតាមសេចក្តីជំនឿនោះ យើងស្ថាបនាកម្លាំងដើម្បីធ្វើតាមព្រះឫទ័យនៃព្រះ ។ ហើយតាមរយៈការអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ទើបយើងអាចទប់ទល់នឹងសេចក្តីល្បួង ហើយទទួលបានការអភ័យទោសតាមរយៈដង្វាយធួន ។ . . .

« គ្រាដ៏ល្អបំផុតដើម្បីទប់ទល់នឹងសេចក្តីល្បួងគឺមុនហេតុការណ៍នោះកើតឡើង ។ គ្រាដ៏ល្អបំផុតដើម្បីប្រែចិត្តនៅពេលឥឡូវនេះ ។ មារសត្រូវនៃព្រលឹងរបស់យើងនឹងដាក់គំនិតក្នុងចិត្តរបស់យើងដើម្បីល្បួងយើង ។ យើងអាចសម្រេចចិត្តជាមុនដើម្បីអនុវត្តសេចក្តីជំនឿ ដើម្បីបណ្តេញគំនិតអាក្រក់ពីមុនយើងធ្វើវា » ។

**ប្រធាន ហិនរី ប៊ី អាវរិង ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ « Spiritual Preparedness: Start Early and Be Steady »** ***Liahona*** **ខែ វិច្ឆិកា ឆ្នាំ 2005 ទំព័រ 38, 40 ។**

**ចូរស្តាប់តាមព្រះវិញ្ញាណបរិសុទ្ធ**

ខ្ញុំបានរកឃើញថា នៅពេលសេចក្តីល្បួងកើតឡើង នោះព្រះវិញ្ញាណបរិសុទ្ធបានព្យាយាមព្រមានដល់ខ្ញុំឲ្យជ្រើសរើសផ្លូវត្រូវ ។ សូមធ្វើរឿងទាំងឡាយ—ដូចជាការអធិស្ឋាន និងការអានព្រះគម្ពីររបស់អ្នក—ដើម្បីរក្សាព្រះវិញ្ញាណឲ្យគង់ជាមួយនឹងអ្នក ហើយជៀសវាងពីទីកន្លែងដែលព្រះវិញ្ញាណបរិសុទ្ធមិនអាចយាងមកបាន ។

*វ៉ាដែល អូ អាយុ 13 ឆ្នាំ រដ្ឋ ផេនស៊ីលវេញ៉ា ស.រ.អា.*

**ឈរនៅក្នុងទីបរិសុទ្ធ**



បងប្រុសរបស់ខ្ញុំតែងតែប្រាប់ខ្ញុំឲ្យ « ឈរនៅក្នុងទីបរិសុទ្ធ » ។ ខ្ញុំបានរកឃើញថា ឃ្លានេះមានន័យថាឈរនៅទីកន្លែងដែលសេចក្តីល្បួងទាំងឡាយមានតិចតួច ឬ មិនធ្ងន់ធ្ងរ ។ ប្រធានស្តេករបស់ខ្ញុំបាននិយាយថា « កុំគ្រាន់តែទប់ទល់នឹងការល្បួង—ប៉ុន្តែត្រូវជៀសវាងពីការល្បួងផង » ។ នឹងមានពេលដែលអ្នកត្រូវទប់ទល់នឹងសេចក្តីល្បួងនឹងកើតមាន ប៉ុន្តែវាកាន់តែងាយស្រួលដើម្បីរស់នៅតាមដំណឹងល្អនៅពេលសេចក្តីល្បួងមិនបាននៅទីនោះដើម្បីល្បួងអ្នក ។

*អើរិន អិល អាយុ 18 ឆ្នាំ រដ្ឋ យូថាហ៍ ស.រ.អា.*

**យើងត្រូវតែសម្រេចចិត្តជានិច្ច**

អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យស្គាល់ពីភាពខុសគ្នារវាងសេចក្តីល្អ និងសេចក្តីអាក្រក់ ហើយជួយយើងឲ្យដឹងពីពេលដែលយើងនឹងត្រូវបានល្បួង ។ យើងគួរចងចាំថាសេចក្តីល្បួងទាំងឡាយគឺជាការសាកល្បងដែលជួយយើងឲ្យដឹងពេលយើងធ្វើរឿងត្រឹមត្រូវ និងពេលយើងធ្វើរឿងខុសឆ្គង ហើយយើងគួរដឹងថាប្រសិនបើយើងធ្វើតាមព្រះអម្ចាស់ នោះទ្រង់នឹងពុំអនុញ្ញាតឲ្យយើងត្រូវបានល្បួងលើសពីអ្វីដែលយើងអាចទប់ទល់បានឡើយ ( សូមមើល កូរិនថូសទី 1 10:13 ) ។ យើងត្រូវតែធ្វើការសម្រេចចិត្តជានិច្ច មិនថាត្រូវជ្រើសរើសផ្លូវត្រូវ ជំនួសឲ្យផ្លូវខុសមួយនោះឡើយ ។

*ជូន ធី អាយុ 19 ឆ្នាំ ម៉ុងតេវីដេអូ ប្រទេស អ៊ុយរូហ្គាយ*

**ការសម្តែងជ្រើសរើសផ្លូវត្រូវ**



ខ្ញុំគិតថា វាជាការសំខាន់ដើម្បីសម្រេចចិត្តទុកជាមុនពីការជ្រើសរើសដែលខ្ញុំនឹងប្រឈមមុខ ។ ដោយពុំបានដឹងទុកជាមុន ខ្ញុំបានជួបនឹងស្ថានភាពដ៏លំបាកមួយ ហើយលទ្ធផលមានភាពវិជ្ជមាន ដោយសារខ្ញុំបានគិតរួចស្រេចហើយថា ខ្ញុំនឹងមិនបន្ទាបបទដ្ឋានរបស់ខ្ញុំឡើយ ។ ទោះជាពេលខ្លះខ្ញុំមិនស្រណុកនៅក្នុងចិត្តក្តី គ្រួសាររបស់ខ្ញុំបានហាត់នូវការដើរតួដើម្បីឲ្យខ្ញុំដឹងពីអ្វីដែលត្រូវនិយាយ ឬធ្វើនៅពេលជួបនឹងសេចក្តីល្បួងទាំងឡាយ ។

*អេមេលីន ភី អាយុ 14 ឆ្នាំ រដ្ឋ វ៉ាយអូមីង ស.រ.អា.*

**មានមិត្តភក្តិល្អ**

ការមានមិត្តភក្តិល្អដែលជ្រើសរើសផ្លូវត្រូវ គឺជាអ្វីមួយដែលអ្នកអាចធ្វើដើម្បីទប់ទល់នឹងសេចក្តីល្បួង ។ ពួកគេធ្វើគំរូល្អមួយ ។ អ្នកអាចហៅពួកគេប្រសិនបើអ្នកត្រូវបានល្បួង ។ ពួកគេនឹងជួយអ្នកឲ្យរើសផ្លូវត្រូវ ។ មិត្តល្អអាចរំឭកអ្នកឲ្យអធិស្ឋាន អានព្រះគម្ពីរ ហើយគោរពប្រតិបត្តិ ។

*សែម អ៊ី អាយុ 17 ឆ្នាំ រដ្ឋ វ៉ាស៊ីងតោន ស.រ.អា.*

## សំណួរបន្ទាប់

« តើខ្ញុំគួរធ្វើអ្វីនៅពេលខ្ញុំត្រូវបានគេមើលងាយនៅឯសាលា ដោយសារធ្វើតាមបទដ្ឋានសាសនាចក្រនោះ ? »

ប្រសិនបើអ្នកមានបំណង សូមផ្ញើចម្លើយរបស់អ្នក និងរូបថតច្បាស់មួយសន្លឹកត្រឹមថ្ងៃទី 15 ខែ មករា ឆ្នាំ 2014 នៅliahona.lds.org ដោយអ៊ីម៉ែលទៅliahona@ldschurch.org ឬផ្ញើសំបុត្រ ( សូមមើលអាសយដ្ឋាននៅទំព័រទី 3 ) ។

ចម្លើយអាចនឹងត្រូវបាន ធ្វើការកែសម្រួលឡើងវិញ ដោយព្រោះវែងពេក ឬ ដើម្បីភាពច្បាស់លាស់ ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោម ត្រូវតែបញ្ចូលនៅក្នុងអ៊ីម៉ែល ឬ សំបុត្ររបស់អ្នក ៖ (1) ឈ្មោះពេញ, (2) ថ្ងៃខែឆ្នាំកំណើត, (3) វួដ ឬ សាខា, (4) ស្តេក ឬ មណ្ឌល, (5) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយបើសិនអ្នកមានអាយុក្រោម 18 ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្តាយរបស់អ្នកជាលាយលក្ខណ៍អក្សរ ( អ៊ីម៉ែល អាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។





អែលឌើរ
ប្រេដលី ឌី ហ្វស្ទើរ
នៃពួកចិតសិបនាក់

# ទិដ្ឋភាពពី ***ចុងផ្លូវ***

*សារលិខិតពីចុងផ្លូវនោះបានបង្ហាញយ៉ាងច្បាស់ថា ៖ « អ្នកអាចធ្វើកិច្ចការនេះបាន ។ ហើយនៅពេលអ្នកធ្វើ អ្វីៗគ្រប់យ៉ាងនឹងបានប្រសើរឡើង » ។*

« ខ្ញុំនឹងមិនភ្លេចលោកឡើយ ប៊ីស្សព ។ លោកបានសង្គ្រោះជីវិតខ្ញុំ » ។

បុរសដែលបានថ្លែងនូវពាក្យទាំងនោះនៅពេលនេះ មិនបានមានអារម្មណ៍បែបហ្នឹងកាលពីដំបូងឡើយ ។ កាលពីវ័យជំទង់ គាត់មានការភ័យខ្លាច ។ គាត់បានដឹងថា គាត់ត្រូវការប្រែចិត្ត ។ ខ្ញុំជាប៊ីស្សពរបស់គាត់នៅពេលនោះ ហើយគាត់បានដឹងថា យើងត្រូវការនិយាយគ្នា ។ ប៉ុន្តែគាត់ពោរពេញដោយភាពសង្ស័យ ។

« តើអ្វីខ្លះទៅដែលប៊ីស្សពនឹងគិតពីខ្ញុំ ? »

« តើគាត់នឹងរក្សាការសម្ងាត់នេះដែរទេ ? »

« តើខ្ញុំនឹងហ៊ានមើលមុខគាត់ម្តងទៀតបានដោយរបៀបណា ? »

ការព្រួយបារម្ភបែបនេះអាចទទួលអារម្មណ៍នូវភាពលើសលុប ដោយធ្វើឲ្យវាហាក់ដូចជាស្ទើរតែមិនអាចធ្វើទៅបាន ដើម្បីប្រមូលនូវភាពក្លាហានដែលចាំបាច់ ដើម្បីធ្វើដំណើរទៅកាន់ផ្លូវនៃការប្រែចិត្ត ។

## ការសម្លឹងមើលផ្លូវ

ប៉ុន្តែចូរយើងសម្លឹងមើលផ្លូវនោះ ។ ផ្នែកមួយចំនួននៃការប្រែចិត្តគឺងាយជាងផ្នែកផ្សេងទៀត ។ ជំហានមួយគឺការទទួលស្គាល់ ។ ជាធម្មតា យើងដឹងនៅពេលយើងកំពុងធ្វើអ្វីខុស ព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យទទួលអារម្មណ៍ពីការណ៍នោះ ។ យើងត្រូវតែកែប្រែ ហើយបំណងប្រាថ្នាដើម្បីកែប្រែជាធម្មតា មានភាពរឹងមាំ ។

បន្ទាប់មកជំហានទាំងឡាយនឹងកាន់តែពិបាកទៅៗ ។ ព្រះអម្ចាស់មានបន្ទូលថា យើងត្រូវតែសារភាព ហើយលះបង់ចោល ។ វាហាក់ដូចជាងាយដើម្បីសារភាពចំពោះព្រះវរបិតាសួគ៌ នៅក្នុងការអធិស្ឋានរបស់យើង ។ យើងអាចកែតម្រូវអំពើបាបជាច្រើនតាមរបៀបនេះ ដោយស្វែងរកការអភ័យទោស ការជួសជុលឲ្យដូចដើមវិញ និងការធ្វើឲ្យអាកប្បកិរិយាបានប្រសើរឡើងរហូតដល់ព្រះវិញ្ញាណបញ្ជាក់ថា យើងបានធ្វើនូវរាល់កិច្ចការដែលយើងអាចធ្វើបានហើយ ។

ប៉ុន្តែការសារភាពមួយចំនួនតម្រូវឲ្យអ្នកពិភាក្សានឹងប៊ីស្សព ឬប្រធានសាខារបស់អ្នក ។ ហើយនោះជាចំណុចដែលយុវជននេះបានរកឃើញខ្លួនឯង ។ គាត់ត្រូវការជំនួយលើសពីសមត្ថភាពផ្ទាល់របស់គាត់ ហើយគាត់ត្រូវដឹងថាដំណើរនោះអាចធ្វើទៅបាន ។

## សេចក្តីសង្ឃឹមនៅលើផ្លូវដ៏ធំ

អស់អ្នកដែលបានធ្វើដំណើរនៅលើផ្លូវនៃការប្រែចិត្តនឹងប្រាប់អ្នកថា ពុំមែនតែដំណើរនោះអាចធ្វើឡើងទៅបានប៉ុណ្ណោះទេ ប៉ុន្តែថានៅពេលអ្នកបានទៅដល់ទីនោះ ហើយក្រឡេកមើលមកក្រោយវិញ នេះគឺជាអ្វីដែលអ្នកនឹងមើលឃើញ ៖

*អ្នកអាចធ្វើកិច្ចការនេះបាន ។ ហើយនៅពេលអ្នកធ្វើ អ្វីៗគ្រប់យ៉ាងនឹងបានប្រសើរឡើង ។*

ព្រះអម្ចាស់បញ្ជាឲ្យយើងប្រែចិត្ត ដោយសារទ្រង់ស្រឡាញ់យើង ។ តាមរយៈដង្វាយធួនរបស់ទ្រង់ ទ្រង់បានបង់ថ្លៃសម្រាប់អំពើបាបរបស់យើង ហេតុដូច្នេះហើយទើបទ្រង់ដឹងថា ការប្រែចិត្តអាចដោះលែងយើងឲ្យមានសេរីភាពបាន ។ ទ្រង់នឹងពង្រឹងមនុស្សគ្រប់គ្នាដែលបែរមករកទ្រង់ ។ អាលម៉ាបានបង្រៀនថា ដើម្បីទទួលបានប្រយោជន៍ពីដង្វាយធួន យើងត្រូវតែប្រែចិត្ត—យើងគ្រប់គ្នា ( សូមមើល អាលម៉ា 5:33–34 ) ។ ផ្លូវនោះប្រហែល



**យើងគួរតែញញឹម**

« ការប្រែចិត្តគឺជាអំណោយទានមួយមកពីព្រះ ហើយនៅលើផ្ទៃមុខរបស់យើងគួរតែមានស្នាមញញឹម នៅពេលយើងនិយាយពីកិច្ចការនេះ » ។

**អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « The Divine Gift of Repentance » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 38 ។**



ជាមានការលំបាក ប៉ុន្តែប៊ីស្សពនឹងដើរនៅលើផ្លូវនោះជាមួយនឹងអ្នក ។ *មានជំនួយនៅតាមផ្លូវនោះ ។*

*កាលណាអ្នកចាប់ផ្តើមកាន់តែឆាប់រហ័ស នោះអ្នកនឹងទទួលបានអារម្មណ៍ធូរស្រាល ។*

សូមទៅរកប៊ីស្សពរបស់អ្នក ។ អ្នកនឹងរកឃើញបុរសម្នាក់ដែលស្រឡាញ់អ្នក ហើយគោរពអ្នក ។ សេចក្តីទុកចិត្តដែលអ្នកមានចំពោះប៊ីស្សពរបស់អ្នក គឺមានជម្រៅដ៏រឹងមាំ ។ វានឹងមានជារៀងរហូត ហើយវានឹងជួយអ្នកឲ្យមានអារម្មណ៍សុខសាន្តជាមួយនឹងប៊ីស្សពផ្សេងៗទៀតនាពេលអនាគត ។ អ្នកនឹងត្រូវបានផ្តល់ឲ្យនូវគំនិតផ្សេងៗគ្នាពីកង្វល់របស់អ្នក ។ តាមរយៈប្រាជ្ញា និងបទពិសោធន៍របស់គាត់ និងជាមួយការបំផុសគំនិតពីព្រះអម្ចាស់ នោះប៊ីស្សពនឹងជួយថ្លឹងថ្លែងឲ្យអ្នក នូវអ្វីដែលអ្នកបានគិតថាវាគ្មានដំណោះស្រាយ នៅពេលវាប្រហែលគ្រាន់តែ ទូលមួយនៅតាមផ្លូវនោះតែប៉ុណ្ណោះ ។

គាត់នឹងជួយអ្នកឲ្យយល់យ៉ាងច្បាស់ថា ព្រះអង្គសង្គ្រោះគឺជាពន្លឺនៃលោកិយ ។ តាមរយៈការទាញយកប្រយោជន៍របស់អ្នកពីដង្វាយធួន នោះជីវិតរបស់អ្នកនឹងមានភាពភ្លឺថ្លៃងចាំង អនាគតរបស់អ្នកនឹងមានក្តីសង្ឃឹម ហើយអ្នកនឹងយល់ថា ការទទួលបានសេចក្តីជំនឿលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ គឺជាគោលបំណងដ៏ធំមួយសម្រាប់ការមករស់នៅលើផែនដីនេះ ។

*ប៊ីស្សពរបស់អ្នកនឹងជួយអ្នកនៅក្នុងកិច្ចការនេះ ។ អ្នកនឹងស្រឡាញ់គាត់ ហើយនឹងមិនភ្លេចគាត់ឡើយ ។*

ខ្ញុំមានជំនឿយ៉ាងមុតមាំថា មនុស្សដែលជួយអ្នកនៅក្នុងគ្រានៃវិបត្តិនឹងដក់ជាប់នៅក្នុងដួងចិត្តរបស់អ្នក ។ ដូច្នេះ តើប៊ីស្សពម្នាក់នឹងដក់ជាប់នៅក្នុងចិត្តអ្នកកាន់តែខ្លាំងប៉ុណ្ណាទៅ នៅពេលគាត់ជួយអ្នកនៅក្នុងវិបត្តិខាងវិញ្ញាណមួយនោះ ? ព្រះអម្ចាស់អាចបង្កើនចិត្តសប្បុរសរបស់ប៊ីស្សព និងសមត្ថភាពរបស់គាត់ដើម្បីដឹកនាំអ្នក ។ ប៊ីស្សពរបស់អ្នកនឹងក្លាយទៅជាមិត្តរបស់អ្នកជារៀងរហូត ។

ហើយសម្រាប់អ្នករាល់គ្នាដែលជាយុវជន ដែលនឹងក្លាយជាប៊ីស្សព ឬប្រធានស្តេកនៅថ្ងៃណាមួយ បទពិសោធន៍របស់អ្នកជាមួយនឹងប៊ីស្សពនឹងបង្រៀនអ្នកសម្រាប់ពេលវេលានោះ ដែលអ្នកប្រហែលជាអង្គុយនៅឯជ្រុងតុម្ខាងទៀត ។

ខ្ញុំសូមបញ្ចប់ដោយប្រាប់អ្នកបន្តិចទៀតពីការជួប របស់ខ្ញុំជាមួយនឹងយុវជនម្នាក់នោះ ។ គាត់បាននិយាយថា « ប៊ីស្សព លោកនឹងស្អប់ខ្ញុំ ដោយសារតែអ្វីដែលខ្ញុំត្រូវប្រាប់ដល់លោក ។ លោកនឹងមិនចង់មើលមុខខ្ញុំទៀតឡើយ ហើយប្រសិនបើលោកចែកចាយអ្វីដែលខ្ញុំបាននិយាយនឹងអ្នកផ្សេង ខ្ញុំនឹងសម្លាប់ខ្លួនឯង » ។

ខ្ញុំបាននិយាយថា « ខ្ញុំសន្យាថា ខ្ញុំនឹងមិនក្បត់នឹងរឿងសម្ងាត់របស់ប្អូនឡើយ ។ ខ្ញុំនឹងលាក់ទុកវារហូតដល់ខ្ញុំស្លាប់ » ។

គាត់បានប្រាប់ខ្ញុំពីស្ថានភាពតូចៗមួយចំនួន ហើយមើល ពីប្រតិកម្មរបស់ខ្ញុំ ។ នៅពេលខ្ញុំនិយាយថា « ខ្ញុំដឹងនូវអ្វីដែលប្អូនកំពុងឆ្លងកាត់ ។ ខ្ញុំអាចជួយដល់ប្អូនបាន » គាត់បានចាប់ផ្តើមបន្តិចម្តងៗរហូតគាត់ទៅដល់ចំណុចដែលគាត់ចង់ពិភាក្សា ។ ខ្ញុំបានរំឭកគាត់ម្តងហើយម្តងទៀតថា ខ្ញុំបានកោតសរសើរគាត់ចំពោះការសារភាព និងការចង់កែប្រែ ។ ទោះជាគាត់ហាក់ដូចជាមានភាពរួចរាល់ដើម្បីរត់ចេញនៅពេលណាក៏បានក្តី ក៏យើងបានពិភាក្សារួមគ្នានូវអ្វីដែលគាត់ត្រូវចែកចាយដែរ ។

តើវាជារឿងធំដុំដែរទេ ? វាជារឿងធំដុំចំពោះគាត់ ។ ប៉ុន្តែនៅពេលយើងបានពិភាក្សាគ្នា គាត់យល់បានប្រសើរជាងនូវសេចក្តីមេត្តាករុណាដែលព្រះអម្ចាស់ប្រទានដល់អស់អ្នកណាដែលប្រែចិត្តដោយស្មោះត្រង់ ។ បន្ទាប់ពីការជួបគ្នាលើកដំបូង យើងបានធ្វើការរួមគ្នា ហើយក្រោយមកការប្រែចិត្តរបស់គាត់ត្រូវបានបញ្ចប់ ។ សព្វថ្ងៃនេះ គាត់នៅតែទូរស័ព្ទសួរសុខទុក្ខខ្ញុំ ហើយយើងបានសន្ទនាជាមួយនឹងគ្នាយ៉ាងរីករាយ ។

ខ្ញុំមានអភ័យឯកសិទ្ធិដើម្បីជួយគាត់ឲ្យរៀនយល់ថា យើងទាំងអស់គ្នាត្រូវពឹងផ្អែកលើដង្វាយធួន ។ ហើយខ្ញុំចូលរួមជាមួយនឹងគាត់ដើម្បីសរសើរដល់ព្រះយេស៊ូវគ្រីស្ទ ជាអង្គដែលបានសង្គ្រោះជីវិតរបស់គាត់ពិតមែន ។ ■



# ឈប់ញៀនទៀតហើយ ៖ ដំណើររបស់ខ្ញុំដើម្បីយកឈ្នះលើរូបអាសគ្រាម

ឈ្មោះត្រូវបានដកចេញ

*ក្នុងនាមជាយុវនារីម្នាក់ ខ្ញុំពុំធ្លាប់គិតថា ខ្ញុំនឹងជួបបញ្ហាជាមួយនឹងរូបភាពអាសគ្រាមឡើយ ។*

ខ្ញុំពុំធ្លាប់គិតថា ការញៀននូវរូបភាពអាសគ្រាមអាចជាបញ្ហារបស់ក្មេងស្រីម្នាក់នោះឡើយ ។ ខ្ញុំបានគិតខុស នៅពេលខ្ញុំមានអាយុប្រហែលជា 16 ឆ្នាំ ។ ខ្ញុំបានឃើញវីដេអូអាសគ្រាមមួយ ហើយចាប់ពីពេលនោះមក ខ្ញុំបាននៅតែឯងហើយចង់ចេះចង់ដឹង ខ្ញុំបានមើលវា ។ បន្ទាប់ពីលើកដំបូងនោះមក ខ្ញុំមានអារម្មណ៍ហាក់ដូចជាខ្ញុំត្រូវតែមើលអ្វីមួយជារៀងរាល់ថ្ងៃ ។ ខ្ញុំបានញៀននឹងរូបភាពអាសគ្រាម ។

ការមើលរូបភាពអាសគ្រាមបានធ្វើឲ្យខ្ញុំមានអារម្មណ៍មិនល្អ ។ ខ្ញុំបានដឹងថាវាជារឿងខុសឆ្គង

ប៉ុន្តែខ្ញុំមិនបានធ្វើការផ្លាស់ប្ដូរអ្វីឡើយ ។ ខ្ញុំតែងតែពិបាកចិត្ត ហើយខ្ញុំមានអារម្មណ៍កខ្វក់ ហើយឆ្លងវាលដាលដោយសារតែការល្បួងដ៏ស្មោកគ្រោករបស់សាតាំង ។ ប៉ុន្តែខ្ញុំនៅតែរកវិធីដើម្បីមើលវា ដើម្បីខ្ញុំអាចបំពេញនូវចំណង់របស់ខ្ញុំ ។ ការញៀនរបស់ខ្ញុំបានដឹកនាំទៅរកការធ្វើខុសកាន់តែច្រើនឡើងៗ ។ ខ្ញុំបានកុហកមនុស្សគ្រប់គ្នា ៖ បងប្រុសខ្ញុំ ម្ដាយខ្ញុំ ហើយលើសពីនេះទៀត គឺព្រះអម្ចាស់ និងខ្លួនឯង ។ ខ្ញុំបានប្រាប់ខ្លួនឯងថា មើលវីដេអូមួយទៀតនឹងមិនធ្វើឲ្យខ្ញុំឈឺចាប់ឡើយ មើលរឿងកខ្វក់មួយទៀតនឹងមិនអាក្រក់នោះទេ ។

ខ្ញុំនៅតែទៅព្រះវិហារ ចូលរួមម៉ូតឆល និងថ្នាក់សិក្ខាសាលា ប៉ុន្តែខ្ញុំគ្មានឥរិយាបថត្រឹមត្រូវ ឬមានព្រះវិញ្ញាណគង់ជាមួយខ្ញុំឡើយ ។ ខ្ញុំមិនសប្បាយចិត្ត ដូច្នេះខ្ញុំមិនបានរៀនអ្វីពីមេរៀននានាឡើយ ។ ខ្ញុំបានឈប់បង់ដង្វាយមួយភាគក្នុងដប់ ឈប់អធិស្ឋាន និងអានព្រះគម្ពីរ ។ ខ្ញុំមានអារម្មណ៍ថាធ្វើខុស ប៉ុន្តែខ្ញុំនៅតែមិនអាចបញ្ឈប់ខ្លួនឯងបាន ។ ខ្ញុំបានធ្វើឲ្យខ្លួនឯងធ្លាក់ចុះជារៀងរាល់ថ្ងៃ ។

នៅទីបំផុត ការចូលមើលរូបភាពអាសគ្រាមរបស់ខ្ញុំត្រូវបានដាក់កំហិត ។ ដំបូង ខ្ញុំមានអារម្មណ៍ថា អត់រូបភាពអាសគ្រាមមិនបាន ប៉ុន្តែក្រោយមកខ្ញុំបានដឹងថា រឿងទាំងឡាយបានផ្លាស់ប្ដូរដើម្បីធ្វើឲ្យប្រសើរឡើង ។ ទម្លាប់របស់ខ្ញុំមានភាពខុសប្លែក ។ ខ្ញុំមិនបានមើលរូបភាពអាសគ្រាមរាល់ថ្ងៃនោះទេ ។ ខ្ញុំនៅតែមានបំណងដើម្បីមើលវា ប៉ុន្តែខ្ញុំបានប្រសើរជាងមុននៅក្នុងការទប់ទល់នឹងវា ។ នៅទីបំផុត បន្ទាប់ពីញៀននឹងរូបភាពអាសគ្រាមរយៈពេលពីរឆ្នាំ ខ្ញុំបានចាប់ផ្ដើមអធិស្ឋានជាទៀងទាត់សុំកម្លាំង ហើយបានឈប់មើលវាទាំងស្រុង ។ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍កខ្វក់នៅក្នុងចិត្ត ។ ខ្ញុំបានដឹងថា ខ្ញុំត្រូវជួបនឹងប៊ីស្សព ។ ខ្ញុំមិនអាចនាំខ្លួនឯងឲ្យធ្វើកិច្ចការនេះបានឡើយ ។

នៅទីបំផុត បន្ទាប់ពីស្ដាប់ឮមនុស្សជាច្រើននិយាយពីការឆ្លងកាត់ដំណើរការនៃការប្រែចិត្ត និងការសាកល្បងដែលពួកគេបានយកឈ្នះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំពិតជាត្រូវទៅជួបនឹងប៊ីស្សពរបស់ខ្ញុំ ។ ខ្ញុំក៏បានដឹងថា ខ្ញុំកំពុងបាត់បង់នូវពរជ័យដ៏ធំមួយនៅក្នុងសាសនាចក្រ ៖ ជាពរនៃលោកអយ្យកោ ។

ខ្ញុំបានធ្វើការណាត់ជួបមួយដើម្បីជួបនឹងប៊ីស្សពរបស់ខ្ញុំ ។

ខ្ញុំមានអារម្មណ៍ខ្មាស់អៀន នៅពេលដើរទៅកាន់ការិយាល័យរបស់ប៊ីស្សពខ្ញុំសម្រាប់ការសម្ភាសន៍នាយប់នោះ ។ ខ្ញុំភ័យខ្លាចថា គាត់គ្រាន់តែមើលមុខខ្ញុំ ហើយប្រាប់ខ្ញុំថា ករណីរបស់ខ្ញុំគឺគ្មានសង្ឃឹមទេ ហើយថាខ្ញុំបានជីករណ្ដៅមួយយ៉ាងជ្រៅកប់ខ្លួនឯង ហើយមិនអាចចេញមករួចឡើយ ។ ខ្ញុំភ័យខ្លាចថា គាត់នឹងមិនមើលខ្ញុំដូចពីមុនទៀត ។ ប៉ុន្តែនៅពេលខ្ញុំប្រាប់គាត់ពីដំណើររឿងទាំងមូលរបស់ខ្ញុំ គាត់បានញញឹមដាក់ខ្ញុំ ហើយបានស្ដាប់ដោយយកចិត្តទុកដាក់ ។ គាត់ពិតជាខ្វល់ខ្វាយអំពីខ្ញុំ ។ បន្ទាប់ពីនិយាយនឹងប៊ីស្សពរបស់ខ្ញុំ ហើយដោះស្រាយបញ្ហាទាំងឡាយ នៅទីបំផុតគាត់បានប្រាប់ខ្ញុំថាខ្ញុំស្អាតស្អំហើយ ។

ការញៀននឹងរូបភាពអាសគ្រាមប៉ុន្មានឆ្នាំរបស់ខ្ញុំនេះគឺជាពេលដ៏សែនលំបាកមួយនៅក្នុងជីវិតរបស់ខ្ញុំ ប៉ុន្តែខ្ញុំមានអារម្មណ៍ល្អណាស់ដោយចាកចេញពីការិយាល័យរបស់ប៊ីស្សពខ្ញុំ ហើយមានអារម្មណ៍ស្អាតស្អំ ។ បន្ទុកដែលខ្ញុំបានស្ពាយជាច្រើនឆ្នាំត្រូវបានដកចេញពីលើស្មាររបស់ខ្ញុំ ។ ខ្ញុំមានចិត្តរីករាយដែលខ្ញុំអាចទទួលពរជ័យលោកអយ្យកោរបស់ខ្ញុំ ហើយទទួលទានសាក្រាម៉ង់ដោយសក្ដិសម ហើយមានព្រះវិញ្ញាណម្ដងទៀត ។ ខ្ញុំមានអារម្មណ៍ដូចជាមនុស្សថ្មីម្នាក់ ។ មានមនុស្សជាច្រើនថែមទាំងបានប្រាប់ខ្ញុំថា ខ្ញុំហាក់ដូចជាប្លែកជាងពីមុន ហើយថា ទឹកមុខរបស់ខ្ញុំគឺមានភាពភ្លឺខុសពីមុន ។ ខ្ញុំរីករាយជាងមុននៅគ្រប់ពេលវេលា ហើយមានឥរិយាបថល្អអំពីគ្រប់រឿងទាំងអស់ ។

ខ្ញុំដឹងថាដោយមានជំនួយរបស់ព្រះអម្ចាស់ យើងអាចកែប្រែ ហើយយកឈ្នះលើការញៀនទាំងឡាយ ។ ហើយមិនចាំបាច់ព្រួយបារម្ភពីការនិយាយជាមួយនឹងប៊ីស្សពឡើយ ដោយសារគាត់នឹងជួយយើង នៅពេលយើងប្រែចិត្ត ដើម្បីយើងអាចទទួលអារម្មណ៍ស្អាតស្អំម្ដងទៀតតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ■



## តើការប្រែចិត្តគឺជាអ្វី ?

« តាមរយៈដង្វាយធួនអ្នកអាចទទួលបានការអភ័យទោស ហើយត្រូវបានស្អាតពីអំពើបាបទាំងឡាយ របស់អ្នកនៅពេលដែលអ្នកប្រែចិត្ត ។

« ការប្រែចិត្តគឺសំខាន់ជាងការទទួលស្គាល់កំហុសដ៏សាមញ្ញ ។ . . . វារួមមានការបែរចេញពីអំពើបាប ហើយបែរទៅរកព្រះសម្រាប់ការអភ័យទោស ។ . . .

« . . . ប្រសិនបើអ្នកបានធ្វើបាប ហើយឆាប់ប្រែចិត្ត នោះអ្នកឆាប់ចាប់ផ្ដើមត្រឡប់មករកព្រះអម្ចាស់វិញ ហើយស្វែងរកសេចក្ដីសុខសាន្ត និងសេចក្ដីអំណរដែលភ្ជាប់មកជាមួយនឹងការអភ័យទោស ។ . . .

នៅពេលដែលអ្នកព្យាយាមប្រែចិត្ត ចូរស្វែងរកជំនួយ និងការប្រឹក្សាពីឪពុកម្ដាយរបស់អ្នក ។ អំពើបាបធ្ងន់ធ្ងរ ដូចជាអំពើរំលងខាងផ្លូវភេទ ឬ ការប្រើរូបអាសគ្រាមតម្រូវឲ្យសារភាពដល់ប៊ីស្សពរបស់អ្នក ។ ចូរមានសេចក្ដីស្មោះត្រង់ពេញលេញជាមួយនឹងគាត់ ។ គាត់នឹងជួយអ្នកឲ្យប្រែចិត្ត » ។

*ដើម្បីកម្លាំងនៃយុវជន* ( កូនសៀវភៅ ឆ្នាំ 2011 ) ទំព័រ 28, 29 ។

រចនាដោយ ជីង ឃេមសេន រៀងលម្អិតចេញពី *CHRIST IN GETHESEMANE* ដោយ ហេនរីក ហ៊ូហ្វម៉ែន

# លើសពី ដៃគូ

តើអ្នកគិតថានៅពេលអ្នក ទៅបង្រៀនតាមផ្ទះ គឺអ្នកគ្រាន់តែរួម ដំណើរនឹងមនុស្សម្នាក់ដើម្បី ទៅសួរសុខទុក្ខមែនទេ ? សូមគិតម្ដងទៀត ។




អ្នកធ្លាប់បានឃើញការណ៍នេះនៅក្នុងប្រលោមលោក និងខ្សែវីដេអូជាច្រើនមកហើយ ។ មានបញ្ហាធំមួយគួរឲ្យភ័យខ្លាចកំពុងកើតមានដូចជាពពកខ្មៅងងឹតពីចម្ងាយ ។ គ្រោះមហន្តរាយហាក់ដូចជាជៀសមិនរួច ។ បន្ទាប់មកក៏មានវីរៈបុរសបានមានជំនះលើឧបសគ្គ ហើយបានដោះស្រាយបញ្ហានោះ ។

ពួកវីរៈបុរសបែបនេះជារឿយៗបានរួមដំណើរដោយដៃគូម្នាក់ ។ តួអង្គនេះជាធម្មតាមានជំនាញមូលដ្ឋានបន្តិចបន្តួច ប៉ុន្តែដើរតួយ៉ាងសំខាន់ដើម្បីជួយដល់វីរៈបុរសរូបនោះពេលខ្មាំងសត្រូវវាយសម្រុកមកលើគាត់ ។

ក្នុងនាមជាដៃគូបង្រៀនតាមផ្ទះវ័យក្មេងម្នាក់ វាអាចនឹងត្រូវបានល្បួងឲ្យគិតថាខ្លួនអ្នកជាដៃគូម្នាក់នឹងដៃគូរៀមច្បង ។ ទោះជាយ៉ាងណាក្ដី ដៃគូរបស់អ្នកដែលមានអាយុច្រើនជាង ធ្លាប់បានឆ្លងកាត់នូវបទពិសោធន៍ច្រើនជាងអ្នក ។ ដូច្នេះវាគឺអាស្រ័យទៅលើគាត់ដើម្បីដោះស្រាយបញ្ហា តើត្រឹមត្រូវទេ ?

មិនពិតនោះទេ ។

ចំពោះការបង្រៀនតាមផ្ទះ គឺគ្មានមហាវីរៈបុរស ( ដៃគូវ័យចំណាស់របស់អ្នក ) និងដៃគូរបស់គាត់ ( អ្នក ) នោះទេ—គឺមានតែមហាវីរៈបុរសពីរនាក់ដែលអាចផ្លាស់ប្ដូរពិភពលោកនេះរួមគ្នាតែប៉ុណ្ណោះ ។

មិនថាអ្នកជានរណា ហើយបទពិសោធន៍របស់អ្នកជាអ្វីនោះទេ អ្នកផ្ទាល់មាននូវអ្វីដែលត្រូវការដើម្បីធ្វើឲ្យមានការផ្លាស់ប្ដូរដ៏ធំមួយ នៅក្នុងជីវិតរបស់មនុស្សដែលអ្នកបានទៅសួរសុខទុក្ខ ។

**គ្មានការហៅណាធំជាងនេះឡើយ**

ប្រធាន អ៊ែសរ៉ា ថាហ្វ ប៉ែនសឹន ( 1899–1994 ) បានមានប្រសាសន៍ថា « គ្មានការហៅក្នុងសាសនាចក្រណាមួយដែលធំជាងការធ្វើជាគ្រូបង្រៀនតាមផ្ទះម្នាក់ឡើយ » ។[1]

ពួកគ្រូបង្រៀនតាមផ្ទះធ្វើលើសពីការចែកចាយសារលិខិតមួយខាងវិញ្ញាណទៅទៀត ។ ពួកគេជួយគ្រួសារនីមួយៗឲ្យដឹងថា ពួកគេមានមិត្តដែលពួកគេអាចពឹងពាក់បាន ។

ប្រធានថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា « មិត្តម្នាក់ធ្វើលើសពីការសួរសុខមួយដោយយកចិត្តទុកដាក់មួយជារៀងរាល់ខែទៅទៀត » ។ . . . មិត្តម្នាក់ត្រូវចេះខ្វាយខ្វល់ ។ មិត្តម្នាក់ត្រូវចេះស្រឡាញ់ ។ មិត្តម្នាក់ត្រូវចេះស្ដាប់ ។ ហើយមិត្តម្នាក់ត្រូវចេះជួយយកអាសារ » ។[2]

ពិតណាស់ មិត្តភាពដ៏អស្ចារ្យទាំងឡាយអាចត្រូវបានបង្កើតឡើងនៅគ្រប់វ័យទាំងអស់ ។

**ការបម្រើជាមិត្តម្នាក់**

ស្បុន ស៊ី អាយុ 16 ឆ្នាំ មកពីរដ្ឋ យូថាហ៍ ភាគខាងត្បូង ស.រ.អា. ស្គាល់ពីរបៀបដើម្បីធ្វើជាមិត្ត

ម្នាក់ ក៏ដូចជាគ្រូបង្រៀនតាមផ្ទះផងដែរ ។ ស្បូន មានចំណាប់អារម្មណ៍ជាច្រើនផ្សេងៗពីគ្នា ដែលរួមបញ្ចូលទាំងការប្រកួតជិះសេះ ការបោកចំបាប់ ការថែទាំហ្វូងគោ និងការជួសជុលរថយន្ត ។ គាត់ក៏ស្រឡាញ់ការបង្កើតមិត្តភាពជាមួយនឹងមនុស្សដែលគាត់ទៅបង្រៀនតាមផ្ទះផងដែរ ។

ស្បូននិយាយថា « ខ្ញុំចូលចិត្តនិយាយនឹងមនុស្សទូទៅ ហើយមើលពីអ្វីដែលខ្ញុំអាចធ្វើដើម្បីជួយពួកគេ » ។

ដៃគូបង្រៀនតាមផ្ទះរបស់គាត់គឺជាប៊ីស្សពនៃវួដរបស់ពួកគេ ។ នៅផ្ទះមួយដែលពួកគេទៅសួរសុខទុក្ខ ស្ត្រីជាភរិយាគឺជាសមាជិកនៃសាសនាចក្រ ប៉ុន្តែស្វាមីពុំមែនជាសមាជិកនោះទេ ។ ស្បូន បានមានទំនាក់ទំនងល្អនឹងស្វាមីឈ្មោះ ភ្លយ នៅពេលពួកគេទៅសួរសុខទុក្ខជាលើកដំបូង ។ នៅពេលភ្លយបានចាប់ផ្ដើមនិយាយពីរថយន្ត Jeep របស់គាត់ ស្បូន បានមានការចាប់អារម្មណ៍ភ្លាម ។ ស្បូននិយាយថា « យើងមានចំណាប់អារម្មណ៍ដូចគ្នា » ។

នៅក្នុងឆ្នាំដែលស្បូន និងប៊ីស្សពបានទៅសួរសុខទុក្ខភ្លយ និងភរិយារបស់គាត់ ស្បូនបានពង្រឹងមិត្តភាពទាំងនោះ—រួមទាំងការជួយភ្លយធ្វើការផ្នែកម៉ាស៊ីនពីមួយគ្រាទៅមួយគ្រា ។

ខគម្ពីរមួយដែលស្បូនចូលចិត្តគឺពីការបម្រើ ៖ « កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ » ( ម៉ូសាយ 2:17 ) ។

ស្បូនពន្យល់ថា « មនុស្សគ្រប់រូបត្រូវសម្លឹងមើលរកវិធីដើម្បីបម្រើ » ។

**អំណោយទានខាងវិញ្ញាណរបស់អ្នក**

យើងទាំងអស់គ្នាមាននូវអំណោយទានខាងវិញ្ញាណ និងទេពកោសល្យ ។ ជាងនេះទៀត យើងមាននូវចំណាប់អារម្មណ៍ និងកិច្ចការកំសាន្តដែលប្លែកពីគេ ។ យើងម្នាក់ៗមានអ្វីមួយពិសេសដើម្បីផ្ដល់ឲ្យ ដែលគ្មាននរណាម្នាក់ផ្សេងទៀតអាចធ្វើតាមរបៀបដូចគ្នាបាននោះឡើយ ។

ប្រធាន ហិនរី ប៊ី អាវរិង ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ បានបង្រៀនថា « មនុស្សគ្រប់គ្នាគឺខុសពីគ្នា ហើយមានការបរិច្ចាគផ្សេងៗពីគ្នា » ។ « គ្មាននរណាម្នាក់ត្រូវបានកំណត់ឲ្យបរាជ័យនោះទេ » ។[3] ការបង្រៀនតាមផ្ទះអាចជាឱកាសមួយសម្រាប់អ្នក ដើម្បីប្រើអំណោយទានទាំងនោះដើម្បីជាប្រយោជន៍ដល់មនុស្សដទៃទៀត ។

ឧទាហរណ៍ នៅពេលវេនរបស់អ្នកដើម្បីចែកចាយសារលិខិតខាងវិញ្ញាណមួយ អ្នកគប្បីគិតពិចារណាដើម្បីធ្វើការអធិស្ឋានទុកជាមុនពីអ្វីដែលអ្នកអាចនិយាយ ដែលវានឹងផ្ដល់ជាប្រយោជន៍យ៉ាងច្រើនដល់មនុស្សដែលអ្នកទៅសួរសុខទុក្ខ ។

ជារឿយៗ អ្នកនឹងមានបទពិសោធន៍ផ្ទាល់ខ្លួនមួយទាក់ទងនឹងប្រធានបទដែលលើកឡើង ដែលអ្នកអាចប្រាប់ទៅគ្រួសារនោះ ។ ចូរធ្វើឲ្យពន្លឺរបស់អ្នកបានភ្លឺឡើង ! សូមចែកចាយអ្វីដែលអ្នកដឹង ។

អ្នកក៏អាចស្វែងរករបៀបដ៏ច្នៃប្រឌិត ហើយមានអត្ថន័យដើម្បីបម្រើដល់ក្រុមគ្រួសារដែលអ្នកទៅសួរសុខទុក្ខ ។ ឧទាហរណ៍ ឧបមាថាមានមនុស្សម្នាក់នៅក្នុងគ្រួសារមួយ ដែលអ្នកបង្រៀនចង់រៀនលេងហ្គីតា ។ ចៃដន្យអី អ្នកចេះលេងហ្គីតាជាយូរមកហើយ ។ នៅក្នុងស្ថានភាពនេះ គន្លឹះតន្ត្រីមួយចំនួនពីមួយគ្រាទៅមួយគ្រាអាចមានអត្ថប្រយោជន៍ ដូចជាការចូកព្រិលចេញពីផ្លូវរបស់ពួកគេ ឬកាត់តម្រឹមដើមឈើរបស់ពួកគេផងដែរ ។

នៅពេលនិយាយពីការបង្រៀនតាមផ្ទះ ដៃគូរៀមច្បងរបស់អ្នកអាចជាមនុស្សមានជំហរខាងវិញ្ញាណយ៉ាងរឹងមាំម្នាក់ ។ ប៉ុន្តែកុំយល់ខុសឲ្យសោះ ។ អ្នកជាកូនចៅនៃព្រះ ហើយមានសមត្ថភាពដើម្បីបំពេញតួនាទីរបស់អ្នកជាគ្រូបង្រៀនតាមផ្ទះ ។

អ្នកនឹងតែងតែមានអ្វីដែលមួយអស្ចារ្យដើម្បីបន្ថែមបង្គ្រប់ពីលើនោះ ។ ■

**កំណត់ចំណាំ**

1. អ៊ែសរ៉ា ថាហ្វ ប៉ែនសឹន « To the Home Teachers of the Church » *Ensign* ខែ ឧសភា ឆ្នាំ 1987 ទំព័រ 50 ។
2. ថូម៉ាស អេស ម៉នសុន « Home Teaching—a Divine Service » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1997 ទំព័រ 47 ។
3. ហិនរី ប៊ី អាវរិង « Help Them Aim High » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 60 ។
4. លីនដា ខេ ប៊ើរតុន « First Observe, Then Serve » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 78 ។

មេរៀនថ្ងៃអាទិត្យ

ប្រធានបទសម្រាប់ខែនេះ ៖

ការស្ដាយនានគរព្រះនៅថ្ងៃចុងក្រោយ

## សូមចូលរួមការសន្ទនានេះ



ពេញមួយខែធ្នូនេះ មេរៀនរបស់អ្នកនៅថ្ងៃអាទិត្យនឹងផ្ដោតសំខាន់លើការស្ថាបនានគរនៃព្រះ ។ ការបង្រៀនតាមផ្ទះគឺជារបៀបមួយដើម្បីធ្វើកិច្ចការនេះ ប៉ុន្តែមនុស្សគ្រប់គ្នាអាចស្ថាបនានគរនៃព្រះតាមរយៈទង្វើរនៃការបម្រើប្រចាំថ្ងៃ ។ នៅពេលអ្នកអធិស្ឋានឲ្យអ្នកដទៃ នោះព្រះវិញ្ញាណអាចនាំឲ្យអ្នកនឹកឃើញនូវអ្វីមួយដែលអ្នកអាចធ្វើ ។ សូមចងចាំ ការប្រឹក្សានេះមកពីស៊ិស្ទើរ លីនដា ខេ ប៊ើរតុន ជាប្រធានសមាគមសង្គ្រោះទូទៅ ថា ៖ « ដំបូងសង្កេតមើល បន្ទាប់មកបម្រើ » ។[4] តើអ្នកបានរកឃើញរបៀបដើម្បីសង្កេតមើល រួចហើយបម្រើនៅក្នុងការស្ថាបនានគររបស់ព្រះដោយរបៀបណា ? សូមរៀបចំខ្លួនដើម្បីចែកចាយបទពិសោធន៍របស់អ្នកនៅក្នុងវួដរបស់អ្នក ជាមួយគ្រួសារអ្នក ឬជាមួយយុវវ័យរបស់អ្នកផ្សេងទៀត ។

# ការឈរនៅក្នុង ទីដ៏បរិសុទ្ធ



*ទស្សនាវដ្ដីសាសនាចក្រឆ្នាំនេះអញ្ជើញយុវវ័យនៅជុំវិញពិភពលោក ឲ្យផ្ញើរូបភាពដែលបង្ហាញពីរបៀបដែលពួកគេឈរនៅក្នុងទីដ៏បរិសុទ្ធ ។ សូមមើលនូវរូបភាពមួយចំនួនដែលបានផ្ញើមក ហើយមើលពីអ្វីដែលយុវវ័យបានធ្វើ ដើម្បីរស់នៅតាមបាវចនាសម្រាប់ម៉ូឆល 2013 ។*





**1** នៅគ្រប់ពេលដែលខ្ញុំធ្វើនូវសកម្មភាពល្អៗ ជាពិសេសជាមួយគ្រួសាររបស់ខ្ញុំ ខ្ញុំកំពុងឈរនៅទីដ៏បរិសុទ្ធ ។
***ឡារ៉ា អ័រ អាយុ 16 ឆ្នាំ ប្រ៊ីធីស កូឡុំប៊ី ប្រទេស កាណាដា***

**2** ខ្ញុំឈរនៅក្នុងទីបរិសុទ្ធនៅពេលខ្ញុំឲ្យតម្លៃទៅលើអ្វីៗទាំងឡាយ ដែលមានតម្លៃអស់កល្បជានិច្ចលើសពីកិច្ចការនៃលោកិយ ។
***ឃើក អិម អាយុ 18 ឆ្នាំ នេហ្គ្រូសខាងលិច ប្រទេស ហ្វីលីពីន***

**3** ចំពោះខ្ញុំ ការឈរនៅទីបរិសុទ្ធមានន័យថា ការធ្វើការបម្រើ ។ របៀបដែលខ្ញុំពេញចិត្តដើម្បីធ្វើការបម្រើគឺនៅក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំអាចទទួលអារម្មណ៍មួយដ៏រឹងមាំបែបនេះ នៅពេលខ្ញុំធ្វើកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងដំណាក់របស់ទ្រង់ ។
***ឃីអាណា ប៊ី អាយុ 15 ឆ្នាំ រដ្ឋ យូថាហ៍ ស.រ.អា.***













**4** ខ្ញុំកំពុងឈរនៅក្បែរអាងជ្រមុជទឹក ដែលខ្ញុំបានទទួលបុណ្យជ្រមុជទឹក ។ ខ្ញុំចាត់ទុកអាងនេះជាទីបរិសុទ្ធមួយ ដោយសារវាជាកន្លែងដែលមនុស្សទូទៅធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះ ហើយក្លាយខ្លួនជាមនុស្សថ្មី ។

***ចូ-ស្មីធ អី អាយុ 17 ឆ្នាំ អាកក៏ អីប៊ម ប្រទេស នីហ្សេរីយ៉ា***

**5** នៅពេលណាខ្ញុំឡើងទៅលើភ្នំ ហើយដកខ្លួនចេញពីពិភពលោកនេះ ខ្ញុំដឹងថា វាអាចជាទីបរិសុទ្ធ ហើយសុខសាន្ត ។

***អិមម៉ា ភី អាយុ 17 ឆ្នាំ រដ្ឋអូរេហ្គិន ស.រ.អា.***

**6** ខ្ញុំចូលចិត្តចេញទៅខាងក្រៅ ហើយនៅពេលណាខ្ញុំនៅទីកន្លែងមួយបែបនេះ ( ដេឡាខិត អាធដ៏ប្រណិតនៅម៉ូអាប រដ្ឋ យូថាហ៍ ) ខ្ញុំទទួលអារម្មណ៍កាន់តែនៅនឹងព្រះវរបិតាសួគ៌ ។ ការអាចមើលឃើញនូវការណ៍ដ៏អស្ចារ្យទាំងឡាយ ដែលព្រះវរបិតាសួគ៌បានបង្កើតសម្រាប់យើងជួយខ្ញុំឲ្យទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។

***ចន ធី អាយុ 18 ឆ្នាំ រដ្ឋ យូថាហ៍ ស.រ.អា.***

**7** ផ្ទះរបស់ខ្ញុំគឺជាទីបរិសុទ្ធ ហើយពិសិដ្ឋមួយ ដោយសារខ្ញុំមានអារម្មណ៍រីករាយ ហើយសុខសាន្តខ្លាំងណាស់នៅទីនោះ ។ ហើយនៅពេលខ្ញុំអានព្រះគម្ពីរមរមន ខ្ញុំមានអារម្មណ៍ស្ងប់សុខសាន្តតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

***មេលីស្សា ឌី អាយុ 13 ឆ្នាំ កូសូវ៉ូ***


NOITE
DE
8


11


12


9


10


13

**8** នេះជារូបភាពមួយពីការចាប់ផ្ដើមថ្មី ។ ចំពោះខ្ញុំ អគារសាសនាចក្រគឺជាទីបរិសុទ្ធមួយដែលខ្ញុំរៀនពីតម្លៃរបស់យុវនារី និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ នៅឯព្រះវិហារ ខ្ញុំក៏ពង្រឹងមិត្តភាពដែលខ្ញុំមានជាមួយនឹងយុវនារីដែលចែកចាយរីលែកជំនឿដូចគ្នាដែរ ។
*តាអ៊ីសស អេស អាយុ 12 ឆ្នាំ នៅរីអូ ហ្គ្រានឌេ ដូ ស៊ូល ប្រទេសប្រេស៊ីល*

**9** ខ្ញុំឈរនៅទីបរិសុទ្ធនៅពេលខ្ញុំជួយ មនុស្សទូទៅ ហើយសប្បាយរីករាយជាមួយនឹងមិត្តល្អៗ ។
*ជេមស៍ អ័រ អាយុ 17 ឆ្នាំ រដ្ឋ ផែនស៊ីលវេនៀ ស.រ.អ.*

**10** ខ្ញុំឈរនៅទីបរិសុទ្ធមួយនៅពេលខ្ញុំនៅជាមួយនឹងមិត្តដែលរស់នៅតាមដំណឹងល្អ ។ ពួកគេជួយខ្ញុំឲ្យមានទំនាក់ទំនងជិតស្និទ្ធនឹងព្រះវរបិតាសួគ៌របស់ខ្ញុំ ហើយមានភាពសុខដុមដ៏មហិមាជាមួយនឹងព្រះវិហារបរិសុទ្ធ ។
*ចូណាថាន់ អិន អាយុ 17 ឆ្នាំ ប៊ូណូស អ៊ែរ៉េស ប្រទេស អាហ្សង់ទីន*

**11** ខ្ញុំឈរនៅទីបរិសុទ្ធមួយនៅពេលខ្ញុំលេងព្យាណូក្នុងការប្រជុំសាក្រាម៉ង់ ។ បទភ្លេង និងទំនុកច្រៀងនៃទំនុកតម្កើងព្រះបានពង្រឹងដល់សេចក្ដីជំនឿ និងទីបន្ទាល់របស់ខ្ញុំ ។
*ឆែលស៊ី អេ អាយុ 13 ឆ្នាំ បានធិន ប្រទេស ឥណ្ឌូណេស៊ី*

**12** ខ្ញុំឈរនៅទីបរិសុទ្ធមួយនៅពេលខ្ញុំដឹកនាំភ្លេង នៅក្នុងការប្រជុំសាក្រាម៉ង់ ដោយសារខ្ញុំមានចិត្តរំភើបដោយការច្រៀងដ៏ពិរោះនៃក្រុមជំនុំ ។
*អ៊ីអារ៉ន្ទី ដមុលយូ អាយុ 15 ឆ្នាំ បានធិន ប្រទេស ឥណ្ឌូណេស៊ី*

**13** ខ្ញុំឈរនៅទីបរិសុទ្ធមួយនៅពេលខ្ញុំបង្រៀនក្លូរ៉ុមរបស់ខ្ញុំនៅថ្ងៃអាទិត្យ ។ *ខ្ញុំចូលចិត្តចែកចាយដំណឹងល្អ ។*
*រ៉ាម៉ូន អិម អាយុ 16 ឆ្នាំ រដ្ឋ កាលីហ្វ័រញ៉ា ស.រ.អ.*

## ទីបរិសុទ្ធផ្សេងទៀត

**នេះ** ជារបៀបដែលយុវវ័យផ្សេងទៀតបានបំពេញនូវប្រយោគថា « ខ្ញុំឈរនៅទីបរិសុទ្ធនៅពេល . . . »

- « ខ្ញុំចែកចាយដំណឹងល្អជាមួយមិត្តរបស់ខ្ញុំ » ។ ***ចន ប៊ី អាយុ 17 ឆ្នាំ, ស៊ីអ៊ែរ៉ា ប្រទេស ប្រេស៊ីល***
- « ខ្ញុំឈរជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនា ដោយសារធ្វើការជាមួយនឹងពួកគាត់ផ្ដល់បទពិសោធន៍ដល់ខ្ញុំបន្ថែមទៀតពីការចែកចាយដំណឹងល្អ ហើយមិនយូរប៉ុន្មានខ្ញុំនឹងក្លាយជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងម្នាក់ » ។ ***យ៉ូសែប អេផ អាយុ 18 ឆ្នាំ, ហ្សាការតា ប្រទេស ឥណ្ឌូណេស៊ី***
- « ខ្ញុំនៅទីលានលេងកីឡាបាល់បោះ ហើយបានជួយដល់មិត្តរួមក្រុមរបស់ខ្ញុំ ហើយបង្ហាញការគោរពដ៏ល្អដល់កីឡាករទាំងឡាយ សូម្បីតែចំពោះក្រុមផ្សេងក៏ដោយ » ។ ***អេមីលី ស៊ី អាយុ 12 ឆ្នាំ, រដ្ឋ យូថាហ៍ ស.រ.អ.***
- « យើងសម្ដែងនៅក្នុងក្រុមចម្រៀងនៅវិទ្យាល័យរបស់យើង ហើយចែកចាយនូវទេពកោសល្យរបស់យើង » ។ ***ថែនណឺ អិម អាយុ 17 ឆ្នាំ, យេលិន អេស អាយុ 15 ឆ្នាំ, ឡិចហ្ស៊ី ជេ អាយុ 17 ឆ្នាំ, ស្ពេនសើរ អិម អាយុ 17 ឆ្នាំ, រដ្ឋ អៃដាហូ ស.រ.អ.***
- « ខ្ញុំទៅការបោះជំរំសម្រាប់យុវនារី ។ ខ្ញុំមានឱកាសដើម្បីជួបនឹងយុវនារីផ្សេងទៀតដែលចែករំលែកបទដ្ឋាន និងតម្លៃដូចគ្នា ហើយជួបនឹងពួកអ្នកដឹកនាំដែលបង្រៀនយើងពីគោលការណ៍ទាំងឡាយ ដើម្បីយើងអាចរៀនធ្វើអ្វីដែលត្រឹមត្រូវ » ។ ***ន័រម៉ា រី អាយុ 17 ឆ្នាំ, ហ្គាយ៉ាស ប្រទេស អេក្វាឌ័រ***
- « ខ្ញុំចូលរៀនថ្នាក់សិក្ខាសាលា ។ វាជួយខ្ញុំឲ្យរក្សាព្រះវិញ្ញាណនៅក្នុងជីវិតរបស់ខ្ញុំ ! » ***សាវណ្ណា អេហ្វ អាយុ 17 ឆ្នាំ, រដ្ឋ អារីហ្សូណា ស.រ.អ.***
- « ខ្ញុំបានប្រាប់មិត្តរួមក្រុមរបស់ខ្ញុំពីអ្វីដែលខ្ញុំជឿ នៅក្នុងការហាត់សមគាំទ្រនៅឯសាលារបស់ខ្ញុំ » ។ ***ម៉ាខេនណា អេហ្វ អាយុ 15 ឆ្នាំ, រដ្ឋ កាលីហ្វ័រញ៉ា ស.រ.អ.***
- « ខ្ញុំបានចែកសាក្រាម៉ង់ ហើយចងចាំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ » ។ ***អាហ្សេល អេស អាយុ 14 ឆ្នាំ, ហ្សាការតា ប្រទេស ឥណ្ឌូណេស៊ី***
- « ខ្ញុំបានរក្សា ខ្លួនខ្ញុំឲ្យស្អាតស្អំ ហើយរើសផ្លូវត្រូវ ដោយសារខ្ញុំដឹងថា ប្រសិនបើខ្ញុំបន្តធ្វើបែបនោះ នៅថ្ងៃណាមួយខ្ញុំអាចរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ។ » ***រិតនី អេផ អាយុ 15 ឆ្នាំ, រដ្ឋ យូថាហ៍ ស.រ.អ.***
- «ខ្ញុំរក្សាសេចក្ដីសញ្ញារបស់ខ្ញុំជាមួយនឹងព្រះ » ។ ***ម៉ាក អិម អាយុ 17 ឆ្នាំ, រដ្ឋ អូហៃអូ ស.រ.អ.***

ឥឡូវនេះ សូមគិតពីអ្វីដែល*អ្នក*បានរៀនពីបាវចនាម៉្វូឆលសម្រាប់ឆ្នាំនេះ ។ តើទីបរិសុទ្ធមួយចំនួនរបស់អ្នកគឺជាអ្វីទៅ ? តើអ្នកអាចបន្តឈរនៅទីបរិសុទ្ធបានដោយរបៀបណា ? សូមពិចារណាកត់ត្រាគំនិតរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។




រូបថតនៃព្រះវិហារបរិសុទ្ធ ខរីទា ប្រេស៊ីល ដោយ ហ្វ៊ីងឆិន ល្វីស ស៊ីលវ៉ា



# ចម្រៀង បុណ្យគ្រីស្ទម៉ាស់ ដ៏ពេញចិត្ត

ដោយ ស៊ី ឌី លីនស្រ្តូម

ខ្ញុំចងចាំថាវាជាពិធីជប់លៀងបុណ្យគ្រីស្ទម៉ាស់ក្នុងវួដធម្មតា ៖ នៅលើតុមានក្រាលក្រដាសពណ៌ក្រហម និងពណ៌បៃតង មានបម្រើអាហារពេលល្ងាចដាក់លើចានក្រដាស មានក្មេងតូចៗរត់លេង និងសំឡេងជជែកគ្នាដោយរីករាយនៃសមាជិកវួដ ។ នោះមានមនុស្សម្នាក់បានធ្វើឲ្យរឿងទាំងឡាយស្ងប់ស្ងាត់ ដើម្បីប្រសិទ្ធពរដល់អាហារ រួចហើយមនុស្សគ្រប់គ្នាចាប់ផ្ដើមបរិភោគ ។ កម្មវិធីនេះរៀបនឹងចាប់ផ្ដើម ។

*ខ្ញុំពុំបានមានអំណរគុណចំពោះចម្រៀងរបស់នាងរហូតដល់ខ្ញុំបានដឹងថា នាងកំពុងច្រៀងចម្រៀងទៅកាន់នរណា ។*

វាពុំមែនវួដរបស់ខ្ញុំនោះទេ ។ ខ្ញុំបានទៅជាមួយនឹងមិត្តភក្តិនៅក្នុងពិធីជប់លៀងក្នុងវួដរបស់នាង ដូច្នេះខ្ញុំពុំបានស្គាល់មនុស្សច្រើននោះទេ ។ យើងបានចង់ចេញមុន ប៉ុន្តែម្ដាយរបស់នាងបានលួងលោមយើងឲ្យនៅមើលកម្មវិធីនោះ ។

ចម្រៀងដំបូងសម្រាប់កម្មវិធីនោះគឺច្រៀងដោយកុមារបឋមសិក្សា ដែលបានដើរមកលើឆាកដោយស្លៀកពាក់បន្ទះលោហៈភ្លឺពណ៌ មានរាងជារង្វង់នៅលើក្បាលរបស់ពួកគេ ។ ពួកគេបានច្រៀងចម្រៀងមួយបទ រួចហើយនៅពេលពួកគេដើរចុះពីឆាកវិញពួកគេបានដើរទង្គិចគ្នា ហើយសើចកក្អឹក ដោយបន្សល់នូវកម្ទេចនៃបន្ទះលោហៈភ្លឺពណ៌នោះនៅពីខាងក្រោយពួកគេ ។

បន្ទាប់មកមានអ្នកលេងព្យាណូពីរនាក់បានលេងនូវបទដ៏រីករាយ ។ អ្នកលេងព្យាណូទីមួយលេងបទ « Oh, Come, All Ye Faithful » ( *Hymns* ល.រ. 202 ) ដោយគ្មានបាត់មួយខ្ទង់ណាឡើយ ។ អ្នកលេងម្នាក់ទៀត ជាក្មេងប្រុសម្នាក់ បានអង្គុយចុះនៅត្រង់ព្យាណូនោះ ហើយក្រឡេកមើលទាំងភិតភ័យទៅរកម្ដាយរបស់គេដែលបានចាប់ផ្ដើមរៀបណោទភ្លេងយ៉ាងស្ងាមស្ងាត់ ។ ក្មេងប្រុសនោះបានដកដង្ហើមធំ បានងាកទៅរកព្យាណូ ហើយលេងនូវបទរបស់គាត់គឺ « Up on the Housetop » ។

កម្មវិធីបន្ទាប់ទៀតគឺចម្រៀងគ្រីស្ទម៉ាស់មួយដែលខ្ញុំចូលចិត្ត—« C-h-r-i-s-t-m-a-s » ( គ្រីស្ទម៉ាស់ ) ។

ខ្ញុំបានសម្លឹងមើលទៅឃើញបងស្រីម្នាក់ដើរឆ្ពោកមុខ ហើយដាក់ដៃម្ខាងឱបខ្លួនរបស់នាង ដោយប្រឹងដើរទៅ ក្បែរព្យាណូ ។ គាត់បានឈរផ្អៀងខ្លួនទៅម្ខាង ហើយបានធ្វើមុខពីមុនគាត់ចាប់ផ្ដើម ។ ខ្ញុំសារភាពថា ខ្ញុំងឿងឆ្ងល់ដោយមិនដឹងថាចម្រៀងនោះពិរោះដែរឬអត់នោះទេ ។

គាត់បានច្រៀង « កាលខ្ញុំនៅក្មេង បុណ្យគ្រីស្ទម៉ាស់មានអត្ថន័យម៉្យាង » ចម្រៀងនោះបានបន្តដើម្បីប្រាប់ពីរបៀបដែលក្មេងម្នាក់រៀនពីរបៀបប្រកបពាក្យ *Christmas* ហើយបានរកឃើញពីអត្ថន័យដ៏ពិតនៃថ្ងៃបុណ្យនោះ ។

មាត់របស់គាត់វៀចចុះម្ខាង ហើយគាត់មានការពិបាកក្នុងការនិយាយ ។

ខ្ញុំបានសម្លឹងមើលជុំវិញបន្ទប់នោះដោយយកចិត្តទុកដាក់ ហើយសិក្សាពីទឹកមុខនៃសមាជិកក្នុងវួដរបស់គាត់ ។ គ្មាននរណាម្នាក់ខ្មាស់អៀនឡើយ ។ ផ្ទុយទៅវិញ ពួកគេបានអង្គុយញញឹម ហើយស្ដាប់ដោយយកចិត្តទុកដាក់ ។

គាត់បានបន្តច្រៀង ហើយងើយមុខរបស់ខ្លួនទៅលើ ទាំងសម្លឹងភ្នែកទៅលើពិដាន។ មិនយូរប៉ុន្មានខ្ញុំក៏បានសម្លឹងមើលទៅលើដែរ ប៉ុន្តែខ្ញុំបានឃើញតែពិដាន ។ ប៉ុន្តែ



នៅពេលខ្ញុំសម្លឹងមើលទៅគាត់វិញ ខ្ញុំបានសង្កេតឃើញគាត់កំពុងសម្រក់ទឹកភ្នែក ។

នៅពេលគាត់បញ្ចប់ មនុស្សគ្រប់គ្នានៅក្នុងបន្ទប់នោះបាននាំគ្នាទះដៃ ។ ថ្ពាល់របស់គាត់ឡើងក្រហម ។ នៅពេលគាត់ដើរទៅកន្លែងអង្គុយរបស់គាត់វិញ សមាជិកវួដបានសម្តែងការដឹងគុណដ៏ធំធេងដោយការចាប់ដៃគាត់ ឬយកដៃទះស្មារបស់គាត់ ។ មានបងស្រីម្នាក់អង្គុយក្បែរខ្ញុំបានប្រាប់គាត់ថាគាត់ធ្វើបានល្អណាស់ ហើយគាត់បានតបវិញថា « អរគុណ ។ ខ្ញុំសង្ឃឹមថាទ្រង់ចូលចិត្តវា » ។

*ទ្រង់* ? តើគាត់ច្រៀងទៅកាន់នរណា ? ទោះជាខ្ញុំសួរខ្លួនឯងនូវសំណួរនេះក្តី ក៏ខ្ញុំបានដឹងពីចម្លើយរួចហើយ ។ ខ្ញុំបានដឹងថា គាត់មិនបានច្រៀងទៅមនុស្សគ្រប់គ្នានៅក្នុងបន្ទប់នោះទេ ។ គាត់មិនបានសម្តែងសម្រាប់ការអបអរពីអ្នកស្តាប់នោះទេ ។ គាត់បានច្រៀងទៅកាន់ព្រះអង្គសង្គ្រោះដើម្បីសរសើរតំកើងដល់ទ្រង់ ។



ចាប់តាំងពីពិធីជប់លៀងក្នុងវួដនោះមក បុណ្យគ្រីស្ទម៉ាស់បានកន្លងផុតទៅជាច្រើនដង ហើយខ្ញុំបានឮចម្រៀង « C-h-r-i-s-t-m-a-s » ច្រៀងដោយអ្នកចម្រៀងដ៏ឆ្នើមជាច្រើននាក់ ។ ប៉ុន្តែបទដែលខ្ញុំបានឮនៅបុណ្យគ្រីស្ទម៉ាស់នោះ បានច្រៀងដោយមនុស្សម្នាក់ដែលការសម្តែងរបស់គាត់សោះក្រក្រោះបន្តិច ប៉ុន្តែវាចេញពីចិត្តស្មោះគឺជាចម្រៀងមួយដែលខ្ញុំចងចាំជាងគេបំផុត ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ វ៉ាស៊ីងតោន ស.រ.អា. ។*

រូបភាពគំនូរ ដោយ ដាន ប៊ឺ

# បងប្រុសខ្ញុំជាអ្នកផ្សព្វផ្សាយសាសនា



**ដោយ ខេរិន រី អាយុ 11 ឆ្នាំ ប្រទេស ម៉ិកស៊ិក**

*« ខ្ញុំសង្ឃឹមថា ខ្ញុំអាចចែកចាយដំណឹងល្អដល់អ្នកដែលចង់ដឹងពីសេចក្ដីពិត » ( « I Hope They Call Me on a Mission »* Children's Songbook *ទំព័រ 169 )* ។

គ្រួសាររបស់យើងមាន—ឪពុកម្ដាយខ្ញុំ បងប្រុសខ្ញុំ និងខ្ញុំ—បានរៀបចំខ្លួនយូរហើយដើម្បីឲ្យបងប្រុសខ្ញុំបម្រើបេសកកម្ម ។ នៅពេលណាយើងនិយាយពីគាត់ធ្វើជាអ្នកផ្សព្វផ្សាយសាសនា ខ្ញុំបាននិយាយលេងដាក់គាត់ ដោយនិយាយថា ខ្ញុំនឹងមិននឹកគាត់ទេ ហើយខ្ញុំនឹងរីករាយដែលបាននៅតែឯង ។

នៅទីបំផុត ថ្ងៃនោះបានមកដល់សម្រាប់គាត់ដើម្បីផ្ញើបែបបទបេសកកម្មរបស់គាត់ ។ គាត់បានព្យាយាមធ្វើយ៉ាងល្អនៅឯសាលា ហើយយើងទាំងអស់គ្នាបានខិតខំធ្វើការ ដើម្បីសន្សំប្រាក់សម្រាប់បេសកកម្មរបស់គាត់ ។

មានថ្ងៃមួយប្រធានស្ដេកបានទូរស័ព្ទហៅយើង ហើយបាននិយាយថា ការហៅរបស់គាត់បានមកដល់ហើយ ។ បងប្រុសខ្ញុំបានសម្រេចចិត្តបើកសំបុត្រនោះ នៅផ្ទះបន្ទាប់ពីអាហារពេលល្ងាច ។ គាត់ត្រូវបានហៅឲ្យបម្រើនៅបេសកកម្មម៉ិចស៊ិកូស៊ីធីខាងកើត ។

ក្រោយពីនោះមិនយូរប៉ុន្មាន យើងបានជូនគាត់ទៅអាកាសយានដ្ឋាន ហើយលាគ្នា ។ តាមផ្លូវត្រឡប់មកផ្ទះវិញ ម្ដាយរបស់ខ្ញុំយំរហូត ប៉ុន្តែខ្ញុំមិនបានយំនោះទេ ។ ប៉ុន្តែគ្រាន់តែពីរម៉ោងក្រោយប៉ុណ្ណោះ នៅពេលខ្ញុំបាននៅក្នុងបន្ទប់ដែលខ្ញុំធ្លាប់នៅជាមួយនឹងបងប្រុសរបស់ខ្ញុំ រំពេចនោះខ្ញុំបានដឹងថា ខ្ញុំមិនបានឃើញគាត់ម្ដងទៀត ក្នុងរយៈពេលដ៏យូរ ។ បន្ទាប់មក ខ្ញុំជាមនុស្សម្នាក់ដែលយំមិនឈប់សោះ ហើយខ្ញុំក៏បណ្ដោយឲ្យខ្លួនឯងយំតទៅទៀត ។ ឪពុកម្ដាយខ្ញុំបានមកឱបខ្ញុំ ហើយលួងលោមខ្ញុំ ហើយយើងទាំងអស់គ្នាមានសេចក្ដីអំណរ និងសេចក្ដីសោកសៅយ៉ាងខ្លាំងក្នុងពេលជាមួយគ្នានោះ ។

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំអធិស្ឋានទៅព្រះវរបិតាសួគ៌ ហើយសុំទ្រង់ឲ្យមើលថែដល់បងប្រុសរបស់ខ្ញុំ នៅពេលគាត់បម្រើ ។

បងប្រុសរបស់ខ្ញុំបានបង្រៀនខ្ញុំថា ខ្ញុំក៏ត្រូវរៀបចំខ្លួនសម្រាប់បេសកកម្មដែរ ។ ខ្ញុំត្រូវមានភាពសក្ដិសមដើម្បីទទួលបព្វជិតភាព ចូលរៀនថ្នាក់សិក្ខាសាលា ហើយសម្រេចគោលដៅនានានៅក្នុង*ការបំពេញកាតព្វកិច្ចរបស់ខ្ញុំចំពោះព្រះ* ។ គាត់បានបង្រៀនខ្ញុំឲ្យធ្វើការ ហើយសន្សំប្រាក់ អានព្រះគម្ពីរ ហើយគោរពតាមពួកអ្នកដឹកនាំរបស់ខ្ញុំ ។

ខ្ញុំចង់បម្រើបេសកកម្មផងដែរ ដើម្បីឲ្យមនុស្សដទៃទៀតអាចមានពរជ័យនៃដំណឹងល្អ ហើយដឹងថាវាជាការពិត ។ ■

គំនូរព្រាងដោយ ប្រាដ ធ

សាក្សីពិសេស



# ហេតុអ្វីការចំណាយពេលជាមួយក្រុមគ្រួសាររបស់យើងសំខាន់ ?

**ដោយ ប្រធាន**
**ប៊យដ៏ ឃេ ផាកកឺ**
ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*



ពេលវេលាជាគ្រួសារគឺជាពេលវេលាដ៏ពិសិដ្ឋ ។
ផែនការនៃសុភមង្គលគឺជាផែនការមួយសម្រាប់ក្រុមគ្រួសារ ។
គ្រួសារគឺជាអង្គភាពដ៏សំខាន់ក្នុងកាលវេលានេះ និងក្នុងភាពដ៏នៅអស់កល្បជានិច្ច ។
យើងជម្រុញឲ្យសមាជិកយើងបង្ហាញនូវការលះបង់ចំពោះគ្រួសាររបស់ខ្លួន ។
ខ្ញុំសូមអធិស្ឋានថា ក្រុមគ្រួសារនៃសាសនាចក្រនេះនឹងទទួលបានពរ ទាំងឪពុកម្ដាយ និងកូនចៅ ។

*ប៊យដ៏ ឃេ ផាកកឺ « And a Little Child Shall Lead Them » លីអាហូណា ខែ ឧសភា ឆ្នាំ 2012 ទំព័រ 9 ។*

រូបភាពដោយ ម៉េត ដាប់

អ្នកអាចប្រើមេរៀន និងសកម្មភាពនេះ ដើម្បីរៀនសូត្របន្ថែមទៀតពីបាវចនានៃថ្នាក់កុមារសម្រាប់ខែនេះ ។

# ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទនឹងយាងមកម្ដងទៀត

តើអ្នកអាចស្រមើស្រមៃឃើញព្រះយេស៊ូវឱបក្រសោបអ្នក ហើយប្រទានពរដល់អ្នកដែរឬទេ ? នោះជាអ្វីដែលទ្រង់បានធ្វើសម្រាប់កុមារសាសន៍នីហ្វៃ នៅក្នុងព្រះគម្ពីរមរមន បន្ទាប់ពីទ្រង់បានរស់ឡើងវិញ ។

« ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានបញ្ជាឲ្យគេនាំកូនក្មេងតូចៗមករកព្រះអង្គ ។

« ម្ល៉ោះហើយ គេបាននាំកូនក្មេងតូចៗមកអង្គុយនៅលើទីដីជុំវិញព្រះអង្គ ហើយព្រះយេស៊ូវទ្រង់ឈរនៅកណ្ដាល ។ . . .

« . . . ទ្រង់បានយកកូនក្មេងរបស់ពួកគេម្ដងម្នាក់ៗ ហើយបានប្រទានពរដល់ពួកវា ហើយបានអធិស្ឋានដល់ព្រះវរបិតាសម្រាប់ពួកគេ ( នីហ្វៃទី 3 17:11–12, 21 ) ។

យើងដឹងថាព្រះយេស៊ូវនឹងយាងមកម្ដងទៀត ហើយគង់នៅលើផែនដីជាមួយនឹងយើង ។ ទ្រង់នឹងធ្វើជាស្ដេច និងជាអ្នកដឹកនាំរបស់យើង ។ វានឹងក្លាយជាពេលវេលាមួយនៃសេចក្ដីសុខសាន្ត និងសុភមង្គលសម្រាប់ជនដែលបានរៀបចំខ្លួន ដើម្បីជួបនឹងទ្រង់ ។

ព្រះយេស៊ូវស្រឡាញ់អ្នកដូចជាទ្រង់បានស្រឡាញ់ដល់កុមារសាសន៍នីហ្វៃផងដែរ ។ អ្នកអាចរៀបចំខ្លួនដើម្បីជួបទ្រង់ នៅពេលទ្រង់យាងមកម្ដងទៀតដោយការធ្វើល្អចំពោះមនុស្សដទៃទៀត ដោយការគោរពប្រតិបត្តិ ដោយការពោលពាក្យអធិស្ឋានរបស់អ្នក និងដោយការរើសផ្លូវត្រូវ ។ បន្ទាប់មកអ្នកនឹងរៀបចំខ្លួនជាស្រេចនៅពេលទ្រង់យាងមកម្ដងទៀត ! ■

គំនូរព្រាងៈ ព្រះយេស៊ូវ ជៅ មជ្ឈសុទ© IRI, គំនូរៈ ព្រះយេស៊ូវ ជេឌ អិម វ៉ាតធើឃើ

## គំនិតយោបល់សម្រាប់ការនិយាយក្នុងគ្រួសារ

សូមនិយាយនឹងគ្រួសាររបស់អ្នកថា តើផែនដីនឹងមានទិដ្ឋភាពបែបណានៅពេលព្រះយេស៊ូវគង់នៅទីនេះជាមួយនឹងយើងនោះ ។ អ្នកអាចអាន នីហ្វៃទី 2 21:6–9 ។ បន្ទាប់មកអ្នកអាចពិភាក្សាថាតើមនុស្សនឹងប្រព្រឹត្តចំពោះគ្នាបែបណា តើពពួកសត្វនឹងមានចរិតបែបណា ហើយថាតើពិភពលោកនៃនឹងមានសុវត្ថិភាពដល់កម្រិតណា ។ សូមផ្ដល់វេនដល់សមាជិកគ្រួសារម្នាក់ៗ ដើម្បីប្រាប់ពីអ្វីដែលគេរំពឹងរង់ចាំពីគ្រាដែលព្រះយេស៊ូវយាងមកម្ដងទៀត ។



## ចម្រៀង និង ព្រះគម្ពីរ

- « When He Comes Again » ( *Children’s Songbook* 82–83 )
- ម៉ាថាយ 16:27



ដោយសារទ្រង់បានមានបន្ទូលកាលពីមុនថា
« ទុកឲ្យកូនក្មេងមករកខ្ញុំចុះ » ។



# ពេលទ្រង់យាងមកម្ដងទៀត

ដោយ ម៉ីឡា ហ្វ្រីនវូដ ឆេន





តើពន្លឺនៃពេលថ្ងៃនឹងនៅរហូត
ដល់ពេលយប់ដែរទេ ?



ខ្ញុំងឿងឆ្ងល់ថាប្រសិនបើមានផ្កាយមួយ
រះនៅទីឆ្ងាយភ្លឺជាងផ្កាយទាំងអស់

ខ្ញុំជឿងធ្ងល់ថា នៅពេលទ្រង់យាងមកម្តងទៀត
តើពួកទេវតានឹងច្រៀងដែរទេ ?





ខ្ញុំជឿជាក់ថាទ្រង់នឹងហៅក្មេងតូចៗរបស់
ទ្រង់ឲ្យមកជុំគ្នានៅជុំវិញទ្រង់



តើផែនដីនឹងគ្របដណ្តប់ដោយ
ព្រិលពណ៌ស ឬតើពិភពលោក
នេះនឹងមាននិទាឃរដូវដែរទេ ?



តើពួកបក្សាបក្សីនឹងចាកចេញពី
ទ្រនំរបស់វាដែរទេ ?

# ទំព័ររបស់យើង

ខ្ញុំចូលចិត្តអានទំព័ររបស់កុមារអំពី ជីវិតរបស់ពួកព្យាការី និងព្រះយេស៊ូវគ្រីស្ទ ។ វាពង្រឹងទីបន្ទាល់របស់ខ្ញុំ នៅពេលខ្ញុំអានទីបន្ទាល់របស់មនុស្សដទៃទៀត ។ *លីអាហូណា*ជួយខ្ញុំឲ្យរើសផ្លូវត្រូវ ហើយរក្សាបទដ្ឋានរបស់សាសនាចក្រ ។ វាក៏ជួយខ្ញុំផងដែរឲ្យមានអារម្មណ៍កាន់តែជិតស្និទ្ធនឹងព្រះវរបិតាសួគ៌ ។

**ខាមីឡា ខេ អាយុ 11 ឆ្នាំ ម៉ាឡេស៊ីខាងលិច**



នៅថ្ងៃមួយនោះ ថ្នាក់បឋមសិក្សារបស់យើងបានទៅទស្សនាព្រះវិហារបរិសុទ្ធ សៅប៉ូឡូ ប្រេស៊ីល ។ សួនច្បារទាំងនោះពិតជាស្រស់ស្អាតជាងកន្លែងណា។ផ្សេងទៀតដែលខ្ញុំធ្លាប់ឃើញ ។ ពួកយើងបានរៀនថា តាមរយៈសេចក្ដីសញ្ញាដែលយើងធ្វើនៅក្នុងព្រះវិហារបរិសុទ្ធនោះយើងអាចរស់នៅជាមួយក្រុមគ្រួសាររបស់យើងអស់កល្បអស់កាលជានិច្ច ។ ប្រធានព្រះវិហារបរិសុទ្ធ បាននិយាយមកកាន់យើងនៅក្នុងបន្ទប់រង់ចាំ ជាកន្លែងដែលយើងបានឃើញរូបគំនូរដ៏ស្រស់ស្អាតទាំងឡាយ ។ ខ្ញុំមានអារម្មណ៍កក់ក្ដៅ និង រីករាយ ហើយម្ដាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា នេះគឺមកពីព្រះវិញ្ញាណបរិសុទ្ធដែលថ្លែងទីបន្ទាល់ដល់ខ្ញុំថា អ្វីដែលខ្ញុំកំពុងរៀនគឺពិត ។ ខ្ញុំទទួលទីបន្ទាល់មួយថា ព្រះវិហារបរិសុទ្ធ គឺជាដំណាក់នៃព្រះអម្ចាស់ ។

**ប៉ាណាតូ ប៊ី អាយុ 8 ឆ្នាំ ប្រទេស ប្រេស៊ីល**



*ម៉ោរីស្ស៊ី អេជ អាយុ 7 ឆ្នាំ មកពីប្រទេស ម៉ិចស៊ិកូ មានក្ដីប្រាថ្នាមួយដើម្បីទទួលបុណ្យជ្រមុជទឹក ហើយមានការគោរពប្រតិបត្តិ ដើម្បីនៅថ្ងៃមួយគាត់អាចចូលព្រះវិហារបរិសុទ្ធបាន ។ គាត់បានព្យាយាមធ្វើជាគំរូល្អដល់ប្អូនប្រុសរបស់ខ្លួន ដានីយ៉ែល ។*



*ដានីយ៉ែល អាយុ 3 ឆ្នាំ មកពី ហុងកុង គឺជាកូនពៅក្នុងគ្រួសាររបស់គាត់ ។ គាត់ចិត្តល្អ ហើយតែងញញឹម ហើយគាត់ចូលចិត្តបម្រើដល់អ្នកដទៃ ។ គាត់តែងស្ម័គ្រចិត្តអធិស្ឋានទាំងនៅព្រះវិហារ និងនៅផ្ទះ ហើយគាត់ចូលចិត្តឈរជាមួយនឹងឪពុករបស់គាត់ស្វាគមន៍ដល់សមាជិកវួដពីមុនការប្រជុំសាក្រាម៉ង់ ។ គាត់ក៏ចូលចិត្តប្រមូលសៀវភៅទំនុកតម្កើងព្រះ ហើយសម្អាតសាលប្រជុំក្រោយម៉ោងព្រះវិហារ ។ មានថ្ងៃមួយគាត់បានធ្វើគំរូល្អមួយដល់ម្ដាយគាត់នៅពេលគាត់បានអញ្ជើញក្មេងប្រុសតូចម្នាក់ដែលគាត់បានជួបតាមផ្លូវទៅព្រះវិហារ ឲ្យមកព្រះវិហារជាមួយនឹងគាត់ ។*



**អៃលីន ស៊ី អាយុ 8 ឆ្នាំ ប្រទេស ក្វាតែម៉ាឡា**



*ប៉ាណាតូ និង គ្រួសារនៅពេលបុណ្យជ្រមុជទឹករបស់គាត់*



**ធីម៉ា ប៊ី អាយុ 6 ឆ្នាំ ប្រទេស អ៊ុយក្រែន**

*កុមារនៅក្នុងសាខា ខាយ៉ៃយីន បារាំង ចូលចិត្តបង្ហាញការប្រជុំសាក្រាម៉ង់ថ្នាក់បឋមសិក្សារបស់ពួកគេ ។ ពួកគេរីករាយអានផ្នែករបស់ពួកគេ ហើយពួកគេច្រៀងបានយ៉ាងពិរោះ ។ ពួកគេស្រឡាញ់ថ្នាក់កុមារ ។ ចម្រៀងមួយដែលពួកគេចូលចិត្តគឺបទ « ខ្ញុំជាកូនរបស់ព្រះ » ( ទំនុកតម្កើងព្រះ ទំព័រ 58 ) ។*



**ដោយ ម៉ាចាយ ឌី ហ្វិតតុន**
ទស្សនាវដ្ដីសាសនាចក្រ

*« ព្រោះកូនមនុស្សនឹងមកក្នុងសិរីល្អនៃព្រះវរបិតាជាមួយនឹងពួកទេវតារបស់លោក »* ( *ម៉ាថាយ 16:27* ) ។

**ខេធី** បានកកាយ រកនៅក្នុងប្រអប់មួយ ដោយយកចិត្តទុកដាក់ ដើម្បីរកមើលក្រដាសសម្រាប់ខ្ចប់កាដូ ។ នាងនៅតែរកមិនឃើញនូវអ្វីដែលនាងកំពុងស្វែងរក ។

នាងបានប្រមូលអីវ៉ាន់ដាក់ក្នុងប្រអប់វិញ ហើយដើរទៅរកម្ដាយ ។

ខេធី បានរកមើលនៅខាងក្រោយព្យាណូ នៅក្រោមសាឡុង គឺនៅលើគ្រែទារករបស់ ថូម៉ាស ។ វាបានបាត់ ។ នាងត្រូវតែប្រាប់ដល់ម្ដាយ ។

« ម៉ាក់ ព្រះឱរសយេស៊ូវបានបាត់ហើយ » ។

ខេធី បាននាំម្ដាយទៅកន្លែងដាក់ប្រសូតិកម្មក្នុងបន្ទប់ទទួលភ្ញៀវ ។ យ៉ូសែប និងម៉ារា ព្រមទាំងពួកគង្វាលគឺនៅទីនោះ ។ ពួកហោរា–សូម្បីសត្វអូដ្ឋ និងសត្វលា—ក៏នៅទីនោះដែរ ។ រូបទាំងនោះត្រូវបានដាក់នៅជុំវិញស្នូកមួយដែលទទេស្អាត ។

« វាមើលទៅបែបហ្នឹងហើយ មែនទេ ? » ម៉ាក់បាននិយាយ ។

« មែនហើយ កូនមិនអាចរកទ្រង់ឃើញសោះនៅគ្រប់ទីកន្លែង ។ កូនខំមើលហើយមើលទៀត » ។ ប្រសូតិកម្មនោះនឹងឥតមានន័យបើគ្មានព្រះឱរសយេស៊ូវ ។

ម្ដាយបានដើរទៅធ្នើរដាក់សៀវភៅ ។ នៅពេលគាត់ឈោងដៃទៅយកអ្វីមួយនៅផ្នែកខាងលើនៃធ្នើរនោះ គាត់បាននិយាយថា « ទ្រង់ពុំបានបាត់ទេ » ។

ខេធីបានធូរនៅក្នុងចិត្ត ។ « ទ្រង់នៅទីនោះ ! » ម៉ាក់បាននិយាយ ។ « កូននឹងដាក់ទ្រង់នៅក្នុងស្នូក » ។

នាងបានឈោងដៃយករូបនោះ ប៉ុន្តែម្ដាយបានដាក់វានៅលើធ្នើរវិញ ។ ម្ដាយបាននិយាយថា « ឆ្នាំនេះយើងនឹងដាក់ព្រះឱរសយេស៊ូវនៅក្នុងស្នូកនៅព្រឹកថ្ងៃបុណ្យគ្រីស្ទម៉ាស់ » ។ « វាជាទំនៀមទម្លាប់មួយដែលប៉ាបានរៀននៅប្រទេសបារាំង » ។

« ហេតុអ្វី ? មនុស្សគ្រប់គ្នាមើលទៅហាក់ដូចជាសោកសៅណាស់ » ។

« ម៉ាក់មិនដឹងថាពួកគេសោកសៅដែរឬអត់នោះទេ » ។ ម៉ាក់បាននិយាយ ។ « ចំពោះម៉ាក់ វាមើលទៅហាក់ដូចជាពួកគេកំពុងរង់ចាំ » ។

ខេធី បានពិនិត្យមើលរូបទាំងនោះ ។ នាងបានមើលឃើញស្នូកទទេសម្រាប់ដាក់ព្រះឱរសយេស៊ូវ ។ មានរូបមួយចំនួនបានដាក់ទៅរកកន្លែងនោះហើយ ។

# ការរង់ចាំព្រះយេស៊ូវ





ខេធី បាននិយាយថា « កូនក៏គិតថាអញ្ចឹងដែរ » ។

« នៅចាំទេ ពីមុនថូម៉ាសកើតកូនរីករាយប៉ុណ្ណារង់ចាំគាត់កើតមក ? » ម៉ាក់បានសួរ ។

ខេធី បានញញឹមដាក់ប្អូនប្រុសតូចរបស់នាងដែលកំពុងលេងនៅលើភួយ ។ « មែនហើយ វាមានអារម្មណ៍ថាយូរណាស់ » ។

« តើកូនដឹងទេថា ពួកព្យាការីបានរង់ចាំព្រះយេស៊ូវយាងមកជួយយើងឲ្យត្រឡប់ទៅរស់នៅជាមួយនឹងព្រះវរបិតាសួគ៌វិញដល់ទៅរាប់ពាន់ឆ្នាំ ? »

ខេធី បាននៅចាំថាបានឃើញរូបភាពមួយនៅក្នុង ថ្នាក់កុមារស្ដីពីព្យាការីម្នាក់សរសេរពីការប្រសូតរបស់ព្រះអង្គសង្គ្រោះ ។ នាងបាននិយាយថា « កូនគិតអញ្ចឹងដែរ » ។

ម្ដាយបាននិយាយថា « ពួកព្យាការីដូចជាអេសាយបានគិត ហើយសរសេរពីអ្វីដែលព្រះអង្គសង្គ្រោះនឹងធ្វើពេលទ្រង់យាងមក » ។ « ពួកគេបានចំណាយពេលពេញមួយជីវិតរង់ចាំទ្រង់នឹងប្រសូតមក ។ នោះជាហេតុផលមួយដែលយើងរៀបចំប្រសូតិកម្មដូចនេះ ដើម្បីរំឭកយើងថា មានមនុស្សជាច្រើនបានរង់ចាំយ៉ាងយូរសម្រាប់ព្រះអង្គសង្គ្រោះយាងមក » ។

ដោយសម្លឹងមើលទៅពួកគង្វាលចៀមដែលកំពុងរង់ចាំព្រះយេស៊ូវ ខេធី បាននិយាយថា « កូន នឹងមានភាពធុញទ្រាន់ ក្នុងការរង់ចាំពេញមួយជីវិតរបស់កូន »

ម៉ាក់បាននិយាយថា « ប៉ុន្តែ ក៏មានហេតុផលមួយទៀតដែលយើងធ្វើបែបនេះ » ។

« អ្វីទៅម៉ាក់ ? »

« តើកូននៅចាំទេ ក្នុងរាត្រីជួបជុំក្រុមគ្រួសារពេលយើងនិយាយពីការយាងមកជាលើកទីពីរនោះ ? »

ខេធីបានគិតមួយសន្ទុះ ។ « តើនោះជាពេលដែលព្រះយេស៊ូវយាងមកម្ដងទៀតមែនទេ ?

ម្ដាយបាននិយាយថា « ត្រឹមត្រូវហើយ » ។

« តើវានឹងកើតឡើងនៅពេលណា ? »

« យើងមិនដឹងនោះទេ ។ ប៉ុន្តែយើងកំពុងរង់ចាំព្រះយេស៊ូវយាងមក ដូចជាពួកគង្វាលចៀមនៅក្នុងប្រសូតិកម្ម និងដូចជាពួកព្យាការីពីបុរាណដែរ ។ នោះជាហេតុផលមួយទៀតដែលយើងកំពុងរង់ចាំរហូតដល់បុណ្យគ្រីស្ទម៉ាស់ ដើម្បីដាក់ព្រះឱរសយេស៊ូវនៅក្នុងប្រសូតិកម្មនេះ—ដើម្បីរំឭកយើងថាយើងកំពុងរង់ចាំព្រះយេស៊ូវដែរ » ។

« តើទ្រង់នឹងយាងមកក្នុងស្នូកម្ដងទៀតឬ ? » ខេធីបានសួរ ។

« ទេ ទ្រង់នឹងមិនក្លាយជាព្រះឱរសម្ដងទៀតឡើយ ។ ពេលព្រះយេស៊ូវយាងមកម្ដងទៀតទ្រង់នឹងក្លាយជាអង្គដែលបានរស់ឡើងវិញ ។ ប៉ុន្តែស្នូកទទេស្អាតនៅក្នុងប្រសូតិកម្មនេះរំឭកយើងថា ដូចជាយើងកំពុងរង់ចាំព្រឹកថ្ងៃបុណ្យគ្រីស្ទម៉ាស់ដូច្នោះដែរ ហើយដូចជាមនុស្សបានរង់ចាំព្រះយេស៊ូវយាងមកផែនដីដែរ ឥឡូវនេះយើងកំពុងរង់ចាំទ្រង់យាងមកម្ដងទៀត ។ យើងមិនបានបាត់ព្រះឱរសយេស៊ូវទេ ។ នេះជាផ្នែកនៃរបៀបមួយ ដែលគ្រួសាររបស់យើងចងចាំដល់ទ្រង់ » ។

ខេធី បាននិយាយទាំងញញឹមថា « យើងត្រូវតែរងចាំ » ។

ម្ដាយនិយាយថា « ត្រឹមត្រូវហើយ » ។

« ខណៈដែលយើងកំពុងរង់ចាំ តើយើងអាចធ្វើនំយុកឃីខ្លះបានទេ ? » ■



« យើងសូមប្រកាសថា ទ្រង់នឹងយាងមកផែនដីម្ដងទៀត គ្រានេះទ្រង់នឹងយាងមកដោយអំណាច ភាពអស្ចារ្យ និងសិរីល្អ ដើម្បីគ្រងរាជជាស្ដេចនៃអស់ទាំងស្ដេច និងជាព្រះអម្ចាស់នៃអស់ទាំងព្រះអម្ចាស់ » ។

**អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Standing Together for the Cause of Christ » *Liahona* ខែ សីហា ឆ្នាំ 2012 ទំព័រ 28 ។**

*សូមមកតាមយើងដើម្បីស្វែងរកទីតាំងសំខាន់មួយ នៅក្នុងប្រវត្តិសាស្ត្រនៃសាសនាចក្រ !*

អេលីស និងខាល អេជ អាយុ 9 និង 6 ឆ្នាំ កំពុងដើរនៅលើផ្លូវដែលពោរពេញដោយព្រិលនៃសំណាកតុបតែឲ្យដូចជាភូមិអ្នកត្រួសត្រាយមួយដែលបានសាងសង់ឡើងវិញ ក្នុងទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ។ វាមើលទៅហាក់ដូចជាពួកគេបានវិលត្រឡប់ទៅរកពេលវេលានៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ 1800 ។ ពេលនោះគឺជាពេលដែលពួកអ្នកត្រួសត្រាយកំពុងតាំងលំនៅក្នុងជ្រលងភ្នំ សលត៍ លេក ។ សូមចូលរួមនឹងអេលីស និងខាល នៅពេលពួកគេរុករកនៅក្នុងសួនមួយឈ្មោះ « This Is the Place Heritage Park » ដើម្បីស្វែងយល់ថាតើការធ្វើជាកុមារត្រួសត្រាយម្នាក់មានសភាពបែបណា ។ ■



# កន្លែងនេះហើយ !

ដោយ អាន់នី បៀរ



ជាងកាត់សក់នៅក្នុងក្រុងបានបញ្ជូនសក់ដែលបានយកពីការកាត់សក់ និងកោរសក់ទៅឲ្យពួកអ្នកធ្វើប្រដាប់ប្រដារក្មេងលេង ដើម្បីប្រើវាធ្វើសក់សម្រាប់តុក្កតា ។





គ្រួសារមួយមានគ្នា 12 នាក់ បានរស់នៅក្នុងផ្ទះត្រួសត្រាយដ៏តូចនេះ ។ កុមារទាំងឡាយត្រូវចេញទៅខាងក្រៅ ហើយឡើងតាមកាំជណ្ដើរ ទៅកន្លែងដេកនៅជាន់ដំបូល ។



បន្ទាប់ពីការងារប្រចាំថ្ងៃរបស់ពួកគេ កុមារត្រួសត្រាយលេងជាមួយនឹងប្រដាប់លេងរបស់ពួកគេ ។ របស់លេងដែលខាលចូលចិត្តនោះគឺសត្វខ្លាឃ្មុំធ្វើពីក្រណាត់មួយដែលមានខ្សែទាញពីរ ។ វាបានជួយដល់កុមារត្រួសត្រាយរៀនពីរបៀបយកទឹកដោះពីសត្វគោ !

ពួកត្រួសត្រាយក្រុមដំបូងបានបញ្ចប់ដំណើររបស់ខ្លួនទៅទិសខាលិចក្នុងឆ្នាំ 1847 ។ នៅពេល ព្រិកហាំ យ៉ង់ បានឃើញជ្រលងភ្នំ សលត៍លេកជាលើកដំបូង លោកបានមានប្រសាសន៍ថា « នេះជាទីកន្លែងដ៏ត្រឹមត្រូវ » ។ រូបសំណាកនេះបានគូសប្លង់ដោយចៅប្រុសរបស់ ព្រិកហាំ យ៉ង់ ដើម្បីផ្ដល់កិត្តិយសដល់ពួកត្រួសត្រាយដ៏អង់អាចទាំងនោះ ។



ឆ្ងាញ់មែន ! កុមារត្រួសត្រាយចូលចិត្តស្ករគ្រាប់ផងដែរ !



កុមារត្រួសត្រាយផ្លូវជារឿយៗបានទៅសាលារៀននៅអគារដែលមានបន្ទប់តែមួយ ។ កុមារគ្រប់វ័យបានជួបជុំគ្នានៅក្នុងបន្ទប់តែមួយ—ថ្វីបើពួកគេរៀនរឿងផ្សេងៗពីគ្នាក្ដី ។



ថតរូបដោយ ខូឌី បើល, លើកលែងដូចបានកត់សំគាល់, រូបថតនៃសំណាកកន្លែងនេះហើយដោយ រ៉ែនដា ធី វិល្លាមស៍ © IRI

# ព្រះយេស៊ូវបានប្រសូតហើយ

ដោយ ឆាឡុត មេ ហ្សិបប៊ីដ



ម៉ារា និងយ៉ូសែបបានធ្វើដំណើរទៅភូមិបេថ្លេហិម ។ វាជាការធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយ ។ មិនយូរប៉ុន្មានទៀត ម៉ារានឹងមានបុត្រមួយអង្គ ។

ផ្ទះសំណាក់ពេញអស់ហើយ ។ ម៉ារា និងយ៉ូសែបបានស្នាក់នៅក្នុងក្រោលសត្វមួយ ។ ខណៈដែលពួកគេនៅទីនោះ ព្រះយេស៊ូវបានប្រសូតមក ។



រចនាដោយ កាសី ណៀលសុន

នៅក្បែរនោះ មានពួកអ្នកគង្វាលនៅឯទីវាលកំពុងឃាមចៀមរបស់ខ្លួន ។ មានទេវតាមួយអង្គបានយាងមកប្រាប់ពួកគេឲ្យទៅភូមិ បេថ្លេហិម ដើម្បីទៅមើលព្រះឱរសដែលទើបនឹងប្រសូត ។

ពួកគង្វាលបានរកឃើញក្រោលនោះជាទីកន្លែងដែលម៉ារី និងយ៉ូសែបស្នាក់នៅ ។ នៅក្នុងស្នូកមានព្រះឱរសយេស៊ូវ ដែលរុំនឹងសំពត់ ។ ទ្រង់នឹងក្លាយជាព្រះអង្គសង្គ្រោះនៃពិភពលោកទាំងមូល ។



ពេលខ្លះ នៅបុណ្យគ្រីស្ទម៉ាស់គ្រួសារ និងមិត្តភក្តិយើងបាន ផ្តល់អំណោយដល់យើង ។ ប៉ុន្តែអំណោយដ៏ធំជាងគេបំផុតគឺ ជាអំណោយមួយដែលព្រះវរបិតាសួគ៌បានប្រទានដល់យើង ។ ទ្រង់បានបញ្ជូនព្រះរាជបុត្រាផ្ទាល់របស់ទ្រង់ ជាព្រះយេស៊ូវគ្រីស្ទ ឲ្យប្រសូតនៅលើផែនដី ។ ■



# ហេតុផលសម្រាប់រដូវនេះ

ដោយ រ៉ូល ឆាដវីគ បាត្តី

សូមស្វែងរក ហើយគូសរង្វង់លើវត្ថុដែលបានលាក់កំបាំងក្នុងរូបភាពនេះ ។



រូបភាពដោយ រ៉ូល ឆាដវីគ បាត្តី

# ដំណើរត្រឡប់ទៅផ្ទះវិញ

ដោយ ហ៊ីតធើរ វិតធល ហ្វ្រីចលី



ការជិះលើរថយន្តក្រុងពីកន្លែងធ្វើការត្រឡប់ទៅផ្ទះរបស់ខ្ញុំវិញ គឺដដែលជាដដែល ។ ក្នុងរយៈពេលប្រាំនាទី ខ្ញុំបានផ្អែកក្បាលរបស់ខ្ញុំនឹងបង្អួច ហើយមិនយូរប៉ុន្មានការឈប់ និងចាប់ផ្ដើមនៃរថយន្តក្រុងនោះបានអង្រួនខ្ញុំឲ្យដេក ។ ខ្ញុំកំពុងតែសម្របខ្លួននឹងទំនួលខុសត្រូវថ្មីៗដែលកើតមានជាមួយនឹងការរៀបការថ្មីថ្មោងរបស់ខ្ញុំ ខណៈដែលខ្ញុំធ្វើការ និងរៀនពេញម៉ោងនោះ ។ ថ្ងៃខ្លះ ខ្ញុំបានដេកនៅរថយន្តក្រុងរហូតចាប់តាំងពីពេលជិះទៅធ្វើការ ហើយត្រឡប់ពីធ្វើការវិញ ។

នៅពេលខ្ញុំដេកលក់ស្កុង ខ្ញុំបានឮសំឡេងប្រាប់ថាខុសផ្លូវហើយ ។ រំពេចនោះ ខ្ញុំបានដឹងថា អ្នកបើករថយន្តក្រុងថ្មីត្រូវការការប្រាប់ផ្លូវដែលមានចម្ងាយ ៨០ គ.ម. ។

ដោយដឹងថាវាប្រហែលជាចំណាយពេលមួយម៉ោងកន្លះលើសធម្មតា ដើម្បីទៅដល់ផ្ទះ នោះខ្ញុំបានចាប់ផ្ដើមមានចិត្តមួរម៉ៅ ។ គំនិតមិនល្អចំពោះសមត្ថភាពរបស់អ្នកបើករថយន្តនោះបានកើតមានពេញក្នុងគំនិតរបស់ខ្ញុំ ។ សំឡេងប្រាប់ថាខុសផ្លូវហើយបានបន្តរំខានដល់ការដេករបស់ខ្ញុំ ។

ប៉ុន្តែមិនយូរប៉ុន្មាន ខ្ញុំបានសង្កេតឃើញថាការស្រែកនោះបានឈប់ ។ ខ្ញុំបានងើបមុខឡើងឃើញស្ត្រីម្នាក់បានប្រាប់ផ្លូវដល់អ្នកបើករថយន្តក្រុងនោះ ដោយទន់ភ្លន់ពីកន្លែងអង្គុយរបស់នាង គឺនៅពីរជួរពីមុខខ្ញុំ ។ ខ្ញុំបានមើល នៅពេលគាត់ប្រាប់ផ្លូវដល់បុរសនោះដោយទន់ភ្លន់ផ្អែមល្ហែម ពីមុនឈប់នៅត្រង់កន្លែងរបស់គាត់ គាត់បានប្រាប់បុរសនោះពីចំណុចបន្ទាប់មួយចំនួនទៀតដែលឡាននោះត្រូវឈប់ ។ ក្រោយមកខ្ញុំបានមកដល់ផ្ទះ ខ្ញុំមានចិត្តរសាប់រសល់ដោយសារតែទង្វើរិះគន់របស់ខ្ញុំដោយប្រៀបធៀបនឹងការណែនាំដ៏គួរឲ្យស្រឡាញ់របស់ស្ត្រីនោះ ។

*នៅពេលយើងមិនដឹងថាត្រូវបែរទៅផ្លូវណា នោះព្រះយេស៊ូវបង្ហាញផ្លូវដល់យើង ។*

ខ្ញុំបានដឹងថា ខ្ញុំដូចជាអ្នកបើករថយន្តក្រុងនោះដែរ—ខ្ញុំមិនបានស្គាល់ផ្លូវនៅក្នុងជីវិតរបស់ខ្ញុំប្រសើរជាងអ្នកបើករថយន្តក្រុងនោះបានដឹងពីផ្លូវថ្មីរបស់គាត់ឡើយ ។ យើងទាំងពីរនាក់គឺស្ថិតនៅលើផ្លូវដែលពុំធ្លាប់ស្គាល់ ។ ខ្ញុំជឿយ៉ាងប្រាកដថា គាត់មានអំណរគុណដែលមានមនុស្សម្នាក់ ដែលធ្លាប់ជិះតាមផ្លូវនោះពីមុន មានឆន្ទៈប្រាប់ផ្លូវដែលនៅខាងមុខដោយអត់ធ្មត់ ។

ព្រះគ្រីស្ទធ្វើដូចគ្នានេះសម្រាប់យើង ។ នៅពេលយើងមិនដឹងត្រូវបានបែរតាមផ្លូវណា នោះគំរូរបស់ទ្រង់បង្ហាញផ្លូវដល់យើង ។ នៅពេលយើងមានសំណួរ ទ្រង់ផ្ដល់ចម្លើយដោយសេចក្ដីស្រឡាញ់ ។ តើប៉ុន្មានដងហើយដែលទ្រង់បាននឿយហត់ បន្ទាប់ពីធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយ ខិតខំបំពេញសេចក្ដីត្រូវការរបស់មនុស្សដទៃនោះ ?

ចាប់តាំងពីថ្ងៃនោះមក យើងបានមានអ្នកបើករថយន្តក្រុងថ្មីពីរបីនាក់ ។ម្ដងម្កាល ពួកគេត្រូវការការប្រាប់ផ្លូវខ្លះៗ ហើយអរគុណចំពោះគំរូដែលបានបង្ហាញខ្ញុំដោយស្ត្រីម្នាក់ និងព្រះអង្គសង្គ្រោះរបស់យើងដែលគួរឲ្យស្រឡាញ់ ខ្ញុំបានមានឆន្ទៈដើម្បីប្រាប់ផ្លូវដល់ពួកគេ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

រចនារូបថតដោយ ឡូយ អែលឌ្រីដ




រចនារូបភាពដោយ រ៉ូប៊ើត ធី បារ៉េត

# យ៉ូសែប ហ្វិលឌីង ស្ម៊ីធ

**យ៉ូសែប ហ្វិលឌីង ស្ម៊ីធ**បានរៀនខិតខំធ្វើការតាំងពីក្មេង ។ ម្ដាយរបស់លោកមើលថែស្ត្រីដែលសម្រាលកូន ហើយ យ៉ូសែប បររទេះជូនគាត់ នៅពេលគាត់ទៅមើលអ្នកជំងឺ ។ នៅពេលលោកធំឡើង យ៉ូសែប បានអភិវឌ្ឍសេចក្ដីស្រឡាញ់មួយចំពោះព្រះគម្ពីរ ។ លោកបានសរសេរ**សៀវភៅ**ជាច្រើនអំពីគោលលទ្ធិនៃសាសនាចក្រ ។ ក្នុងនាមជាប្រធានសាសនាចក្រ លោកបានសរសេរការអធិស្ឋានដើម្បីឧទ្ទិសឆ្លង **ព្រះវិហារបរិសុទ្ធ ប្រូវ៉ូ យូថាហ៍** ។



ពួកទេវតាបាននាំដំណឹងពីការប្រសូតរបស់ព្រះអង្គសង្គ្រោះប្រាប់ដល់ពួកអ្នកគង្វាល ដែលកំពុងចាំយាមកូនចៀមកើតថ្មីរបស់ខ្លួន ក្នុងទីវាលនៅក្បែរភូមិ បេថ្លេហិម ។ អែលឌើរ ប្រ៊ូស ឌី ភទើរ៍ នៃពួកចិតសិបនាក់សរសេរថា « បុត្រាតូចដែលប្រសូតមកក្នុងរដូវដែលកូនចៀមកើតគឺត្រូវបានគេស្គាល់ថាជា ‹កូនចៀមនៃព្រះ ›» ។ « វាគឺជាងារមួយដ៏សំខាន់ ពីព្រោះទ្រង់បានប្រសូតមកក្បែរហ្វូងសត្វចៀម ហើយថ្ងៃណាមួយនឹងត្រូវនាំយកទៅ ‹ ដូចជាកូនចៀមដែលគេដឹកទៅសម្លាប់ › ។ . . . ទ្រង់ដែលជាអង្គដ៏អស្ចារ្យជាងគេបំផុតបានធ្វើឲ្យអង្គទ្រង់តូចបំផុត–ជាអ្នកគង្វាលចៀមសួគ៌ាបានក្លាយជាកូនចៀម » ។ សូមមើល « ចូរយើងនាំគ្នាចូលមកថ្វាយបង្គំទ្រង់ » ទំព័រ 16 ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02107 92258 0
10792 Dec 13